CITY CLERK
CITY OF LOS ANGELES
FOUNDED 1781
ELECTION DIVISION

★★★★★★★★★★★★★★

ខិត្តប័ណ្ណ
ព័ត៌មាន
ស្តីពីការបោះឆ្នោត

★★★★★★★★★★★★★★

ចងក្រងដោយ **PATRICE Y. LATTIMORE** ស្មៀនក្រុង

★ ការបោះឆ្នោតសាលាក្រុងទូទៅ ★

ថ្ងៃអង្គារ ទី 3 ខែវិច្ឆិកា ឆ្នាំ 2026

clerk.lacity.gov/elections

KHMER

សម្រាប់ព័ត៌មានស្តីពីការបោះឆ្នោត
សូមទូរស័ព្ទទៅកាន់លេខ 1-888-873-1000

ទីក្រុង Los Angeles ផ្តល់ព័ត៌មានអ្នកបោះឆ្នោតជាភាសាអង់គ្លេស ក៏ដូចជាភាសាដូចខាងក្រោម៖

Այս բրոշյուրի հայերեն օրինակն ստանալու համար զանգահարեք 1-888-873-1000 հեռախոսահամարով:

要索取本手冊的中文版，
請致電 **1-888-873-1000**

برای تهیه‌ی نسخه‌ای از این جزوه به زبان فارسی، با شماره تلفن
1-888-873-1000 تماس بگیرید

हिन्दी में इस पैम्फलेट की प्रति प्राप्त करने के लिए,
1-888-873-1000 पर फोन करें

このパンフレットの日本語版をご希望の方は、
1-888-873-1000までお電話ください。

ដើម្បីទទួលបានឯកសារថតចម្លងមួយច្បាប់ពីកូនសៀវភៅនេះជាភាសាខ្មែរ
សូមហៅទូរស័ព្ទលេខ **1-888-873-1000**

이 팸플릿을 한국어로 원하시면 다음 전화번호로
연락하십시오. **1-888-873-1000**

Для получения копии данной брошюры на русском языке позвоните по номеру 1-888-873-1000.

Para obtener una copia de este folleto en español,
llame al 1-888-873-1000

Para makakuha ng kopya ng pamplet na ito sa Tagalog,
tumawag sa 1-888-873-1000

เพื่อขอสำเนาจุลสารนี้ในภาษาไทย โปรดโทรศัพท์ติดต่อที่หมายเลข
1-888-873-1000

Muốn có một tập sách này bằng tiếng Việt, hãy gọi số
1-888-873-1000

តារាងមាតិកា

ទំព័រ

សេចក្តីសង្ខេបនៃសន្លឹកឆ្នោត 3-10

វិធានការនៃសន្លឹកឆ្នោត សេចក្តីអះអាង និងអត្ថបទ

សំណើ TE. 11

វិសោធនកម្មធម្មនុញ្ញ LA 17

វិសោធនកម្មធម្មនុញ្ញ PL 36

វិសោធនកម្មធម្មនុញ្ញ EE 45

វិសោធនកម្មធម្មនុញ្ញ PRK 58

វិសោធនកម្មធម្មនុញ្ញ PRT 65

វិសោធនកម្មធម្មនុញ្ញ SC 71

ការផ្ទូចផ្ទើមនៃបទប្បញ្ញត្តិ FD. 88

ព័ត៌មានអ្នកបោះឆ្នោត

មន្ត្រីចុះបញ្ជី-អ្នកកត់ត្រា/ស្មៀនខោនធីរបស់ខោនធី Los Angeles គឺជាអ្នកគ្រប់គ្រងការបោះឆ្នោតសាលាក្រុងនៃទីក្រុង Los Angeles។

ខិត្តប័ណ្ណនេះមានតែព័ត៌មានវិធានការនៃវិធានការសន្លឹកឆ្នោតរបស់ទីក្រុង/ LAUSD សម្រាប់ការបោះឆ្នោតសាលាក្រុងទូទៅនាថ្ងៃទី 3 ខែវិច្ឆិកា ឆ្នាំ 2026 ប៉ុណ្ណោះ។

សម្រាប់ព័ត៌មានទាក់ទងនឹងការបោះឆ្នោត ដូចជាមណ្ឌលបោះឆ្នោត សូមទាក់ទងមកកាន់ខោនធី LA តាមរយៈលេខ (800) 815-2666 ឬសូមចូលទៅកាន់គេហទំព័ររបស់ពួកគេតាមរយៈ www.lavote.gov។

8 ទំព័របន្ទាប់នេះមានកំណែសាមញ្ញនៃវិធានការនៃសន្លឹកឆ្នោតរបស់ទីក្រុង/LAUSD។ អត្ថបទទាំងស្រុងនៃវិធានការនីមួយៗដោយអមជាមួយនឹងព័ត៌មានផ្សេងទៀតត្រូវបានបោះពុម្ពបន្ទាប់ពីការសង្ខេបសន្លឹកឆ្នោត (សូមមើលតារាងទំព័រមាតិកា)។

ចំណងជើង៖
ការលើកលែងពន្ធលើការផ្ទេរទ្រព្យសម្បត្តិសម្រាប់ជនរងគ្រោះនៃគ្រោះមហន្តរាយអគ្គិភ័យខែមករា ឆ្នាំ 2025 ។

បញ្ហា៖
តើបទបញ្ញត្តិគួរត្រូវបានអនុម័តដើម្បីផ្តល់ការលើកលែងមួយដងពីពន្ធលើដំណោះស្រាយភាពគ្មានផ្ទះសម្បែង និងលំនៅឋានរបស់ទីក្រុង (សំណើ ULA) សម្រាប់ទ្រព្យសម្បត្តិលំនៅឋានដែលបានខូចខាត ឬបំផ្លាញនៅក្នុងអគ្គិភ័យ Palisades និងលក់ក្នុងរយៈពេលប្រាំឆ្នាំគិតចាប់ពីកាលបរិច្ឆេទដែលអគ្គិភ័យបានចាប់ផ្តើមដែរឬទេ ?

ស្ថានភាព៖
នៅក្នុងឆ្នាំ 2022 អ្នកបោះឆ្នោតបានអនុម័តសំណើ ULA ដែលជាពន្ធផ្ទេរឯកសារពិសេសលើការលក់ទ្រព្យសម្បត្តិលើសពី $5 លាន (ដូចដែលបានកែសម្រួលតាមអតិផរណា) ដើម្បីផ្តល់មូលនិធិដល់លំនៅឋានដែលមានតម្លៃសមរម្យ និងកម្មវិធីជំនួយអ្នកជួលផ្ទះ ។ អគ្គិភ័យ Palisades ដែលបានចាប់ផ្តើមនៅថ្ងៃទី 7 ខែមករា ឆ្នាំ 2025 បានធ្វើឱ្យខូចខាត ឬបំផ្លាញទ្រព្យសម្បត្តិលំនៅឋានជាច្រើន រួមទាំងផ្ទះ និងយូនីតលំនៅឋាន ។ ទ្រព្យសម្បត្តិដែលខូចខាតដោយអគ្គិភ័យ ដែលត្រូវបានលក់ ឬនឹងត្រូវលក់ក្នុងតម្លៃលើសពី $5 លាន (ដូចដែលបានកែសម្រួលតាមអតិផរណា) នឹងត្រូវជាប់ពន្ធនៃសំណើ ULA ។

សំណើ៖
វិធានការនេះនឹងលើកលែងការលក់ទ្រព្យសម្បត្តិលំនៅឋានដែលមានតម្លៃលើសពី $5 លាន (ដូចដែលបានកែសម្រួលតាមអតិផរណា) ដែលបានខូចខាត ឬបំផ្លាញដោយអគ្គិភ័យ Palisades ពីពន្ធនៃសំណើ ULA។ ប្រសិនបើទ្រព្យសម្បត្តិលំនៅឋានដែលរងការខូចខាត ឬត្រូវបានបំផ្លាញ ត្រូវបានលក់នៅចន្លោះថ្ងៃទី 7 ខែមករា ឆ្នាំ 2025 ដល់ថ្ងៃទី 6 ខែមករា ឆ្នាំ 2030 ដោយម្ចាស់កម្មសិទ្ធិនៅកាលបរិច្ឆេទដែលអគ្គិភ័យបានចាប់ផ្តើម នោះការលក់នឹងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការសងប្រាក់វិញ ឬការលើកលែងមួយដងពីពន្ធនៃសំណើ ULA ។

ការបោះឆ្នោតគាំទ្រមានន័យថា៖
អ្នកចង់ឱ្យការលក់ទ្រព្យសម្បត្តិលំនៅឋានដែលមានតម្លៃលើសពី $5 លាន (ដូចដែលបានកែសម្រួលតាមអតិផរណា) ដែលបានខូចខាត ឬបំផ្លាញដោយអគ្គិភ័យ Palisades មានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់ការសងប្រាក់វិញ ឬការលើកលែងមួយដងពីពន្ធនៃសំណើ ULA ប្រសិនបើបានលក់ក្នុងរយៈពេលប្រាំឆ្នាំគិតចាប់ពីកាលបរិច្ឆេទដែលអគ្គិភ័យបានចាប់ផ្តើម ។

ការបោះឆ្នោតជំទាស់មានន័យថា៖
អ្នកមិនចង់ឱ្យការលក់ទ្រព្យសម្បត្តិលំនៅឋានដែលមានតម្លៃលើសពី $5 លាន (ដូចដែលបានកែសម្រួលតាមអតិផរណា) ដែលបានខូចខាត ឬបំផ្លាញដោយអគ្គិភ័យ Palisades មានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់ការសងប្រាក់វិញ ឬការលើកលែងមួយដងពីពន្ធនៃសំណើ ULA ទេ ប្រសិនបើបានលក់ក្នុងរយៈពេលប្រាំឆ្នាំគិតចាប់ពីកាលបរិច្ឆេទដែលអគ្គិភ័យបានចាប់ផ្តើម ។

អត្ថបទពេញលេញនៃវិធានការនេះចាប់ផ្តើមនៅទំព័រ 15 ។

ចំណងជើង៖
ហេដ្ឋារចនាសម្ព័ន្ធ ថវិកា ហិរញ្ញវត្ថុ និងការចុះកិច្ចសន្យាទីក្រុង ។

បញ្ហា៖
តើធម្មនុញ្ញក្រុងគួរមានការធ្វើវិសោធនកម្មដើម្បី៖ បង្កើតផែនការហេដ្ឋារចនាសម្ព័ន្ធមូលធន និងវដ្តថវិកាពីរឆ្នាំសម្រាប់ទីក្រុង; បង្កើនអំណាចរបស់នាយកការងារសាធារណៈ (នាយក) និងអនុញ្ញាតឱ្យមានការលុបបំបាត់ ឬការផ្លាស់ប្តូរចំពោះគណៈកម្មការការងារសាធារណៈ (គណៈកម្មការ); ដកចេញនូវការកំហិតដែលហាមឃាត់ទីក្រុងមិនឱ្យចូលរួមក្នុងសហគ្រាសពាណិជ្ជកម្ម និងការដាក់បញ្ចាំទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់ក្រុង; និងផ្លាស់ប្តូរច្បាប់ និងនីតិវិធីចុះកិច្ចសន្យាជាក់លាក់ណាមួយដែរឬទេ ?

ស្ថានភាព៖
ធម្មនុញ្ញនាពេលបច្ចុប្បន្ននេះ៖ បង្កើតវដ្តថវិកាមួយឆ្នាំ; ហាមឃាត់ក្រុងមិនឱ្យដាក់បញ្ចាំទ្រព្យសម្បត្តិរបស់ខ្លួន; ដាក់កម្រិតលើការធ្វើអាជីវកម្មពាណិជ្ជកម្ម; ចែងថានាយកដ្ឋានការងារសាធារណៈត្រូវបានគ្រប់គ្រងដោយគណៈកម្មការពេញម៉ោង និងត្រូវបានជួយដោយនាយកម្នាក់; មិនតម្រូវឱ្យមានផែនការហេដ្ឋារចនាសម្ព័ន្ធមូលធន; និងគ្រប់គ្រងការផ្តល់កិច្ចសន្យា ។

សំណើ៖
វិធានការនេះនឹង៖

- បង្កើតវដ្តថវិកាពីរឆ្នាំ ដែលអាចកែសម្រួលដោយបទបញ្ញត្តិ;
- ដកចេញនូវការកំហិតលើសមត្ថភាពរបស់ទីក្រុងក្នុងការចូលរួមក្នុងអាជីវកម្មពាណិជ្ជកម្ម ឬការដាក់បញ្ចាំទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់ក្រុង;
- ពង្រីកអំណាចរបស់នាយកដើម្បីគ្រប់គ្រងនាយកដ្ឋានការងារសាធារណៈ និងអនុញ្ញាតឱ្យមានការផ្លាស់ប្តូរ ឬការលុបបំបាត់គណៈកម្មការ ដោយបទបញ្ញត្តិ;
- តម្រូវឱ្យក្រុងបង្កើតផែនការហេដ្ឋារចនាសម្ព័ន្ធមូលធន;
- លើកលែងគម្រោងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗមួយចំនួនពីច្បាប់ចុះកិច្ចសន្យាប្រកួតប្រជែងដេញថ្លៃរបស់ទីក្រុង; និង
- តាមរយៈបទបញ្ញត្តិ អនុញ្ញាតឱ្យក្រុងអាចលើកលែងកំហុសបច្ចេកទេស ឬរដ្ឋបាល និងអនុញ្ញាតឱ្យអ្នកដេញថ្លៃកែតម្រូវកំហុស ឬការខកខានផ្សេងទៀត នៅលើទម្រង់ក្រមសីលធម៌ មុនពេលការដេញថ្លៃកិច្ចសន្យាត្រូវបានវាយតម្លៃ ។

ការបោះឆ្នោតគាំទ្រមានន័យថា៖
អ្នកចង់ឱ្យធម្មនុញ្ញមានការធ្វើវិសោធនកម្ម ដើម្បីធ្វើការផ្លាស់ប្តូរដែលបានពិពណ៌នាខាងលើទាក់ទងនឹងហេដ្ឋារចនាសម្ព័ន្ធក្រុង ថវិកា ហិរញ្ញវត្ថុ និងការចុះកិច្ចសន្យា ។

ការបោះឆ្នោតជំទាស់មានន័យថា៖
អ្នកមិនចង់ឱ្យធម្មនុញ្ញមានការធ្វើវិសោធនកម្ម ដើម្បីធ្វើការផ្លាស់ប្តូរដែលបានពិពណ៌នាខាងលើទាក់ទងនឹងហេដ្ឋារចនាសម្ព័ន្ធក្រុង ថវិកា ហិរញ្ញវត្ថុ និងការចុះកិច្ចសន្យាទេ ។

អត្ថបទពេញលេញនៃវិធានការនេះចាប់ផ្តើមនៅទំព័រ 23 ។

ចំណងជើង៖
នាយកដ្ឋានរៀបចំផែនការទីក្រុង ។

បញ្ហា៖
តើធម្មនុញ្ញក្រុងគួរមានការធ្វើវិសោធនកម្មដើម្បី៖ បង្កើតគណៈកម្មការបណ្តឹងឧទ្ធរណ៍សង្កាត់ដើម្បីជំនួសគណៈកម្មការផែនការតំបន់; ផ្លាស់ប្តូរបៀបដែលសេចក្តីសម្រេចផែនការជាក់លាក់ត្រូវបានពិនិត្យឡើងវិញ និងអនុម័ត; បញ្ជាក់ឱ្យច្បាស់ពីអំណាចរបស់នាយកដ្ឋានផែនការក្រុងសម្រាប់ពាក្យសុំដែលមានអំណាចជាតុលាការ; អនុញ្ញាតឱ្យមានការផ្លាស់ប្តូរចំពោះបទបញ្ញត្តិនៃផ្ទៃជាន់អាគារដោយបទបញ្ញត្តិ; និងធ្វើការផ្លាស់ប្តូរដែលពាក់ព័ន្ធដែរឬទេ?

ស្ថានភាព៖
ធម្មនុញ្ញបង្កើតនូវអំណាច និងការណីកិច្ចរបស់អ្នកធ្វើសេចក្តីសម្រេចសំខាន់ៗនៅក្នុងការធ្វើផែនការ និងការប្រើប្រាស់ដី រួមទាំងនាយកដ្ឋានផែនការទីក្រុង គណៈកម្មការផែនការទីក្រុងនិងផែនការតំបន់ នាយកផែនការ ការិយាល័យរដ្ឋបាលបែងចែកតំបន់ក្រុមប្រឹក្សាក្រុង និងចៅហ្វាយក្រុង ។

សំណើ៖
វិធានការនេះនឹង៖

- ជំនួសគណៈកម្មការផែនការតំបន់ទាំងប្រាំពីរដោយគណៈកម្មការបណ្តឹងឧទ្ធរណ៍សង្កាត់ (NAC) តែមួយដែលមានសមាជិកយ៉ាងហោចណាស់ប្រាំពីរនាក់;
- ផ្តល់សិទ្ធិអំណាចដល់ NAC ដែលទើបបង្កើតថ្មីនូវអំណាចដើម្បីស្តាប់បណ្តឹងឧទ្ធរណ៍រដ្ឋបាល និងពិចារណាបណ្តឹងឧទ្ធរណ៍ទាំងនោះសារជាថ្មីដោយមិនមានការយោគយល់ចំពោះអ្នកធ្វើសេចក្តីសម្រេចពីមុន និងសម្រេចលើបញ្ហាផ្សេងទៀតដែលបានចែងដោយបទបញ្ញត្តិ;
- បង្កើតលក្ខខណ្ឌតម្រូវនៃនីតិវិធី និងកាលវិភាគបន្ថែមសម្រាប់ក្រុមប្រឹក្សាក្រុង ដើម្បីអនុវត្តយុត្តាធិការក្នុងបញ្ហាការធ្វើផែនការ និងការប្រើប្រាស់ដី;
- បញ្ជាក់នៅក្នុងធម្មនុញ្ញថានាយកដ្ឋានផែនការទីក្រុងទទួលខុសត្រូវចំពោះការពិនិត្យឡើងវិញដែលមានអំណាចជាតុលាការ ដូចដែលបានអនុវត្តដោយបុគ្គលិកនាយកដ្ឋានផែនការទីក្រុងដែលត្រូវបានចាត់តាំងដែលបានអនុញ្ញាតដោយបទបញ្ញត្តិ និងដូចដែលបានតែងតាំងដោយនាយកផែនការ;
- ដកចេញនូវមាត្រាដែលទាក់ទងនឹងការអនុម័តការប្រើប្រាស់ដីជាក់លាក់ និងអំណាចនីតិបញ្ញត្តិដែលបានប្រតិភូកម្ម;
- ចែងថាវិសោធនកម្មផែនការទូទៅត្រូវបានអនុម័ត ប្រសិនបើក្រុមប្រឹក្សាក្រុងមិនចាត់វិធានការក្នុងរយៈពេល 75 ថ្ងៃបន្ទាប់ពីការអនុម័តពីមុន; និង
- អនុញ្ញាតឱ្យក្រុមប្រឹក្សាក្រុងផ្លាស់ប្តូរការកំហិតផ្ទៃជាន់អាគារបច្ចុប្បន្នដោយបទបញ្ញត្តិ ។

ការបោះឆ្នោតគាំទ្រមានន័យថា៖
អ្នកចង់ធ្វើវិសោធនកម្មធម្មនុញ្ញជាមួយនឹងការផ្លាស់ប្តូរខាងលើទាក់ទងនឹងនាយកដ្ឋានផែនការទីក្រុង ។

ការបោះឆ្នោតជំទាស់មានន័យថា៖
អ្នកមិនចង់ធ្វើវិសោធនកម្មធម្មនុញ្ញជាមួយនឹងការផ្លាស់ប្តូរខាងលើទាក់ទងនឹងនាយកដ្ឋានផែនការទីក្រុងទេ ។

អត្ថបទពេញលេញនៃវិធានការនេះចាប់ផ្តើមនៅទំព័រ 40 ។

ចំណងជើង៖
ក្រមសីលធម៌ ការបោះឆ្នោត និងអភិបាលកិច្ចទីក្រុង ។

បញ្ហា៖
តើធម្មនុញ្ញក្រុងគួរត្រូវបានធ្វើវិសោធនកម្មដើម្បី៖ ពង្រឹងកម្លាំងស្មារតីនៃឯកសារជ្យកាពរបស់អគ្គត្រួតពិនិត្យនាយកដ្ឋានប៉ូលិស និងអ្នកវាយតម្លៃឯកសារជ្យនាយកដ្ឋានអគ្គិភ័យ; ហាមឃាត់មិនឱ្យស្នងការក្រមសីលធម៌ឈរឈ្មោះសម្រាប់ការបោះឆ្នោត សម្រាប់តំណែងជាប់ឆ្នោតជាក់លាក់រយៈពេលប្រាំឆ្នាំបន្ទាប់ពីចាកចេញពីតំណែង; បង្កើនទណ្ឌកម្មរូបិយវត្ថុសម្រាប់ការបំពានហិរញ្ញវត្ថុយុទ្ធនាការ; តម្រូវឱ្យក្រុមប្រឹក្សាក្រុងប្រជុំយ៉ាងហោចណាស់ប្រចាំសប្តាហ៍ ជាជាងបីថ្ងៃក្នុងមួយសប្តាហ៍ដែលតម្រូវនាពេលបច្ចុប្បន្ន; បង្កើនចំនួនហត្ថលេខាដែលត្រូវការសម្រាប់ញត្តិប្រជាមតិ; និងធ្វើការផ្លាស់ប្តូរផ្សេងទៀតទាក់ទងនឹងក្រមសីលធម៌ការបោះឆ្នោត និងរដ្ឋាភិបាលដែរឬទេ ?

ស្ថានភាព៖
ធម្មនុញ្ញក្រុងកំណត់អំពីរចនាសម្ព័ន្ធ អំណាច និងការទទួលខុសត្រូវរបស់រដ្ឋាភិបាលក្រុង ។

សំណើ៖
វិធានការនេះនឹងធ្វើការផ្លាស់ប្តូរដូចខាងក្រោម ៖

- ហាមឃាត់នាយកប្រតិបត្តិ និងស្នងការនៃគណៈកម្មការក្រមសីលធម៌ មិនឱ្យឈរឈ្មោះសម្រាប់ការបោះឆ្នោតសម្រាប់តំណែងទីក្រុង ឬតំណែងនៃគណៈកម្មការអប់រំ Los Angeles រយៈពេលប្រាំឆ្នាំបន្ទាប់ពីចាកចេញពីតំណែងរបស់ពួកគេ;
- បង្កើនទណ្ឌកម្មរូបិយវត្ថុជាអតិបរមាសម្រាប់ការបំពានហិរញ្ញវត្ថុយុទ្ធនាការដល់កម្រិតធំទៅចំនួនច្រើនជាង $15,000 (ដោយកែសម្រួលប្រចាំឆ្នាំតាមអតិផរណា) ឬ បីដងនៃចំនួនទឹកប្រាក់ ដែលបានរាយការណ៍ ឬបានបរិច្ចាគមិនត្រឹមត្រូវ សម្រាប់ការបំពាននីមួយៗ;
- បង្កើនចំនួនហត្ថលេខាដែលត្រូវបានតម្រូវសម្រាប់ញត្តិប្រជាមតិពី 10 ភាគរយទៅ 15 ភាគរយនៃឆ្នោតដែលបានបោះនៅក្នុងការបោះឆ្នោតរើសចៅហ្វាយក្រុងក្រុងចុងក្រោយ;
- ពង្រឹងកម្លាំងស្មារតីនៃឯកសារជ្យភាពរបស់អគ្គត្រួតពិនិត្យនាយកដ្ឋានប៉ូលិស និងអ្នកវាយតម្លៃឯកសារជ្យនៃនាយកដ្ឋានអគ្គិភ័យ ដើម្បីបើក និងធ្វើការស៊ើបអង្កេត ឬសវនកម្ម;
- តម្រូវឱ្យក្រុមប្រឹក្សាក្រុងប្រជុំយ៉ាងហោចណាស់ប្រចាំសប្តាហ៍ ជាជាងបីថ្ងៃក្នុងមួយសប្តាហ៍ និងធ្វើការផ្លាស់ប្តូរពាក់ព័ន្ធទៅនឹងលក្ខខណ្ឌតម្រូវនៃពេលវេលាសម្រាប់ការធ្វើការវាយតម្លៃលើចំណាត់ការរបស់គណៈកម្មការ;
- បញ្ជាក់ឱ្យច្បាស់នូវភាសាទាក់ទងនឹងការផ្ទេរអំណាចសម្រាប់នាយកដ្ឋានប៉ូលិស និងនាយកដ្ឋានអគ្គិភ័យ; និង
- អនុញ្ញាតឱ្យនិយមន័យនៃអ្នកសួមចំណែកក្នុងក្រុមប្រឹក្សាសង្កាត់ត្រូវកំណត់ដោយបទបញ្ញត្តិ ។

ការបោះឆ្នោតគាំទ្រមានន័យថា៖
អ្នកចង់ឱ្យធម្មនុញ្ញមានការធ្វើវិសោធនកម្ម ដើម្បីធ្វើការផ្លាស់ប្តូរដែលបានពិពណ៌នាខាងលើទាក់ទងនឹងក្រមសីលធម៌ការបោះឆ្នោត និងអភិបាលកិច្ច ។

ការបោះឆ្នោតជំទាស់មានន័យថា៖
អ្នកមិនចង់ឱ្យធម្មនុញ្ញមានការធ្វើវិសោធនកម្ម ដើម្បីធ្វើការផ្លាស់ប្តូរដែលបានពិពណ៌នាខាងលើទាក់ទងនឹងក្រមសីលធម៌ការបោះឆ្នោត និងអភិបាលកិច្ចទេ ។

អត្ថបទពេញលេញនៃវិធានការនេះចាប់ផ្តើមនៅទំព័រ 50 ។

ចំណងជើង៖
ថវិកានាយកដ្ឋានការកំសាន្ត និងឧទ្យានទីក្រុង ។

បញ្ហា៖
តើធម្មនុញ្ញក្រុងគួរមានការធ្វើវិសោធនកម្មដើម្បីបង្កើនថវិកាអប្បបរមាសម្រាប់នាយកដ្ឋានកែកំសាន្ត និងឧទ្យាន ដែលអនុវត្តជាដំណាក់កាលក្នុងរយៈពេលដប់ឆ្នាំ រហូតដល់វាមានចំនួនទ្វេដងនៃការបែងចែកថវិកាអប្បបរមាបច្ចុប្បន្ន ដោយមានការលើកលែងសម្រាប់ភាពអាសន្នផ្នែកសារពើពន្ធដែរឬទេ ?

ស្ថានភាព៖
ធម្មនុញ្ញបង្កើតថវិកាអប្បបរមាសម្រាប់កែកំសាន្ត និងឧទ្យានពីមូលនិធិទូទៅ ។ ថវិកាអប្បបរមានោះគឺជាចំនួនទឹកប្រាក់ស្មើនឹង 0.0325% នៃតម្លៃដែលបានវាយតម្លៃនៃអចលនទ្រព្យទាំងអស់ ដែលត្រូវបានវាយតម្លៃសម្រាប់ពន្ធទីក្រុង។ អត្រាភាគរយនៃការបែងចែករបស់ធម្មនុញ្ញនាពេលបច្ចុប្បន្ន និងការបែងចែកថវិកាដែលទទួលបាន មិនដើរទាន់ជាមួយនឹងការកើនឡើងនៃចំនួនប្រជាជន ការពង្រីកប្រព័ន្ធឧទ្យាន និងការកើនឡើងនៃថ្លៃពលកម្មនោះទេ ។ នេះបានរួមចំណែកដល់ការកាត់បន្ថយនៅក្នុងសេវាកម្មកែកំសាន្ត និងឧទ្យាន ។

សំណើ៖
វិធានការនេះនឹងបង្កើនចំនួនទឹកប្រាក់អប្បបរមានៃលុយមូលនិធិទូទៅដែលបានផ្តល់ដល់កែកំសាន្ត និងឧទ្យាន ។ ភាគរយនឹងកើនឡើងពី 0.0325% ទៅ 0.065% នៃតម្លៃដែលបានវាយតម្លៃនៃទ្រព្យសម្បត្តិទាំងអស់ដូចដែលបានវាយតម្លៃសម្រាប់ពន្ធទីក្រុង ដែលអនុវត្តជាដំណាក់កាលក្នុងរយៈពេលដប់ឆ្នាំ ។ វិធានការនេះនឹងមិនបង្កើតពន្ធថ្មី ឬបង្កើតប្រាក់ចំណូលបន្ថែមរបស់ទីក្រុងទេ។ វានឹងតម្រូវឱ្យមានថវិកាមូលនិធិទូទៅបន្ថែមទៀតដើម្បីផ្តល់ជូនដល់កន្លែងកម្សាន្ត និងឧទ្យាន។

ការបង្កើនការផ្តល់មូលនិធិនេះនឹងជួយដោះស្រាយកម្រិតសេវាកម្មកែកំសាន្ត និងឧទ្យាន គម្លាតសមធម៌ឧទ្យាន និងអនុញ្ញាតឱ្យនាយកដ្ឋានកែកំសាន្ត និងឧទ្យានរ៉ាប់រងការចំណាយលើការប្រតិបត្តិការ និងកម្មវិធីនានា ។

ក្នុងអំឡុងពេលនៃការប្រកាសភាពអាសន្នផ្នែកសារពើពន្ធ ក្រុមប្រឹក្សាក្រុងអាចកាត់បន្ថយការផ្តល់មូលនិធិដែលកើនឡើងនេះក្នុងចំនួនជាក់លាក់មួយ ។ ទោះជាយ៉ាងណាក៏ដោយ ការបែងចែកថវិកាអប្បបរមារបស់ផ្នែកកម្សាន្ត និងឧទ្យានមិនអាចកាត់បន្ថយឱ្យនៅក្រោមកម្រិតបច្ចុប្បន្ន 0.0325% នៃតម្លៃវាយតម្លៃនៃអចលនទ្រព្យទាំងអស់ដែលបានវាយតម្លៃសម្រាប់ពន្ធទីក្រុងបានទេ។

ការបោះឆ្នោតគាំទ្រមានន័យថា៖
អ្នកចង់បង្កើនថវិកាអប្បបរមាសម្រាប់នាយកដ្ឋានកែកំសាន្ត និងឧទ្យាន ដែលអនុវត្តជាដំណាក់កាលក្នុងរយៈពេលដប់ឆ្នាំ ដោយមានការលើកលែងសម្រាប់ភាពអាសន្នផ្នែកសារពើពន្ធ ។

ការបោះឆ្នោតជំទាស់មានន័យថា៖
អ្នកមិនចង់បង្កើនថវិកាអប្បបរមាសម្រាប់នាយកដ្ឋានកែកំសាន្ត និងឧទ្យានទេ ។

អត្ថបទពេញលេញនៃវិធានការនេះចាប់ផ្តើមនៅទំព័រ 63 ។

ចំណងជើង៖
នាយកដ្ឋានអាកាសយានដ្ឋាន កំពង់ផែ និងទឹក និងអគ្គិសនីទីក្រុង ។

បញ្ហា៖
តើធម្មនុញ្ញទីក្រុងគួរមានការធ្វើវិសោធនកម្មដើម្បី៖ តម្រូវឱ្យនាយកដ្ឋានកំពង់ផែបម្រុងទុកមូលនិធិសម្រាប់គម្រោងសាធារណៈនៅមាត់សមុទ្រដែលអាចចូលប្រើប្រាស់បាន; តម្រូវឱ្យមានការបង្ហាញពីផលប៉ះពាល់កម្លាំងពលកម្មសម្រាប់កិច្ចសន្យាជួល និងកិច្ចព្រមព្រៀងជាក់លាក់នៅកំពង់ផែ Los Angeles; បង្កើនរយៈពេលអតិបរមាសម្រាប់កិច្ចសន្យាជួលជាក់លាក់; និងផ្លាស់ប្តូរលក្ខខណ្ឌតម្រូវនៃសមាសភាពសម្រាប់គណៈកម្មការអ អាកាសយានដ្ឋានដែរឬទេ ?

ស្ថានភាព៖
ធម្មនុញ្ញអនុញ្ញាតឱ្យក្រុមប្រឹក្សាក្រុងអនុម័តកិច្ចសន្យាជួលរហូតដល់ 50 ឆ្នាំសម្រាប់នាយកដ្ឋានអាកាសយានដ្ឋាន (LAWA) និងនាយកដ្ឋានទឹក និងថាមពល (DWP) និងរហូតដល់ 66 ឆ្នាំសម្រាប់នាយកដ្ឋានកំពង់ផែ ។

ធម្មនុញ្ញបង្កើតគណៈកម្មការអាកាសយានដ្ឋានដែលមានសមាជិកប្រាំពីររូប ដោយមានសមាជិកមួយរូបមកពីតំបន់ជុំវិញអាកាសយានដ្ឋានអន្តរជាតិ Los Angeles (LAX) និងសមាជិកមួយរូបមកពីតំបន់ជុំវិញអាកាសយានដ្ឋាន Van Nuys (VNY)។

ធម្មនុញ្ញផ្តល់អំណាចដល់គណៈកម្មការកំពង់ផែក្នុងការគ្រប់គ្រងមណ្ឌលកំពង់ផែ។ ច្បាប់រដ្ឋតម្រូវឱ្យមានលិខិតអនុញ្ញាតការអភិវឌ្ឍឆ្នេរសមុទ្រសម្រាប់គម្រោងអភិវឌ្ឍកំពង់ផែជាច្រើន។

សំណើ៖
វិធានការនេះនឹង៖

- អនុញ្ញាតឱ្យក្រុមប្រឹក្សាក្រុងផ្តល់សិទ្ធិលើកិច្ចសន្យាជួលរហូតដល់ 66 ឆ្នាំសម្រាប់ LAWA និង DWP;
- តម្រូវឱ្យសមាជិកបីរូបនៃគណៈកម្មការអាកាសយានដ្ឋានមកពីតំបន់ជុំវិញ LAX និងពីររូបមកពីតំបន់ជុំវិញ VNY;
- តម្រូវឱ្យនាយកដ្ឋានកំពង់ផែប្រើប្រាស់ប្រាក់ចំណូលប្រតិបត្តិការមួយចំនួនរបស់ខ្លួនសម្រាប់គម្រោងសាធារណៈនៅមាត់សមុទ្រដែលអាចចូលប្រើប្រាស់បាន; និង
- តម្រូវឱ្យអ្នកដាក់ពាក្យសុំសម្រាប់កិច្ចសន្យាជួលដែលបានស្នើឡើងជាក់លាក់ និងសម្រាប់ការអភិវឌ្ឍដែលតម្រូវឱ្យមានលិខិតអនុញ្ញាតការអភិវឌ្ឍឆ្នេរសមុទ្រនៅកំពង់ផែ Los Angeles បង្ហាញពីផលប៉ះពាល់លើកម្រិតការងារដែលទាក់ទងនឹងគម្រោងដែលបានស្នើឡើង។

ការបោះឆ្នោតគាំទ្រមានន័យថា៖
អ្នកចង់ឱ្យធម្មនុញ្ញមានការធ្វើវិសោធនកម្ម ដើម្បីធ្វើការផ្លាស់ប្តូរដែលបានពិពណ៌នាខាងលើទាក់ទងនឹងនាយកដ្ឋានអាកាសយានដ្ឋាន កំពង់ផែ និងទឹក និងថាមពលរបស់ទីក្រុង ។

ការបោះឆ្នោតជំទាស់មានន័យថា៖
អ្នកមិនចង់ឱ្យធម្មនុញ្ញមានការធ្វើវិសោធនកម្ម ដើម្បីធ្វើការផ្លាស់ប្តូរដែលបានពិពណ៌នាខាងលើទាក់ទងនឹងនាយកដ្ឋានអាកាសយានដ្ឋាន កំពង់ផែ និងទឹក និងថាមពលរបស់ទីក្រុងទេ ។

អត្ថបទពេញលេញនៃវិធានការនេះចាប់ផ្តើមនៅទំព័រ 69 ។

ចំណងជើង៖
ច្បាប់ហិរញ្ញវត្ថុសម្រាប់យុទ្ធនាការទាក់ទងនឹងការបោះឆ្នោតគណៈកម្មការអប់រំ ។

បញ្ហា៖
តើធម្មនុញ្ញទីក្រុង Los Angeles គួរតែមានការធ្វើវិសោធនកម្ម ដើម្បីបញ្ជាក់ឱ្យច្បាស់នូវច្បាប់ហិរញ្ញវត្ថុយុទ្ធនាការសម្រាប់ការបោះឆ្នោតគណៈកម្មការអប់រំ និងអនុញ្ញាតឱ្យមានការផ្លាស់ប្តូរដោយបទបញ្ញត្តិដែរឬទេ ?

ស្ថានភាព៖
ធម្មនុញ្ញមានច្បាប់ហិរញ្ញវត្ថុយុទ្ធនាការសម្រាប់បេក្ខជនគណៈកម្មការអប់រំ ។ ធម្មនុញ្ញក៏មានច្បាប់ហិរញ្ញវត្ថុយុទ្ធនាការសម្រាប់បេក្ខជនចៅហ្វាយក្រុងផងដែរ ។ សំណុំច្បាប់ទាំងពីរគឺស្រដៀងគ្នាខ្លាំងណាស់ ប៉ុន្តែមាននៅក្នុងផ្នែកផ្សេងគ្នានៃធម្មនុញ្ញ ។

សំណើ៖
វិធានការនេះនឹងលុបចេញនូវភាសាដដែលៗ និងអនុវត្តច្បាប់ហិរញ្ញវត្ថុយុទ្ធនាការដូចគ្នាលើបេក្ខជនគណៈកម្មការអប់រំ ដែលអនុវត្តចំពោះបេក្ខជនចៅហ្វាយក្រុង ដោយមានការលើកលែងជាក់លាក់មួយចំនួន ។ វិធានការនេះក៏នឹងអនុញ្ញាតឱ្យក្រុមប្រឹក្សាក្រុងអនុម័តការផ្លាស់ប្តូរបន្ថែមដោយបទបញ្ញត្តិផងដែរ ។

ការបោះឆ្នោតគាំទ្រមានន័យថា៖
អ្នកចង់លុបចេញនូវភាសាដដែលៗចេញពីធម្មនុញ្ញ បញ្ជាក់ឱ្យច្បាស់នូវច្បាប់ហិរញ្ញវត្ថុយុទ្ធនាការសម្រាប់បេក្ខជនគណៈកម្មការអប់រំ និងអនុញ្ញាតឱ្យក្រុមប្រឹក្សាក្រុងអនុម័តការផ្លាស់ប្តូរបន្ថែមដោយបទបញ្ញត្តិ ។

ការបោះឆ្នោតជំទាស់មានន័យថា៖
អ្នកមិនចង់លុបចេញនូវភាសាដដែលៗចេញពីធម្មនុញ្ញ បញ្ជាក់ឱ្យច្បាស់នូវច្បាប់ហិរញ្ញវត្ថុយុទ្ធនាការសម្រាប់បេក្ខជនគណៈកម្មការអប់រំ ឬអនុញ្ញាតឱ្យក្រុមប្រឹក្សាក្រុងអនុម័តការផ្លាស់ប្តូរបន្ថែមដោយបទបញ្ញត្តិទេ ។

អត្ថបទពេញលេញនៃវិធានការនេះចាប់ផ្តើមនៅទំព័រ 74 ។

បទបញ្ញត្តិផ្តួចផ្តើម FD នៅទីក្រុង LOS ANGELES

ចំណងជើង៖
ការផ្តល់ថវិកាសម្រាប់នាយកដ្ឋានពន្លត់អគ្គិភ័យ LOS ANGELES តាមរយៈពន្ធលើការលក់ក្នុងកម្រិតកន្លះភាគរយ ។

បញ្ហា៖
តើបទបញ្ញត្តិគួរត្រូវបានអនុម័តដើម្បីបង្កើតពន្ធលក់កន្លះភាគរយ (0.5%) នៅក្នុងទីក្រុង Los Angeles ដើម្បីផ្តល់មូលនិធិបន្ថែមសម្រាប់នាយកដ្ឋានអគ្គិភ័យ Los Angeles រួមទាំងសម្រាប់ការរៀបចំបុគ្គលិក យានយន្ត និងឧបករណ៍ ស្ថានីយអគ្គិភ័យ ការកាប់ឆ្ការព្រៃតូចៗ និងតម្រូវការផ្សេងទៀតរបស់នាយកដ្ឋានអគ្គិភ័យដែរឬទេ ? ពន្ធនេះនឹងប្រមូលប្រាក់បានប្រមាណ $345 លានជារៀងរាល់ឆ្នាំ និងតម្រូវឱ្យមានសវនកម្មប្រចាំឆ្នាំ និងគណៈកម្មការគ្រប់គ្រងរបស់ពលរដ្ឋ។

ស្ថានភាព៖
នាយកដ្ឋានអគ្គិភ័យ Los Angeles (LAFD) ទទួលបានការផ្តល់មូលនិធិជារៀងរាល់ឆ្នាំតាមរយៈដំណើរការថវិការបស់ទីក្រុង ។ ស្ទើរតែទាំងអស់នៃការផ្តល់មូលនិធិនោះគឺតាមរយៈមូលនិធិទូទៅរបស់ទីក្រុង ដែលមានធនធានមានកម្រិត និងត្រូវតែគាំទ្រនាយកដ្ឋាននានាភាគច្រើនរបស់ទីក្រុង ស្របពេលដែលធ្វើឱ្យមានតុល្យភាពលើអាទិភាពប្រកួតប្រជែងជាច្រើន ។

សំណើ៖
វិធានការនេះមានលក្ខណៈគ្រប់គ្រាន់សម្រាប់សន្លឹកឆ្នោតតាមរយៈញត្តិផ្តួចផ្តើមដែលឧបត្ថម្ភដោយពលរដ្ឋ ។ វិធានការនេះនឹងបង្កើតពន្ធលក់ 0.5% ដែលនឹងបង្កើតប្រាក់ចំណូលប្រចាំឆ្នាំបន្ថែមដែលត្រូវបានបម្រុងទុកដើម្បីគាំទ្រ LAFD ។ ប្រាក់ចំណូលពីពន្ធនឹងត្រូវបានប្រើប្រាស់សម្រាប់រួមមានជាអាទិ៍ ៖

- ការរៀបចំបុគ្គលិកពន្លត់អគ្គិភ័យ ជំនួយការគ្រូពេទ្យ និងបុគ្គលិកស៊ីវិល;
- រថយន្តពន្លត់អគ្គិភ័យ រថយន្តសង្គ្រោះបន្ទាន់ ឧទ្ធម្ភាគចក្រ ឧបករណ៍ និងប្រព័ន្ធទំនាក់ទំនងសង្គ្រោះបន្ទាន់;
- ការកាប់ឆ្ការព្រៃតូចៗ និងការត្រៀមរៀបចំទប់ទល់នឹងភ្លើងឆេះព្រៃ; និង
- ការថែរក្សា ការជំនួស និងការសាងសង់ស្ថានីយអគ្គិភ័យ និងឧបករណ៍សម្រួលសេវាផ្ទះសាស្ត្រសង្គ្រោះបន្ទាន់ ។

វិធានការនេះនឹងបង្កើតគណៈកម្មការគ្រប់គ្រងរបស់ពលរដ្ឋ ដើម្បីធានាថាប្រាក់ចំណូលពីពន្ធត្រូវបានចំណាយស្របតាមបទបញ្ញត្តិ ។ ពន្ធនេះអាចត្រូវបានដាក់លុះត្រាតែទីក្រុងរក្សាកម្រិតអប្បបរមានៃការចំណាយមូលនិធិទូទៅសម្រាប់ LAFD ដោយផ្អែកលើកម្រិតនៃការផ្តល់មូលនិធិជាប្រវត្តិសាស្ត្រ ។

ការបោះឆ្នោតគាំទ្រមានន័យថា៖
អ្នកចង់បង្កើតពន្ធលក់ 0.5% ដើម្បីផ្តល់មូលនិធិបន្ថែមសម្រាប់នាយកដ្ឋានអគ្គិភ័យ Los Angeles ។

ការបោះឆ្នោតជំទាស់មានន័យថា៖
អ្នកមិនចង់បង្កើតពន្ធលក់ 0.5% ដើម្បីផ្តល់មូលនិធិបន្ថែមសម្រាប់នាយកដ្ឋានអគ្គិភ័យ Los Angeles ទេ ។

អត្ថបទពេញលេញនៃវិធានការនេះចាប់ផ្តើមនៅទំព័រ 99 ។

TE ការលើកលែងពន្ធលើការផ្ទេរទ្រព្យសម្បត្តិសម្រាប់ជនរងគ្រោះនៃគ្រោះមហន្តរាយអគ្គិភ័យ ខែមករា ឆ្នាំ 2025។ សំណើ TE។

តើគួរតែអនុម័តបទបញ្ញត្តិមួយដើម្បីផ្តល់ការលើកលែងតែម្តងគត់ពីពន្ធលើការផ្ទេរឯកសារពិសេសរបស់ក្រុង (សំណើ ULA) សម្រាប់អចលនទ្រព្យនៃគេហដ្ឋានដែលបានរងការខូចខាត ឬត្រូវបានបំផ្លាញនៅក្នុងអគ្គិភ័យ Palisades ហើយត្រូវបានលក់ក្នុងរយៈពេលប្រាំឆ្នាំគិតចាប់ពីកាលបរិច្ឆេទនៃអគ្គិភ័យនេះដែរឬទេ?

សេចក្តីសង្ខេបឥតលម្អៀង
ដោយ SHARON M. TSO ប្រធានអ្នកវិភាគនិតិបញ្ញត្តិ

ក្រុង Los Angeles ដាក់ពន្ធលើការផ្ទេរឯកសារចំនួន 0.45 ភាគរយលើការលក់ ឬការផ្ទេរអចលនទ្រព្យ។ នៅឆ្នាំ 2022 អ្នកបោះឆ្នោតបានអនុម័តពន្ធលើដំណោះស្រាយសម្រាប់ភាពគ្មានផ្ទះសម្បែង និងលំនៅឋាន (សំណើ ULA) ដែលជាពន្ធផ្ទេរឯកសារពិសេសបន្ថែមលើការលក់ ឬការផ្ទេរអចលនទ្រព្យ។ សំណើ ULA បានបង្កើតពន្ធបួនភាគរយលើការលក់ ឬការផ្ទេរអចលនទ្រព្យលើសពី $5 លានដុល្លារ និងពន្ធ 5.5 ភាគរយលើការលក់ ឬការផ្ទេរចំនួន $10 លានដុល្លារ ឬច្រើនជាងនេះ។ កម្រិតនៃការលក់អចលនទ្រព្យដែលត្រូវបង់ពន្ធត្រូវបានកែតម្រូវជារៀងរាល់ឆ្នាំដោយផ្អែកលើសន្ទស្សន៍តម្លៃទំនិញប្រើប្រាស់ដែលមានខ្សែសង្វាក់ ហើយបច្ចុប្បន្នមានចំនួន 5.4 លានដុល្លារ និង $10.9 លានដុល្លារ។ អង្គភាពរដ្ឋាភិបាល អង្គការលំនៅឋានដែលមានតម្លៃសមរម្យដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងអង្គការមិនស្វែងរកប្រាក់ចំណេញមួយចំនួនត្រូវបានលើកលែងពន្ធ។

ចំណូលពីពន្ធលើសំណើ ULA ត្រូវបានប្រើប្រាស់សម្រាប់លំនៅឋានដែលមានតម្លៃសមរម្យ និងកម្មវិធីជំនួយដល់អ្នកជួល។ កម្មវិធីលំនៅឋានមានតម្លៃសមរម្យផ្តល់មូលនិធិដល់ការផលិត និងការស្តារឡើងវិញនូវលំនៅឋានដែលមានតម្លៃសមរម្យ។ កម្មវិធីបង្ការភាពគ្មានផ្ទះសម្បែងផ្តល់មូលនិធិដល់សកម្មភាពជំនួយដល់អ្នកជួលផ្សេងៗ ដូចជាការគាំទ្រផ្នែកហិរញ្ញវត្ថុ ឬការគាំទ្រផ្នែកច្បាប់ក្នុងករណីបណ្តេញចេញ។ មិនលើសពីប្រាំបីភាគរយនៃប្រាក់ចំណូលអាចត្រូវបានប្រើប្រាស់សម្រាប់ការគ្រប់គ្រងកម្មវិធី ការរាយការណ៍ ការអនុលោមតាមច្បាប់ និងការអនុវត្ត។

នៅថ្ងៃទី 7 ខែមករា ឆ្នាំ 2025 អគ្គីភ័យ Palisades បានចាប់ផ្តើម។ យោងតាមទិន្នន័យពីនាយកដ្ឋានសំណង់ និងសុវត្ថិភាពទីក្រុង Los Angeles អគ្គីភ័យ Palisades បាននាំឱ្យមានការខូចខាត និងការបំផ្លិចបំផ្លាញសំណង់ប្រមាណ 5,620 ដែលក្នុងនោះប្រមាណ 5,495 ជាសំណង់លំនៅឋាន។ ប្រសិនបើអចលនទ្រព្យណាមួយត្រូវបានលក់ ឬផ្ទេរក្នុងតម្លៃលើសពី $5 លានដុល្លារ (ដូចដែលបានកែតម្រូវសម្រាប់អតិផរណា) ប្រតិបត្តិការនេះនឹងត្រូវជាប់ពន្ធសំណើច្បាប់ ULA។

វិធានការនេះនឹងលើកលែងការលក់ ឬការផ្ទេរអចលនទ្រព្យលំនៅឋានដែលមានតម្លៃលើសពី $5 លានដុល្លារ (ដូចដែលបានកែតម្រូវសម្រាប់អតិផរណា) ដែលត្រូវបានខូចខាត ឬបំផ្លាញដោយអគ្គីភ័យ Palisades ពីពន្ធសំណើច្បាប់ ULA។ ការខូចខាត ឬការបំផ្លិចបំផ្លាញ នឹងត្រូវបានផ្ទៀងផ្ទាត់ដោយនាយកដ្ឋានសំណង់ និងសុវត្ថិភាព។ ប្រសិនបើអចលនទ្រព្យលំនៅឋានដែលខូចខាត ឬរងការបំផ្លិចបំផ្លាញត្រូវបានលក់ ឬផ្ទេររវាងថ្ងៃទី 7 ខែមករា ឆ្នាំ 2025 និងថ្ងៃទី 6 ខែមករា ឆ្នាំ 2030 ដោយម្ចាស់កម្មសិទ្ធិដែលមានកំណត់ត្រានៅថ្ងៃដែលអគ្គីភ័យ Palisades បានចាប់ផ្តើម ការលក់ ឬការផ្ទេរនោះនឹងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការសងប្រាក់វិញម្តង ឬការលើកលែងពីពន្ធសំណើច្បាប់ ULA។

នាយកហិរញ្ញវត្ថុនឹងត្រូវបានអនុញ្ញាតឱ្យសងប្រាក់វិញលើការទាមទារដែលមានសិទ្ធិទទួលបានសម្រាប់ពន្ធ ULA ណាមួយដែលបានបង់មុនកាលបរិច្ឆេទចូលជាធរមាននៃវិធានការនេះ។

វិធានការនេះនឹងផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុដល់ម្ចាស់អចលនទ្រព្យដែលរងផលប៉ះពាល់ដោយអគ្គីភ័យ Palisades។ វិធានការនេះអាចនាំឱ្យមានការថយចុះនៃចំណូលពន្ធលើសំណើ ULA ដែលនឹងបណ្តាលឱ្យមានការថយចុះនៃមូលនិធិសម្រាប់លំនៅឋានដែលមានតម្លៃសមរម្យ និងកម្មវិធីជំនួយដល់អ្នកជួល។

វិធានការនេះនឹងមានប្រសិទ្ធភាព ប្រសិនបើត្រូវបានយល់ព្រមដោយអ្នកបោះឆ្នោតភាគច្រើន។

របាយការណ៍ផលប៉ះពាល់ហិរញ្ញវត្ថុ
ដោយ MATTHEW W. SZABO មន្ត្រីរដ្ឋបាលទីក្រុង

វិធានការនេះផ្តល់ការលើកលែងម្តងម្កាងពីពន្ធផ្ទេរឯកសារសំណើច្បាប់រួមគ្នាដើម្បីផ្តល់ផ្ទះ LA (ULA) ចំពោះអចលនទ្រព្យលំនៅឋានដែលខូចខាត ឬបំផ្លាញនៅក្នុងអគ្គីភ័យ Palisades ឆ្នាំ 2025 និងត្រូវបានលក់រវាងថ្ងៃទី 7 ខែមករា ឆ្នាំ 2025 និងថ្ងៃទី 6 ខែមករា ឆ្នាំ 2030។ ការលើកលែងនេះនឹងមិនប៉ះពាល់ដល់មូលនិធិទូទៅរបស់ទីក្រុងទេ ប៉ុន្តែនឹងកាត់បន្ថយប្រាក់ចំណូលទៅមូលនិធិសភា LA ដែលផ្តល់ហិរញ្ញប្បទានដល់ការផលិតលំនៅឋានដែលមានតម្លៃសមរម្យ និងកម្មវិធីទប់ស្កាត់ភាពគ្មានផ្ទះសម្បែង។ ការថយចុះដែលប៉ាន់ស្មាននៃប្រាក់ចំណូល ULA គឺស្ថិតនៅចន្លោះពី $35 លានដុល្លារ ទៅ $66 លានដុល្លារ រហូតដល់ខែមករា ឆ្នាំ 2030។ ការប៉ាន់ស្មាននេះគឺផ្អែកលើពន្ធ ULA ជាមធ្យមដែលបានបង់ក្នុងមួយប្រតិបត្តិការដែលមានសិទ្ធិទទួលបាននៅក្នុង Palisades ចំនួនផ្ទះដែលបានសាងសង់ឡើងវិញដែលបានចុះបញ្ជីសម្រាប់លក់គិតត្រឹមខែកក្កដា ឆ្នាំ 2026 និងការលក់ដីទំនេរបន្ទាប់ពីអគ្គីភ័យ។ ការប៉ាន់ស្មានខាងលើសន្មតថាចំនួនប្រតិបត្តិការជាមធ្យមកើនឡើងទ្វេដង។ ការខាតបង់ប្រាក់ចំណូលជាក់ស្តែងនឹងអាស្រ័យលើអចលនទ្រព្យលំនៅឋានសរុបដែលមានសិទ្ធិលក់មុនពេលការលើកលែងផុតកំណត់។

សេចក្តីអះអាងគាំទ្រសំណើ TE

អ្នកបោះឆ្នោត Los Angeles បានអនុម័តវិធានការ ULA ដើម្បីដោះស្រាយភាពគ្មានផ្ទះសម្បែង និងវិបត្តិលំនៅដ្ឋាន ។ វិធានការនេះមិនដែលមានគោលបំណងពិន័យអ្នកនៅរស់រានមានជីវិត ដែលបានបាត់បង់អ្វីៗទាំងអស់នៅក្នុងគ្រោះមហន្តរាយដែលបានប្រកាសនោះទេ ។

នៅពេលដែលមានអគ្គិភ័យ ការញ្ជួយដី ឬគ្រោះមហន្តរាយផ្សេងទៀតបំផ្លាញលំនៅដ្ឋាន ឬសហគមន៍ទាំងមូល ជនរងគ្រោះតែងតែ គ្មានជម្រើសក្រៅពីលក់ទ្រព្យសម្បត្តិរបស់ពួកគេដើម្បីបង់ការចំណាយ ផ្លាស់ប្តូរទីលំនៅ ស្តារឡើងវិញ ឬ ស្តារហិរញ្ញវត្ថុ ឡើងវិញនោះទេ ។ ការតម្រូវឱ្យពួកគេបង់ពន្ធអចលនទ្រព្យ ULA នៅពេលដែលពួកគេបានបាត់បង់ អ្វីៗទាំងអស់ទៅហើយនោះ - ដោយគ្មានកំហុសរបស់ពួកគេផ្ទាល់ - គ្រាន់តែធ្វើឱ្យស្ថានភាពដ៏មហន្តរាយកាន់តែអាក្រក់ប៉ុណ្ណោះ ។

បន្ទាប់ពីឆ្លងកាត់ការលំបាកដែលនឹកស្មានមិនដល់ជាមួយក្រុមហ៊ុនធានារ៉ាប់រង ការកើនឡើងយ៉ាងខ្លាំងនៃតម្លៃសាងសង់ឡើងវិញ និងពេលវេលាមិនច្បាស់លាស់ អ្នកនៅរស់រានមានជីវិតពីអគ្គិភ័យជាច្រើនប្រឈមមុខនឹងជម្រើសដែលមិនអាចទៅរួចៈ ទទួលយកថ្លៃចំណាយ ដែលពួកគេមិនអាចមានលទ្ធភាពសាងសង់ឡើងវិញ ឬលក់ទ្រព្យសម្បត្តិដែលពួកគេបានបាត់បង់ ។ ពួកគេមិនគួរទទួលរងការពិន័យបន្ថែមទៀតដោយពន្ធ ULA ចំពោះកាលៈទេសៈដែលហួសពីការគ្រប់គ្រងរបស់ពួកគេឡើយ ។

ការផ្តល់ការអនុគ្រោះពន្ធដល់ជនរងគ្រោះដោយគ្រោះមហន្តរាយ គឺទាក់ទងនឹងភាពយុត្តិធម៌ ក្តីមេត្តាករុណា និងការយល់ដឹងទូទៅ ។ វារក្សាគោលបំណងស្នូលនៃ ULA ខណៈពេលដែលទទួលស្គាល់ថាអ្នកនៅរស់រានមានជីវិតពីការបាត់បង់ដ៏មហន្តរាយ សមនឹងទទួលបានការគាំទ្រ និងភាពបត់បែន ។

វិធានការនេះមិនលុបចោល ULA ឬបង្កើតចន្លោះប្រហោងសម្រាប់អ្នកវិនិយោគ ឬអ្នកកសាងចំណេញនោះទេ ។ ផ្ទុយទៅវិញ វិធានការដែលបានតម្រូវយ៉ាងច្បាស់លាស់នេះផ្តល់នូវការលើកលែងមួយដងក្នុងកម្រិតកំណត់សម្រាប់ម្ចាស់ ទ្រព្យសម្បត្តិជាលំនៅដ្ឋាន រួមទាំងអគារពហុគ្រួសារ ដែលបានខូចខាត ឬបំផ្លាញនៅក្នុងអគ្គិភ័យថ្ងៃទី 7 ខែមករា ឆ្នាំ 2025 ។

ដូចដែល Los Angeles ធ្លាប់មានបទពិសោធន៍ផ្ទាល់ គ្រោះមហន្តរាយអាចកើតមានចំពោះសង្កាត់ណាមួយក៏បាន ។ នៅពេលដែល គ្រោះមហន្តរាយត្រូវបានប្រកាស ការឆ្លើយតបរបស់យើងគួរតែជួយប្រជាពលរដ្ឋឱ្យងើបឡើងវិញ មិនមែនដាក់បន្ទុក ផ្នែកហិរញ្ញវត្ថុបន្ថែមនៅពេលវេលាដ៏អាក្រក់បំផុតនោះទេ ។

ការគាំទ្រជនរងគ្រោះដោយគ្រោះមហន្តរាយមិនមែនជាបញ្ហាប្រកាន់បក្សពួកនោះទេ ។ វាគឺជាសេចក្តីថ្លែងការណ៍មួយដែលបញ្ជាក់ថា Los Angeles នៅជាមួយ អ្នករស់នៅរបស់ខ្លួននៅក្នុងពេលវេលាដែលពួកគេត្រូវការជំនួយបំផុត ។

ការបោះឆ្នោត**គាំទ្រ**រក្សាគោលបំណងនៃ ULA ខណៈពេលដែលលុបបំបាត់រាំងហិរញ្ញវត្ថុចំពោះការស្តារឡើងវិញពីគ្រោះមហន្តរាយ ។

បុគ្គលដែលចុះហត្ថលេខាលើសេចក្តីអះអាងគាំទ្រសំណើ TE

TRACI PARK
សមាជិកក្រុមប្រឹក្សា, មណ្ឌលទី 11
City of Los Angeles

KAREN BASS
ចៅហ្វាយក្រុង
City of Los Angeles

MARQUEECE HARRIS-DAWSON
ប្រធានក្រុមប្រឹក្សា, មណ្ឌលទី 8
City of Los Angeles

MONICA RODRIGUEZ
សមាជិកក្រុមប្រឹក្សា, មណ្ឌលទី 7
City of Los Angeles

BEN ALLEN
ព្រឹទ្ធសភារដ្ឋ
State of California

JACQUI ERWIN
សមាជិកសភា
State of California

NICK MELVOIN
សមាជិកក្រុមប្រឹក្សាសាលា
Los Angeles Unified School District

LA/OC BUILDING & CONSTRUCTION TRADES COUNCIL
Ernesto Medrano
លេខាធិការប្រតិបត្តិ

WESTERN STATES REGIONAL COUNCIL OF CARPENTERS
Favian Guillen
លេខាធិការប្រតិបត្តិ និងហេរញ្ញិក

PACIFIC PALISADES COMMUNITY COUNCIL
Allison Holdorff Polhill
ប្រធាន

គ្មានសេចក្តីអះអាងប្រឆាំងវិធានការនេះត្រូវបានដាក់ជូនទេ ។

សេចក្តីអះអាងដែលបានបោះពុម្ព គឺជាមតិរបស់អ្នកនិពន្ធ ហើយមិនត្រូវបានត្រួតពិនិត្យភាពត្រឹមត្រូវដោយទីភ្នាក់ងារក្រុងណាមួយឡើយ ។ លើសពីនេះ មុខតំណែងនៅក្រោមឈ្មោះអ្នកចុះហត្ថលេខា គឺសម្រាប់គោលបំណងកំណត់អត្តសញ្ញាណតែប៉ុណ្ណោះ ហើយមិនបង្ហាញថាបុគ្គលនោះកំពុងចុះហត្ថលេខាក្នុងនាមអង្គការនោះទេ ។

បទបញ្ញត្តិថ្មី ឬភាសាដែលបានបន្ថែមទៅក្នុងក្រមសាលាក្រុង ឬទៅក្នុងផ្នែកដែលមានស្រាប់នៃក្រមសាលាក្រុងត្រូវបានបង្ហាញដោយប្រភេទ<u>អក្សរគ្មានសបន្ទាត់ពីក្រោម</u> ដោយពាក្យដែលបានលុបចេញពីក្រមសាលាក្រុង ឬពីផ្នែកដែលមានស្រាប់នៃក្រមសាលាក្រុង ត្រូវបានបង្ហាញដោយប្រភេទ~~អក្សរឆ្លងកាត់~~។

សំណើ TE

អត្ថបទនៃវិធានការសន្ធឹកឆ្នោតដែលបានស្នើឡើង

ផ្នែក 1. ផ្នែកថ្មី 21.9.17 ត្រូវបានបន្ថែមទៅក្នុងក្រមសាលាក្រុងនៃទីក្រុង Los Angeles ពាក់ព័ន្ធនឹងការលើកលែងចំពោះពន្ធលើដំណោះស្រាយការផ្តត់ផ្គង់លំនៅដ្ឋាន និងភាពគ្មានផ្ទះសម្បែង ដើម្បីអានដូចខាងក្រោម៖

<u>ផ្នែកទី 21.9.17. ការលើកលែង - អគ្គិភ័យ PALISADES</u>

<u>(a) ពន្ធលើដំណោះស្រាយភាពគ្មានផ្ទះសម្បែង និងលំនៅឋាន ដែលដាក់ដោយផ្នែករង (b) នៃផ្នែកទី 21.9.2 នៃក្រមនេះ មិនត្រូវអនុវត្តទាក់ទងនឹងការផ្ទេរកម្មសិទ្ធិ លិខិតបំណុល ឬលិខិតស្នាមណាមួយដែលដី ផ្ទះជួល ឬអចលនទ្រព្យផ្សេងទៀតដែលបានលក់នៅក្នុងទីក្រុង Los Angeles នឹងត្រូវបានធ្វើសម្បទាន ប្រគល់សិទ្ធ ផ្ទេរកម្មសិទ្ធិ ឬកាត់ឈ្មោះឱ្យអ្នកទិញម្នាក់ ឬអ្នកអ្នកទិញច្រើន ឬបុគ្គលម្នាក់ ឬមនុស្សណាមួយផ្សេងទៀត ដោយផ្តល់ជូនថា៖</u>

<u>(1) ដីធ្លី អចលនទ្រព្យ ឬអចលនទ្រព្យផ្សេងទៀតដែលបានលក់នៅក្នុងទីក្រុង Los Angeles គឺជាទ្រព្យសម្បត្តិលំនៅដ្ឋានដែលបានខូចខាត ឬត្រូវបានបំផ្ទិចបំផ្លាញដោយអគ្គិភ័យ Palisades នៅក្នុងខែមករា ឆ្នាំ 2025;</u>

<u>(2) ការខូចខាត ឬការបំផ្ទិចបំផ្លាញនៃទ្រព្យសម្បត្តិលំនៅដ្ឋានដែលបានពិពណ៌នានៅក្នុងផ្នែករង (a)(1) ត្រូវបានបញ្ជាក់ដោយនាយកដ្ឋានសំណង់ និងសុវត្ថិភាព;</u>

<u>(3) អ្នកប្រគល់ អ្នកផ្ទេរសិទ្ធិ ឬអ្នកផ្ទេរ គឺជាម្ចាស់ ឬម្ចាស់ទាំងឡាយនៃទ្រព្យសម្បត្តិលំនៅដ្ឋានដែលបានពិពណ៌នានៅក្នុងផ្នែក (a)(1);</u>

<u>(4) អ្នកប្រគល់ អ្នកផ្ទេរសិទ្ធិ ឬអ្នកផ្ទេរ ដែលបានពិពណ៌នានៅក្រោមផ្នែករង (a)(3) គឺជាម្ចាស់ ឬម្ចាស់ទាំងឡាយនទ្រព្យសម្បត្តិលំនៅដ្ឋានដែលបានពិពណ៌នានៅក្នុងផ្នែករង (a)(1) នៅថ្ងៃទី 7 ខែមករា ឆ្នាំ 2025;</u>

<u>(5) ទ្រព្យសម្បត្តិដែលបានពិពណ៌នានៅក្នុងផ្នែករង (a)(1) មិនបានទទួលការលើកលែងជាមុនមកក្រោមផ្នែកនេះឡើយ; និង</u>

<u>(6) ទ្រព្យសម្បត្តិដែលបានពិពណ៌នានៅក្នុងផ្នែករង (a)(1) មិនត្រូវបានលើកលែងពីផ្នែករង (a) នៃផ្នែក 21.9.2 នៃក្រមនេះតាមវិធីផ្សេងទៀតឡើយ។</u>

<u>(b) ពាក្យ “ខូចខាត” ត្រូវមានការអនុវត្តដូចគ្នាដូចដែលបានកំណត់នៅក្នុងផ្នែក 16.03 នៃក្រមនេះ។</u>

<u>(c) ផ្នែករង (a) ត្រូវមានប្រសិទ្ធភាពចាប់ផ្តើមពីថ្ងៃទី 7 ខែមករា ឆ្នាំ 2025 រហូតដល់ថ្ងៃទី 6 ខែមករា ឆ្នាំ 2030។</u>

<u>(d) ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ត្រូវបានផ្តល់សិទ្ធិ និងអំណាចក្នុងការចេញប្រាក់សងវិញលើការទាមទារដែលមានសិទ្ធិទទួល ដែលត្រូវបានចាត់ទុកថាបានកើតឡើង សម្រាប់ពន្ធលើដំណោះស្រាយកាត់បន្ថយជនអនាថា និងការផ្តត់ផ្គង់ជម្រកណាមួយដែលបានដាក់ចេញអនុលោមតាមផ្នែករង (b) នៃផ្នែក 21.9.2 ដែលត្រូវបានបង់មុនកាលបរិច្ឆេទចូលជាធរមាននៃផ្នែកនេះ ក្នុងលក្ខណៈដែលបានផ្តល់នៅក្នុងផ្នែក 21.9.10 នៃក្រមនេះ។ កាលកំណត់ពេលវេលាណាមួយដែលបានកំណត់ដោយផ្នែក 21.9.10 នៃក្រមនេះ ពាក់ព័ន្ធនឹងការសងប្រាក់វិញដែលបានពិពណ៌នានៅទីនេះ មិនត្រូវចាប់ផ្តើមដំណើរការរហូតដល់កាលបរិច្ឆេទចូលជាធរមាននៃផ្នែកនេះឡើយ។</u>

ផ្នែកទី 2. ភាពអាចបំបែកបាន។ ប្រសិនបើផ្នែក ផ្នែករង ឃ្លា ប្រយោគ ឃ្លាឃ្លោង ឬការអនុវត្តនៃបទបញ្ញត្តិណាមួយ ឬផ្នែកណាមួយនៃបទបញ្ញត្តិនេះ ត្រូវបានកាន់កាប់ថារំលោភលើរដ្ឋធម្មនុញ្ញ ឬគ្មានសុពលភាពដោយតុលាការ ឬក្រុមប្រឹក្សា

ជំនុំជម្រះដែលមានយុត្តាធិការ ផ្នែក ផ្នែករង ឃ្លា ប្រយោគ ឃ្លាឃ្លោង ផ្នែក ឬការអនុវត្តដែលនៅសល់នៃបទបញ្ញត្តិនេះ ត្រូវតែបន្ត មានអនុភាព និងប្រសិទ្ធភាពពេញលេញ ហើយរហូតដល់ចុងបញ្ចប់នេះ លក្ខខណ្ឌនៃបទបញ្ញត្តិនេះគឺអាចបំបែកចេញពីគ្នាបាន។ លើសពីនេះ អ្នកបោះឆ្នោតប្រកាសថា ពួកគេនឹងបានអនុម័តគ្រប់ផ្នែក អនុភាគ ខចែង ប្រយោគ ឃ្លា ចំណែក និងការអនុវត្ត ទាំងអស់នៃបទបញ្ញត្តិនេះ ដោយគ្មានផ្នែក អនុភាគ ខចែង ប្រយោគ ឃ្លា ចំណែក ឬការអនុវត្តណាមួយត្រូវបានចាត់ទុកថាផ្ទុយ នឹងរដ្ឋធម្មនុញ្ញ ឬមិនមានសុពលភាពឡើយ។

LA ហេដ្ឋារចនាសម្ព័ន្ធទីក្រុង ថវិកា ហិរញ្ញវត្ថុ និងការចុះកិច្ចសន្យា។ វិសោធនកម្មធម្មនុញ្ញ LA។

តើធម្មនុញ្ញក្រុងគួរត្រូវបានធ្វើវិសោធនកម្មដើម្បី៖ បង្កើតផែនការហេដ្ឋារចនាសម្ព័ន្ធមូលធន និងរដ្ឋថវិការយៈពេលពីរឆ្នាំសម្រាប់ក្រុង បង្កើនអំណាចរបស់ប្រធាននាយកដ្ឋានសាធារណការ និងអនុញ្ញាតឱ្យមានការលុបចោល ឬការផ្លាស់ប្តូរក្រុមប្រឹក្សាសាធារណការ លុបចោលការដាក់កម្រិតដែលហាមប្រាមទីក្រុងមិនឱ្យចូលរួមក្នុងសហគ្រាសពាណិជ្ជកម្ម និងការដាក់បញ្ចាំទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់ក្រុង និងផ្លាស់ប្តូរច្បាប់កិច្ចសន្យាជាក់លាក់ និងដំណើរការមួយចំនួនដែរឬទេ?

សេចក្តីសង្ខេបឥតលម្អៀង
ដោយ SHARON M. TSO ប្រធានអ្នកវិភាគនិតិបញ្ញត្តិ

ធម្មនុញ្ញក្រុង Los Angeles (ធម្មនុញ្ញ) រួមមានវិធានសម្រាប់របៀបដែលក្រុងគ្រប់គ្រងថវិការបស់ខ្លួន ការចុះកិច្ចសន្យា ទ្រព្យសម្បត្តិដែលគ្រប់គ្រងដោយក្រុង និងនាយកដ្ឋានការងារសាធារណៈ។ វិធានការនេះនឹងធ្វើវិសោធនកម្មធម្មនុញ្ញដើម្បីធ្វើការផ្លាស់ប្តូរវិធានទាំងនេះ ដូចខាងក្រោម៖

- ថវិការយៈពេលពីរឆ្នាំ៖ បច្ចុប្បន្ននេះ ក្រុងតម្រូវឱ្យអនុម័តថវិកាជារៀងរាល់ឆ្នាំ។ វិធានការនេះនឹងផ្លាស់ប្តូររដ្ឋថវិការបស់ក្រុងទៅជារដ្ឋថវិការយៈពេលពីរឆ្នាំ លើកលែងតែរដ្ឋថវិកាមួយផ្សេងទៀតត្រូវបានអនុម័តដោយបញ្ញត្តិ ហើយកែប្រែកាលបរិច្ឆេទដែលចៅហ្វាយក្រុងដាក់បញ្ជូនថវិកាដែលបានស្នើឡើង។ វិធានការនេះនឹងតម្រូវឱ្យចៅហ្វាយក្រុងដាក់បញ្ជូនថវិការយៈពេលពីរឆ្នាំដែលបានស្នើឡើងទៅក្រុមប្រឹក្សាក្រុង (ក្រុមប្រឹក្សា) នៅត្រឹមថ្ងៃទី 1 ខែមេសា។ ក្រុមប្រឹក្សានឹងមានពេលរហូតដល់ថ្ងៃទី 1 ខែមិថុនា ដើម្បីអនុម័ត ឬកែប្រែថវិការយៈពេលពីរឆ្នាំដែលបានស្នើឡើង។ ការផ្លាស់ប្តូរក្រុមប្រឹក្សានឹងស្ថិតនៅក្រោមការវេតូរបស់ចៅហ្វាយក្រុង និងការបដិសេធរបស់ក្រុមប្រឹក្សា ដូចដែលបានបញ្ជាក់នៅក្នុងធម្មនុញ្ញ។ សម្រាប់ឆ្នាំសារពើពន្ធនីមួយៗនៃរដ្ឋថវិការយៈពេលពីរឆ្នាំ ក្រុមប្រឹក្សានឹងអនុម័តចំនួនទឹកប្រាក់ដែលបានបែងចែកក្នុងថវិកាសម្រាប់ឆ្នាំសារពើពន្ធខាងមុខ តាមសេចក្តីសម្រេច នៅថ្ងៃទី 1 ខែមិថុនា ឬមុននោះ ដោយអាស្រ័យលើការវេតូរបស់ចៅហ្វាយក្រុង និងបទបញ្ញត្តិដែលក្រុមប្រឹក្សាលុបចោល។
- ផែនការហេដ្ឋារចនាសម្ព័ន្ធមូលធន (CIP)៖ បច្ចុប្បន្ននេះ សាលាក្រុងមិនតម្រូវឱ្យមានផែនការមូលធនសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធក្រុងទេ។ វិធានការនេះនឹងតម្រូវឱ្យសាលាក្រុងបង្កើត CIP មួយតាមអនុក្រឹត្យ។ បទបញ្ជានេះនឹងរួមបញ្ចូលវិសាលភាព រយៈពេល មូលនិធិ និងតម្រូវការរាយការណ៍សម្រាប់ CIP។ គម្រោងនានាអាចរួមមានការសាងសង់ ឬការកែលម្អផ្លូវថ្នល់ ឧទ្យាន ស្ពាន និងអគារនានាក្នុងទីក្រុង។
- ការដេញថ្លៃបែបប្រកួតប្រជែង៖ បច្ចុប្បន្ននេះ ធម្មនុញ្ញតម្រូវឱ្យទីក្រុងអនុវត្តតាមច្បាប់ដេញថ្លៃកិច្ចសន្យាប្រកួតប្រជែង ដូចជាការផ្តល់កិច្ចសន្យាដល់អាជីវកម្មដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងតម្លៃទាបបំផុត។ វិធានការនេះបន្ថែមការណីលើកលែងមួយចំពោះវិធានទាំងនេះសម្រាប់សេវាកម្មកម្មវិធី ឬកិច្ចសន្យាថ្មីទាំងដែលទទួលបានពីក្រុមហ៊ុនផលិតកម្មវិធី។ វិធានការនេះក៏អនុញ្ញាតឱ្យទីក្រុង តាមបញ្ញត្តិ បង្កើតការណីលើកលែងចំពោះវិធានសម្រាប់កិច្ចសន្យាហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗមួយចំនួន ដែលមានសារៈសំខាន់ចំពោះសន្តិសុខ សុខភាពសាធារណៈ ឬសុវត្ថិភាពរបស់ទីក្រុង។
- នាយកដ្ឋានការងារសាធារណៈ (នាយក) អភិបាលកិច្ច៖ បច្ចុប្បន្ននេះ ធម្មនុញ្ញបង្កើតក្រុមប្រឹក្សាភិបាលមុខងារសាធារណៈ (ក្រុមប្រឹក្សាភិបាល) ពេញម៉ោង ដែលត្រូវបានជួយដោយប្រធានការិយាល័យជាច្រើនរូប និងនាយកដ្ឋានការងារសាធារណៈ (ប្រធាននាយកដ្ឋាន) ដើម្បីត្រួតពិនិត្យនាយកដ្ឋាន។ វិធានការនេះនឹងបង្កើនអំណាច និងភារកិច្ចរបស់ប្រធាននាយកដ្ឋានដើម្បី៖ គ្រប់គ្រងដោយផ្ទាល់នូវគម្រោងសាងសង់សំណង់

សាធារណៈ រួមទាំងការជួល ឬទិញអចលនទ្រព្យ, អនុវត្តអំណាចនៃកម្មសិទ្ធិឯកជន ដោយស្ថិតនៅក្រោមការអនុម័តពីក្រុមប្រឹក្សា, ត្រួតពិនិត្យការគ្រប់គ្រងកិច្ចសន្យា, ផ្តល់លិខិតអនុញ្ញាតផ្លូវ និងណែនាំថវិកាប្រតិបត្តិការសម្រាប់នាយកដ្ឋាន។ ផ្ទុយទៅវិញ អំណាចមួយចំនួនរបស់ក្រុមប្រឹក្សាភិបាលនឹងត្រូវផ្ទេរទៅឱ្យប្រធាននាយកដ្ឋាន ប៉ុន្តែក្រុមប្រឹក្សាភិបាលនឹងរក្សាភារកិច្ចមួយចំនួនរបស់ខ្លួន ដូចជា៖ ការអនុម័តការផ្តល់កិច្ចសន្យា, ការធ្វើសវនាការតាមការអនុញ្ញាតដោយច្បាប់, ការអនុម័ត ដោយពិគ្រោះយោបល់ជាមួយនាយក នូវលក្ខណៈបច្ចេកទេសសម្រាប់គម្រោងការងារសាធារណៈ, និងការធ្វើអនុសាសន៍អំពីផែនការការងារសាធារណៈដល់នាយក ចៅហ្វាយក្រុង និងក្រុមប្រឹក្សា។ វិធានការនេះក៏ផ្តល់សិទ្ធិអំណាចដល់ក្រុមប្រឹក្សា តាមរយៈព្រះរាជក្រឹត្យ ដើម្បីធ្វើការផ្លាស់ប្តូរ ឬលុបបំបាត់ក្រុមប្រឹក្សាភិបាលផងដែរ។ លើសពីនេះ វិធានការនេះលុបបំបាត់ការតែងតាំងមន្ត្រីរដ្ឋបាលជាន់ខ្ពស់សម្រាប់ប្រធានការិយាល័យ ដែលស្របតាមអំណាច និងកាតព្វកិច្ចដែលបានស្នើឡើងរបស់ប្រធាននាយកដ្ឋាន។

- ប្រតិបត្តិការអាជីវកម្ម៖ បច្ចុប្បន្ននេះ ធម្មនុញ្ញហាមឃាត់ក្រុងពីការបញ្ចាំទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់ក្រុង និងរារាំងក្រុងពីការដំណើរការអាជីវកម្មពាណិជ្ជកម្ម ឬឧស្សាហកម្មសុទ្ធសាធ។ វិធានការនេះនឹងលុបចោលការរឹតបន្តឹងទាំងនេះ ដើម្បីអនុញ្ញាតឱ្យក្រុងប្រើប្រាស់ទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់ក្រុង និងចូលរួមក្នុងអាជីវកម្មពាណិជ្ជកម្ម ឬឧស្សាហកម្ម។
- ទម្រង់កិច្ចសន្យា៖ បច្ចុប្បន្ននេះ នៅពេលដែលក្រុមហ៊ុនខាងក្រៅដេញថ្លៃលើកិច្ចសន្យារបស់សាលាក្រុង ពួកគេត្រូវបានតម្រូវឱ្យដាក់បញ្ជូនទម្រង់បែបបទជាក់លាក់។ វិធានការនេះនឹងអនុញ្ញាតឱ្យក្រុង ដោយបញ្ញត្តិ លើកលែង ឬអនុញ្ញាតឱ្យកែតម្រូវកំហុសបច្ចេកទេស ឬរដ្ឋបាលតូចតាច មុនពេលវាយតម្លៃសំណើកិច្ចសន្យា។ ទោះជាយ៉ាងណាក៏ដោយ កំហុសធ្ងន់ធ្ងរសំខាន់ៗក្នុងទម្រង់សីលធម៌មិនអាចលើកលែងបានទេ ហើយត្រូវតែកែតម្រូវឱ្យបានពេញលេញ។

វិធានការនេះនឹងមានប្រសិទ្ធភាព ប្រសិនបើត្រូវបានយល់ព្រមដោយអ្នកបោះឆ្នោតភាគច្រើន។

របាយការណ៍ផលប៉ះពាល់ហិរញ្ញវត្ថុ
ដោយ MATTHEW W. SZABO មន្ត្រីរដ្ឋបាលទីក្រុង

វិធានការនេះបង្កើតផែនការហេដ្ឋារចនាសម្ព័ន្ធមូលធន ផ្លាស់ប្តូរទីក្រុងទៅជារដ្ឋថវិការយៈពេលពីរឆ្នាំ ពង្រីកអំណាចរបស់ប្រធាននាយកដ្ឋានការងារសាធារណៈ និងអនុញ្ញាតឱ្យទីក្រុងចូលរួមក្នុងសហគ្រាសអាជីវកម្ម ដាក់បញ្ចាំទ្រព្យសម្បត្តិទីក្រុង និងកែប្រែនីតិវិធីចុះកិច្ចសន្យា។ **ការផ្លាស់ប្តូរទៅរដ្ឋថវិការយៈពេលពីរឆ្នាំ និងការបង្កើតផែនការហេដ្ឋារចនាសម្ព័ន្ធមូលធននឹងត្រូវការការចំណាយម្តងម្កាលប្រមាណ $4 ទៅ $6 លានដុល្លារ ដើម្បីកែលម្អឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងថវិកា និងទ្រព្យសកម្ម បណ្តុះបណ្តាលបុគ្គលិក និងពិគ្រោះយោបល់ជាមួយអ្នកជំនាញផ្នែកប្រធានបទ។** មូលនិធិនឹងទទួលបានមកពីមូលនិធិទូទៅ ស្ថិតក្រោមការអនុម័តពីចៅហ្វាយក្រុង និងក្រុមប្រឹក្សាក្រុងតាមរយៈដំណើរការថវិកា។ ការចំណាយជាបន្តបន្ទាប់សម្រាប់ធាតុទាំងពីរនៃវិធានការនេះ ដូចជាការគ្រប់គ្រងគម្រោង នឹងត្រូវបានស្រូបយកដោយការរៀបចំឡើងវិញនូវធនធានដែលមានស្រាប់។ ផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ និងប្រាក់ចំណូលនៃវិសោធនកម្មធម្មនុញ្ញដែលនៅសល់ — រួមទាំងការផ្លាស់ប្តូរកិច្ចសន្យា ប្រាក់កម្ចីទិញផ្ទះ និងសហគ្រាសអាជីវកម្ម — មិនអាចវាស់វែងបាននៅពេលនេះទេ។

សេចក្តីអះអាងគាំទ្រនៃវិសោធនកម្មធម្មនុញ្ញ LA

សូមបោះឆ្នោតគាំទ្រវិធានការ LA ដើម្បីទាមទារឱ្យសាលាក្រុងផ្តល់សេវាមូលដ្ឋានឱ្យកាន់តែប្រសើរឡើង ជួសជុលហេដ្ឋារចនាសម្ព័ន្ធដែលទ្រុឌទ្រោមឱ្យបានលឿនជាងមុន និងប្រើប្រាស់មូលនិធិរបស់អ្នកបង់ពន្ធឱ្យកាន់តែមានប្រសិទ្ធភាព ។

ទីក្រុង Los Angeles មិនអាចដោះស្រាយការជួសជុលហេដ្ឋារចនាសម្ព័ន្ធដែលត្រូវការទឹកប្រាក់រាប់ពាន់លានដុល្លារ ឬដាក់ហិរញ្ញវត្ថុរបស់ខ្លួនឱ្យមានស្ថិរភាពរឹងមាំជាងមុនបានឡើយ ដោយគ្មានផែនការសម្រាប់អ្វីដែលត្រូវធ្វើ តើត្រូវចំណាយអស់ប៉ុន្មាន និងអ្នកណាជាអ្នកទទួលខុសត្រូវក្នុងការធ្វើឱ្យវាសម្រេចបាន ។

ប្រជាជន Los Angeles ឃើញផ្ទាល់ភ្នែកនូវអ្វីដែលកើតឡើង នៅពេលដែលទីក្រុងខកខានក្នុងការរៀបចំផែនការទុកជាមុន ។ ទីក្រុងត្រូវចំណាយពេលច្រើនឆ្នាំដើម្បីក្រាលផ្លូវថ្នល់ឡើងវិញ ជួសជុលផ្លូវថ្មើរជើង និងអំពូលភ្លើងតាមដងផ្លូវ ព្រមទាំងដោះស្រាយការងារថែទាំដែលត្រូវធ្វើជាបន្តបន្ទាប់ ដោយតែងតែរង់ចាំរហូតដល់បញ្ហាកាន់តែស្មុគស្មាញ និងចំណាយប្រាក់កាន់តែច្រើនក្នុងការជួសជុល ។

វិធានការ LA ដោះស្រាយបញ្ហានោះ ។ វាទាមទារឱ្យទីក្រុង Los Angeles រៀបចំផែនការទុកជាមុន ។ វាបង្កើតការរៀបចំផែនការហេដ្ឋារចនាសម្ព័ន្ធរយៈពេលវែង ដើម្បីឱ្យទីក្រុងអាចផ្តល់អាទិភាពដល់ការជួសជុល ដោះស្រាយការថែទាំមុនពេលបញ្ហាក្លាយជាការចំណាយប្រាក់ច្រើន និងជំរុញគម្រោងឱ្យឈានទៅមុខដោយមានការទទួលខុសត្រូវច្បាស់លាស់ក្នុងការបំពេញការងារឱ្យបានសម្រេច ។

វាក៏តម្រូវឱ្យមានការរៀបចំថវិការយៈពេលពីរឆ្នាំផងដែរ ដើម្បីឱ្យថ្នាក់ដឹកនាំទីក្រុងពិចារណាលើការចំណាយនាពេលអនាគតនៅពេលធ្វើការសម្រេចចិត្តក្នុងពេលបច្ចុប្បន្ន ។ ហើយវាដកចេញនូវការដាក់កម្រិតធម្មនុញ្ញដែលហួសសម័យ ដែលធ្វើឱ្យទីក្រុង Los Angeles ពិបាកដំណើរការប្រកបដោយប្រសិទ្ធភាព និងធ្វើឱ្យមូលនិធិរបស់អ្នកបង់ពន្ធអាចប្រើប្រាស់បានកាន់តែមានប្រសិទ្ធភាព ។

វិធានការ LA នឹងមិនជួសជុលរណ្តៅទាំងអស់ក្នុងមួយយប់នោះទេ ។ ប៉ុន្តែផ្លូវថ្នល់ ផ្លូវថ្មើរជើង ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទីក្រុងកាន់តែប្រសើរ ចាប់ផ្តើមចេញពីការរៀបចំផែនការកាន់តែល្អ ការទទួលខុសត្រូវកាន់តែច្បាស់លាស់ និងការរៀបចំថវិកាកាន់តែមានប្រសិទ្ធភាព ។

ពួកយើងបានចំណាយពេលច្រើនឆ្នាំដើម្បីពិនិត្យពិចារណាទីក្រុង ធ្វើសវនកម្មកម្មវិធី ត្រួតពិនិត្យនាយកដ្ឋាន និងខិតខំប្រឹងប្រែងដើម្បីឱ្យមានហេដ្ឋារចនាសម្ព័ន្ធកាន់តែប្រសើរ ។ ពួកយើងបានឃើញផ្ទាល់ភ្នែកនូវអ្វីដែលជាឧបសគ្គរារាំង ។ យើងជឿជាក់ថាការកែទម្រង់ទាំងនេះនឹងជួយទីក្រុង Los Angeles ផ្តល់លទ្ធផលកាន់តែប្រសើរសម្រាប់ប្រជាជនដែលរស់នៅទីនេះ ។

សូមបោះឆ្នោតគាំទ្រវិធានការ LA ។

បុគ្គលដែលចុះហត្ថលេខាលើសេចក្តីអះអាងគាំទ្រនៃវិសោធនកម្មធម្មនុញ្ញ LA

KENNETH MEJIA
អ្នកគ្រប់គ្រង
City of Los Angeles

BOB BLUMENFIELD
សមាជិកក្រុមប្រឹក្សាទីក្រុង LA
City of Los Angeles

RON GALPERIN
អ្នកគ្រប់គ្រងទីក្រុង
City of Los Angeles

MICHAEL SCHNEIDER
CEO
Streets For All

KATY YAROSLAVSKY
សមាជិកក្រុមប្រឹក្សាទីក្រុង LA
City of Los Angeles

JESSICA MEANEY
នាយកប្រតិបត្តិ
Investing in Place

DAVID LEVITUS
CEO
LA Forward

សេចក្តីអះអាងដែលបានបោះពុម្ព គឺជាមតិរបស់អ្នកនិពន្ធ ហើយមិនត្រូវបានត្រួតពិនិត្យភាពត្រឹមត្រូវដោយទីភ្នាក់ងារក្រុងណាមួយឡើយ ។ លើសពីនេះ មុខតំណែងនៅក្រោមឈ្មោះអ្នកចុះហត្ថលេខា គឺសម្រាប់គោលបំណងកំណត់អត្តសញ្ញាណតែប៉ុណ្ណោះ ហើយមិនបង្ហាញថាបុគ្គលនោះកំពុងចុះហត្ថលេខាក្នុងនាមអង្គការនោះទេ ។

សេចក្តីអះអាងប្រឆាំងវិធានការវិសោធនកម្មធម្មនុញ្ញ LA

នៅក្នុងពេលវេលាដែល Los Angeles បានជួបប្រទះនូវអាស្រូវពុករលួយជាបន្តបន្ទាប់ ហើយទំនុកចិត្តសាធារណៈលើសាលាក្រុងត្រូវបានខូចខាត យើងគួរតែពង្រឹងតម្លាភាព និងគណនេយ្យភាព មិនមែនលុបបំបាត់ការត្រួតពិនិត្យឯករាជ្យនោះទេ។

ប្រសិនបើត្រូវបានអនុម័ត វិសោធនកម្មធម្មនុញ្ញ LA នឹងផ្តល់អំណាចឱ្យក្រុមប្រឹក្សាក្រុងលុបបំបាត់ក្រុមប្រឹក្សាកិបាលការងារសាធារណៈ ហើយបង្រួមអំណាចទាំងនោះឱ្យស្ថិតនៅក្រោមបុគ្គលតែម្នាក់។ ក្រុមប្រឹក្សានេះត្រូវបានបង្កើតឡើង ដើម្បីផ្តល់ការពិនិត្យឡើងវិញដោយឯករាជ្យលើការចុះកិច្ចសន្យារបស់ក្រុង ដោយការសម្រេចចិត្តត្រូវធ្វើឡើងនៅក្នុងកិច្ចប្រជុំសាធារណៈដែលអនុលោមតាមច្បាប់កិច្ចប្រជុំបើកចំហរបស់ California។ ការដកចេញនូវប្រព័ន្ធត្រួតពិនិត្យ និងតុល្យភាពអំណាចដ៏សំខាន់នេះ នឹងកាត់បន្ថយការស៊ើបសួរពីសាធារណជន និងធ្វើឱ្យទន់ខ្សោយនូវគណនេយ្យភាពលើប្រាក់ពន្ធរាប់ពាន់លានដុល្លាររបស់អ្នកបង់ពន្ធ សម្រាប់គម្រោងសាធារណៈនានា។

អ្នកគាំទ្រវិសោធនកម្មលក្ខន្តិកៈនេះ បានចង្អុលបង្ហាញពីការកែទម្រង់ដូចជា ផែនការកែលម្អដើមទុន ប៉ុន្តែការផ្លាស់ប្តូរនោះអាចអនុវត្តបាន ដោយមិនបាច់ធ្វើវិសោធនកម្មលក្ខន្តិកៈនោះទេ។

ទីក្រុង Los Angeles ត្រូវការតម្លាភាពបន្ថែមទៀត ការត្រួតពិនិត្យបន្ថែមទៀត និងការការពារកាន់តែរឹងមាំប្រឆាំងនឹងការរំលោភបំពាន មិនមែនកាត់បន្ថយវិធានការសុវត្ថិភាពនោះឡើយ។

សូមបោះឆ្នោតប្រឆាំងនឹងវិសោធនកម្មធម្មនុញ្ញ LA។

បុគ្គលដែលចុះហត្ថលេខាលើសេចក្តីអះអាងប្រឆាំងវិសោធនកម្មធម្មនុញ្ញ LA

MONICA RODRIGUEZ
សមាជិកាក្រុមប្រឹក្សាក្រុង Los Angeles, មណ្ឌលទី 7
City of Los Angeles

សេចក្តីអះអាងដែលបានបោះពុម្ព គឺជាមតិរបស់អ្នកនិពន្ធ ហើយមិនត្រូវបានត្រួតពិនិត្យភាពត្រឹមត្រូវដោយទីភ្នាក់ងារក្រុងណាមួយឡើយ ។ លើសពីនេះ មុខតំណែងនៅក្រោមឈ្មោះអ្នកចុះហត្ថលេខា គឺសម្រាប់គោលបំណងកំណត់អត្តសញ្ញាណតែប៉ុណ្ណោះ ហើយមិនបង្ហាញថាបុគ្គលនោះកំពុងចុះហត្ថលេខាក្នុងនាមអង្គការនោះទេ ។

ការបដិសេធទៅនឹងសេចក្តីអះអាងដែលបានប្រឆាំងនឹងវិសោធនកម្មធម្មនុញ្ញ LA

ក្រុមអ្នកប្រឆាំងនិយាយត្រូវលើរឿងមួយ៖ ទីក្រុង Los Angeles បានពឹងផ្អែកលើប្រព័ន្ធបែកបាក់ដដែលៗក្នុងការត្រួតពិនិត្យហេដ្ឋារចនាសម្ព័ន្ធរបស់ខ្លួនអស់ជាច្រើនជំនាន់មកហើយ។ ការទទួលខុសត្រូវត្រូវបានបែងចែកទៅកាន់មន្ត្រី គណៈកម្មការ ភ្នាក់ងារ និងការិយាល័យជាច្រើន។ ប្រជាជន Angelenos បានឃើញលទ្ធផលទាំងនេះតាមរយៈផ្លូវថ្នល់ដែលទ្រុឌធ្រោម ចិញ្ចើមផ្លូវប្រេះស្រាំ និងអំពូលភ្លើងផ្លូវដែលងងឹតសូន្យសុង។

វិធានការ LA ផ្ទាស់ប្តូររឿងទាំងនេះ។ វាទាមទារឱ្យមានកម្មវិធីហេដ្ឋារចនាសម្ព័ន្ធរយៈពេលវែងទូទាំងក្រុងចំនួនមួយ និងការរៀបចំថវិការយៈពេលពីឆ្នាំ ដើម្បីឱ្យ Los Angeles កំណត់អាទិភាពច្បាស់លាស់ ស្វែងរកគម្រោងដែលត្រូវបញ្ចប់ និងរៀបចំផែនការផ្តល់ថវិការលើគម្រោងទាំងនោះតាមពេលវេលា។

វាក៏ដាក់ឱ្យនាយកចំនួនមួយរូបទទួលខុសត្រូវលើការសម្របសម្រួលការងារសាធារណៈ និងអនុវត្តផែនការនោះ។ នាយកត្រូវរាយការណ៍ជូនអភិបាលក្រុង និងក្រុមប្រឹក្សាក្រុង ហើយនៅតែស្ថិតក្រោមការត្រួតពិនិត្យដោយអគ្គធិការហិរញ្ញវត្ថុក្រុងដែលជ្រើសរើសដោយការបោះឆ្នោតឯករាជ្យ។ ប្រជាជន Angelenos នឹងដឹងថា នរណាជាអ្នកទទួលខុសត្រូវលើការចាក់កៅស៊ូផ្លូវឡើងវិញ ការជួសជុលចិញ្ចើមផ្លូវ ការជួសជុលអំពូលភ្លើងផ្លូវ និងការបញ្ចប់គម្រោងនានា។

គណនេយ្យភាពមានន័យថា ផែនការច្បាស់លាស់ ការទទួលខុសត្រូវច្បាស់លាស់ និងការត្រួតពិនិត្យច្បាស់លាស់។

បុគ្គលដែលចុះហត្ថលេខាប្រឆាំងនឹងសេចក្តីអះអាងប្រឆាំងនឹងវិសោធនកម្មធម្មនុញ្ញ LA

KENNETH MEJIA
អ្នកគ្រប់គ្រង
City of Los Angeles

KATY YAROSLAVSKY
សមាជិកក្រុមប្រឹក្សាទីក្រុង LA
City of Los Angeles

BOB BLUMENFIELD
សមាជិកក្រុមប្រឹក្សាទីក្រុង LA និងជាប្រធានបណ្តោះអាសន្ន
City of Los Angeles

JESSICA MEANEY
នាយកប្រតិបត្តិ
Investing in Place

RON GALPERIN
អ្នកគ្រប់គ្រងទីក្រុង

DAVID LEVITUS
CEO
LA Forward

MICHAEL SCHNEIDER
CEO
Streets For All

សេចក្តីអះអាងដែលបានបោះពុម្ព គឺជាមតិរបស់អ្នកនិពន្ធ ហើយមិនត្រូវបានត្រួតពិនិត្យភាពត្រឹមត្រូវដោយទីភ្នាក់ងារក្រុងណាមួយឡើយ ។ លើសពីនេះ មុខតំណែងនៅក្រោមឈ្មោះអ្នកចុះហត្ថលេខា គឺសម្រាប់គោលបំណងកំណត់អត្តសញ្ញាណតែប៉ុណ្ណោះ ហើយមិនបង្ហាញថាបុគ្គលនោះកំពុងចុះហត្ថលេខាក្នុងនាមអង្គការនោះទេ ។

បទប្បញ្ញត្តិថ្មី ឬភាសាដែលបានបន្ថែមទៅមាត្រាធម្មនុញ្ញ ឬមាត្រាធម្មនុញ្ញដែលមានស្រាប់ត្រូវបានបង្ហាញជាប្រភេទ គូសបន្ទាត់ពីក្រោម ។ ពាក្យដែលបានលុបចេញពីធម្មនុញ្ញ ឬពីមាត្រាធម្មនុញ្ញ ដែលមានស្រាប់ត្រូវបានបង្ហាញជាប្រភេទការ គូសចេញ ។

វិសោធនកម្មធម្មនុញ្ញ LA
(ហេដ្ឋារចនាសម្ព័ន្ធទីក្រុង ថវិកា ហិរញ្ញវត្ថុ និងការចុះកិច្ចសន្យា)

អត្ថបទនៃវិធានការសន្លឹកឆ្នោតដែលបានស្នើឡើង

មាត្រា 1. ផ្នែករង (a) នៃមាត្រា 104 នៃធម្មនុញ្ញរបស់ទីក្រុង Los Angeles ត្រូវបាននិរាករណ៍ដូចតទៅ ៖

(a) [ត្រូវបានលុបចោល ។] ~~**ការដាក់បញ្ចាំទ្រព្យសម្បត្តិ** ។ ទីក្រុងមិនមានអំណាចក្នុងការដាក់បញ្ចាំទ្រព្យសម្បត្តិរបស់ខ្លួន សម្រាប់គោលបំណងណាមួយឡើយ ប៉ុន្តែអាចទិញទ្រព្យសម្បត្តិដែលស្ថិតក្រោមការដាក់បញ្ចាំបាន ។~~

មាត្រា 2. ផ្នែករង (g) នៃមាត្រា 104 នៃធម្មនុញ្ញនៃទីក្រុង Los Angeles ត្រូវបាននិរាករណ៍ដូចតទៅ ៖

(g) [ត្រូវបានលុបចោល ។] ~~**សហគ្រាសពាណិជ្ជកម្ម** ។ ទីក្រុងនឹងមិនចូលរួមក្នុងសហគ្រាសពាណិជ្ជកម្ម ឬឧស្សាហកម្ម ទាំងស្រុងណាមួយនោះឡើយ លើកលែងតែនៅលើការបោះឆ្នោតភាគច្រើននៃអ្នកបោះឆ្នោតរបស់ទីក្រុងដែលបោះឆ្នោតលើ បញ្ហានេះ លុះត្រាតែសហគ្រាសត្រូវបានចូលរួមដោយទីក្រុងនៅពេលដែលធម្មនុញ្ញចូលជាធរមាន ឬលុះត្រាតែការចូលរួមក្នុង សហគ្រាសត្រូវបានអនុញ្ញាតជាពិសេសនៅកន្លែងផ្សេងទៀតនៅក្នុងធម្មនុញ្ញ ។ គ្មានអ្វីនៅក្នុងផ្នែករងនេះនឹងហាមឃាត់ទីក្រុងពី ការចូលរួមដោយផ្ទាល់នៅក្នុងការអនុញ្ញាតឱ្យដាក់លក់រាយចំពោះអាហារ និងទំនិញឡើយ នៅពេលដែលការអនុញ្ញាតទាំងនោះ គឺស្របតាម និងគាំទ្រដល់ប្រតិបត្តិការ និងគោលបំណងរបស់ទីក្រុង ។~~

មាត្រា 3. ផ្នែករង (g) នៃមាត្រា 231 នៃធម្មនុញ្ញនៃទីក្រុង Los Angeles ទាក់ទងនឹងថវិការបស់ទីក្រុង និងអំណាច និង ករណីយកិច្ចរបស់ចៅហ្វាយក្រុង ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖

(g) រៀបចំ និងដាក់ជូននូវថវិកាប្រចាំឆ្នាំដែលបានស្នើឡើងរបស់ចៅហ្វាយក្រុងទៅក្រុមប្រឹក្សាសម្រាប់ការពិចារណា អនុលោមតាមមាត្រា III នៃធម្មនុញ្ញនេះ

មាត្រា 4. ផ្នែករង (b) នៃមាត្រា 291 នៃធម្មនុញ្ញនៃទីក្រុង Los Angeles ទាក់ទងនឹងថវិការបស់ក្រុង និងអំណាច និង ករណីយកិច្ចរបស់ប្រធានមន្ត្រីរដ្ឋបាល ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖

(b) ជួយក្នុងការរៀបចំថវិកាប្រចាំឆ្នាំស្របតាមគោលនយោបាយដែលកំណត់ដោយចៅហ្វាយក្រុង

មាត្រា 5. មាត្រា 310 នៃធម្មនុញ្ញនៃទីក្រុង Los Angeles ទាក់ទងនឹងថវិការបស់ក្រុង ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖

មាត្រា 310. <u>វដ្តថវិកា</u> ឆ្នាំសារពើពន្ធ ។

<u>(a) ទីក្រុងត្រូវប្រតិបត្តិការលើវដ្តថវិកាប្រចាំពីរឆ្នាំ ដែលរួមមានឆ្នាំសារពើពន្ធជាប់គ្នាចំនួនពីរ លើកលែងតែវដ្តថវិកា ផ្សេងទៀតត្រូវបានបង្កើតឡើងដោយបទបញ្ញត្តិ ។</u>

<u>(b)</u> ឆ្នាំសារពើពន្ធ<u>នីមួយៗ</u> របស់ទីក្រុង <u>ទោះបីជាឆ្នាំសារពើពន្ធនោះស្ថិតនៅក្នុងវដ្តថវិកាក៏ដោយ</u> នឹងចាប់ផ្តើមនៅថ្ងៃទី 1 ខែកក្កដា នៃឆ្នាំនីមួយៗ ហើយត្រូវបញ្ចប់នៅថ្ងៃទី 30 ខែមិថុនា នៃឆ្នាំបន្ទាប់ ។

<u>(c) សម្រាប់ឆ្នាំសារពើពន្ធនីមួយៗនៃវដ្តថវិកាច្រើនឆ្នាំ ក្រុមប្រឹក្សា តាមដំណោះស្រាយ ត្រូវកំណត់ចំនួនទឹកប្រាក់ដែលបាន បែងចែកនៅក្នុងថវិកាសម្រាប់ឆ្នាំសារពើពន្ធនោះ នៅត្រឹម ឬមុនថ្ងៃទី 1 ខែមិថុនា នៃឆ្នាំសារពើពន្ធមុន ។ ដំណោះស្រាយនេះត្រូវ ស្ថិតក្រោមចុះហត្ថលេខាហាមឃាត់ដោយចៅហ្វាយក្រុង ហើយត្រូវលុបចោលការចុះហត្ថលេខាហាមឃាត់របស់ចៅហ្វាយក្រុង ដោយការបោះឆ្នោតពីរភាគបីរបស់ក្រុមប្រឹក្សា ។</u>

មាត្រា 6. មាត្រា 311 នៃធម្មនុញ្ញរបស់ទីក្រុង Los Angeles ទាក់ទងនឹងថវិការបស់ទីក្រុង ត្រូវបានធ្វើវិសោធនកម្ម ដូចតទៅ ៖

មាត្រា 311. ការប៉ាន់ប្រមាណថវិកាទៅកាន់ចៅហ្វាយក្រុង; សេចក្តីថ្លែងការណ៍អំពីអាទិភាពថវិកា ។

(a) នៅពេលដែលចៅហ្វាយក្រុងបានកំណត់ ប៉ុន្តែមិនឱ្យហួសពីថ្ងៃទី 1 ខែមករា មុនរដ្ឋថវិកានីមួយ ~~នៃឆ្នាំនីមួយៗ~~ គណៈកម្មការ ឬមន្ត្រីនីមួយៗដែលជាប្រធាននាយកដ្ឋាន ឬការិយាល័យណាមួយ ឬសកម្មភាពរដ្ឋាភិបាលទីក្រុងផ្សេងទៀត ក្រៅពីនាយកដ្ឋានទាំងឡាយណាដែលមានការគ្រប់គ្រងលើមូលនិធិផ្ទាល់ខ្លួន ត្រូវដាក់ជូនចៅហ្វាយក្រុង ដោយមានច្បាប់ចម្លងជូនក្រុមប្រឹក្សា និងមន្ត្រីរដ្ឋបាលក្រុង តាមទម្រង់ និងរបៀបដែលបានកំណត់ដោយចៅហ្វាយក្រុង នូវការប៉ាន់ស្មានលម្អិតនៃប្រាក់ដែលត្រូវការសម្រាប់~~ឆ្នាំសារពើពន្ធនៃ~~រដ្ឋថវិកា បន្ទាប់សម្រាប់ប្រតិបត្តិការដ៏ត្រឹមត្រូវនៃនាយកដ្ឋាន និងការិយាល័យរបស់ខ្លួន ។ ការប៉ាន់ស្មានទាំងនេះត្រូវមានចំណាត់ថ្នាក់ថវិកាស្តង់ដា ហើយត្រូវបញ្ជាក់យ៉ាងច្បាស់អំពីមុខងារដែលត្រូវបានអនុវត្ត ព្រមទាំងមុខទំនិញនិងសេវាកម្មដែលត្រូវការសម្រាប់ការអនុវត្តបែបនេះ ។ សេចក្តីសង្ខេប កាលវិភាគ និងទិន្នន័យគាំទ្រត្រូវភ្ជាប់មកជាមួយការប៉ាន់ស្មាន ។ ប្រធាននាយកដ្ឋាន ឬមន្ត្រីណាមួយដែលស្នើសុំការដំឡើងលើសពីការត្រៀមបម្រុងទុកសម្រាប់ឆ្នាំនៃ<u>រដ្ឋថវិការ</u>មុនត្រូវបញ្ជាក់ថាចំណាត់ថ្នាក់ណាដែលត្រូវការការដំឡើង និងរៀបចំណាត់ថ្នាក់តាមលំដាប់នៃតម្រូវការបន្ទាន់សម្រាប់ចំណាត់ថ្នាក់នីមួយៗ ។ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយមន្ត្រី ឬប្រធានក្រសួងមួយ ចៅហ្វាយក្រុងអាចបញ្ជូនការប៉ាន់ស្មានត្រឡប់មកវិញជាមួយនឹងការណែនាំដើម្បីរៀបចំការប៉ាន់ស្មានដែលបានកែសម្រួលដោយផ្អែកលើចំនួនទឹកប្រាក់អតិបរមាសម្រាប់ក្រសួង ការិយាល័យ ឬសកម្មភាព ដែលចំនួនទឹកប្រាក់អតិបរមាត្រូវកំណត់ដោយចៅហ្វាយក្រុង ឬដោយមានលក្ខណសម្បត្តិគ្រប់គ្រាន់បន្ថែមទៀតដែលចៅហ្វាយក្រុងត្រូវកំណត់ ។ មន្ត្រី ឬ ប្រធាននាយកដ្ឋានត្រូវបង្ហាញការប៉ាន់ស្មានដែលបានកែសម្រួលទៅកាន់ចៅហ្វាយក្រុង ដោយមានការចម្លងជូនទៅក្រុមប្រឹក្សា និងចម្លងទៅកាន់ នាយកការិយាល័យសេវារដ្ឋបាល និងស្រាវជ្រាវមន្ត្រីរដ្ឋបាលក្រុង តាមកាលបរិច្ឆេទដែលបានកំណត់ដោយចៅហ្វាយក្រុង ។

(b) នៅ ឬមុន នៃថ្ងៃទី 1 ខែកុម្ភៈ:<u>មុនរដ្ឋថវិកានីមួយៗ</u> ចៅហ្វាយក្រុងត្រូវផ្សព្វផ្សាយអាទិភាពថវិការបស់ខ្លួនសម្រាប់អាណត្តិ<u>រដ្ឋថវិកាឆ្នាំសារពើពន្ធ</u> បន្ទាប់ ដើម្បីសម្រួលដល់ការបញ្ចេញមតិជាសាធារណៈ ។

(c) នៅ ឬមុនថ្ងៃទី 1 ខែមីនា <u>មុនរដ្ឋថវិការនីមួយៗ</u>~~នៃឆ្នាំនីមួយៗ~~ អ្នកគ្រប់គ្រងត្រូវដាក់ជូនចៅហ្វាយក្រុង ដោយមានការចម្លងជូនក្រុមប្រឹក្សា និង~~ផ្ទ~~មន្ត្រីរដ្ឋបាលទីក្រុង នូវរបាយការណ៍លម្អិតអំពីប្រាក់ដែលអ្នកគ្រប់គ្រងប៉ាន់ស្មានថានឹងត្រូវការសម្រាប់ប្រាក់ការ និងមូលនិធិសម្រាប់បំណុល និងសម្រាប់បំណុលជាសញ្ញាប័ណ្ណកម្ចីដែលមិនទាន់សងទាំងអស់ និងកាតព្វកិច្ចស្របច្បាប់ផ្សេងទៀតរបស់ទីក្រុង ឬនៃមណ្ឌលពិសេស និងការប៉ាន់ស្មាននៃប្រាក់ចំណូលដែលនឹងទទួលបានពីការផាកពិន័យ អាជ្ញាប័ណ្ណ និងប្រភពផ្សេងទៀត ។

មាត្រា 7. មាត្រា 312 នៃធម្មនុញ្ញនៃទីក្រុង Los Angeles ទាក់ទងនឹងថវិការបស់ទីក្រុង ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖

មាត្រា 312. ថវិកាដែលបានស្នើឡើងដោយចៅហ្វាយក្រុង ។

នៅ ឬមុន <u>ថ្ងៃទី 1 ខែមេសា</u> ~~ថ្ងៃទី 20 ខែមេសា~~ <u>មុនរដ្ឋថវិកានីមួយៗ</u>~~នៃឆ្នាំនីមួយៗ~~ ចៅហ្វាយក្រុងត្រូវដាក់ជូនក្រុមប្រឹក្សានូវថវិកាសម្រាប់ <u>រដ្ឋថវិកានៃ</u>~~ឆ្នាំសារពើពន្ធ~~ពេលបន្ទាប់ដែលរៀបរាប់ដោយសង្ខេប និងលម្អិត ៖

(a) ការប៉ាន់ប្រមាណនៃការចំណាយ និងការបែងចែកថវិកាចាំបាច់សម្រាប់ការគាំទ្រដល់កម្មវិធីការងារដែលត្រូវការរបស់រដ្ឋាភិបាលទីក្រុងសម្រាប់ <u>រដ្ឋថវិកាឆ្នាំ</u>~~សារពើពន្ធ~~ជាបន្តបន្ទាប់ រួមទាំងការប្រាក់ និងមូលនិធិសម្រាប់បំណុល ឬការបង់ប្រាក់ដើមលើបំណុលដែលមានការប្រាក់ធានារបស់ទីក្រុង និងមណ្ឌលពិសេស

(b) ការប៉ាន់ប្រមាណលម្អិតនៃចំណូលរបស់ទីក្រុងក្នុងអំឡុងពេលបន្ទាប់ <u>រដ្ឋថវិកាឆ្នាំ</u>~~សារពើពន្ធ~~ ក្រោមច្បាប់ដែលមានជាធរមាននៅពេលដែលថវិកាត្រូវបានបញ្ជូន ហើយក៏ក្រោមការស្នើ ប្រសិនបើមាន ដែលមាននៅក្នុងថវិកាផងដែរ

(c) ការចំណាយ និងចំណូលរបស់រដ្ឋាភិបាលទីក្រុងក្នុងអំឡុងពេលដែលបានបញ្ចប់ចុងក្រោយ<u>រដ្ឋថវិកាឆ្នាំ</u>~~សារពើពន្ធ~~

(d) ការប៉ាន់ប្រមាណនៃការចំណាយ និងចំណូលរបស់រដ្ឋាភិបាលទីក្រុងក្នុងអំឡុងពេលរដ្ឋថវិកាឆ្នាំ~~សារពើពន្ធ~~ កំពុងដំណើរការ

(e) ចំនួនទឹកប្រាក់នៃការបែងចែកប្រចាំឆ្នាំ អចិន្ត្រៃយ៍ ឬផ្សេងទៀត រួមទាំងសមតុល្យនៃការបែងចែកសម្រាប់ រដ្ឋថវិកាឆ្នាំ~~សារពើពន្ធ~~ មុនៗដែលអាចប្រើប្រាស់បានសម្រាប់ការចំណាយក្នុងអំឡុងពេល រដ្ឋថវិកាឆ្នាំ~~សារពើពន្ធ~~ កំពុងដំណើរការ~~ គិតត្រឹមថ្ងៃទី 30 ខែមិថុនា នៃឆ្នាំនោះ~~

(f) សេចក្តីថ្លែងការណ៍ដែលមានតុល្យភាពនៃ ៖

(1) ស្ថានភាពនៃរតនាគារនៅចុងបញ្ចប់នៃការបញ្ចប់ចុងក្រោយនៃ រដ្ឋថវិកាឆ្នាំ~~សារពើពន្ធ~~

(2) ស្ថានភាពប៉ាន់ស្មានរបស់រតនាគារនៅចុងបញ្ចប់នៃ រដ្ឋថវិកាឆ្នាំ~~សារពើពន្ធ~~ កំពុងដំណើរការ និង

(3) ស្ថានភាពប៉ាន់ស្មានរបស់រតនាគារនៅចុងបញ្ចប់នៃ រដ្ឋថវិកាឆ្នាំ~~សារពើពន្ធ~~ បន្ទប់ក្នុងករណីដែលដាក់ស្នើហិរញ្ញវត្ថុដែលមាននៅក្នុងថវិកាត្រូវបានអនុម័ត ។

(g) ការពិតសំខាន់ៗទាំងអស់ទាក់ទងនឹងសញ្ញាប័ណ្ណកម្ចី មូលបត្របំណុល និងកាតព្វកិច្ចស្របច្បាប់ផ្សេងទៀតរបស់ទីក្រុង

(h) របាយការណ៍ហិរញ្ញវត្ថុ និងទិន្នន័យផ្សេងទៀតដែលចាំបាច់ ឬចង់បាន ដើម្បីបង្ហាញឱ្យឃើញលម្អិតអំពីស្ថានភាពហិរញ្ញវត្ថុរបស់រដ្ឋាភិបាលទីក្រុង ។

(i) សមតុល្យដែលមិនទាន់បានបែងចែក ដែលនឹងអាចរកបានសម្រាប់ការបម្រុងទុកនៅពេលក្រោយនៃរបាយការណ៍ រដ្ឋថវិកាឆ្នាំ~~សារពើពន្ធ~~ បន្ទាប់ដើម្បីប្រឈមនឹងកាលៈទេសៈដែលកើតឡើង និង

(j) សេចក្តីថ្លែងការណ៍អំពីធនធាននៃមូលនិធិបម្រុង ដែលត្រូវអនុវត្តទៅ រដ្ឋថវិកាឆ្នាំ~~សារពើពន្ធ~~ បន្ទាប់ដើម្បីបំពេញតម្រូវការសាច់ប្រាក់របស់ទីក្រុងសម្រាប់ផ្នែក រដ្ឋថវិកាឆ្នាំ~~សារពើពន្ធ~~ បន្តបន្ទាប់មុនពេលទទួលពន្ធ ឬសម្រាប់ការបែងចែកទៅក្នុងសមតុល្យដែលមិនទាន់បានបែងចែក ដូចដែលបានចែងក្នុងធម្មនុញ្ញ ។

មាត្រា 8. មាត្រា 313 នៃធម្មនុញ្ញរបស់ទីក្រុង Los Angeles ទាក់ទងនឹងថវិការបស់ទីក្រុង ត្រូវបានធ្វើវិសោធនកម្មដើម្បីអានដូចខាងក្រោម ៖

មាត្រា 313. ការពិចារណាលើថវិការបស់ក្រុមប្រឹក្សា ។

បន្ទាប់ពីទទួលបានថវិកាដែលដាក់ជូនដោយចៅហ្វាយក្រុង និងមុនពេលចាត់វិធានការលើថវិកា ក្រុមប្រឹក្សាត្រូវធ្វើសវនាការសាធារណៈមួយដែលបានជូនដំណឹង ។ នៅ ឬមុន ថ្ងៃទី 1 ខែមិថុនា មុនរដ្ឋថវិកានីមួយៗ ក្រុមប្រឹក្សាត្រូវ ៖

(a) អនុម័តថវិកាដូចដែលបានដាក់ជូនដោយចៅហ្វាយក្រុង ឬ

(b) កែប្រែថវិកាដោយមិនអនុម័តទាំងស្រុង ឬមួយផ្នែកលើចំណុចណាមួយ ឬដោយការបង្កើន ឬបន្ថយចំណុចណាមួយ ឬដោយការបន្ថែមចំណុចថ្មី ហើយប្រគល់ថវិកាវិញតាមការកែប្រែរបស់ក្រុមប្រឹក្សាទៅចៅហ្វាយក្រុង ។ រាល់ចំណាត់ការណាមួយដែលក្រុមប្រឹក្សាបានធ្វើឡើងក្រោមផ្នែកនេះ ត្រូវធ្វើឡើងដោយការបោះឆ្នោតភាគច្រើនពីសមាជិករបស់ខ្លួន ។

នៅពេលដែលក្រុមប្រឹក្សាមិនអាចប្រគល់ថវិកាទៅចៅហ្វាយក្រុងវិញបាន ដូចដែលមានចែងក្នុងផ្នែកនេះ ថវិកាដែលចៅហ្វាយក្រុងបានដាក់ជូនក្រុមប្រឹក្សា ត្រូវចុះហត្ថលេខាដោយស្មៀនសាលាក្រុង ហើយបន្ទាប់មកក្លាយជាថវិកាទូទៅរបស់ទីក្រុងសម្រាប់ រដ្ឋថវិកាបន្ទាប់ឆ្នាំ~~សារពើពន្ធ~~ ។

មាត្រា 9. ផ្នែក 315 នៃធម្មនុញ្ញរបស់ទីក្រុង Los Angeles ដែលទាក់ទងនឹងថវិការបស់ទីក្រុងត្រូវបានធ្វើវិសោធនកម្មដែលមានសេចក្តីដូចខាងក្រោម ៖

មាត្រា 315. ការពិចារណារបស់ក្រុមប្រឹក្សាលើសារវេតូរបស់ចៅហ្វាយក្រុង ថវិកាចុងក្រោយដែលបានអនុម័ត ។

នៅពេលក្រុមប្រឹក្សាទទួលបានសារវេតូថវិកាពីចៅហ្វាយក្រុង ក្រុមប្រឹក្សាមានរយៈពេលប្រាំថ្ងៃដោយមិនរាប់បញ្ចូល ថ្ងៃសៅរ៍ ថ្ងៃអាទិត្យ និងថ្ងៃឈប់សម្រាកស្របច្បាប់ ដើម្បីជម្នះចំណាត់ការរបស់ចៅហ្វាយក្រុង ដែលទាក់ទងនឹងចំណុចនានា ឬ ចំណុចណាមួយនៃថវិកានេះ ។ រាល់ចំណុចណាមួយ ឬចំណុចនានានៃថវិកាដែលត្រូវបានធ្វើវេតូ ឬផ្លាស់ប្តូរដោយចៅហ្វាយក្រុង ហើយមិនត្រូវអនុម័តវិញដោយសំឡេងពីរភាគបីពីសមាជិកក្រុមប្រឹក្សាទាំងអស់របស់ក្រុមប្រឹក្សា ទោះបីជាមានការជំទាស់ពី ចៅហ្វាយក្រុងក៏ដោយ ឬក៏មិនត្រូវផ្លាស់ប្តូរទៅជាចំនួនទឹកប្រាក់នៅចន្លោះចំនួនដែលបានអនុម័តដំបូងដោយក្រុមប្រឹក្សា និង ចំនួនទឹកប្រាក់ដែលបានផ្លាស់ប្តូរដោយចៅហ្វាយក្រុង នឹងនៅតែដដែលដូចដែលបានកែប្រែដោយចៅហ្វាយក្រុង ។

ក្នុងករណីដែលចៅហ្វាយក្រុងបានផ្លាស់ប្តូរការពិពណ៌នា ឬការកំណត់ណាមួយដែលអនុវត្តចំពោះចំណុចណាមួយ ក្រុមប្រឹក្សា ដែលនៅក្នុងចំណាត់ការរបស់ខ្លួនស្របតាមផ្នែកនេះ នឹងមិនមានអំណាចក្នុងការផ្លាស់ប្តូរការពិពណ៌នា ឬការកំណត់ នោះទេ ក្រៅពីការស្តារវាឡើងវិញទៅតាមស្ថានភាពដែលវាត្រូវបានអនុម័តដំបូងដោយក្រុមប្រឹក្សា ។

ពេលផុតកំណត់រយៈពេលប្រាំថ្ងៃរបស់ក្រុមប្រឹក្សា-ឬលឿនជាងនេះ ប្រសិនបើក្រុមប្រឹក្សាណែនាំដូច្នេះដោយការបោះឆ្នោត ភាគច្រើន ថវិកាដែលចៅហ្វាយក្រុងបានប្រគល់មកវិញ និងចំពោះវិសាលភាពដែលត្រូវបានកែប្រែបន្ទាប់ពីនោះដោយក្រុមប្រឹក្សា នឹងក្លាយជាថវិកាទូទៅរបស់ទីក្រុងសម្រាប់ <u>វដ្តថវិកា</u>~~ឆ្នាំសារពើពន្ធ~~បន្ទាប់ ហើយនឹងមិនត្រូវបានរក្សាទុកសម្រាប់ការពិចារណា ឡើងវិញទេ ប៉ុន្តែត្រូវបញ្ជូនភ្លាមៗទៅស្មៀនសាលាក្រុង ដែលចុះហត្ថលេខាដោយស្មៀនសាលាក្រុង និងដាក់នៅការិយាល័យ អ្នកគ្រប់គ្រង ។

មាត្រា 10. ផ្នែក 320 នៃធម្មនុញ្ញរបស់ទីក្រុង Los Angeles ដែលទាក់ទងនឹងថវិការបស់ទីក្រុងត្រូវបានធ្វើវិសោធនកម្ម ដែលមានសេចក្តីដូចខាងក្រោម ៖

មាត្រា 320. កម្មវិធីចំណាយ ។

ការិយាល័យ និងក្រសួងនីមួយៗដែលត្រូវបានផ្តល់សម្រាប់ថវិកាទូទៅរបស់ទីក្រុង ហើយក្រសួងបណ្ណាល័យ និងកន្លែង កម្សាន្ត និងឧទ្យានក្នុងវិសាលភាពដែលពួកគេត្រូវបានជួយដោយប្រាក់ចាត់ចែងពីមូលនិធិទូទៅ ត្រូវមានសិទ្ធិអំណាចក្នុងការ ចំណាយ តាមវិធីដែលផ្តល់ដោយលក្ខខណ្ឌផ្សេងទៀតនៃ ធម្មនុញ្ញ បទបញ្ញត្តិ និងច្បាប់ជាធរមានផ្សេងទៀត មូលនិធិដែលត្រូវ បានចាត់ចែងសម្រាប់ការគាំទ្ររបស់ខ្លួនក្នុងអំឡុង<u>វដ្តថវិកា</u>បន្ទាប់~~ឆ្នាំសារពើពន្ធ~~ ប៉ុន្តែបានតែស្របតាមកម្មវិធីអំពីការចំណាយ ដែលបានគ្រោងទុក ដែលនឹងត្រូវរៀបចំ ដាក់ពាក្យ និងកែប្រែម្តងម្កាលដូចដែលបានចែងដោយច្បាប់ប៉ុណ្ណោះ ។ គ្មានក្រសួង ការិយាល័យ ឬការិយាល័យរបស់រដ្ឋាភិបាលក្រុងណាមួយត្រូវធ្វើការចំណាយ ឬទទួលបន្ទុកបំណុលលើសពីចំនួនដែលត្រូវបាន ចាត់ចែងនោះទេ ។

មាត្រា 11. ផ្នែក 323 ថ្មីត្រូវបានបន្ថែមក្នុងធម្មនុញ្ញនៃទីក្រុង Los Angeles ដែលមានសេចក្តីដូចខាងក្រោម ៖

<u>**មាត្រា 323. ការបង្កើតផែនការហេដ្ឋារចនាសម្ព័ន្ធមូលធន ។**</u>

<u>ផែនការហេដ្ឋារចនាសម្ព័ន្ធមូលធនត្រូវបង្កើតឡើងដោយបទបញ្ញត្តិ ស្របតាមលក្ខខណ្ឌ តម្រូវនៃធម្មនុញ្ញ ។ បទបញ្ញត្តិ នេះត្រូវបង្កើតការគ្រប់គ្រងសម្រាប់ផែនការ ក៏ដូចជាវិសាលភាព រយៈពេល ដំណើរការធ្វើផែនការមូលធន លក្ខណៈវិនិច្ឆ័យ សម្រាប់ការដាក់បញ្ចូលគម្រោងទៅក្នុងផែនការ តម្រូវការនៃការរាយការណ៍ និងដំណើរការរៀបចំថវិកាសម្រាប់ផែនការ ។</u>

មាត្រា 12. ផ្នែក 341 នៃធម្មនុញ្ញរបស់ទីក្រុង Los Angeles ដែលទាក់ទងនឹងថវិការបស់ទីក្រុងត្រូវបានធ្វើវិសោធនកម្ម ដែលមានសេចក្តីដូចខាងក្រោម ៖

មាត្រា 341. ការផ្ទេរពីមូលនិធិបម្រុង ការបែងចែកពីសមតុល្យដែលមិនទាន់បានបែងចែក ។

ការផ្ទេរអាចត្រូវបានធ្វើឡើងពីមូលនិធិបម្រុងបន្ទាប់ពីការអនុម័តថវិកា ~~ប្រចាំឆ្នាំ~~ ដើម្បីបំពេញតាមធាតុណាមួយដែលបាន អនុម័តទាំងស្រុង ឬមួយផ្នែកនៃថវិកា ~~ប្រចាំឆ្នាំ~~ ឬអាចត្រូវបានធ្វើឡើងទៅមូលនិធិទូទៅ ឬសមតុល្យដែលមិនបានបម្រុងទុក ។

ការផ្ទេរទាំងនេះ និងការបែងចែកថវិកាណាមួយពីសមតុល្យដែលមិនទាន់បែងចែក អាចត្រូវបានធ្វើឡើងបន្ទាប់ពីការអនុម័តថវិកា ដូចខាងក្រោម ៖

(a) តាមអនុសាសន៍របស់ចៅហ្វាយក្រុង ដែលត្រូវបានអនុម័តដោយការបោះឆ្នោតភាគច្រើនរបស់ក្រុមប្រឹក្សា

(b) តាមការបោះឆ្នោតភាគច្រើនរបស់ក្រុមប្រឹក្សា អាស្រ័យលើការយល់ព្រមពីចៅហ្វាយក្រុង ឬការអនុម័តដោយក្រុមប្រឹក្សា លើសកម្រិតវេតូរបស់ចៅហ្វាយក្រុងដោយការបោះឆ្នោតពីរភាគបី ។

ប្រសិនបើដីកាណាមួយដែលធ្វើការផ្ទេរ ឬការចាត់ចែងមិនត្រូវបានប្រគល់ជូនស្មៀនក្រុងវិញដោយចៅហ្វាយក្រុង ដើម្បីដាក់ជូនក្រុមប្រឹក្សា ដោយមានសំណើជំទាស់ជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេលដប់ថ្ងៃ បន្ទាប់ពីការដាក់ជូននោះទេ វានឹងចូលជាធរមាន ហើយមានសុពលភាពដូចជាអភិបាលក្រុងបានអនុម័ត និងចុះហត្ថលេខាលើវា ។

មាត្រា 13. ផ្នែករង (a) និង (b) ផ្នែក 343 នៃធម្មនុញ្ញរបស់ទីក្រុង Los Angeles ដែលទាក់ទងនឹងថវិការបស់ទីក្រុងត្រូវបានធ្វើវិសោធនកម្ម ដែលមានសេចក្តីដូចខាងក្រោម ៖

(a) **ក្រសួងមិនគ្រប់គ្រងមូលនិធិរបស់ពួកគេផ្ទាល់ទេ** ។ ប្រធាននាយកដ្ឋានណាមួយដែលមិនមានការគ្រប់គ្រងមូលនិធិផ្ទាល់ទេ អាចដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរទៅកាន់ចៅហ្វាយក្រុង ដើម្បីផ្ទេរចំនួនទឹកប្រាក់ពីធាតុមួយដែលបានបែងចែកទៅធាតុមួយទៀតនៅក្នុងប្រាក់ឧបត្ថម្ភថវិការបស់នាយកដ្ឋាន ឬទៅធាតុថ្មីដែលបង្កើតឡើងបន្ទាប់ពីការអនុម័តច្បាប់ស្តីពីថវិកា ~~អ្នកចាំឆ្នាំ~~ ។ ដោយមានការយល់ព្រមពីចៅហ្វាយក្រុង អ្នកគ្របគ្រងនឹងធ្វើការផ្ទេរ ប៉ុន្តែការផ្ទេរចំនួនទឹកប្រាក់លើសពីសាមសិបប្រាំពាន់ដុល្លារ ($35,000) ឬចំនួនទឹកប្រាក់ផ្សេងទៀតដែលកំណត់ដោយបទបញ្ញត្តិមិនត្រូវធ្វើឡើងទេ លុះត្រាតែត្រូវបានអនុម័តដោយការបោះឆ្នោតភាគច្រើនរបស់ក្រុមប្រឹក្សា ។ បើទោះបីជាមានចែងខាងលើក៏ដោយ ចំពោះការផ្ទេរក្នុងថវិការបស់ក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សាត្រូវបានអនុញ្ញាតឱ្យអនុម័តការផ្ទេរ ។

(b) **នាយកដ្ឋានដែលគ្រប់គ្រងមូលនិធិរបស់ពួកគេផ្ទាល់** ។ អ្នកគ្រប់គ្រងទូទៅនៃនាយកដ្ឋានណាមួយដែលមានការគ្រប់គ្រងថវិកាផ្ទាល់ខ្លួន អាចដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរទៅកាន់ក្រុមប្រឹក្សាភិបាលដែលមានការគ្រប់គ្រង និងគ្រប់គ្រងលើនាយកដ្ឋាន ដើម្បីផ្ទេរចំនួនទឹកប្រាក់ពីធាតុថវិកាមួយទៅធាតុថវិកាមួយទៀតនៅក្នុងថវិកា ~~អ្នកចាំឆ្នាំ~~ របស់នាយកដ្ឋាន ឬចំពោះធាតុថ្មីដែលបង្កើតឡើងបន្ទាប់ពីការអនុម័តថវិកា ~~អ្នកចាំឆ្នាំ~~ ។ ដោយមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល អ្នកគ្រប់គ្រងនឹងធ្វើការផ្ទេរ ប៉ុន្តែការផ្ទេរចំនួនទឹកប្រាក់លើសពីសាមសិបប្រាំពាន់ដុល្លារ ($35,000) ឬចំនួនទឹកប្រាក់ផ្សេងទៀតដែលកំណត់ដោយបទបញ្ញត្តិមិនត្រូវធ្វើឡើងទេ លុះត្រាតែមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីចៅហ្វាយក្រុង ។

មាត្រា 14. ផ្នែករង (e) ផ្នែក 371 នៃធម្មនុញ្ញរបស់ទីក្រុង Los Angeles ដែលទាក់ទងនឹងកិច្ចសន្យាដែលមានការដេញថ្លៃការប្រកួតប្រជែង ដែលមានសេចក្តីដូចខាងក្រោម ៖

(e) **ការលើកលែង** ។ ការរឹតបន្តឹងនៃមាត្រានេះមិនត្រូវអនុវត្តចំពោះ ៖

(1) កិច្ចសន្យាដែលពាក់ព័ន្ធនឹងការពិចារណាណាដែលមានតម្លៃសមហេតុផលតិចជាងចំនួនទឹកប្រាក់ដែលបានបញ្ជាក់ដោយបទបញ្ញត្តិ ។

(2) កិច្ចសន្យា ដូចដែលបានកំណត់ដោយអាជ្ញាធរចុះកិច្ចសន្យា សម្រាប់ការអនុវត្តសេវាកម្មវិជ្ជាជីវៈ វិទ្យាសាស្ត្រ អ្នកជំនាញ បច្ចេកទេស ឬសេវាកម្មពិសេសផ្សេងទៀតដែលមានលក្ខណៈបណ្តោះអាសន្ន និងម្តងម្កាល ដែលអាជ្ញាធរចុះកិច្ចសន្យារកឃើញថា ការដេញថ្លៃប្រកួតប្រជែងមិនអាចអនុវត្តបាន ឬមិនអាចផ្តល់អត្ថប្រយោជន៍ ។

(3) កិច្ចសន្យាសម្រាប់ការផ្គត់ផ្គង់វត្ថុដែលគ្របដណ្តប់ដោយលិខិតប៉ាតង់ដែលផ្តល់ដោយរដ្ឋាភិបាលសហរដ្ឋអាមេរិក ។

(4) កិច្ចសន្យាសម្រាប់ជួលក្នុងនាមជាអ្នកជួល ឬទិញអចលនទ្រព្យ នៅពេលដែលត្រូវបានអនុម័តដោយសំឡេងភាគច្រើនរបស់ក្រុមប្រឹក្សា ។

(5) កិច្ចសន្យាសម្រាប់ការជួសជុល ការកែប្រែ ការងារ ឬការកែលម្អ ដែលបានប្រកាសជាលាយលក្ខណ៍អក្សរដោយមន្ត្រីចុះកិច្ចសន្យា ឬក្រុមប្រឹក្សាភិបាល ឬអ្នកតំណាងរបស់ខ្លួន ថាមានភាពចាំបាច់ជាបន្ទាន់សម្រាប់ការអភិរក្សជីវិត សុខភាព ឬទ្រព្យសម្បត្តិ ។ សេចក្តីប្រកាសនេះត្រូវផ្តល់មូលហេតុរបស់ភាពចាំបាច់បន្ទាន់ ហើយត្រូវតែទទួលបានការយល់ព្រមពីក្រុមប្រឹក្សា ឬអ្នកតំណាងរបស់ខ្លួន ។ ការអនុម័តអាចមានលក្ខខណ្ឌលើការអនុលោមតាមតម្រូវការមួយ ឬច្រើននៃផ្នែកនេះ ។

(6) កិច្ចសន្យាដែលបានធ្វើឡើងក្នុងអំឡុងពេលសង្គ្រាម ឬគ្រាអាសន្នជាតិ រដ្ឋ ឬមូលដ្ឋានដែលបានប្រកាសស្របតាមច្បាប់សហព័ន្ធ រដ្ឋ ឬមូលដ្ឋាន ដែលក្រុមប្រឹក្សា តាមរយៈសេចក្តីសម្រេចដែលអនុម័តដោយការបោះឆ្នោតពីរភាគបី និងត្រូវបានអនុម័តដោយចៅហ្វាយក្រុង ផ្អាកការរឹតបន្តឹងណាមួយ ឬទាំងអស់នៃមាត្រានេះ ឬការអនុវត្តរបស់ពួកគេចំពោះក្រុមប្រឹក្សាភិបាល មន្ត្រី ឬបុគ្គលិកជាក់លាក់ ។

(7) កិច្ចសន្យាសម្រាប់ការជួសជុលឧបករណ៍ ឬគ្រឿងបន្លាស់ <u>ឬសម្រាប់សេវាកម្ម ឬការថែទាំកម្មវិធី</u> ទទួលបានពីក្រុមហ៊ុនផលិតឧបករណ៍ <u>ឬកម្មវិធី</u> ឬភ្នាក់ងារផ្គាត់ផ្គង់មុខរបស់ក្រុមហ៊ុននោះ ។

(8) កិច្ចសន្យាសម្រាប់ការរៀបចំកិច្ចសហប្រតិបត្តិការជាមួយភ្នាក់ងាររដ្ឋាភិបាលផ្សេងទៀត សម្រាប់ការប្រើប្រាស់កិច្ចសន្យាទិញ និងកិច្ចសន្យាប្រើប្រាស់សេវាកម្មវិជ្ជាជីវៈ វិទ្យាសាស្ត្រ អ្នកជំនាញ ឬបច្ចេកទេសរបស់ភ្នាក់ងារទាំងនោះ និងកិច្ចព្រមព្រៀងអនុវត្តណាមួយ ទោះបីជាកិច្ចសន្យា និងកិច្ចព្រមព្រៀងអនុវត្តមិនត្រូវបានចុះតាមរយៈដំណើរការដេញថ្លៃប្រកួតប្រជែងក៏ដោយ ។

(9) កិច្ចព្រមព្រៀងសម្បទានថ្មីរយៈពេលវែងជាមួយពាណិជ្ជការដែលមានស្រាប់ គិតត្រឹមថ្ងៃអនុម័តធម្មនុញ្ញនៅលើផ្លូវ Olvera ដែលត្រូវបានចរចាដោយនាយកដ្ឋានរបស់សាលាក្រុងដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងវិមានប្រវត្តិសាស្ត្រ El Pueblo de Los Angeles ។

(10) អនុលោមតាមតម្រូវការនៃផ្នែក 1022 កិច្ចសន្យា (រួមទាំងប៉ុន្តែមិនកំណត់ចំពោះតែកិច្ចសន្យាទាំងនោះ ដូចដែលបានកំណត់ដោយអាជ្ញាធរចុះកិច្ចសន្យា សម្រាប់ការផ្តល់សេវាកម្មវិជ្ជាជីវៈ វិទ្យាសាស្ត្រ អ្នកជំនាញ បច្ចេកទេស ឬសេវាកម្មពិសេសផ្សេងទៀត) ដែលអាជ្ញាធរចុះកិច្ចសន្យារកឃើញថា ការប្រើប្រាស់ការដេញថ្លៃប្រកួតប្រជែងនឹងមិនគួរឱ្យចង់បាន មិនអាចអនុវត្តបាន ឬមិនអាចទៅរួច ឬកន្លែងដែលច្បាប់ទូទៅលើកលែងទោសឱ្យអនុលោមតាមតម្រូវការដេញថ្លៃប្រកួតប្រជែង ។

<u>(11) កិច្ចសន្យាជាមួយពាណិជ្ជការដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលស្ពង់ជាគុណវុធ្ឍិនឹងត្រូវបញ្ជាក់ដោយបទបញ្ញត្តិ សម្រាប់ការចរចា ការអភិវធ្ឍ ការផ្គត់ផ្គង់ ឬការផ្តល់សេវាកម្មហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ដែលរួមមានទ្រព្យសកម្ម ប្រព័ន្ធ និងបណ្តាញ ទាំងរូបវន្ត ឬនិម្មិត ដែលមានសារៈសំខាន់ខ្លាំងចំពោះទីក្រុង ដែលការអសមត្ថភាព ឬការបំផ្លាញរបស់ពួកគេនឹងមានឥទ្ធិពលអាក្រក់ដល់សន្តិសុខ សន្តិសុខសេដ្ឋកិច្ច សុខភាពសាធារណៈ ឬសុវត្ថិភាព ឬការរួមបញ្ចូលគ្នាណាមួយនៃពួកវា ។</u>

មាត្រា 15. អនុកថាខណ្ឌ (H) នៃអនុផ្នែក (12) ផ្នែករង (c) នៃផ្នែកទី 470 នៃធម្មនុញ្ញរបស់ទីក្រុង Los Angeles ទាក់ទងនឹងការកំណត់ និងការបង្ហាញព័ត៌មានអំពីវិភាគទានយុទ្ធនាការ ត្រូវបានធ្វើវិសោធនកម្មដើម្បីអានដូចខាងក្រោម ៖

(H) រាល់ការស្នើសុំកិច្ចសន្យាទាក់ទងនឹងកិច្ចសន្យាដែលស្ថិតនៅក្រោមបទឃ្លាត្តិនេះ ត្រូវរួមបញ្ចូលការជូនដំណឹងអំពីការហាមឃាត់នៃអនុផ្នែកនេះ ។ នៅពេលដាក់សំណើដេញថ្លៃ ឬសំណើសម្រាប់កិច្ចសន្យាដែលស្ថិតនៅក្រោមផ្នែកនេះ អ្នកដេញថ្លៃ ឬអ្នកស្នើសុំត្រូវតែបំពេញទម្រង់បែបបទដែលកំណត់អត្តសញ្ញាណឈ្មោះរបស់នាយក អ្នកម៉ៅការរងរបស់ខ្លួនយ៉ាងហោចណាស់ $100,000 នាយករបស់អ្នកម៉ៅការរងទាំងនោះ ហើយបញ្ជាក់ថាអ្នកដេញថ្លៃ ឬអ្នកស្នើសុំនឹងអនុវត្តតាម និងជូនដំណឹងដល់នាយក និងអ្នកម៉ៅការរងរបស់ខ្លួនអំពីការហាមឃាត់នៅក្នុងផ្នែករងនេះ និងផ្តល់ព័ត៌មានផ្សេងទៀតដែលកំណត់ថាចាំបាច់ ។ <u>តាមការសម្រេចចិត្តរបស់អាជ្ញាធរចុះកិច្ចសន្យា ចំណុចខ្វះខាតផ្នែកបច្ចេកទេស ឬរដ្ឋបាលណាមួយក្នុងការបំពេញទម្រង់បែបបទណាមួយដែលស្ថិតនៅក្រោមបទឃ្លាត្តិនេះអាចត្រូវបានលើកលែងថាជាបញ្ហាតូចតាច ឬមិនសំខាន់ ឬអាចជាកម្មវត្ថុនៃការ</u>

ជួសជុល ដូចដែលបានចែងបន្ថែមដោយបទបញ្ញត្តិ ។ កំហុស ឬការលុបចោលព័ត៌មានសំខាន់ៗដែលតម្រូវដោយគណៈកម្មការក្រមសីលធម៌មិនអាចលើកលែងបានទេ ប៉ុន្តែអាចនឹងត្រូវកែតម្រូវមុនពេលការវាយតម្លៃ ឬការដាក់ពិន្ទុលើការដេញថ្លៃ ឬសំណើ ដូចដែលបានចែងបន្ថែមដោយបញ្ញត្តិ ។

មាត្រា 16. ផ្នែក 507 នៃធម្មនុញ្ញរបស់ទីក្រុង Los Angeles ត្រូវបានធ្វើវិសោធនកម្មដើម្បីអានដូចខាងក្រោម ៖

មាត្រា 507. ប្រធានមន្ត្រីរដ្ឋបាលសាលាក្រុង ។

ក្រៅពីការិយាល័យដែលត្រូវបានជ្រើសតាំង នាយកដ្ឋាន និងការិយាល័យនីមួយៗដែលបង្កើតឡើងដោយធម្មនុញ្ញ ឬបង្កើតឡើងដោយបទបញ្ញត្តិ និងការិយាល័យសាធារណការនីមួយៗនៃរដ្ឋបាលកិច្ចសន្យា វិស្វកម្ម អនាម័យ ភ្លើងបំភ្លឺផ្លូវ និងសេវាកម្មផ្លូវ នឹងមានប្រធានមន្ត្រីរដ្ឋបាលម្នាក់ ។ នៅក្នុងនាយកដ្ឋាននានាដែលស្ថិតនៅក្រោមការត្រួតពិនិត្យ និងការគ្រប់គ្រងរបស់គណៈកម្មការស្នងការ ប្រធានផ្នែករដ្ឋបាលគ្រប់គ្រងកិច្ចការរបស់នាយកដ្ឋាន ។ នៅក្នុងនាយកដ្ឋាន និងការិយាល័យដែលមិនស្ថិតនៅក្រោមការត្រួតពិនិត្យ និងការគ្រប់គ្រងរបស់គណៈកម្មការស្នងការ ប្រធានផ្នែករដ្ឋបាលទទួលបន្ទុក និងត្រួតពិនិត្យការងារទាំងអស់របស់នាយកដ្ឋាន ឬការិយាល័យ ។ នៅកន្លែងផ្សេងទៀតនៅក្នុងធម្មនុញ្ញ និងនៅក្នុងក្រមរដ្ឋបាលនៃទីក្រុង Los Angeles ប្រធានផ្នែករដ្ឋបាលអាចមានមុខតំណែងផ្សេងៗគ្នា រួមទាំងអ្នកគ្រប់គ្រងទូទៅ និងនាយក ។

មាត្រា 17. ផ្នែករង (e) នៃផ្នែក 509 នៃធម្មនុញ្ញក្នុងទីក្រុង Los Angeles ទាក់ទងនឹងថវិការបស់ទីក្រុង និងអំណាចរបស់ប្រធានផ្នែករដ្ឋបាលនៃនាយកដ្ឋានត្រូវបានធ្វើវិសោធនកម្មដែលមានសេចក្តីដូចខាងក្រោម ៖

(e) សូមណែនាំដល់ក្រុមគណៈកម្មការនៃនាយកដ្ឋានមុនពេលចាប់ផ្តើម វដ្តថវិកា នីមួយៗឆ្នាំសារពើពន្ធប្រចាំឆ្នាំ ថវិការបស់នាយកដ្ឋានដែលប៉ាន់រងលើចំណូល និងចំណាយដែលបានរំពឹងទុករបស់នាយកដ្ឋាន ឬការិយាល័យ ដោយអនុលោមតាមទម្រង់បែបបទ និងកាលបរិច្ឆេទដែលមានចែងក្នុងមាត្រា III ទាក់ទងនឹងថវិកាទូទៅរបស់នាយកដ្ឋាន

មាត្រា 18. ផ្នែករង (e) នៃផ្នែក 510 នៃធម្មនុញ្ញក្នុងទីក្រុង Los Angeles ទាក់ទងនឹងថវិការបស់ទីក្រុង និងសិទ្ធិអំណាចរបស់ប្រធានផ្នែករដ្ឋបាលនៃនាយកដ្ឋានត្រូវបានធ្វើវិសោធនកម្មដែលមានសេចក្តីដូចខាងក្រោម ៖

(g) មុនពេលចាប់ផ្តើម វដ្តថវិកា នីមួយៗនៃឆ្នាំសារពើពន្ធ ដាក់ជូន ប្រចាំឆ្នាំ ថវិកាដែលប៉ាន់រងលើចំណូល និងចំណាយដែលរំពឹងទុករបស់នាយកដ្ឋាន រួមទាំងស្របតាមការណែនាំរបស់គណៈកម្មការស្នងការ ប្រសិនបើមាន ប្រាក់ដែលត្រូវការសម្រាប់ការប្រព្រឹត្តទៅនៃកិច្ចការរបស់គណៈកម្មការឱ្យបានត្រឹមត្រូវ

មាត្រា 19. ផ្នែករង (a) នៃផ្នែក 511 នៃធម្មនុញ្ញរបស់ទីក្រុង Los Angeles ដែលទាក់ទងនឹងថវិការបស់ទីក្រុង និងទំនួលខុសត្រូវរបស់គណៈកម្មការនៃក្រសួងត្រូវបានធ្វើវិសោធនកម្ម ដែលមានសេចក្តីដូចខាងក្រោម ៖

(b) មុនពេលចាប់ផ្តើម វដ្តថវិកានីមួយៗឆ្នាំសារពើពន្ធ អនុម័ត ប្រចាំឆ្នាំ ថវិការបស់នាយកដ្ឋាន និងធ្វើការចាត់ចែង ប្រចាំឆ្នាំ ថវិការបស់នាយកដ្ឋាន ដោយប៉ាន់រងលើចំណូល និងចំណាយដែលបានរំពឹងទុករបស់នាយកដ្ឋាន ។ ថវិការបស់នាយកដ្ឋានត្រូវអនុលោមតាមទម្រង់បែបបទ និងកាលបរិច្ឆេទដែលបានចែងក្នុងមាត្រា III សម្រាប់ថវិកាសាលាក្រុងទូទៅ ឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ។ ថវិការបស់នាយកដ្ឋាននីមួយៗត្រូវមានចំនួនទឹកប្រាក់មួយ ដែលគេស្គាល់ថាជាសមតុល្យមិនទាន់ចាត់ចែង ដែលចំនួនទឹកប្រាក់នោះនឹងអាចរកបានសម្រាប់ការចាត់ចែងដោយគណៈកម្មការនៅពេលក្រោយនៅក្នុង វដ្តថវិកាបន្ទាប់ឆ្នាំសារពើពន្ធ ដើម្បីឆ្លើយតបតម្រូវការជាយថាហេតុ នៅពេលវាកើតឡើង ។ ច្បាប់ចម្លងនៃថវិកានៅពេលដែលត្រូវបានអនុម័ត និងសេចក្តីសម្រេចនីមួយៗដែលត្រូវបានអនុម័តជាបន្តបន្ទាប់ក្នុងការចាត់ចែងពីសមតុល្យដែលមិនទាន់ចាត់ចែងនឹងត្រូវដាក់ជូនចៅហ្វាយក្រុង និងអ្នកគ្រប់គ្រងភ្លាមៗ ។ នាយកដ្ឋាននឹងមិនមានការចំណាយ ឬកាតព្វកិច្ចហិរញ្ញវត្ថុណាមួយត្រូវធ្វើឡើងឡើយ លើកលែងតែមានការអនុញ្ញាតពី ប្រចាំឆ្នាំ ការចាត់ចែងថវិការបស់នាយកដ្ឋាន ឬការចាត់ចែងដែលបានធ្វើឡើងបន្ទាប់ពីការអនុម័ត ប្រចាំឆ្នាំ ថវិកា ឬដូចដែលមានចែងផ្សេងពីនេះនៅក្នុងធម្មនុញ្ញ ។

មាត្រា 20. ផ្នែករង (d) នៃផ្នែកទី 572 នៃធម្មនុញ្ញរបស់ទីក្រុង Los Angeles ទាក់ទងនឹងសិទ្ធិអំណាច និងភារកិច្ចនាយកប្រតិបត្តិនៃគណៈកម្មការស្នងការ ត្រូវបានធ្វើវិសោធនកម្មដែលមានសេចក្តីដូចខាងក្រោម ៖

(d) សូមណែនាំដល់គណៈកម្មការស្នងការមុនពេលចាប់ផ្តើម វដ្តថវិកា ~~ឆ្នាំសារពើពន្ធ~~ថវិកាដែលវ៉ាប់រងលើចំណូល និងចំណាយដែលរំពឹងទុករបស់គណៈកម្មការ និងបុគ្គលិករបស់ខ្លួន ដោយអនុលោមតាមទម្រង់បែបបទ និងកាលបរិច្ឆេទដែលមានចែងក្នុងធម្មនុញ្ញទាក់ទងនឹងថវិកាទូទៅរបស់ក្រុង ឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន

មាត្រា 21. ផ្នែករង (e) នៃមាត្រាទី 574 នៃធម្មនុញ្ញរបស់ទីក្រុង Los Angeles ទាក់ទងនឹងសិទ្ធិអំណាច និងភារកិច្ចមេប៉ូលិស ត្រូវបានធ្វើវិសោធនកម្មដែលមានសេចក្តីដូចខាងក្រោម ៖

(e) សូមណែនាំដល់គណៈកម្មការស្នងការមុនពេលចាប់ផ្តើម វដ្តថវិកា នីមួយៗ~~ឆ្នាំសារពើពន្ធប្រចាំឆ្នាំ~~ ថវិការបស់នាយកដ្ឋានដែលវ៉ាប់រងលើចំណូល និងចំណាយដែលបានរំពឹងទុករបស់នាយកដ្ឋាន លើកលែងតែចំណូល និងចំណាយដែលបានរំពឹងទុកក្រោមការគ្រប់គ្រងរបស់នាយកប្រតិបត្តិ និងអនុលោមតាមទម្រង់បែបបទ និងកាលបរិច្ឆេទដែលបានចែងក្នុងធម្មនុញ្ញសម្រាប់ថវិកាទីក្រុងទូទៅឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន

មាត្រា 22. មាត្រា 581 នៃធម្មនុញ្ញរបស់ទីក្រុង Los Angeles ទាក់ទងនឹងគណៈកម្មការការងារសាធារណៈត្រូវបានធ្វើវិសោធនកម្មដែលមានសេចក្តីដូចខាងក្រោម ៖

មាត្រា 581. គណៈកម្មការការងារសាធារណៈ ។

សមាជិកគណៈកម្មការការងារសាធារណៈត្រូវលះបង់ពេលវេលាទាំងអស់របស់ខ្លួន ដើម្បីបំពេញភារកិច្ចក្នុងមុខតំណែងលុះត្រាតែមានចែងដោយបទបញ្ញត្តិផ្សេងពីនេះ ។ ទោះបីជាមានមាត្រា 514 ក៏ដោយ ក្រុមប្រឹក្សាក្រុងអាចធ្វើការផ្លាស់ប្តូរណាមួយចំពោះសមាសភាព ឬអត្ថិភាពនៃគណៈកម្មការការងារសាធារណៈ ក៏ដូចជាបន្ថែម ឬដកចេញនូវសិទ្ធិអំណាច និងភារកិច្ចណាមួយរបស់ខ្លួន ដោយបទបញ្ញត្តិដែលអនុម័តដោយសំឡេងពីរភាគបីរបស់ក្រុមប្រឹក្សា ដោយស្ថិតនៅក្រោមការវេតូរបស់ចៅហ្វាយក្រុង ឬដោយសំឡេងបីភាគបួនរបស់ក្រុមប្រឹក្សាលើការវេតូរបស់ចៅហ្វាយក្រុង ។ ដោយអនុលោមតាមធម្មនុញ្ញ និងបទបញ្ញត្តិ ព្រមទាំងច្បាប់ជាធរមាន គណៈកម្មការ នឹងមានសិទ្ធិអំណាច និងភារកិច្ចក្នុងការ៖

(a) កំណត់គោលនយោបាយសម្រាប់គ្រប់គ្រងក្រសួងការងារសាធារណៈ

(b) បង្កើតនីតិវិធីសម្រាប់ការពិនិត្យ ការពិចារណា និងការរៀបចំសំណើសុំសេចក្តីស្នើ ឬការដេញថ្លៃ និងសម្រាប់ការផ្សព្វផ្សាយ និងការកំណត់ចំនួនទឹកប្រាក់ពីសញ្ញាប័ណ្ណកម្ចីដែលត្រូវការ ទាំងអស់ដូចដែលមានចែងក្នុងមាត្រា 370 ដល់ 378 និងបទបញ្ញត្តិពាក់ព័ន្ធនានា សម្រាប់ការងារ ឬការកែលម្អណាមួយ

(c) អនុម័តការផ្តល់កិច្ចសន្យា

(d) កំណត់ពេលវេលាដែលការងារត្រូវចាប់ផ្តើម និងបញ្ចប់ស្របតាមច្បាប់ដែលធរមាន

~~(e) ប្រើប្រាស់សិទ្ធិអំណាចរបស់រដ្ឋាភិបាលក្នុងការទិញដីយកទៅប្រើប្រាស់ជាសាធារណៈ ដោយស្ថិតក្រោមការអនុញ្ញាតពីក្រុមប្រឹក្សា និងការផ្ទូល ឬទិញទ្រព្យសម្បត្តិជំនួសមុខឱ្យទីក្រុងសម្រាប់ការសាងសង់ និងការថែទាំគម្រោងការងារសាធារណៈ~~

(e)~~(f)~~ ប្រើប្រាស់សិទ្ធិអំណាច និងភារកិច្ចដែលតម្រូវដោយច្បាប់ ឬដែលបានផ្ទេរសិទ្ធិដោយក្រុមប្រឹក្សា ទាក់ទងនឹងការផ្តល់កិច្ចសន្យាសម្រាប់ការងារដែលបានបញ្ជាក់ក្នុងមាត្រា 580 និងការកំណត់ផលប្រយោជន៍ ការខូចខាត និងថ្លៃចំណាយដែលកើតឡើងពីការផ្លាស់ប្តូរ ឬការកែលម្អដែលបានស្នើឡើងសម្រាប់ទីកន្លែងសាធារណៈ សិទ្ធិលើដងផ្លូវ ឬទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់ទីក្រុង និងការបង្កើត និងការដាក់ពន្ធលើការវាយតម្លៃទ្រព្យសម្បត្តិដើម្បីធានាវ៉ាប់រងលើការខូចខាត និងថ្លៃចំណាយ

(f)~~(g)~~ ធ្វើការសវនាការ និងស្តាប់បណ្តឹងឧទ្ធរណ៍ដូចដែលបានអនុញ្ញាតដោយបទបញ្ញត្តិទាក់ទងនឹងការងាររបស់នាយកដ្ឋាន រួមទាំងសវនាការដែលទាក់ទងនឹងការវាយតម្លៃពិសេស

(g)~~(h)~~ តាមរយៈគំនិតផ្ទួចផ្តើមខ្លួនឯង ឬតាមរយៈពាក្យបណ្តឹង ធ្វើការស៊ើបអង្កេតលើប្រតិបត្តិការរបស់នាយកដ្ឋាន និងកិច្ចការរបស់និយោជិត ព្រមទាំងរាយការណ៍អំពីការរកឃើញទៅកាន់នាយកផ្នែកការងារសាធារណៈ ចៅហ្វាយក្រុង និងក្រុមប្រឹក្សា

(h)~~(i)~~ អនុម័តដោយមានការពិគ្រោះយោបល់ជាមួយនាយកការងារសាធារណៈ សេចក្តីបញ្ជាក់សម្រាប់គម្រោងសាងសង់ផ្នែកការងារសាធារណៈ

~~(j) ទទួលយកគម្រោងការងារសាធារណៈដែលបានបញ្ជូន ក្នុងលក្ខខណ្ឌថាគណៈកម្មការអាចផ្ទេរសិទ្ធិទៅឱ្យនាយកផ្នែកការងារសាធារណៈ ដើម្បីទទួលយកគម្រោងដែលពាក់ព័ន្ធនឹងទឹកប្រាក់តិចជាងមួយរយពាន់ដុល្លារ ($100,000) ឬចំនួនទឹកប្រាក់ផ្សេងទៀតដែលកំណត់ដោយគណៈកម្មការ~~

(i)~~(k)~~ សូមធ្វើការណែនាំអំពីផែនការ និងកម្មវិធីស្តីពីការងារសាធារណៈរយៈពេលវែង និងខ្លីដល់ នាយកផ្នែកការងារសាធារណៈ:ចៅហ្វាយក្រុង និងក្រុមប្រឹក្សា និង

(j)~~(l)~~ ជារៀងរាល់ឆ្នាំ ដែលត្រូវបង្ហាញជូនក្រុមប្រឹក្សានៅក្នុងកិច្ចប្រជុំរបស់ខ្លួននៅសប្តាហ៍ទីពីរនៃខែកក្កដា នូវរបាយការណ៍សម្រាប់ឆ្នាំសារពើពន្ធមុន ដែលបញ្ជាក់អំពីចំនួនទឹកប្រាក់ចំណូលពីការលក់សញ្ញាប័ណ្ណកម្ចី គោលបំណងដែលប្រាក់ចំណូលទាំងនោះត្រូវបានចំណាយ ចំនួនទឹកប្រាក់ដែលបានចំណាយ សមតុល្យនៅក្នុងមូលនិធិសញ្ញាប័ណ្ណកម្ចីនីមួយៗ និងព័ត៌មានព្រមទាំងការផ្តល់យោបល់ផ្សេងទៀតតាមការសមស្រប ។

គណៈកម្មការការងារសាធារណៈមានសិទ្ធិអំណាចក្នុងដំណើរការសាងសង់ និងការថែទាំទាំងអស់ ព្រមទាំងអនុវត្តគោលបំណងណាមួយដែលបានរៀបរាប់នៅទីនេះ ពីមូលនិធិណាមួយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន និងមានសម្រាប់គោលបំណងបែបនេះ ក្នុងលក្ខខណ្ឌថាគ្មានអ្វីនៅក្នុងមាត្រានេះនឹងត្រូវបានបកស្រាយថា ជាការបន្ថយសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាក្នុងការបញ្ជាឱ្យមានការងារ ឬការកែលម្អណាមួយ និងដើម្បីផ្តល់វិធីសាស្ត្រនៃការទូទាត់សម្រាប់ការងារទាំងនោះ ទោះជាយ៉ាងណាក៏ដោយ ការងារ ឬការកែលម្អបែបនេះត្រូវធ្វើក្រោមការត្រួតពិនិត្យ និងការគ្រប់គ្រងរបស់គណៈកម្មការការងារសាធារណៈ ។

មាត្រា 23. មាត្រា 582 នៃធម្មនុញ្ញរបស់ទីក្រុង Los Angeles ទាក់ទងនឹងនាយកផ្នែកការងារសាធារណៈ:ត្រូវបានធ្វើវិសោធនកម្មដែលមានសេចក្តីដូចខាងក្រោម ៖

មាត្រា 582. នាយកផ្នែកការងារសាធារណៈ

នឹងមានប្រធានផ្នែករដ្ឋបាលនៃនាយកដ្ឋានការងារសាធារណៈ ដែលគេស្គាល់ថា ជានាយកផ្នែកការងារសាធារណៈ ត្រូវបានតែងតាំង និងដកតំណែងវិញដូចមានចែងក្នុងមាត្រា 508 ។ ~~ជំនួសឱ្យ ការ~~បន្ថែមពីលើ សិទ្ធិអំណាច និងភារកិច្ចទាំងនោះ ដែលមានចែងក្នុងមាត្រា 509 នាយកត្រូវមានសិទ្ធិអំណាច និងភារកិច្ចក្នុងការ ៖

(a) អនុវត្តបទបញ្ជា ច្បាប់ និងបទប្បញ្ញត្តិទាំងអស់ដែលគណៈកម្មការបានអនុម័ត

(b) គ្រប់គ្រងកិច្ចសន្យា

(c) ត្រួតពិនិត្យ និងគ្រប់គ្រងការងារសាងសង់ និងការថែទាំ ដែលត្រូវបានអនុញ្ញាតដោយគណៈកម្មការ

(d) អនុម័តកិច្ចសន្យាការងារសាធារណៈទាំងនោះនៅក្នុងសិទ្ធិអំណាចដែលបានផ្ទេរទៅឱ្យនាយកដោយគណៈកម្មការ ឬដោយបទបញ្ញត្តិ

(e) ផ្តល់ការប្រើប្រាស់លើដងផ្លូវ និងលិខិតអនុញ្ញាតផ្សេងទៀតដែលចាំបាច់សម្រាប់ការប្រើប្រាស់ជាបណ្តោះអាសន្ននូវសិទ្ធិលើដងផ្លូវរបស់ទីក្រុង

(f) ប្រើប្រាស់សិទ្ធិរបស់រដ្ឋាភិបាលក្នុងការទិញដី យកទៅប្រើប្រាស់ជាសាធារណៈ ក្រោមការអនុញ្ញាតពីក្រុមប្រឹក្សា និងជួល ឬទិញទ្រព្យសម្បត្តិក្នុងនាមជាទីក្រុងសម្រាប់ការសាងសង់ និងការថែទាំគម្រោងការងារសាធារណៈ ។~~ធ្វើការណែនាំដល់គណៈកម្មការអំពីផែនការ និងកម្មវិធីការងារសាធារណៈរយៈពេលខ្លី និងរយៈពេលវែង~~

(g) ធ្វើការណែនាំដល់គណៈកម្មការ ចៅហ្វាយក្រុង និងក្រុមប្រឹក្សាអំពីផែនការ និងកម្មវិធីការងារសាធារណៈរយៈពេលខ្លី និងរយៈពេលវែង ដោយបញ្ចូលមតិកែលម្អពីគណៈកម្មតាមការគួរ

(h)(g) ត្រួតពិនិត្យមុខងារនៃគណនេយ្យរបស់នាយកដ្ឋាន និងសេវាកម្មគ្រប់គ្រងនិយោជិត រួមទាំងការិយាល័យណាមួយនៅក្នុងនាយកដ្ឋាន ទទួលបន្ទុកអនុវត្តមុខងារទាំងនោះ និង ចេញសេចក្ដីណែនាំទៅ តែងតាំង បញ្ឈប់ ផ្អាក និងផ្ទេរនិយោជិតដែលអនុវត្តមុខងារទាំងនោះ ដែលទាំងអស់នេះស្ថិតនៅក្រោមលក្ខខណ្ឌសេវាស៊ីវិលនៃធម្មនុញ្ញ

(i) គាំទ្រមុខងារនៃការធ្វើផែនការហេដ្ឋារចនាសម្ព័ន្ធមូលធនទូទាំងក្រុង រួមមានជាអាទិ៍ សិទ្ធិប្រើប្រាស់ផ្លូវសាធារណៈ ការដឹកជញ្ជូនតាមផ្លូវគោក អគារកម្មសិទ្ធិរបស់ក្រុង និងទីសាធារណៈឡើយ

(j) ត្រួតពិនិត្យការទិញផ្គត់ផ្គង់ និងការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាសម្រាប់នាយកដ្ឋាន និងការិយាល័យណាមួយ លើកលែងតែមានចែងផ្សេងពីនេះដោយបទបញ្ញត្តិ

(k) ទទួលយកគម្រោងការងារសាធារណៈដែលបានបញ្ចប់ និងផ្ដល់អនុសាសន៍អំពីថវិកាប្រតិបត្តិការ និងការថែទាំនៅពេលបញ្ចប់គម្រោង ដើម្បីធានាបាននូវស្ថានភាពជួសជុលត្រឹមត្រូវ

(l)(h) ផ្ដល់អនុសាសន៍ជូនចៅហ្វាយក្រុង និងគណៈកម្មការក្រុមប្រឹក្សាក្រុងមុនពេលចាប់ផ្ដើមនៃឆ្នាំសារពើពន្ធវដ្ដថវិកានីមួយៗនូវថវិកានាយកដ្ឋានប្រចាំឆ្នាំដែលប៉ាប់រងលើចំណូល និងចំណាយដែលបានរំពឹងទុករបស់នាយកដ្ឋាន ដោយអនុលោមតាមទម្រង់ និងកាលបរិច្ឆេទដែលមានចែងក្នុង មាត្រា III ទាក់ទងនឹងថវិកាទូទៅរបស់ទីក្រុងតាមដែលអាចធ្វើទៅបាន និង

(m)(i) ដាក់របាយការណ៍ជាលាយលក្ខណ៍អក្សរស្ដីពីការងាររបស់នាយកដ្ឋានជូនគណៈកម្មការ និងចៅហ្វាយក្រុង ជាទៀងទាត់តាមការស្នើសុំរបស់ចៅហ្វាយក្រុង ឬគណៈកម្មការនិង

(n) ត្រួតពិនិត្យការសាងសង់ និងការថែទាំ ហើយអនុវត្តគោលបំណងណាមួយដែលបានលើកឡើងនៅក្នុងនេះពីមូលនិធិណាមួយដែលស្ថិតក្រោមការគ្រប់គ្រងរបស់នាយក ហើយដែលមានសម្រាប់គោលបំណងទាំងនោះ ទោះជាយ៉ាងណាក៏ដោយ គ្មានអ្វីនៅក្នុងផ្នែកនេះត្រូវបកស្រាយថាជាការកាត់បន្ថយអំណាចរបស់ ក្រុមប្រឹក្សា ក្នុងការបញ្ជាឱ្យធ្វើការងារ ឬការកែលម្អណាមួយ និងផ្ដល់របៀបបង់ប្រាក់សម្រាប់កិច្ចការនោះឡើយ ប៉ុន្តែការងារ ឬការកែលម្អបែបនេះត្រូវធ្វើឡើងក្រោមការត្រួតពិនិត្យ និងការគ្រប់គ្រងរបស់នាយកការងារសាធារណៈដោយផ្អែកលើសេចក្ដីណែនាំរបស់គណៈកម្មការ ។

មាត្រា 24. មាត្រា 610 នៃធម្មនុញ្ញរបស់ទីក្រុង Los Angeles ទាក់ទងនឹងថវិការបស់ក្រុង និងក្រសួងកម្មសិទ្ធិ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖

មាត្រា 610. ផែនការគណនេយ្យភាពបំណុល និងការកែលម្អមូលធន ។

រៀងរាល់ពីរឆ្នាំម្ដងដោយភ្ជាប់ជាមួយការដាក់ស្នើថវិកាប្រចាំឆ្នាំរបស់ខ្លួនក្រសួងកម្មសិទ្ធិនីមួយៗត្រូវដាក់ជូនផែនការគណនេយ្យភាពបំណុល និងការកែលម្អមូលធនសំខាន់ៗ ជូនចំពោះចៅហ្វាយក្រុង ក្រុមប្រឹក្សាក្រុង_ និងអ្នកត្រួតពិនិត្យ ។

មាត្រា 25. ផ្នែករង (c) នៃមាត្រា 683 នៃធម្មនុញ្ញរបស់ទីក្រុង Los Angeles ទាក់ទងនឹងថវិការបស់ទីក្រុង និងនាយកប្រតិបត្តិនៃការិយាល័យគណនេយ្យភាពសាធារណៈ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖

(c) នាយកប្រតិបត្តិត្រូវ (1) រាយការណ៍ផ្ទាល់ទៅកាន់គណៈកម្មការ ប៉ុន្តែមិនត្រូវទទួលបានការណែនាំពីគណៈកម្មការឡើយ (2) មានការទទួលខុសត្រូវ និងការគ្រប់គ្រងពេញលេញលើការងារទាំងអស់របស់ OPA (ការិយាល័យគណនេយ្យភាពសាធារណៈ) (3) ទទួលខុសត្រូវចំពោះការគ្រប់គ្រងកិច្ចការងាររបស់ខ្លួនឱ្យបានត្រឹមត្រូវ (4) តែងតាំង បញ្ចប់តំណែង ព្យួរការងារ ឬផ្ទេរនិយោជិតទាំងអស់របស់ខ្លួន ស្ថិតក្រោមលក្ខខណ្ឌសេវាស៊ីវិលនៃធម្មនុញ្ញ (5) ចេញការណែនាំដល់និយោជិត OPA ក្នុងជួរភារកិច្ចរបស់ពួកគេ ស្ថិតក្រោមសេវាស៊ីវិលនៃធម្មនុញ្ញ (6) មុនពេលចាប់ផ្ដើមវដ្ដថវិការនីមួយនៃឆ្នាំសារពើពន្ធ និងស្របតាមកាលវិភាគដែលបានកំណត់ដោយបញ្ញត្តិ ត្រូវដាក់ជូន មន្ត្រីរដ្ឋបាលក្រុង នូវថវិកាប្រចាំឆ្នាំដែលបានស្នើឡើង ដែលប៉ាប់រងលើចំណាយដែលបានរំពឹងទុករបស់ OPA (7) ចំណាយមូលនិធិរបស់ OPA (រួមទាំង ប៉ុន្តែមិនកម្រិតត្រឹមតែ ការប្រគល់កិច្ចសន្យាឡើយ) ស្របតាមបទបញ្ញត្តិវិក័យប័ត្រថវិកា ឬវិក័យប័ត្រដែលបានធ្វើឡើងបន្ទាប់ពីការអនុម័តថវិកា និង (8) អនុវត្តភារកិច្ចផ្សេងទៀតដូចដែលអាចបានកំណត់ដោយបទបញ្ញត្តិ ។

មាត្រា 26. មាត្រា 684 នៃធម្មនុញ្ញរបស់ទីក្រុង Los Angeles ទាក់ទងនឹងថវិការបស់ទីក្រុង និងគណៈកម្មការស្នងការទឹក និងថាមពល ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖

មាត្រា 684. ការដាក់ជូនថវិកាទៅកាន់ ក្រុមប្រឹក្សាក្រុងសម្រាប់គោលបំណងជាព័ត៌មាន ។

គណៈកម្មការស្នងការទឹកនិងថាមពល ត្រូវដាក់ជូនថវិកាបឋមសម្រាប់រដ្ឋថវិកា~~នៃឆ្នាំសារពីពន្ធ~~ខាងមុខ ទៅកាន់ក្រុមប្រឹក្សាក្រុងសម្រាប់គោលបំណងជាព័ត៌មាន ឱ្យបានមុនត្រឹមថ្ងៃទី 31 ខែមីនា មុនរដ្ឋថវិកានីមួយៗ~~នៃឆ្នាំនីមួយ~~ ហើយត្រូវធ្វើបច្ចុប្បន្នភាពថវិកាបឋមនោះត្រឹមថ្ងៃទី 31 ខែឧសភា នៃឆ្នាំនោះ ដោយផ្អែកលើព័ត៌មានបន្ថែមដែលបានទទួលបន្ទាប់ពីថ្ងៃទី 31 ខែមីនា រួមទាំង ប៉ុន្តែមិនកម្រិតត្រឹមតែ ព័ត៌មានបន្ថែមអំពីការប៉ាន់ប្រមាណចំណូល និងចំណាយឡើយ ។ ~~មាត្រានេះត្រូវអនុវត្តចាប់ពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2011 ។~~

មាត្រា 27. ផ្នែករង (a) នៃមាត្រា 1001 នៃធម្មនុញ្ញរបស់ទីក្រុង Los Angeles ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖

មាត្រា 1001. ការលើកលែង ។

មុខតំណែងនីមួយៗខាងក្រោមត្រូវបានលើកលែងពីមាត្រានេះ ៖

(a) មុខតំណែងដែលមានការលើកលែង ។

(1) មន្ត្រីទាំងអស់ដែលត្រូវបានបោះឆ្នោតជ្រើសរើសដោយប្រជាពលរដ្ឋ ។

(2) សមាជិកទាំងអស់នៃគណៈកម្មការស្នងការ ។

(3) នាយករដ្ឋបាលនៃនាយកដ្ឋាន និងការិយាល័យរបស់ទីក្រុងទាំងអស់ និងនាយក<u>ណាមួយ</u>នៃការិយាល័យក្រសួង<u>ការងារ</u>សាធារណៈ ~~ដែលទទួលបន្ទុកកិច្ចសន្យារដ្ឋបាល វិស្វកម្ម អគារម័យ ភ្លើងបំភ្លឺផ្លូវ និងសេវាកម្មផ្លូវមួយ~~ ។

(4) តំណែងពីរក្នុងថ្នាក់ជំនួយការអគ្គនាយក ឬអនុប្រធាននៅក្នុងការិយាល័យ ឬនាយកដ្ឋានមួយៗរបស់ក្រុង និងតំណែងពីរក្នុងថ្នាក់ជំនួយការនាយកនៅក្នុងការ~~ិយាល័យរដ្ឋបាលកិច្ចសន្យា វិស្វកម្ម អគារម័យ ភ្លើងបំភ្លឺផ្លូវ និងសេវាកម្មផ្លូវមួយ~~នីមួយៗនៃ<u>ក្រសួង</u>-ការងារសាធារណៈ <u>ណាមួយ</u> -និងតំណែងពីរក្នុងថ្នាក់អនុប្រធានអ្នកគ្រប់គ្រងនៅក្នុងការិយាល័យអ្នកគ្រប់គ្រង ។

(5) អនុប្រធានប៉ូលិសទាំងអស់ ។

(6) អនុប្រធានពន្លត់អគ្គីភ័យទាំងអស់ ។

(7) តំណែងនានានៅក្នុងការិយាល័យចៅហ្វាយក្រុង ។

(8) តំណែងនានាដែលត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សា ក្នុងគោលបំណងជួយដល់សមាជិកក្រុមប្រឹក្សា ក្នុងការអនុវត្តការកិច្ចរបស់ពួកគេ លើកលែងតែបុគ្គលិករដ្ឋបាល ។

(9) តំណែងទាំងអស់នៅក្នុងការិយាល័យមេធាវីក្រុង ។

(10) ប្រធានផ្នែកហិរញ្ញវត្ថុនៃក្រសួងទឹកនិងថាមពល ។

(11) នាយកប្រតិបត្តិនៃគណៈកម្មការស្នងការប៉ូលិស ។

(12) អគ្គមន្ត្រីអធិការកិច្ចនៃក្រសួងប៉ូលិស ។

(13) នាយកប្រតិបត្តិ និងបុគ្គលិកទាំងអស់នៃគណៈកម្មការសីលធម៌ក្រុង ។

(14) ជំនួយការនាយកទាំងអស់នៅក្នុងការិយាល័យមន្ត្រីរដ្ឋបាលក្រុង ។

(15) អ្នកគ្រប់គ្រងចរាចរណ៍ និងអ្នកយាមកំពង់ផែនៃក្រសួងកំពង់ផែ ។

(16) ឆ្មាំឆ្លងថ្នល់ ។

(17) គ្រូពេទ្យ និងអ្នកចិត្តសាស្ត្រទាំងអស់ដែលស្ថិតក្រោមមាត្រា 1040 ។

(18) មន្ត្រីឈរឈ្មោះបោះឆ្នោតទាំងអស់ ។

(19) បុគ្គលដែលត្រូវបានជួលជាពិសេសដោយស្មៀនក្រុង ដូចដែលបានអនុញ្ញាតដោយលក្ខខណ្ឌនៃមាត្រា 405 នៃធម្មនុញ្ញ ដើម្បីជួយក្នុងការរៀបចំការបោះឆ្នោតណាមួយ ។

(20) តំណែងនានាដែលត្រូវបានលើកលែងជាពិសេសនៅកន្លែងផ្សេងទៀតដោយធម្មនុញ្ញ ។

មាត្រា 28. ផ្នែករង (a) នៃមាត្រា 1160 នៃធម្មនុញ្ញទីក្រុង Los Angeles អំពីថវិការបស់ទីក្រុង និងប្រព័ន្ធចូលនិវត្តន៍របស់និយោជិតទីក្រុង Los Angeles ត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោម ៖

(a) **ការបញ្ជូនថវិកា** ។ គណៈកម្មការត្រូវរៀបចំ និងបញ្ជូនថវិកា~~ប្រចាំឆ្នាំ~~<u>សម្រាប់រដ្ឋថវិកាខាងមុខ</u>ទៅកាន់ចៅហ្វាយក្រុង និងអ្នកគ្រប់គ្រង ដោយកំណត់នូវថ្លៃចំណាយប៉ាន់ប្រមាណនៃការថែរក្សាមូលនិធិចូលនិវត្តន៍ ។ ថវិកានេះត្រូវរួមបញ្ចូលនូវចំណុចដាច់ដោយឡែកពីគ្នាដូចខាងក្រោម ៖

(1) *វិភាគទានរបស់ទីក្រុង* ។ ចំនួនទឹកប្រាក់មួយស្មើនឹងភាគរយមួយនៃប្រាក់បៀវត្សរបស់សមាជិកទាំងអស់នៃប្រព័ន្ធសោធននិវត្តន៍ ដែលភាគរយនោះត្រូវស្មើនឹងភាគរយដែលបានបង្ហាញក្នុងរបាយការណ៍វាយតម្លៃតាមវិធីសាស្ត្រគណនាតាមគោលការណ៍ធានារ៉ាប់រងចុងក្រោយដែលបានរៀបចំ ដូចដែលបានចែងខាងលើថាជាភាគរយដែលតម្រូវសម្រាប់សមាជិកនៃនាយកដ្ឋានដែលមិនមានសេវាកម្មពីមុន ។

(2) *ការទូទាត់បំណុលដែលពុំមានប្រាក់ទ្រទ្រង់* ។ ចំនួនទឹកប្រាក់គ្រប់គ្រាន់ដើម្បីទូទាត់បំណុល ក្នុងរយៈពេលរហូតដល់ 30 ឆ្នាំ នូវបំណុលគ្មានមូលនិធិទ្រទ្រង់បង្កើនណាមួយដែលទទួលរ៉ាប់រងដោយប្រព័ន្ធ ។

(3) *ចំណាយរដ្ឋបាល* ។ តាមឆន្ទានុសិទ្ធិរបស់ក្រុមប្រឹក្សាក្រុង គឺចំណាយរដ្ឋបាលនៃប្រព័ន្ធ ។

មាត្រា 29. ផ្នែករង (a) នៃមាត្រា 1210 នៃធម្មនុញ្ញទីក្រុង Los Angeles អំពីថវិការបស់ទីក្រុង និងប្រព័ន្ធសោធននិវត្តន៍ប៉ូលិស និងពន្លត់អគ្គីភ័យទីក្រុង Los Angeles ត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោម ៖

(a) **ការអនុម័តថវិកា~~ប្រចាំឆ្នាំ~~** ។ គណៈកម្មការស្នងការសោធននិវត្តន៍ប៉ូលិស និងពន្លត់អគ្គីភ័យត្រូវអនុម័តថវិកាសម្រាប់<u>រដ្ឋថវិកា~~ឆ្នាំ~~</u>នីមួយៗដោយកំណត់ការចំណាយរដ្ឋបាលសម្រាប់កម្រិតនីមួយៗនៃផែនសោធននិវត្តន៍ប៉ូលិស និងពន្លត់អគ្គីភ័យ ។ ថវិកានេះត្រូវអនុម័តនៅក្នុងកិច្ចប្រជុំដែលបើកចំហជាសាធារណៈ ។ តាមឆន្ទានុសិទ្ធិរបស់ក្រុមប្រឹក្សា ចំណាយរដ្ឋបាល ដែលរួមបញ្ចូលទាំងចំណាយលើការគ្រប់គ្រងការវិនិយោគ អាចត្រូវបានទូទាត់ចេញពីទ្រព្យសកម្មនៃប្រព័ន្ធ ។

មាត្រា 30. កថាខណ្ឌទីមួយនៃផ្នែករង (b) នៃមាត្រា 1210 នៃធម្មនុញ្ញទីក្រុង Los Angeles អំពីថវិការបស់ទីក្រុង និងប្រព័ន្ធសោធននិវត្តន៍ប៉ូលិស និងពន្លត់អគ្គីភ័យទីក្រុង Los Angeles ត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោម ៖

(b) **ចំណុចដាច់ដោយឡែកពីគ្នានៃថវិកា** ។ គណៈកម្មការត្រូវរៀបចំ និងបញ្ជូនទៅចៅហ្វាយក្រុង ក្រុមប្រឹក្សា និងអ្នកគ្រប់គ្រង~~ជារៀងរាល់ឆ្នាំ~~នូវថវិកាសម្រាប់<u>រដ្ឋថវិកានាពេលខាងមុខ</u>ដោយកំណត់ពីការចំណាយប៉ាន់ស្មាននៃការរក្សាផែនការសោធននិវត្តន៍ប៉ូលិស និងពន្លត់អគ្គីភ័យ ។ ថវិកានេះត្រូវរួមបញ្ចូលនូវចំណុចដាច់ដោយឡែកពីគ្នានីមួយៗដូចខាងក្រោម ទោះបីជាចំណុចនោះជាចំនួនវិជ្ជមាន ឬចំនួនអវិជ្ជមានក៏ដោយ ៖

មាត្រា 31. ភាពអាចបំបែកបាន ។ ប្រសិនបើមាត្រា ផ្នែករង ខចែង ប្រយោគ ឃ្លា ឬការអនុវត្តនៃវិសោធនកម្មធម្មនុញ្ញនេះ ឬផ្នែកណាមួយនៃវិសោធនកម្មនេះ ត្រូវបានតុលាការ ឬសាលាជម្រះក្តីដែលមានយុត្តាធិការ និងដែនមានសមត្ថកិច្ចសម្រេចថា មិនស្របតាមរដ្ឋធម្មនុញ្ញ ឬមិនមានសុពលភាព នោះមាត្រា ផ្នែករង ខចែង ប្រយោគ ឃ្លា ផ្នែក ឬការអនុវត្តវិសោធនកម្មធម្មនុញ្ញដែលនៅសល់ត្រូវបន្តនៅមាន និងមានប្រសិទ្ធភាពពេញលេញ ហើយគិតដល់ចំណុចនេះ លក្ខខណ្ឌនៃវិសោធនកម្មធម្មនុញ្ញនេះគឺអាចបំបែកចេញពីគ្នាបាន ។ លើសពីនេះ អ្នកបោះឆ្នោតប្រកាសថាពួកគេនឹងអនុម័តរាល់មាត្រា ផ្នែករង ខចែង ប្រយោគ ឃ្លា ផ្នែក និងការអនុវត្តនៃវិសោធនកម្មធម្មនុញ្ញនេះ ដោយគ្មានមាត្រា ផ្នែករង ខចែង ប្រយោគ ឃ្លា ផ្នែក ឬការអនុវត្តដែលត្រូវបានសម្រេចថាមិនស្របតាមរដ្ឋធម្មនុញ្ញ ឬមិនមានសុពលភាពនោះឡើយ ។

PL នាយកដ្ឋានរៀបចំផែនការទីក្រុង។ វិសោធនកម្មធម្មនុញ្ញ PL។

តើធម្មនុញ្ញក្រុងគួរត្រូវបានធ្វើវិសោធនកម្មដើម្បី៖ បង្កើតគណៈកម្មការប្តឹងឧទ្ធរណ៍សង្កាត់ ដើម្បីជំនួសគណៈកម្មការរៀបចំផែនការតំបន់ និងបង្កើតដំណើរការសម្រាប់ការពិនិត្យមើលឡើងវិញរបស់ក្រុមប្រឹក្សាក្រុងលើសេចក្តីសម្រេចរបស់គណៈកម្មការប្តឹងឧទ្ធរណ៍សង្កាត់ និងគណៈកម្មការរៀបចំផែនការក្រុង ផ្លាស់ប្តូរពេលវេលា និងដំណើរការសម្រាប់សកម្មភាពរបស់ក្រុមប្រឹក្សាក្រុងលើសេចក្តីសម្រេចរៀបចំផែនការមួយចំនួន ផ្តល់អំណាចដល់នាយកដ្ឋានរៀបចំផែនការក្នុងការស៊ើបអង្កេត បើកសវនាការ និងសម្រេចលើពាក្យសុំសម្រាប់ការពិនិត្យមើលឡើងវិញដោយភ្នាក់ងារតំណាងតុលាការ និងអនុញ្ញាតឱ្យមានការផ្លាស់ប្តូរចំពោះបទឃ្លាញត្តិផ្ទៃក្រឡាជាន់អគារដោយបញ្ញត្តិដែរឬទេ?

សេចក្តីសង្ខេបតតលម្ងៀង
ដោយ SHARON M. TSO ប្រធានអ្នកវិភាគនិតិបញ្ញត្តិ

វិធានការនេះស្នើឱ្យមានការផ្លាស់ប្តូរចំពោះការរៀបចំផែនការ និងការគ្រប់គ្រងការប្រើប្រាស់ដីធ្លីរបស់ទីក្រុង។ វិធានការនេះនឹងបញ្ជាក់នៅក្នុងធម្មនុញ្ញក្រុង (ធម្មនុញ្ញ) អំពីអាជ្ញាធរ និងការកិច្ចរបស់នាយកដ្ឋានរៀបចំផែនការទីក្រុង និងនាយករៀបចំផែនការ ខណៈពេលដែលកំពុងកែប្រែអំណាចរបស់ក្រុមប្រឹក្សាក្រុងក្នុងការពិនិត្យឡើងវិញនូវបញ្ហាផែនការ និងការប្រើប្រាស់ដីធ្លី និងជំនួសគណៈកម្មការរៀបចំផែនការតំបន់ទាំងប្រាំពីរជាមួយនឹងគណៈកម្មការបណ្តឹងឧទ្ធរណ៍សង្កាត់ថ្មីតែមួយ។

សាលាក្រុងគ្រប់គ្រងការធ្វើផែនការ និងការប្រើប្រាស់ដីធ្លីតាមរយៈធម្មនុញ្ញ (រដ្ឋធម្មនុញ្ញក្រុង) និងបទបញ្ញត្តិ (ច្បាប់ក្រុង)។ ធម្មនុញ្ញនេះគឺជាឯកសារមូលដ្ឋានដែលកំណត់អំណាច និងកាតព្វកិច្ចរបស់អ្នកធ្វើការសម្រេចចិត្តសំខាន់ៗ ដែលរួមមាននាយកដ្ឋានរៀបចំផែនការទីក្រុង គណៈកម្មការរៀបចំផែនការទីក្រុង គណៈកម្មការរៀបចំផែនការតំបន់ នាយករៀបចំផែនការ ការិយាល័យរដ្ឋបាលតំបន់ ក្រុមប្រឹក្សាក្រុង និងចៅហ្វាយក្រុង។ ធម្មនុញ្ញនេះក៏បានកំណត់ដំណើរការ និងសិទ្ធិប្តឹងឧទ្ធរណ៍សម្រាប់ការទទួលបានសិទ្ធិប្រើប្រាស់ដីធ្លីមួយចំនួន រួមទាំងវិសោធនកម្មផែនការទូទៅ ការផ្លាស់ប្តូរតំបន់ ការលើកលែងលិខិតអនុញ្ញាតប្រើប្រាស់តាមលក្ខខណ្ឌ និងការអនុម័តស្នើរតែទាំងស្រុងដោយតុលាការស្រដៀងគ្នា។

វិធានការនេះនឹង៖

- ប្តូរគណៈកម្មការរៀបចំផែនការតំបន់ (APC) ទាំងប្រាំពីរ និងគណៈកម្មការចំនួន 35 រូបរបស់ពួកគេ ជាមួយនឹងគណៈកម្មការប្តឹងឧទ្ធរណ៍សង្កាត់ (NAC) ថ្មីតែមួយ ដែលមានសមាជិកយ៉ាងហោចណាស់ប្រាំពីរនាក់ ដោយអនុលោមតាមតម្រូវការគុណវុធ្ឍិទាក់ទងនឹងភូមិសាស្ត្រ ឬការកំណត់ផ្សេងទៀតដែលត្រូវកំណត់ដោយច្បាប់ និងផ្តល់អំណាចដល់ NAC ក្នុងការស្តាប់បណ្តឹងឧទ្ធរណ៍រដ្ឋបាល និងពិចារណាបណ្តឹងឧទ្ធរណ៍ទាំងនោះឡើងវិញ និងដោយមិនគោរពដល់អ្នកធ្វើការសម្រេចចិត្តពីមុនឡើយ។ ការធ្វើបែបនេះនឹងលុបបំបាត់ប្រព័ន្ធ APC ដែលមានតាំងពីធម្មនុញ្ញបច្ចុប្បន្នចូលជាធរមាននៅក្នុងខែកក្កដា ឆ្នាំ 2000 ហើយនឹងប្រគល់ក្រុងទៅឱ្យរចនាសម្ព័ន្ធត្រួតពិនិត្យ និងធ្វើការសម្រេចចិត្តដែលឆ្លុះបញ្ចាំងពីរចនាសម្ព័ន្ធដែលមានមុនឆ្នាំ 2000 ដែលមានស្ថាប័នតុលាការតែមួយដែលមានសមាជិកប្រាំនាក់ គឺក្រុមប្រឹក្សាភិបាលនៃបណ្តឹងឧទ្ធរណ៍តំបន់។
- បញ្ជាក់នៅក្នុងធម្មនុញ្ញអំពីការទទួលខុសត្រូវរបស់នាយកដ្ឋានរៀបចំផែនការទីក្រុង និងនាយករៀបចំផែនការ ដោយធ្វើវិសោធនកម្មផ្នែកធម្មនុញ្ញស្តីពីការិយាល័យរដ្ឋបាលតំបន់ ដើម្បីផ្តល់អំណាចដល់នាយកដ្ឋានលើពាក្យសុំពាក់កណ្តាលតុលាការ និងអំណាចរបស់នាយកផែនការក្នុងការតែងតាំងបុគ្គលិកក្រៅពីការិយាល័យរដ្ឋបាលតំបន់ ដើម្បីអនុវត្តការកិច្ចនៃការពិនិត្យពាក់កណ្តាលតុលាការ ដូចដែលត្រូវបានអនុញ្ញាតដោយច្បាប់។

- ដកផ្នែកធម្មនុញ្ញដែលបង្កើតដំណើរការ និងសិទ្ធិប្តឹងឧទ្ធរណ៍ចេញ ដើម្បីទទួលបានសិទ្ធិប្រើប្រាស់ដីធ្លីមួយចំនួន រួមទាំងវិសោធនកម្មផែនការទូទៅ ការផ្លាស់ប្តូរតំបន់ ការលើកលែង លិខិតអនុញ្ញាតប្រើប្រាស់តាមលក្ខខណ្ឌ និងការអនុម័តស្នើរតែទាំងស្រុងដោយតុលាការស្រដៀងគ្នា និងការផ្ទេរអំណាចនីតិបញ្ញត្តិ ដោយហេតុនេះអនុញ្ញាតឱ្យបញ្ហាបែបនេះត្រូវបានគ្រប់គ្រងដោយច្បាប់។
- ធ្វើការផ្លាស់ប្តូរដំណើរការដែលមានស្រាប់សម្រាប់ក្រុមប្រឹក្សាក្រុង ដើម្បីបញ្ជាក់ពីយុត្តាធិការក្នុងបញ្ហាផែនការ និងការប្រើប្រាស់ដីធ្លី។ វិធានការនេះនឹង៖ (1) បង្កើតរយៈពេលកំណត់ 30 ថ្ងៃសម្រាប់គណៈកម្មការរៀបចំផែនការទីក្រុង ឬគណៈកម្មការប្តឹងឧទ្ធរណ៍សង្កាត់ ដើម្បីយល់ព្រម ឬមិនយល់ព្រមពីក្រុមប្រឹក្សាក្រុងនៅពេលមានការឃុំខ្លួន បន្ទាប់ពីក្រុមប្រឹក្សាអះអាងពីយុត្តាធិការ (2) តម្រូវឱ្យសកម្មភាពរបស់គណៈកម្មការលើការឃុំខ្លួនត្រូវបានបញ្ជូនទៅក្រុមប្រឹក្សាក្រុងសម្រាប់ការបោះឆ្នោតចុងក្រោយ និង (3) តម្រូវឱ្យក្រុមប្រឹក្សាក្រុងធ្វើសកម្មភាពក្នុងរយៈពេល 21 ថ្ងៃ ឬសកម្មភាពរបស់គណៈកម្មការទៅជាការសម្រេចចុងក្រោយ។ សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាក្រុងក្នុងការបញ្ជាក់យុត្តាធិការក្នុងបរិបទផែនការ និងការប្រើប្រាស់ដីធ្លីគឺមានលក្ខណៈពិសេស ដោយក្រុមប្រឹក្សាមានសមត្ថភាពក្នុងការធ្វើសកម្មភាពជំនួសគណៈកម្មការមូលដ្ឋាននៅពេលបញ្ជាក់យុត្តាធិការ។
- វិសោធនកម្មផែនការទូទៅត្រូវបានអនុម័តដោយស្វ័យប្រវត្តិ ប្រសិនបើក្រុមប្រឹក្សាក្រុងមិនធ្វើសកម្មភាពក្នុងរយៈពេល 75 ថ្ងៃបន្ទាប់ពីការអនុម័តដោយចៅហ្វាយក្រុង និងគណៈកម្មការរៀបចំផែនការទីក្រុង។ វិធានការនេះនឹង៖ (1) ជំនួសច្បាប់ក្រុងបច្ចុប្បន្ន ដែលចែងអំពីការមិនយល់ព្រមដោយស្វ័យប្រវត្តិចំពោះវិសោធនកម្មផែនការទូទៅ ប្រសិនបើក្រុមប្រឹក្សាក្រុងមិនចាត់វិធានការលើបញ្ហានេះ និង (2) ធ្វើក្រមកំណត់ពេលវេលា 75 ថ្ងៃសម្រាប់ក្រុមប្រឹក្សាក្រុងដើម្បីធ្វើសកម្មភាព ដែលមានរួចហើយនៅក្នុងច្បាប់ក្រុងនៅក្នុងធម្មនុញ្ញ។
- អនុញ្ញាតឱ្យក្រុមប្រឹក្សាក្រុងផ្លាស់ប្តូរការកំណត់ដែនកំណត់ផ្ទៃកម្រាលដោយបញ្ញត្តិ។ បច្ចុប្បន្ន ធម្មនុញ្ញនេះកំណត់ដែនកំណត់ផ្ទៃក្រឡាអគារចំនួន 13 ដងនៃផ្ទៃក្រឡាដែលអាចសាងសង់បាននៃការដ្ឋាន។

វិធានការនេះនឹងមានប្រសិទ្ធភាព ប្រសិនបើត្រូវបានយល់ព្រមដោយអ្នកបោះឆ្នោតភាគច្រើន។

របាយការណ៍ផលប៉ះពាល់ហិរញ្ញវត្ថុ
ដោយ MATTHEW W. SZABO មន្ត្រីរដ្ឋបាលទីក្រុង

វិធានការនេះនឹងបង្កើតគណៈកម្មការប្តឹងឧទ្ធរណ៍សង្កាត់មួយ ដើម្បីជំនួសគណៈកម្មការផែនការតំបន់ទាំងប្រាំពីរ ដែលបង្កើតដំណើរការសម្រាប់ការពិនិត្យឡើងវិញរបស់ក្រុមប្រឹក្សាក្រុងលើការសម្រេចចិត្តរបស់គណៈកម្មការប្តឹងឧទ្ធរណ៍សង្កាត់ និងគណៈកម្មការរៀបចំផែនការទីក្រុង, ផ្លាស់ប្តូរពេលវេលា និងដំណើរការសម្រាប់សកម្មភាពរបស់ក្រុមប្រឹក្សាក្រុងលើការសម្រេចចិត្តធ្វើផែនការមួយចំនួន, ផ្តល់សិទ្ធិអំណាចដល់នាយកដ្ឋានរៀបចំផែនការក្នុងការស៊ើបអង្កេតស្តាប់ និងកំណត់ពាក្យសុំសម្រាប់ការពិនិត្យឡើងវិញស្នើរតែទាំងស្រុងតាមប្រព័ន្ធតុលាការ និងអនុញ្ញាតឱ្យក្រុមប្រឹក្សាក្រុងធ្វើការផ្លាស់ប្តូរបទប្បញ្ញត្តិផ្ទៃជាន់ដោយច្បាប់។ វិធានការនេះមិនត្រូវបានគេរំពឹងថានឹងប៉ះពាល់ដល់ប្រាក់ចំណូលទេ។ ការចំណាយរដ្ឋបាលប្រចាំឆ្នាំសម្រាប់បុគ្គលិក និងធនធានរបស់គណៈកម្មការត្រូវបានប៉ាន់ប្រមាណថានឹងត្រូវបានកាត់បន្ថយចំនួន $360,000 ដុល្លារពី $1.1 លានដុល្លារមកត្រឹម $740,000 ដុល្លារ។ ការកាត់បន្ថយថ្លៃដើមនឹងប៉ះពាល់ជាវិជ្ជមានដល់មូលនិធិពិសេសសម្រាប់ដំណើរការសំណុំរឿងផែនការ ដែលត្រូវបានឧបត្ថម្ភធនដោយមូលនិធិទូទៅ។

សេចក្តីអះអាងគាំទ្រលើវិសោធនកម្មធម្មនុញ្ញ PL

ទីក្រុង Los Angeles បានជួបប្រទះនូវផលវិបាកនៃប្រព័ន្ធរៀបចំផែនការមួយ ដែលការសម្រេចចិត្តនីមួយៗស្តីពីការប្រើប្រាស់ដីធ្លីអាចជាប់ពាក់ព័ន្ធនឹងនយោបាយ ។ នៅពេលដែលបទបញ្ញត្តិមិនច្បាស់លាស់ ឬសេចក្តីសម្រេច ពឹងផ្អែកខ្លាំងពេកទៅលើឆន្ទានុសិទ្ធិនយោបាយ វាបង្កើតឱកាសសម្រាប់អត្ថប្រយោជន៍ពិសេសដើម្បីស្វែងរកការប្រព្រឹត្តប្រកបដោយការអនុគ្រោះ និងធ្វើឱ្យបាត់បង់ទំនុកចិត្តសាធារណៈចំពោះសាលាក្រុង ។

វិធានការ PL គឺជាជំហានដ៏សំខាន់មួយឆ្ពោះទៅរកការផ្លាស់ប្តូរនោះ ។

វិធានការ PL ធ្វើទំនើបកម្មប្រព័ន្ធរៀបចំផែនការរបស់ Los Angeles ដោយបង្កើតវិធានកាន់តែច្បាស់លាស់ នីតិវិធីកាន់តែមានភាពស៊ីសង្វាក់គ្នា និងការទទួលខុសត្រូវកាន់តែច្បាស់លាស់ចំពោះរបៀបដែលសេចក្តីសម្រេចលើការរៀបចំផែនការត្រូវបានធ្វើឡើង ។

វិធានការនេះជំនួសគណៈកម្មការរៀបចំផែនការតំបន់ដែលមានស្រាប់ ជាមួយនឹងគណៈកម្មការបណ្តឹងឧទ្ធរណ៍សង្កាត់ ដោយបង្កើតដំណើរការទូទាំងទីក្រុងដែលមានភាពស៊ីសង្វាក់គ្នាជាងមុន សម្រាប់ការស្តាប់បណ្តឹងឧទ្ធរណ៍លើការរៀបចំផែនការ ។ វាក៏បង្កើតនីតិវិធីកាន់តែច្បាស់លាស់សម្រាប់ពេលដែលក្រុមប្រឹក្សាក្រុងអាចពិនិត្យឡើងវិញនូវសេចក្តីសម្រេចរបស់គណៈកម្មការបណ្តឹងឧទ្ធរណ៍សង្កាត់ និងគណៈកម្មការរៀបចំផែនការក្រុង ហើយកែលម្អដំណើរការ និងពេលវេលាកំណត់សម្រាប់ចំណាត់ការរបស់ក្រុមប្រឹក្សាលើបញ្ហារៀបចំផែនការមួយចំនួន ។

វិធានការ PL ក៏ផ្តល់សិទ្ធិអំណាចដល់បុគ្គលិកជំនាញនៃក្រសួងផែនការ ដើម្បីស៊ើបអង្កេត ស្តាប់ និងសម្រេចលើពាក្យសុំដែលមានអំណាចជាតុលាការ ដែលសមស្រប ដែលជួយសម្រួលដល់ការសម្រេចចិត្តលើការរៀបចំផែនការជាប្រចាំ ព្រមទាំងរក្សាបាននូវមធ្យោបាយសម្រាប់ការពិនិត្យឡើងវិញ និងការត្រួតពិនិត្យពីសំណាក់សាធារណជន ។ វាក៏អនុញ្ញាតឱ្យដង់ស៊ីតេអគារត្រូវបានធ្វើបច្ចុប្បន្នភាពដោយបទបញ្ញត្តិ ដោយផ្តល់ឱ្យ Los Angeles នូវភាពបត់បែនកាន់តែខ្លាំងដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរតម្រូវការលំនៅដ្ឋាន ការអភិវឌ្ឍ និងសង្កាត់ ។

ការកែទម្រង់ទាំងនេះនឹងធ្វើឱ្យប្រព័ន្ធរៀបចំផែនការរបស់យើងកាន់តែងាយស្រួលយល់ និងងាយស្រួលប្រើប្រាស់សម្រាប់ប្រជាពលរដ្ឋគ្រប់រូប ។ អ្វីដែលសំខាន់ស្មើគ្នានោះ គឺដែនសមត្ថកិច្ចកាន់តែច្បាស់លាស់ និងនីតិវិធីដែលមានភាពស៊ីសង្វាក់គ្នានឹងធ្វើឱ្យកាន់តែពិបាកសម្រាប់នរណាម្នាក់ក្នុងការប្រើប្រាស់ប្រព័ន្ធក្នុងផ្លូវមិនត្រឹមត្រូវ ដើម្បីទទួលបានការអនុគ្រោះ ។

វិធានការ PL រក្សាការចូលរួម និងការត្រួតពិនិត្យពីសំណាក់សាធារណជន ខណៈពេលដែលបង្កើតប្រព័ន្ធរៀបចំផែនការមួយដែលមានតម្លាភាពជាងមុន អាចព្យាករណ៍បាន និងមានគណនេយ្យភាព ។

ប្រជាពលរដ្ឋទីក្រុង Los Angeles សមនឹងដឹងថា អ្នកណាជាអ្នកធ្វើការសម្រេចចិត្តលើការរៀបចំផែនការ តើសេចក្តីសម្រេចទាំងនោះត្រូវបានធ្វើឡើងដោយរបៀបណា និងថាតើមនុស្សគ្រប់គ្នាអនុវត្តតាមវិធានដូចគ្នាដែរឬទេ ។

សម្រួលការរៀបចំផែនការ ។ បង្កើនតម្លាភាព ។ ពង្រឹងគណនេយ្យភាព ។ ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ។

សូមបោះឆ្នោតគាំទ្រវិធានការ PL ។

បុគ្គលដែលចុះហត្ថលេខាលើសេចក្តីអះអាងគាំទ្រនៃវិសោធនកម្មច្បាប់ធម្មនុញ្ញ PL

RAYMOND MEZA
ប្រធាន
Charter Reform Commission

ROY SAMAAN
ប្រធាន
Engineers & Architects Association

គ្មានសេចក្តីអះអាងប្រឆាំងវិធានការនេះត្រូវបានដាក់ជូនទេ ។

សេចក្តីអះអាងដែលបានបោះពុម្ព គឺជាមតិរបស់អ្នកនិពន្ធ ហើយមិនត្រូវបានត្រួតពិនិត្យភាពត្រឹមត្រូវដោយទីភ្នាក់ងារក្រុងណាមួយឡើយ ។ លើសពីនេះ មុខតំណែងនៅក្រោមឈ្មោះអ្នកចុះហត្ថលេខា គឺសម្រាប់គោលបំណងកំណត់អត្តសញ្ញាណតែប៉ុណ្ណោះ ហើយមិនបង្ហាញថាបុគ្គលនោះកំពុងចុះហត្ថលេខាក្នុងនាមអង្គការនោះទេ ។

បទប្បញ្ញត្តិថ្មី ឬភាសាដែលបានបន្ថែមទៅមាត្រាធម្មនុញ្ញ ឬមាត្រាធម្មនុញ្ញដែលមានស្រាប់ត្រូវបានបង្ហាញជាប្រភេទគូសបន្ទាត់ពីក្រោម ។ ពាក្យដែលបានលុបចេញពីធម្មនុញ្ញ ឬពីមាត្រាធម្មនុញ្ញ ដែលមានស្រាប់ត្រូវបានបង្ហាញជាប្រភេទការគូសចេញ ។

វិសោធនកម្មធម្មនុញ្ញ PL
(នាយកដ្ឋានរៀបចំផែនការទីក្រុង)

អត្ថបទនៃវិធានការសន្លឹកឆ្នោតដែលបានស្នើឡើង

មាត្រា 1. ផ្នែករង (e) នៃមាត្រា 104 នៃធម្មនុញ្ញទីក្រុង Los Angeles ត្រូវបានធ្វើវិសោធនកម្មដើម្បីអានដូចខាងក្រោម ៖

(e) **ការដាក់កម្រិតផ្ទៃជាន់** ។ ផ្ទៃជាន់សរុបដែលមាននៅក្នុងអគារទាំងអស់នៅលើការដ្ឋានសំណង់ណាមួយមិនត្រូវលើសពី 13 ដងនៃតំបន់ដែលអាចសាងសង់បាននៃការដ្ឋាននោះទេ លើកលែងតែមានការចែងផ្សេងពីនេះដោយក្រុមប្រឹក្សា ។ ~~ព្រោះថាតំបន់ដែលអាចសាងសង់បានបែបនេះត្រូវបានកំណត់ដោយបទបញ្ញត្តិ ។~~ ក្រុមប្រឹក្សាអាចកំណត់ និងអនុវត្តលក្ខខណ្ឌនៃផ្នែករងនេះ ហើយអាច ~~ដាក់កម្រិតបន្ថែមទៀត និង~~ ធ្វើនិយតកម្មលើផ្ទៃជាន់សរុប តំបន់ដែលអាចសាងសង់បាន និង កម្ពស់ ឬទំហំនៃអគារ ឬរចនាសម្ព័ន្ធដោយបទបញ្ញត្តិ ។

មាត្រា 2. ផ្នែករង (e) ឬមាត្រា 245 នៃធម្មនុញ្ញនៃទីក្រុង Los Angeles ទាក់ទងនឹងការធ្វើវេតូរបស់ក្រុមប្រឹក្សាក្រុងលើសកម្មភាពរបស់គណៈកម្មការ ត្រូវបានធ្វើវិសោធនកម្មដើម្បីអានដូចខាងក្រោម ៖

(e) **ការលើកលែងសកម្មភាពរបស់គណៈកម្មការរៀបចំផែនការទីក្រុង និង គណៈកម្មការប្តឹងឧទ្ធរណ៍សង្កាត់ ~~គណៈកម្មការរៀបចំផែនការតំបន់~~ ។** ក្រុមប្រឹក្សាមិនត្រូវបានកំណត់ត្រឹមតែការធ្វើវេតូលើសកម្មភាពរបស់គណៈកម្មការរៀបចំផែនការទីក្រុង ឬគណៈកម្មការប្តឹងឧទ្ធរណ៍សង្កាត់ ~~គណៈកម្មការរៀបចំផែនការតំបន់~~នោះទេ ប៉ុន្តែ ដោយស្ថិតក្រោមលក្ខខណ្ឌកំណត់ពេល និងការកំហិតផ្សេងទៀតនៃមាត្រានេះ បន្ទាប់ពីការបោះឆ្នោតដើម្បីនាំយកបញ្ហានេះមកពិចារណា ក្រុមប្រឹក្សាត្រូវមានសិទ្ធិអំណាចដូចគ្នាក្នុងការចាត់វិធានការលើបញ្ហានេះ ដូចដែលដើមឡើយត្រូវបានគ្រប់គ្រងដោយគណៈកម្មការរៀបចំផែនការទីក្រុង ឬ គណៈកម្មការប្តឹងឧទ្ធរណ៍សង្កាត់ ~~គណៈកម្មការរៀបចំផែនការតំបន់~~ ។ ប្រសិនបើក្រុមប្រឹក្សាធ្វើវេតូ និងបញ្ជូនបញ្ហានេះត្រឡប់ទៅវិញ នោះគណៈកម្មការរៀបចំផែនការទីក្រុង ឬគណៈកម្មការប្តឹងឧទ្ធរណ៍សង្កាត់ត្រូវមានរយៈពេល 30 ថ្ងៃដើម្បីលើកយកបញ្ហានេះមកពិចារណាម្តងទៀត ហើយយល់ព្រម ឬជំទាស់ ។ សកម្មភាពរបស់គណៈកម្មការរៀបចំផែនការទីក្រុង ឬគណៈកម្មការប្តឹងឧទ្ធរណ៍សង្កាត់ លើការបញ្ជូនត្រឡប់ទៅវិញ ត្រូវដាក់ជូនក្រុមប្រឹក្សាដើម្បីពិចារណាលើការបោះឆ្នោតចុងក្រោយជាលើកទីពីរលើបញ្ហានេះដោយក្រុមប្រឹក្សា ។ នៅពេលមានការដាក់ជូននូវការបោះឆ្នោតចុងក្រោយជាលើកទីពីរ ក្រុមប្រឹក្សាត្រូវមានសិទ្ធិអំណាចដូចគ្នាក្នុងការចាត់វិធានការលើបញ្ហា ដូចដែលដើមឡើយត្រូវបានគ្រប់គ្រងដោយគណៈកម្មការរៀបចំផែនការទីក្រុង ឬគណៈកម្មការប្តឹងឧទ្ធរណ៍សង្កាត់ ហើយត្រូវតែចាត់វិធានការក្នុងរយៈពេល 21 ថ្ងៃតាមប្រតិទិនពីការដាក់ជូននោះ មិនដូច្នោះទេ សកម្មភាពរបស់គណៈកម្មការរៀបចំផែនការទីក្រុង ឬគណៈកម្មការប្តឹងឧទ្ធរណ៍សង្កាត់លើការបញ្ជូនត្រឡប់ទៅវិញ ក្លាយជាស្ថាពរ ។ ថ្ងៃតាមប្រតិទិនដែលក្រុមប្រឹក្សាឈប់សម្រាក ដែលកើតចេញពីកាលវិភាគឈប់សម្រាកដែលក្រុមប្រឹក្សាបានអនុម័ត ត្រូវដកចេញពី 21 ថ្ងៃតាមប្រតិទិនដែលក្រុមប្រឹក្សាមានពេលដើម្បីចាត់វិធានការ ។

មាត្រា 3. មាត្រា 552 នៃធម្មនុញ្ញរបស់ទីក្រុង Los Angeles ត្រូវបានធ្វើវិសោធនកម្មដើម្បីអានដូចខាងក្រោម ៖

មាត្រា 552. គណៈកម្មការប្តឹងឧទ្ធរណ៍សង្កាត់ ។ ~~គណៈកម្មការរៀបចំផែនការតំបន់ ។~~

ក្រុមប្រឹក្សាត្រូវអនុម័តបទបញ្ញត្តិបង្កើតគណៈកម្មការមួយដែលមានសមាជិកមិនតិចជាងប្រាំពីររូប ដែលពិចារណាលើការប្តឹងឧទ្ធរណ៍នៃសេចក្តីសម្រេចដែលមានអំណាចជាតុលាការដែលធ្វើឡើងដោយនាយកដ្ឋានផែនការទីក្រុង ។ សមាជិកត្រូវតែបានតែងតាំង និងដកចេញតាមរបៀបដូចគ្នាទៅនឹងសមាជិកនៃគណៈកម្មការរៀបចំផែនការទីក្រុង លើកលែងតែការតែងតាំងស្ទួនការដែលត្រូវស្ថិតក្រោមលក្ខខណ្ឌតម្រូវនៃគុណសម្បត្តិទាក់ទងនឹងភូមិសាស្ត្រ ឬការតំណាងផ្សេងទៀតដូចដែលបានកំណត់ដោយបទបញ្ញត្តិ ។ គណៈកម្មការប្តឹងឧទ្ធរណ៍សង្កាត់គឺជាទីភ្នាក់ងារដែលមានអំណាចជាតុលាការ ហើយត្រូវមាន និងប្រើប្រាស់អំណាចដើម្បី ៖

(a) ធ្វើសវនាការ និងសម្រេចការប្តឹងឧទ្ធរណ៍នៃសេចក្តីសម្រេចដែលមានអំណាចជាតុលាការសារជាថ្មី ដោយស្ថិតក្រោមនីតិវិធីដែលបានកំណត់ដោយបទបញ្ញត្តិ និង

(b) ធ្វើសវនាការ និងសម្រេចបញ្ហាផ្សេងទៀតដែលត្រូវបានចាត់មកដល់ខ្លួនដោយបទបញ្ញត្តិ ។

~~ក្រុមប្រឹក្សាត្រូវអនុម័តបទបញ្ញត្តិបង្កើតស្ថាប័នដាច់ដោយឡែកពីគ្នាមិនតិចជាងប្រាំ ដែលត្រូវបានគេស្គាល់ថាជាគណៈកម្មការរៀបចំផែនការតំបន់ ។ បទបញ្ញត្តិត្រូវបង្កើតព្រំប្រទល់នៃតំបន់ដែលត្រូវបប្រើដោយគណៈកម្មការរៀបចំផែនការតំបន់នីមួយៗ ដែលត្រូវគួសបញ្ជាក់ដើម្បីឱ្យតំបន់ទាំងអស់នៃសាលាក្រុងត្រូវបានបម្រើដោយគណៈកម្មការរៀបចំផែនការតំបន់ ។ គណៈកម្មការរៀបចំផែនការតំបន់នីមួយៗត្រូវមានសមាជិកប្រាំរូប ។ សមាជិកត្រូវបានតែងតាំង និងដកចេញក្នុងរបៀបដូចគ្នាទៅនឹងសមាជិកនៃគណៈកម្មការរៀបចំផែនការសាលាក្រុង លើកលែងតែការស្នាក់នៅក្នុងតំបន់ដែលបម្រើដោយគណៈកម្មការរៀបចំផែនការតំបន់ត្រូវជាគុណសម្បត្តិសម្រាប់ការតែងតាំង ។ លើកលែងតែករណីដែលមានចែងក្នុងផ្នែករង (d) គណៈកម្មការរៀបចំផែនការតំបន់គឺជាស្ថាប័នតំណាងតុលាការ ។~~

~~គណៈកម្មការរៀបចំផែនការតំបន់នីមួយៗ ទាក់ទងនឹងបញ្ហាទាក់ទងនឹងទ្រព្យសម្បត្តិដែលមានទីតាំងនៅក្នុងតំបន់ដែលបម្រើដោយគណៈកម្មការរៀបចំផែនការតំបន់ត្រូវមានអំណាច និងអនុវត្តអំណាចដើម្បី ៖~~

~~(a) បើកសវនាការ និងសម្រេចលើបណ្តឹងឧទ្ធរណ៍ ក្នុងករណីមានការអះអាងថាមានកំហុស ឬការរំលោភលើសិទ្ធិអំណាចនៅក្នុងបញ្ជា តប្រូវការ ការសម្រេចចិត្ត ការបកស្រាយ ឬការកំណត់ផ្សេងទៀតដែលធ្វើឡើងដោយអ្នកគ្រប់គ្រងតំបន់~~

~~(b) បើកសវនាការ និងធ្វើការសម្រេចចិត្តលើបញ្ហាណាមួយដែលជាធម្មតាស្ថិតនៅក្រោមយុត្តាធិការរបស់អ្នកគ្រប់គ្រងតំបន់ នៅពេលដែលបញ្ហានោះត្រូវបានផ្ទេរទៅឱ្យយុត្តាធិការរបស់គណៈកម្មការរៀបចំផែនការតំបន់ ដោយសារតែអ្នកគ្រប់គ្រងតំបន់មិនបានធ្វើសកម្មភាពក្នុងរយៈពេលកំណត់ដែលកំណត់ដោយបទបញ្ញត្តិ~~

~~(c) បើកសវនាការ និងសម្រេចលើពាក្យស្នើសុំ ឬការប្តឹងឧទ្ធរណ៍ទាក់ទងនឹងលិខិតអនុញ្ញាតប្រើប្រាស់តាមលក្ខខណ្ឌ និងការអនុម័តពាក់កណ្តាលតុលាការស្រដៀងគ្នាផ្សេងទៀត ស្របតាមនីតិវិធីដែលបានកំណត់ដោយបទបញ្ញត្តិ~~

~~(d) ផ្តល់អនុសាសន៍ទាក់ទងនឹងការផ្លាស់ប្តូរតំបន់ ឬបញ្ហាស្រដៀងគ្នាដែលបានបញ្ជូនបកគណៈកម្មការរៀបចំផែនការទីក្រុង ស្របតាមមាត្រា 562 និង~~

~~(e) បើកសវនាការ និងសម្រេចលើបញ្ហាផ្សេងទៀត ដែលត្រូវបានផ្ទេរទៅឱ្យខ្លួនតាមបទបញ្ញត្តិ ។~~

មាត្រា 4. ផ្នែករង (e) នៃមាត្រា 555 នៃធម្មនុញ្ញរបស់ទីក្រុង Los Angeles ស្តីពីនីតិវិធីសម្រាប់ការអនុម័តផែនការទូទៅរបស់ទីក្រុង ត្រូវបានធ្វើវិសោធនកម្មដើម្បីអានដូចខាងក្រោម ៖

(e) **សំឡេងឆ្នោតចាំបាច់សម្រាប់ការអនុម័ត ។** ប្រសិនបើទាំងគណៈកម្មការរៀបចំផែនការទីក្រុង និងចៅហ្វាយក្រុងផ្តល់អនុសាសន៍ឱ្យអនុម័តលើវិសោធនកម្មដែលបានស្នើឡើង ក្រុមប្រឹក្សាអាចអនុម័តវិសោធនកម្មនោះដោយការបោះឆ្នោតភាគច្រើន ។ ប្រសិនបើគណៈកម្មការរៀបចំផែនការទីក្រុង ឬចៅហ្វាយក្រុងផ្តល់អនុសាសន៍ថាមិនយល់ព្រមលើវិសោធនកម្មដែលបានស្នើឡើង ក្រុមប្រឹក្សាអាចអនុម័តវិសោធនកម្មនោះបានលុះត្រាតែមានការបោះឆ្នោតពីរភាគបីប៉ុណ្ណោះ ។ ប្រសិនបើទាំងគណៈកម្មការរៀបចំផែនការទីក្រុង និងចៅហ្វាយក្រុង ផ្តល់អនុសាសន៍ថាមិនយល់ព្រមលើវិសោធនកម្មដែលបានស្នើឡើង ក្រុមប្រឹក្សាអាចអនុម័តវិសោធនកម្មនោះបានលុះត្រាតែមានការបោះឆ្នោតបីភាគបួនប៉ុណ្ណោះ ។ ប្រសិនបើក្រុមប្រឹក្សាស្នើឱ្យមានការកែប្រែវិសោធនកម្ម អនុសាសន៍របស់គណៈកម្មការ និងចៅហ្វាយក្រុងលើការកែប្រែនឹងប៉ះពាល់តែការកែប្រែនោះប៉ុណ្ណោះ ។ ប្រសិនបើក្រុមប្រឹក្សាមិនបានអនុវត្តសេចក្តីសម្រេចក្នុងរយៈពេល 75 ថ្ងៃគិតចាប់ពីថ្ងៃដែលមានអនុសាសន៍របស់ចៅហ្វាយក្រុង ហើយវិសោធនកម្មផែនការទូទៅដែលបានស្នើឡើងបានទទួលអនុសាសន៍អនុម័តពីគណៈកម្មការរៀបចំផែនការទីក្រុង និងចៅហ្វាយក្រុង នោះវិសោធនកម្មនោះនឹងត្រូវបានចាត់ទុកថាត្រូវបានអនុម័ត ។

មាត្រា 5. មាត្រា 560 នៃធម្មនុញ្ញរបស់ទីក្រុង Los Angeles ត្រូវបានធ្វើវិសោធនកម្មដើម្បីអានដូចខាងក្រោម ៖

មាត្រា 560. ការបើកសវនាការ និងការស៊ើបអង្កេត ។

គណៈកម្មការរៀបចំផែនការទីក្រុង និងគណៈកម្មការប្តឹងឧទ្ធរណ៍សង្កាត់ ~~គណៈកម្មការរៀបចំផែនការតំបន់~~ អាចអនុញ្ញាតឱ្យនាយកផែនការ ឬអ្នកតំណាងរបស់នាយកនោះ បើកសវនាការក្នុងនាមគណៈកម្មការ ។ នាយករៀបចំផែនការត្រូវធ្វើការ

ស្បើបអង្កេតទាក់ទងនឹងបញ្ហាទាំងអស់ដែលមានចែងក្នុងមាត្រា 555 និងមាត្រា 558 ដូចដែលគណៈកម្មការរៀបចំផែនការទីក្រុងអាចណែនាំ ហើយត្រូវដាក់របាយការណ៍ទៅគណៈកម្មការរៀបចំផែនការទីក្រុង ។

មាត្រា 6. មាត្រា 561 នៃធម្មនុញ្ញរបស់ទីក្រុង Los Angeles ត្រូវបានធ្វើវិសោធនកម្មដើម្បីអានដូចខាងក្រោម ៖

មាត្រា 561. <u>ការពិនិត្យមើលឡើងវិញដោយភ្នាក់ងារតំណាងតុលាការ</u> ~~ការិយាល័យគ្រប់គ្រងតំបន់~~ ។

<u>នាយកដ្ឋានរៀបចំផែនការទីក្រុងត្រូវទទួលខុសត្រូវចំពោះការពិនិត្យ និងការអនុម័តដោយឯករាជ្យ ការអនុម័តដោយមានលក្ខខណ្ឌ ឬការបដិសេធពាក្យសុំដោយការពិនិត្យមើលឡើងវិញដោយភ្នាក់ងារតំណាងតុលាការ ។ ភារកិច្ចនៃការពិនិត្យមើលឡើងវិញដោយភ្នាក់ងារតំណាងតុលាការត្រូវអនុវត្តដោយបុគ្គលិករៀបចំផែនការទីក្រុងដែលត្រូវបានចាត់តាំង ដែលនឹងរួមបញ្ចូលប៉ុន្តែមិនកំណត់ចំពោះ ការិយាល័យគ្រប់គ្រងតំបន់ អនុប្រធានទីភ្នាក់ងារប្រឹក្សាយោបល់ និងមន្ត្រីសវនាការ តាមការអនុញ្ញាតដោយបទបញ្ញត្តិ ដែលពួកគេទាំងអស់ត្រូវតែងតាំងដោយនាយករៀបចំផែនការ អាស្រ័យលើលក្ខខណ្ឌសេវាស៊ីវិលនៃធម្មនុញ្ញ ។ ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិដែលអាចត្រូវបានកំណត់ដោយបទបញ្ញត្តិ នាយកដ្ឋានរៀបចំផែនការទីក្រុងត្រូវស្បើបអង្កេត បើកសវនាការ និងកំណត់ពាក្យសុំទាំងអស់សម្រាប់ការពិនិត្យឡើងវិញស្នើរតែទាំងស្រុងតាមប្រព័ន្ធតុលាការ ហើយត្រូវមានអំណាច និងកាតព្វកិច្ចផ្សេងទៀតទាក់ទងនឹងការកំណត់តំបន់ និងការប្រើប្រាស់ដីធ្លី ដូចដែលបានកំណត់ដោយបទបញ្ញត្តិ ។</u>

នឹងមានភ្នាក់ងារតំណាងតុលាការមួយ ដែលស្គាល់ថាជា ការិយាល័យគ្រប់គ្រងតំបន់ ។ ភារកិច្ចរបស់ការិយាល័យនេះ ត្រូវអនុវត្តដោយអ្នកគ្រប់គ្រងតំបន់ម្នាក់ឬច្រើននាក់ តាមការអនុញ្ញាតពីក្រុមប្រឹក្សា ដែលត្រូវតែងតាំងដោយនាយករៀបចំផែនការ ដោយអនុលោមតាមលក្ខខណ្ឌសេវាស៊ីវិលនៃធម្មនុញ្ញ ។ ប្រសិនបើមានការអនុញ្ញាតពីអ្នកគ្រប់គ្រងតំបន់ច្រើននាក់ តំណែងជាប្រធានអ្នកគ្រប់គ្រងតំបន់នឹងត្រូវបង្កើតឡើង ដែលការតែងតាំងនឹងត្រូវធ្វើឡើងដោយនាយករៀបចំផែនការ ហើយអ្នកផ្សេងទៀតជាអ្នកគ្រប់គ្រងតំបន់រង ។ ស្ថិតក្រោមវិធាន និងបទបញ្ជាដែលអាចកំណត់ដោយបទបញ្ញត្តិ ការិយាល័យអភិបាលកិច្ចការបែងចែកតំបន់ត្រូវស៊ើបអង្កេត និងសម្រេចលើរាល់ពាក្យសុំសម្រាប់ការលើកលែងពីបទបញ្ជា និងលក្ខខណ្ឌតម្រូវណាមួយនៃបទបញ្ញត្តិស្តីពីការបែងចែកតំបន់ ហើយត្រូវមានអំណាច និងករណីយកិច្ចផ្សេងទៀតទាក់ទងនឹងការបែងចែកតំបន់ និងការប្រើប្រាស់ដី ដូចដែលបានកំណត់ដោយបទបញ្ញត្តិ ។

ក្រុមប្រឹក្សាត្រូវកំណត់ដោយបទបញ្ញត្តិនូវកម្រិតពេលវេលាដែល <u>នាយកដ្ឋានផែនការទីក្រុង</u> ~~រដ្ឋបាលបែងចែកតំបន់~~ត្រូវតែធ្វើសកម្មភាពសម្រាប់ករណីនីមួយៗក្រោមយុត្តាធិការ <u>របស់គាត់/របស់នាង</u>~~របស់ខ្លួន~~ ប្រសិនបើគ្មានការសម្រេចចិត្តណាមួយត្រូវបានធ្វើឡើងទេ ~~ដោយរដ្ឋបាលបែងចែកតំបន់~~ក្នុងរយៈពេលកំណត់ទេ អ្នកដាក់ពាក្យអាចស្នើសុំឱ្យផ្ទេរបញ្ហានេះទៅកាន់យុត្តាធិការ របស់<u>គណៈកម្មការប្តឹងឧទ្ធរណ៍សង្កាត់</u>~~គណៈកម្មការរៀបចំផែនការតំបន់~~ ឬគណៈកម្មការផ្សេងទៀត ដូចដែលបានកំណត់ដោយបទបញ្ញត្តិ ។

រដ្ឋបាលបែងចែកតំបន់អាចអនុម័តច្បាប់ចាំបាច់ដើម្បីអនុវត្តលក្ខខណ្ឌតម្រូវដែលបានកំណត់ដោយបទបញ្ញត្តិ ហើយដែលមិនមានទំនាស់ ឬមិនស្របតាមបទបញ្ញត្តិទាំងនោះ ។ ~~ច្បាប់ និងបទប្បញ្ញត្តិទាំងអស់ត្រូវមានសម្រាប់ការត្រួតពិនិត្យ អនុលោមតាមលក្ខខណ្ឌតម្រូវរបស់ច្បាប់ស្តីពីកំណត់ត្រាសាធារណៈរដ្ឋ California ។~~

មាត្រា 7. មាត្រា 562 របស់ធម្មនុញ្ញរបស់ទីក្រុង Los Angeles ត្រូវបានលុបចោលដូចខាងក្រោម ៖

~~**មាត្រា 562. ការលើកលែង ។**~~

~~ក្រុមប្រឹក្សាត្រូវកំណត់នីតិវិធីសម្រាប់ការផ្តល់ការលើកលែងដោយបទបញ្ញត្តិ ដោយស្ថិតក្រោមលក្ខខណ្ឌដូចខាងក្រោម ៖~~

~~(a) ការសវនាការដំបូង និងការសម្រេច ។ ពាក្យសុំទាំងអស់សម្រាប់ការលើកលែងនឹងត្រូវបានធ្វើសវនាការ និងសម្រេចដោយរដ្ឋបាលបែងចែកតំបន់ លើកលែងតែមានចែងផ្សេងពីនេះនៅក្នុងមាត្រា 564 ។~~

~~(b) ដំណើរការប្តឹងឧទ្ធរណ៍ ។ បុគ្គលដែលមិនសុខចិត្តអាចប្តឹងឧទ្ធរណ៍ចំពោះការសម្រេចចិត្តលើការលើកលែងផ្ទុយពីនេះរបស់រដ្ឋបាលបែងចែកតំបន់ទៅគណៈកម្មការរៀបចំផែនការតំបន់ ។ ការអនុញ្ញាតឱ្យមានការលើកលែងដោយគណៈកម្មការរៀបចំផែនការតំបន់អាចត្រូវបានប្តឹងឧទ្ធរណ៍បន្ថែមទៀតទៅគណៈកម្មការរៀបចំផែនការទីក្រុង ឬក្រុមប្រឹក្សា ដូចដែលបានកំណត់ដោយបទបញ្ញត្តិ ។ នឹងមិនមានការប្តឹងឧទ្ធរណ៍បន្ថែមទៀតពីការសម្រេចចិត្តរបស់គណៈកម្មការរៀបចំផែនការតំបន់ក្នុង~~

~~ការបដិសេធចំពោះការលើកលែងនោះ ។ ទោះជាយ៉ាងណាក៏ដោយ សកម្មភាពរបស់គណៈកម្មការរៀបចំផែនការតំបន់នោះត្រូវស្ថិតនៅក្រោមការពិនិត្យឡើងវិញរបស់ក្រុមប្រឹក្សាអនុលោមទៅតាមមាត្រា 245 ។~~

~~(c) ការរកឃើញសម្រាប់ការផ្តល់ជូនការលើកលែង ។ ការរកឃើញដូចខាងក្រោមនេះត្រូវធ្វើមុនពេលការលើកលែងអាចត្រូវបានផ្តល់ជូន ៖~~

~~(1) ការអនុវត្តយ៉ាងតឹងរ៉ឹងនៃលក្ខខណ្ឌនៃបទបញ្ញត្តិស្តីពីការបែងចែកតំបន់នឹងបណ្តាលឱ្យមានការលំបាកជាក់ស្តែង ឬភាពលំបាកដែលមិនចាំបាច់ ដែលផ្ទុយពីគោលបំណងទូទៅ និងចេតនានៃបទបញ្ញត្តិស្តីពីការបែងចែកតំបន់~~

~~(2) ថាមានកាលៈទេសៈពិសេសដែលអាចអនុវត្តបានចំពោះទ្រព្យសម្បត្តិដូចជាទំហំ សណ្ឋានដី ភូមិសាស្រ្ត ទីតាំង ឬបរិស្ថានជុំវិញ ដែលមិនអនុវត្តជាទូទៅចំពោះអចលនទ្រព្យផ្សេងទៀតនៅក្នុងតំបន់ និងតំបន់ជុំវិញដូចគ្នាទេ~~

~~(3) ថាការលើកលែងនេះមានចាំបាច់សម្រាប់ការអភិរក្ស និងការអាស្រ័យផលពីសិទ្ធិម្ចាស់ទ្រព្យសម្បត្តិសំខាន់ៗ ឬការប្រើប្រាស់ដែលជាទូទៅមានដោយទ្រព្យសម្បត្តិផ្សេងទៀតនៅក្នុងតំបន់ និងតំបន់ជុំវិញដូចគ្នា ប៉ុន្តែដោយសារតែកាលៈទេសៈពិសេស និងការលំបាកក្នុងការអនុវត្តជាក់ស្តែង ឬភាពលំបាកដែលមិនចាំបាច់ ត្រូវបានបដិសេធចំពោះទ្រព្យសម្បត្តិដែលពាក់ព័ន្ធទេ~~

~~(4) ថាការផ្តល់ជូនការលើកលែងនឹងមិនបង្កការខូចខាតធ្ងន់ធ្ងរដល់សុខុមាលភាពសាធារណៈ ឬបង្កគ្រោះថ្នាក់ដល់ទ្រព្យសម្បត្តិ ឬការកែលម្អនៅក្នុងតំបន់ ឬតំបន់ជុំវិញដែលទ្រព្យសម្បត្តិនោះស្ថិតនៅនោះទេ និង~~

~~(5) ថាការផ្តល់ជូនការលើកលែងនឹងមិនប៉ះពាល់អវិជ្ជមានដល់កត្តាណាមួយនៃផែនការទូទៅឡើយ ។~~

~~ការផ្តល់ជូនការលើកលែងអាចរួមបញ្ចូលលក្ខខណ្ឌដែលនឹងដោះស្រាយភាពខុសគ្នានៃសិទ្ធិពិសេស និងដែលចាំបាច់ដើម្បីការពារសុខភាពសាធារណៈ សុវត្ថិភាព ឬសុខុមាលភាព និងធានាការអនុលោមតាមគោលបំណងនៃផែនការទូទៅ និងគោលបំណង និងចេតនានៃបទបញ្ញត្តិស្តីពីការបែងចែកតំបន់ ។ ការលើកលែងមិនត្រូវប្រើដើម្បីផ្តល់សិទ្ធិពិសេស ឬដើម្បីអនុញ្ញាតឱ្យមានការប្រើប្រាស់ដែលមិនស្របគ្នាជាខ្លាំងជាមួយនឹងការរឹតត្បិតលើទ្រព្យសម្បត្តិផ្សេងទៀតនៅក្នុងតំបន់ និងតំបន់ជុំវិញដូចគ្នានោះទេ ។ រដ្ឋបាលបែងចែកតំបន់អាចបដិសេធចំពោះការលើកលែង ប្រសិនបើលក្ខខណ្ឌដែលបង្កើតតម្រូវការសម្រាប់ការលើកលែងត្រូវបានធ្វើឡើងដោយខ្លួនឯង ។~~

មាត្រា 8. មាត្រា 563 របស់ធម្មនុញ្ញរបស់ទីក្រុង Los Angeles ត្រូវបានលុបចោលដូចខាងក្រោម ៖

~~មាត្រា 563. លិខិតអនុញ្ញាតប្រើប្រាស់តាមលក្ខខណ្ឌ និងការអនុម័តផ្សេងទៀត ។~~

~~(a) ការបែងចែកដីបន្ទាប់ ។ នីតិវិធីសម្រាប់ការអនុម័តផែនទីក្បាលដី ផែនទីបែងចែកដីបន្ទាប់ និងការអនុម័តផ្សេងទៀតដែលផ្តល់ឱ្យស្របតាមច្បាប់ផែនទីបែងចែកដីបន្ទាប់របស់រដ្ឋ ត្រូវកំណត់ដោយបទបញ្ញត្តិ ។~~

~~(b) លិខិតអនុញ្ញាតប្រើប្រាស់តាមលក្ខខណ្ឌ និងការអនុម័តដែលមានអំណាចជាតុលាការស្រដៀងគ្នាផ្សេងទៀត ។ ក្រុមប្រឹក្សាត្រូវកំណត់ដោយបទបញ្ញត្តិនូវនីតិវិធីសម្រាប់ការផ្តល់លិខិតអនុញ្ញាតប្រើប្រាស់តាមលក្ខខណ្ឌ និងការអនុម័តដែលមានអំណាចជាតុលាការស្រដៀងគ្នាផ្សេងទៀត ក្រោមលក្ខខណ្ឌដូចខាងក្រោម ៖~~

~~(1) ការសម្រេចដំបូង ។ ពាក្យសុំសម្រាប់លិខិតអនុញ្ញាតឱ្យប្រើប្រាស់ដោយមានលក្ខខណ្ឌ និងការយល់ព្រមប្រើប្រាស់ដីដែលមានអំណាចជាតុលាការស្រដៀងគ្នា ត្រូវតែមានសវនាការ និងសម្រេចដោយអ្នកគ្រប់គ្រងការបែងចែកតំបន់ ឬគណៈកម្មការរៀបចំផែនការតំបន់ ដូចដែលបានចែងដោយបទបញ្ញត្តិ ។ ទោះជាយ៉ាងណាក៏ដោយ អាស្រ័យលើការយល់ព្រមដោយបទបញ្ញត្តិ គណៈកម្មការរៀបចំផែនការទីក្រុងអាចអនុម័តបទបញ្ញត្តិ និងបទបញ្ជា ដែលកំណត់អត្តសញ្ញាណថ្នាក់ ឬប្រភេទនៃការយល់ព្រមដែលមានអំណាចជាតុលាការដែលមានផលប៉ះពាល់ទូទាំងទីក្រុង ហើយផ្តល់ការយល់ព្រមទាំងនោះដើម្បីឱ្យគណៈកម្មការរៀបចំផែនការទីក្រុងមានសវនាការ និងសម្រេច ជំនួសឱ្យគណៈកម្មការរៀបចំផែនការតំបន់ ។~~

~~(2) ដំណើរការប្តឹងឧទ្ធរណ៍ ។ ជនរងគ្រោះអាចប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចរបស់អ្នកគ្រប់គ្រងការបែងចែកតំបន់ ទាក់ទងនឹងលិខិតអនុញ្ញាតឱ្យប្រើប្រាស់ដោយមានលក្ខខណ្ឌ ឬការយល់ព្រមដែលមានអំណាចជាតុលាការស្រដៀងគ្នា ទៅកាន់គណៈកម្មការរៀបចំផែនការតំបន់ ។ សេចក្តីសម្រេចរបស់គណៈកម្មការរៀបចំផែនការតំបន់អាច~~

~~ត្រូវបានប្តឹងឧទ្ធរណ៍ទៅកាន់គណៈកម្មការផែនការទីក្រុង ឬក្រុមប្រឹក្សា ដូចដែលបានចែងដោយបទបញ្ញត្តិ លើកលែងតែសេចក្តីសម្រេចទាំងឡាយណា ដែលធ្វើឡើងដោយគណៈកម្មការរៀបចំផែនការតំបន់លើការប្តឹងឧទ្ធរណ៍ពីសេចក្តីសម្រេចរបស់អ្នកគ្រប់គ្រងការបែងចែកតំបន់ ។ ទោះជាយ៉ាងណាក៏ដោយ ដំណើរការសម្រាប់ការយល់ព្រមលើលិខិតអនុញ្ញាតឱ្យប្រើប្រាស់ដោយមានលក្ខខណ្ឌ និងការយល់ព្រមដែលមានអំណាចជាតុលាការស្រដៀងគ្នា អាចនឹងមិនរួបបញ្ចូលលើសពីបួយកម្រិតនៃការប្តឹងឧទ្ធរណ៍ពីសេចក្តីសម្រេចរបស់បន្ត្រី ឬស្ថាប័នធ្វើសេចក្តីសម្រេចនោះទេ ។ សម្រាប់គោលបំណងនៃការដាក់កម្រិតនេះ ៖~~

~~(A) ការប្រើប្រាស់អ្នកត្រួតពិនិត្យសវនាការ ឬវិធីសាស្ត្រផ្សេងទៀតដែលតាបរយៈនោះអនុសាសន៍ត្រូវបានធ្វើឡើងទៅកាន់បន្ត្រី ឬស្ថាប័នដែលធ្វើសេចក្តីសម្រេច មិនរាវាំងការប្តឹងឧទ្ធរណ៍ពីសេចក្តីសម្រេចរបស់បន្ត្រី ឬស្ថាប័នដែលធ្វើសេចក្តីសម្រេចនោះទេ ។~~

~~(B) ប្រសិនបើក្រុមប្រឹក្សាកំពុងដើរតួជាស្ថាប័នប្តឹងឧទ្ធរណ៍ សកម្មភាពរបស់ក្រុមប្រឹក្សាអាចអាស្ស័យលើការយល់ព្រមពីចៅហ្វាយក្រុង និងការទាត់ចោលដោយក្រុមប្រឹក្សាលើការមិនយល់ព្រមពីចៅហ្វាយក្រុង ដោយសំឡេងពីរភាគបីនៃក្រុមប្រឹក្សា ប្រសិនបើមានចែងដូច្នេះដោយបទបញ្ញត្តិ ។~~

~~(C) ការពិនិត្យឡើងវិញរបស់ក្រុមប្រឹក្សាលើសកម្មភាពក្រោមមាត្រា 245 នៃធម្មនុញ្ញ មិនត្រូវចាត់ទុកថាជាការប្តឹងឧទ្ធរណ៍សម្រាប់គោលបំណងនៃមាត្រានេះទេ ។~~

~~(D) ការដាក់កម្រិតលើការប្តឹងឧទ្ធរណ៍មិនអនុវត្តចំពោះសកម្មភាពនីតិបញ្ញត្តិណាមួយឡើយ ។~~

មាត្រា 9. មាត្រា 564 នៃធម្មនុញ្ញរបស់ទីក្រុង Los Angeles ត្រូវបានលុបចោលដូចខាងក្រោម ៖

~~**មាត្រា 564. តម្រោងដែលតម្រូវឱ្យមានការយល់ព្រមច្រើន ។**~~

~~ប្រសិនបើតម្រោងមួយតម្រូវឱ្យមានការយល់ព្រមដោយអ្នកគ្រប់គ្រងការបែងចែកតំបន់ និងគណៈកម្មការរៀបចំផែនការតំបន់ ឬគណៈកម្មការរៀបចំផែនការទីក្រុង ការយល់ព្រម ដែលបើមិនទទួលបាន នឹងត្រូវមានសវនាការ និងសម្រេចដោយអ្នកគ្រប់គ្រងការបែងចែកតំបន់ទាំងនោះ ត្រូវតែមានសវនាការ និងសម្រេចដោយគណៈកម្មការរៀបចំផែនការតំបន់ ឬគណៈកម្មការរៀបចំផែនការទីក្រុង ដោយយកបួយណា ដែលមានយុត្តាធិការលើការយល់ព្រមផ្សេងទៀតដែលតម្រូវឱ្យមានសម្រាប់គម្រោង ។ ការយល់ព្រមសម្រាប់គម្រោងដែលតម្រូវឱ្យមានសកម្មភាពដែលមានអំណាចជាតុលាការ និងនីតិបញ្ញត្តិត្រូវតែមានសវនាការ និងសម្រេចដោយគណៈកម្មការរៀបចំផែនការទីក្រុង លើកលែងតែដូចបានចែងក្នុងមាត្រា 565 ។~~

មាត្រា 10. មាត្រា 565 នៃធម្មនុញ្ញរបស់ទីក្រុង Los Angeles ត្រូវបានលុបចោលដូចខាងក្រោម ៖

~~**មាត្រា 565. ការចាត់សិទ្ធិអំណាចនីតិបញ្ញត្តិដល់គណៈកម្មការរៀបចំផែនការតំបន់ ។**~~

~~គណៈកម្មការរៀបចំផែនការទីក្រុងអាចអនុម័តវិធាន និងបទបញ្ជា ដោយអាស្ស័យលើការយល់ព្រមដោយបទបញ្ញត្តិ ដែលកំណត់អត្តសញ្ញាណថ្នាក់ ឬប្រភេទនៃសកម្មភាពនីតិបញ្ញត្តិសម្រាប់គម្រោងដែលត្រូវបានកំណត់ថាមិនមានផលប៉ះពាល់ទូទាំងទីក្រុង ហើយរៀបចំឱ្យមានចំណាត់ការលើគម្រោងទាំងនោះដោយគណៈកម្មការរៀបចំផែនការតំបន់ជំនួសឱ្យគណៈកម្មការរៀបចំផែនការទីក្រុង ។~~

មាត្រា 11. ភាពអាចបំបែកបាន ។ ប្រសិនបើមាត្រា ផ្នែករង ខចែង ប្រយោគ ឃ្លា ឬការអនុវត្តនៃវិសោធនកម្មធម្មនុញ្ញនេះ ឬផ្នែកណាមួយនៃវិសោធនកម្មនេះ ត្រូវបានតុលាការ ឬសាលាជម្រះក្តីដែលមានយុត្តាធិការ និងដែនមានសមត្ថកិច្ចសម្រេចថាមិនស្របតាមរដ្ឋធម្មនុញ្ញ ឬមិនមានសុពលភាព នោះមាត្រា ផ្នែករង ខចែង ប្រយោគ ឃ្លា ផ្នែក ឬការអនុវត្តវិសោធនកម្មធម្មនុញ្ញដែលនៅសល់ត្រូវបន្តនៅមាន និងមានប្រសិទ្ធភាពពេញលេញ ហើយគិតដល់ចំណុចនេះ លក្ខខណ្ឌនៃវិសោធនកម្មធម្មនុញ្ញនេះគឺអាចបំបែកចេញពីគ្នាបាន ។ លើសពីនេះ អ្នកបោះឆ្នោតប្រកាសថាពួកគេនឹងអនុម័តរាល់មាត្រា ផ្នែករង ខចែង ប្រយោគ ឃ្លា ផ្នែក និងការអនុវត្តនៃវិសោធនកម្មធម្មនុញ្ញនេះ ដោយគ្មានមាត្រា ផ្នែករង ខចែង ប្រយោគ ឃ្លា ផ្នែក ឬការអនុវត្តដែលត្រូវបានសម្រេចថាមិនស្របតាមរដ្ឋធម្មនុញ្ញ ឬមិនមានសុពលភាពនោះឡើយ ។

EE ក្រមសីលធម៌ ការបោះឆ្នោត និងអភិបាលកិច្ចទីក្រុង។ វិសោធនកម្មធម្មនុញ្ញ EE។

តើធម្មនុញ្ញក្រុងគួរត្រូវបានធ្វើវិសោធនកម្មដើម្បី៖ បង្កើនអំណាចរបស់អគ្គអធិការដ្ឋាននៃនាយកដ្ឋានប៉ូលិស និងអ្នកវាយតម្លៃឯករាជ្យនៃនាយកដ្ឋានពន្លត់អគ្គិភ័យ ហាមប្រាមស្នងការក្រមសីលធម៌មិនឱ្យឈរឈ្មោះសម្រាប់ការិយាល័យបោះឆ្នោតមួយចំនួនរយៈពេលប្រាំឆ្នាំ បង្កើនការពិន័យចំពោះការរំលោភបំពានហិរញ្ញវត្ថុយុទ្ធនាការ តម្រូវឱ្យក្រុមប្រឹក្សាទីក្រុងប្រជុំយ៉ាងហោចណាស់ប្រចាំសប្តាហ៍ ជាជាងការតម្រូវបច្ចុប្បន្នចំនួនបីថ្ងៃក្នុងមួយសប្តាហ៍ បង្កើនតម្រូវការហត្ថលេខាលើញត្តិប្រជាមតិ និងធ្វើការផ្លាស់ប្តូរផ្សេងទៀតទាក់ទងនឹងក្រមសីលធម៌ការបោះឆ្នោត និងអភិបាលកិច្ចដែរឬទេ?

សេចក្តីសង្ខេបតតលម្អៀង
ដោយ SHARON M. TSO ប្រធានអ្នកវិភាគនិតិបញ្ញត្តិ

ធម្មនុញ្ញក្រុងកំណត់រចនាសម្ព័ន្ធ អំណាច មុខងារ ដំណើរការ និងការទទួលខុសត្រូវរបស់រដ្ឋាភិបាលទីក្រុង។ សាលាក្រុងកំពុងស្នើឱ្យមានការផ្លាស់ប្តូរ និងបំភ្លឺផ្សេងៗចំពោះធម្មនុញ្ញក្រុងទាក់ទងនឹងក្រមសីលធម៌ ការបោះឆ្នោត និងអភិបាលកិច្ចទីក្រុង។

វិធានការនេះនឹងកែប្រែធម្មនុញ្ញក្រុងដូចខាងក្រោម៖

- ហាមឃាត់នាយកប្រតិបត្តិ និងស្នងការនៃគណៈកម្មការក្រមសីលធម៌មិនឱ្យឈរឈ្មោះសម្រាប់ការិយាល័យជាប់ឆ្នោតរបស់ក្រុង ឬការិយាល័យគណៈកម្មការអប់រំមណ្ឌលសិក្សាធិការរួបរួម Los Angeles យ៉ាងហោចណាស់ប្រាំឆ្នាំបន្ទាប់ពីចាកចេញពីតំណែងរបស់ពួកគេ ដោយហេតុនេះបង្កើតការហាមឃាត់ក្រោយការបម្រើការងាររយៈពេលប្រាំឆ្នាំលើការឈរឈ្មោះសម្រាប់ការិយាល័យជាប់ឆ្នោតរបស់ក្រុង ឬមណ្ឌលសិក្សាធិការរួបរួម Los Angeles
- បង្កើនការពិន័យជាប្រាក់អតិបរមាចំពោះការល្មើសច្បាប់ហិរញ្ញវត្ថុយុទ្ធនាការឃោសនាបោះឆ្នោតដល់ចំនួនច្រើនជាង $15,000 ដុល្លារ ដែលត្រូវបានកែតម្រូវជារៀងរាល់ឆ្នាំសម្រាប់អតិផរណា ឬបីដងនៃចំនួនទឹកប្រាក់ដែលបានរាយការណ៍មិនត្រឹមត្រូវ ឬបានចូលរួមវិភាគទាន ចំណាយ ផ្តល់ឱ្យ ឬទទួលបានដោយខុសច្បាប់ ក្នុងមួយការល្មើសច្បាប់។
- បង្កើនចំនួនហត្ថលេខាដែលតម្រូវឱ្យមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ចំពោះញត្តិប្រជាមតិសម្រាប់ការដាក់ជូនក្រុមប្រឹក្សាក្រុងពី 10 ភាគរយដល់ 15 ភាគរយនៃចំនួនសន្លឹកឆ្នោតសរុបដែលបានបោះឆ្នោតក្នុងការបោះឆ្នោតជ្រើសរើសចៅហ្វាយក្រុងលើកមុន ដែលជាភាគរយដូចគ្នានៃហត្ថលេខាដែលតម្រូវសម្រាប់ញត្តិផ្តួចផ្តើម។
- ពង្រឹងឯករាជ្យភាពរបស់អគ្គមន្ត្រីអធិការកិច្ចនៃក្រសួងប៉ូលិស ដោយលុបចោលអំណាចរបស់ក្រុមប្រឹក្សាស្នងការនគរបាល ក្នុងការបញ្ជាអគ្គមន្ត្រីអធិការកិច្ចមិនឱ្យចាប់ផ្តើម ឬបន្តការស៊ើបអង្កេត ឬសវនកម្ម។
- ពង្រឹងឯករាជ្យភាពរបស់អ្នកវាយតម្លៃឯករាជ្យរបស់ក្រសួងពន្លត់អគ្គិភ័យ ដោយដកសិទ្ធិអំណាចរបស់គណៈកម្មការស្នងការអគ្គីភ័យ ក្នុងការដឹកនាំអ្នកវាយតម្លៃឯករាជ្យមិនឱ្យចាប់ផ្តើម ឬបន្តការវាយតម្លៃ ឬសវនកម្ម។
- បញ្ជាក់ឱ្យច្បាស់អំពីភាសាដែលនាយកដ្ឋានប៉ូលីស និងក្រសួងពន្លត់អគ្គីភ័យ នៅតែមានការលើកលែងពីការផ្ទេរ ឬការច្របាច់បញ្ចូលអំណាចក្រសួង ប្រសិនបើវាផ្លាស់ប្តូរយ៉ាងសំខាន់ ឬប៉ះពាល់ដល់គោលបំណងចម្បងរបស់ក្រសួង។
- តម្រូវឱ្យក្រុមប្រឹក្សាក្រុងធ្វើកិច្ចប្រជុំជាប្រចាំយ៉ាងហោចណាស់មួយសប្តាហ៍ម្តង ជាជាងការប្រជុំយ៉ាងហោចណាស់បីថ្ងៃក្នុងមួយសប្តាហ៍ ដូចដែលតម្រូវនាពេលបច្ចុប្បន្ន។

- ផ្លាស់ប្តូរលក្ខខណ្ឌតម្រូវពេលវេលាសម្រាប់សកម្មភាពរបស់គណៈកម្មការស្នងការឱ្យទៅសម្រេចបន្ទាប់ពី 15 ថ្ងៃប្រតិទិនក្នុងអំឡុងពេលដែលក្រុមប្រឹក្សាក្រុងបានកោះប្រជុំជាទៀងទាត់ជំនួសឱ្យប្រាំថ្ងៃប្រជុំរបស់ក្រុមប្រឹក្សាក្រុង ដូចដែលបានតម្រូវនៅក្នុងធម្មនុញ្ញបច្ចុប្បន្ន។
- ផ្លាស់ប្តូរលក្ខខណ្ឌតម្រូវពេលវេលាដែលទាក់ទងនឹងសមត្ថភាពរបស់ក្រុមប្រឹក្សាក្រុងក្នុងការធ្វើសកម្មភាពមុនពេលសកម្មភាពរបស់គណៈកម្មការស្នងការប៉ូលិសដើម្បីដកមេប៉ូលីសទៅជាចុងក្រោយដល់ 21 ថ្ងៃតាមប្រតិទិនក្នុងអំឡុងពេលដែលក្រុមប្រឹក្សាក្រុងបានកោះប្រជុំជាទៀងទាត់ជំនួសឱ្យដប់ថ្ងៃប្រជុំរបស់ក្រុមប្រឹក្សាក្រុង ដូចដែលតម្រូវនៅក្នុងធម្មនុញ្ញបច្ចុប្បន្ន
- សូមបញ្ជាក់ថា សាលាក្រុងត្រូវអនុម័ត និងបន្តរក្សាបទបញ្ញត្តិ និងគោលនយោបាយនានា ដើម្បីធានាថាសេវាកម្មក្រុងអាចចូលប្រើប្រាស់បានជាភាសាផ្សេងៗគ្នា និង
- ដាក់បញ្ចូលការផ្លាស់ប្តូរបច្ចេកទេស និងពាក្យបច្ចេកទេសមួយចំនួនទាក់ទងនឹងបទឃ្លាញត្តិទាក់ទងនឹងក្រុមប្រឹក្សាសង្កាត់ ហើយបង្ហាញថានិយមន័យនៃអ្នកពាក់ព័ន្ធនៃក្រុមប្រឹក្សាសង្កាត់ត្រូវត្រូវបានកំណត់ដោយច្បាប់។

វិធានការនេះនឹងមានប្រសិទ្ធភាព ប្រសិនបើត្រូវបានយល់ព្រមដោយអ្នកបោះឆ្នោតភាគច្រើន។

របាយការណ៍ផលប៉ះពាល់ហិរញ្ញវត្ថុ
ដោយ MATTHEW W. SZABO មន្ត្រីរដ្ឋបាលទីក្រុង

វិសោធនកម្មធម្មនុញ្ញក្រុងនេះទាក់ទងនឹងវិស័យអភិបាលកិច្ចផ្សេងៗ រួមមាន៖ សម្រួលដល់ភាពងាយស្រួលប្រើប្រាស់ភាសា, កាត់បន្ថយលក្ខខណ្ឌតម្រូវអប្បបរមាសម្រាប់កិច្ចប្រជុំក្រុមប្រឹក្សាក្រុងដែលបានធ្វើឡើងជាប្រចាំ, បង្កើនហត្ថលេខាដែលត្រូវការសម្រាប់ញត្តិប្រជាមតិ, ការធ្វើបច្ចុប្បន្នភាពមាត្រា 470 នៃធម្មនុញ្ញឱ្យស្របនឹងការពិន័យផ្នែកហិរញ្ញវត្ថុយុទ្ធនាការឃោសនាបោះឆ្នោតនៅក្នុងមាត្រា 706, ហាមឃាត់ស្នងការក្រមសីលធម៌មិនឱ្យឈរឈ្មោះសម្រាប់តំណែងមួយចំនួនរយៈពេលប្រាំឆ្នាំ, និងអនុញ្ញាតឱ្យមានការវាយតម្លៃ និងសវនកម្មនៃនាយកដ្ឋាននគរបាល និងនាយកដ្ឋានពន្លត់អគ្គិភ័យដោយអ្នកវាយតម្លៃឯករាជ្យ ឬអគ្គមន្ត្រីអធិការកិច្ចរៀងៗខ្លួន ដោយមិនចាំបាច់ត្រួតពិនិត្យក្រុមគណៈកម្មការរបស់ពួកគេ។ ការកាត់បន្ថយកិច្ចប្រជុំក្រុមប្រឹក្សាអាចបណ្តាលឱ្យមានការសន្សំសំចៃថ្លៃដើមមូលនិធិទូទៅពីការកាត់បន្ថយសេវាកម្មបកប្រែ និងអក្សរត់។ ការផ្លាស់ប្តូរចំពោះគណៈកម្មការពន្លត់អគ្គីភ័យ និងប៉ូលីសអាចតម្រូវឱ្យជួលអ្នកស៊ើបអង្កេតថ្មី ការរក្សាអ្នកសវនកម្មខាងក្រៅ ឬការពង្រីកបុគ្គលិកស៊ើបអង្កេតអាស្រ័យលើបរិមាណសំណុំរឿងដែលបណ្តាលឱ្យមានការចំណាយដែលមិនអាចកំណត់បាននៅពេលនេះ។ ការផ្លាស់ប្តូរអភិបាលកិច្ចផ្សេងទៀតមិនត្រូវបានគេរំពឹងថានឹងមានផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុទេ។

សេចក្តីអះអាងគាំទ្រនៃវិសោធនកម្មធម្មនុញ្ញ EE

សូមបោះឆ្នោតគាំទ្រវិធានការ EE ដើម្បីពង្រឹងក្រមសីលធម៌ គណនេយ្យភាព ការត្រួតពិនិត្យឯករាជ្យ និងអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព នៅសាលាក្រុង Los Angeles។

វិធានការ EE ពង្រឹងស្ថាប័នទាំងឡាយណាដែលមានទទួលខុសត្រូវក្នុងការធានាឱ្យរដ្ឋបាលក្រុងមានគណនេយ្យភាព។ វិធានការនេះពង្រីកអំណាចរបស់អគ្គអធិការនៃនាយកដ្ឋានគរបាល និងអ្នកវាយតម្លៃឯករាជ្យនៃនាយកដ្ឋានពន្លត់អគ្គិភ័យ ដោយផ្តល់នូវការត្រួតពិនិត្យឯករាជ្យកាន់តែរឹងមាំលើនាយកដ្ឋានសុវត្ថិភាពសាធារណៈដ៏សំខាន់បំផុតទាំងពីររបស់ក្រុង។ វាក៏ពង្រឹងការអនុវត្តច្បាប់ហិរញ្ញវត្ថុយុទ្ធនាការឃោសនាបោះឆ្នោតផងដែរ ដោយការបង្កើនពិន័យចំពោះការល្មើសច្បាប់ និងកំណត់រយៈពេលផ្អាកប្រាំឆ្នាំ មុនពេលស្នងការក្រមសីលធម៌អាចឈរឈ្មោះស្វែងរកតំណែងជាប់ឆ្នោតមួយចំនួនរបស់ក្រុង។

វិធានការ EE ក៏ធ្វើបច្ចុប្បន្នភាពលើរបៀបដែលក្រុមប្រឹក្សាក្រុងប្រតិបត្តិការងាររបស់ខ្លួនផងដែរ។ ធម្មនុញ្ញក្រុងនាពេលបច្ចុប្បន្នតម្រូវឱ្យក្រុមប្រឹក្សាក្រុងប្រជុំយ៉ាងហោចណាស់បីថ្ងៃក្នុងមួយសប្តាហ៍ ដែលនេះជាសេចក្តីចាំបាច់ចម្លែកមួយដែលធ្វើឱ្យទីក្រុង Los Angeles ខុសប្លែកពីទីក្រុងធំៗដទៃទៀតនៅអាមេរិក ហើយវាកាត់បន្ថយពេលវេលារបស់សមាជិកក្រុមប្រឹក្សាក្នុងការចុះបំពេញការងារនៅក្នុងមណ្ឌលរបស់ពួកគេ ការជួបផ្ទាល់ជាមួយប្រជាពលរដ្ឋម្ចាស់ឆ្នោត ការអនុវត្តគោលនយោបាយ និងកម្មវិធីផ្សេងៗ ព្រមទាំងការឆ្លើយតបទៅនឹងតម្រូវការនៅក្នុងសហគមន៍។ វិធានការ EE តម្រូវឱ្យមានការប្រជុំក្រុមប្រឹក្សាក្រុងជាទៀងទាត់ប្រចាំសប្តាហ៍ ខណៈពេលដែលអនុញ្ញាតឱ្យមានការប្រជុំបន្ថែមតាមការចាំបាច់ ដោយផ្តល់នូវភាពបត់បែនកាន់តែច្រើនក្នុងការប្រជុំតាមពេលវេលា និងទីកន្លែងដែលសម្រួលដល់តម្រូវការរបស់ប្រជាពលរដ្ឋនៅទូទាំងក្រុង ហើយអនុញ្ញាតឱ្យក្រុមប្រឹក្សាក្រុងដំណើរការកិច្ចការសាធារណៈប្រកបដោយប្រសិទ្ធភាព និងភាពប៉ិនប្រសប់។ Los Angeles គឺជាទីក្រុងដែលមានប្រជាជនជិតបួនលាននាក់ ហើយតំណាងប្រកបដោយប្រសិទ្ធភាព តម្រូវឱ្យសមាជិកក្រុមប្រឹក្សាក្រុងចុះធ្វើការនៅក្នុងសហគមន៍របស់ពួកគេ ឆ្លើយតបទៅនឹងការព្រួយបារម្ភរបស់ប្រជាពលរដ្ឋនៅពេលកើតមានឡើង និងដោះស្រាយបញ្ហាប្រឈមគោលនយោបាយដ៏ស្មុគស្មាញនៅទូទាំងក្រុង។

វិធានការ EE ក៏ធ្វើបច្ចុប្បន្នភាពលើនីតិវិធីប្រជាមតិ និងការបោះឆ្នោត ព្រមទាំងជំរុញការកែទម្រង់បន្ថែមដែលត្រូវបានអភិវឌ្ឍឡើងតាមរយៈដំណើរការពិនិត្យឡើងវិញនូវធម្មនុញ្ញរបស់ក្រុងផងដែរ។

រួមគ្នាមក ការកែទម្រង់ទាំងនេះពង្រឹងការត្រួតពិនិត្យ លើកកម្ពស់ស្តង់ដារក្រមសីលធម៌ និងធ្វើទំនើបកម្មរដ្ឋបាលក្រុង ខណៈពេលដែលនៅតែរក្សាបាននូវតម្លាភាព និងគណនេយ្យភាពសាធារណៈ។

សូមបោះឆ្នោតគាំទ្រវិធានការ EE ដើម្បីរដ្ឋបាលក្រុងមួយដែលមានក្រមសីលធម៌ គណនេយ្យភាព និងប្រសិទ្ធភាពជាងមុន។

បុគ្គលដែលចុះហត្ថលេខាលើសេចក្តីអះអាងគាំទ្រនៃវិសោធនកម្មធម្មនុញ្ញ EE

TIM MCOSKER
សមាជិកក្រុមប្រឹក្សា, មណ្ឌលទី 15
City of LA

DIEGO ANDRADES
ស្នងការកំណែទម្រង់ធម្មនុញ្ញ

EUNISSES HERNANDEZ
សមាជិកក្រុមប្រឹក្សា, មណ្ឌលទី 1
City of LA

KATY YAROSLAVSKY
សមាជិកាក្រុមប្រឹក្សា, មណ្ឌលទី 5
City of LA

MARQUEECE HARRIS-DAWSON
សមាជិកក្រុមប្រឹក្សា, មណ្ឌលទី 8
City of LA

សេចក្តីអះអាងដែលបានបោះពុម្ព គឺជាមតិរបស់អ្នកនិពន្ធ ហើយមិនត្រូវបានត្រួតពិនិត្យភាពត្រឹមត្រូវដោយទីភ្នាក់ងារក្រុងណាមួយឡើយ ។ លើសពីនេះ មុខតំណែងនៅក្រោមឈ្មោះអ្នកចុះហត្ថលេខា គឺសម្រាប់គោលបំណងកំណត់អត្តសញ្ញាណតែប៉ុណ្ណោះ ហើយមិនបង្ហាញថាបុគ្គលនោះកំពុងចុះហត្ថលេខាក្នុងនាមអង្គការនោះទេ ។

សេចក្តីអះអាងប្រឆាំងវិធានការវិសោធនកម្មធម្មនុញ្ញ EE

វិសោធនកម្មធម្មនុញ្ញ EE ត្រូវបានបង្ហាញជាវិធានការកែទម្រង់សីលធម៌ ប៉ុន្តែត្រូវបានលាក់ទុកនៅក្នុងនោះគឺជាសំណើមួយដើម្បីកាត់បន្ថយកិច្ចប្រជុំក្រុមប្រឹក្សាក្រុង Los Angeles ពីបីដងក្នុងមួយសប្តាហ៍ មកត្រឹមម្តងក្នុងមួយសប្តាហ៍ ។ ឥទ្ធិពលចម្បងរបស់វាគឺកាត់បន្ថយចំនួនកិច្ចប្រជុំសាធារណៈ ដែលអ្នករស់នៅអាចតាមដានដំណើរការ ផ្តល់មតិយោបល់ជាសាធារណៈ និងតម្រូវឱ្យមន្ត្រីជាប់ឆ្នោតមានគណនេយ្យភាព ។

បន្ទាប់ពីរឿងអាស្រូវពុករលួយ និងការបរាជ័យផ្នែកក្រមសីលធម៌អស់រយៈពេលជាច្រើនឆ្នាំនៅសាលាក្រុង Los Angeles ត្រូវការតម្លាភាពកាន់តែច្រើន មិនមែនតិចជាងនេះទេ ។ កិច្ចប្រជុំសាធារណៈកាន់តែតិច មានន័យថា ឱកាសសម្រាប់ការត្រួតពិនិត្យជាសាធារណៈកាន់តែតិច និងមានសក្តានុពលកាន់តែច្រើនសម្រាប់ការសម្រេចចិត្តសំខាន់ៗត្រូវបានធ្វើឡើងនៅក្រៅក្រសៃភ្នែកសាធារណជន ។

បច្ចុប្បន្ន San Fernando Valley រៀបចំកិច្ចប្រជុំក្រុមប្រឹក្សាក្រុងយ៉ាងច្រើនបំផុតម្តងក្នុងមួយខែ ។ ប្រសិនបើវិធានការ EE ត្រូវបានអនុម័ត កិច្ចប្រជុំទាំងនោះទំនងជានឹងប្រព្រឹត្តទៅមិនសូវញឹកញាប់ទេ ដែលកាន់តែកម្រិតលទ្ធភាពរបស់អ្នករស់នៅ Valley ក្នុងការចូលជួបមន្ត្រីជាប់ឆ្នោតរបស់ពួកគេ ។

កំណែទម្រង់ធម្មនុញ្ញគួរតែពង្រីកតម្លាភាព លទ្ធភាពចូលរួមជាសាធារណៈ និងគណនេយ្យភាព មិនមែនកាត់បន្ថយវានោះទេ ។

សូមបោះឆ្នោតប្រឆាំងនឹងវិសោធនកម្មធម្មនុញ្ញ EE ។

ជនដែលចុះហត្ថលេខាលើសេចក្តីអះអាងប្រឆាំងវិសោធនកម្មធម្មនុញ្ញ EE

MONICA RODRIGUEZ
សមាជិកាក្រុមប្រឹក្សាក្រុង Los Angeles, មណ្ឌលទី 7
City of Los Angeles

សេចក្តីអះអាងដែលបានបោះពុម្ព គឺជាមតិរបស់អ្នកនិពន្ធ ហើយមិនត្រូវបានត្រួតពិនិត្យភាពត្រឹមត្រូវដោយទីភ្នាក់ងារក្រុងណាមួយឡើយ ។ លើសពីនេះ មុខតំណែងនៅក្រោមឈ្មោះអ្នកចុះហត្ថលេខា គឺសម្រាប់គោលបំណងកំណត់អត្តសញ្ញាណតែប៉ុណ្ណោះ ហើយមិនបង្ហាញថាបុគ្គលនោះកំពុងចុះហត្ថលេខាក្នុងនាមអង្គការនោះទេ ។

ការបដិសេធទៅនឹងសេចក្តីអះអាងដែលបានប្រឆាំងនឹងវិសោធនកម្មធម្មនុញ្ញ EE

សូមបោះឆ្នោតគាំទ្រវិធានការ EE។ ក្នុងចំណោមការកែទម្រង់ផ្សេងៗទៀត វិសោធនកម្ម EE ធ្វើឱ្យក្រុមប្រឹក្សាក្រុងដំណើរការកាន់តែមានប្រសិទ្ធភាព និងតម្លាភាព ព្រមទាំងបង្កើនការចូលទៅកាន់តំណាងរាស្ត្រដែលត្រូវបានជ្រើសរើសដោយការបោះឆ្នោត។ វិសោធនកម្ម EE អនុញ្ញាតឱ្យកិច្ចការរបស់ក្រុមប្រឹក្សាក្រុងត្រូវបានប្រព្រឹត្តទៅក្នុងកិច្ចប្រជុំមួយលើកក្នុងមួយសប្តាហ៍ ដែលធ្វើឱ្យការចូលរួមរបស់សាធារណជនក្នុងដំណើរការនេះកាន់តែមានភាពច្បាស់លាស់ និងអាចប្រាកដជាមុនបាន។ លើសពីនេះ ដោយសារកិច្ចការរដ្ឋបាលត្រូវបានអនុវត្តក្នុងកិច្ចប្រជុំមួយលើកក្នុងមួយសប្តាហ៍ សមាជិកក្រុមប្រឹក្សាក្រុងអាចចំណាយពេលបន្ថែមទៀតនៅក្នុងសហគមន៍ ដើម្បីផ្តល់សេវាកម្ម និងធ្វើការងារដែលពួកគេត្រូវបានគេបោះឆ្នោតជ្រើសរើសឱ្យធ្វើ។

សេចក្តីអះអាងរបស់ក្រុមប្រឆាំងដែលចង់ឱ្យមានចំនួនកិច្ចប្រជុំតាមអំពើចិត្ត គឺបន្តរក្សាទុកនូវប្រព័ន្ធដែលគ្មានប្រសិទ្ធភាព គ្មានភាពប៉ិនប្រសប់ និងខ្ជះខ្ជាយ។ ក្រុមប្រឆាំងក៏មើលរំលងផងដែរនូវការកែទម្រង់បន្ថែមរបស់វិធានការ EE រួមមាន៖ ការត្រួតពិនិត្យឯករាជ្យលើនាយកដ្ឋាននគរបាល និងនាយកដ្ឋានពន្លត់អគ្គិភ័យ ការបង្កើនពិន័យចំពោះការល្មើសច្បាប់ហិរញ្ញវត្ថុយុទ្ធនាការ ឃោសនាបោះឆ្នោត និងរយៈពេលផ្អាក 5 ឆ្នាំ សម្រាប់ស្នងការក្រមសីលធម៌ដែលស្វែងរកតំណែងជាប់ឆ្នោតមួយចំនួន។

វិសោធនកម្ម EE បង្កើតនូវការចូលរួមរបស់សាធារណជនប្រកបដោយន័យខ្លឹមសារ និងការត្រួតពិនិត្យឯករាជ្យយ៉ាងរឹងមាំ ព្រមទាំងលុបបំបាត់ការអនុវត្តបែបបុរាណ តាមអំពើចិត្ត និងខ្ជះខ្ជាយរបស់ក្រុមប្រឹក្សាក្រុង។ **សូមបោះឆ្នោតគាំទ្រវិធានការ EE។**

បុគ្គលដែលចុះហត្ថលេខាប្រឆាំងនឹងសេចក្តីអះអាងប្រឆាំងនឹងវិសោធនកម្មធម្មនុញ្ញ EE

TIM MCOSKER
សមាជិកក្រុមប្រឹក្សា, មណ្ឌលទី 15
City of LA

KATY YAROSLAVSKY
សមាជិកាក្រុមប្រឹក្សា, មណ្ឌលទី 5
City of LA

MARQUEECE HARRIS-DAWSON
សមាជិកក្រុមប្រឹក្សា, មណ្ឌលទី 8
City of LA

DIEGO ANDRADES
ស្នងការកំណែទម្រង់ធម្មនុញ្ញ

សេចក្តីអះអាងដែលបានបោះពុម្ព គឺជាមតិរបស់អ្នកនិពន្ធ ហើយមិនត្រូវបានត្រួតពិនិត្យភាពត្រឹមត្រូវដោយទីភ្នាក់ងារក្រុងណាមួយឡើយ ។ លើសពីនេះ មុខតំណែងនៅក្រោមឈ្មោះអ្នកចុះហត្ថលេខា គឺសម្រាប់គោលបំណងកំណត់អត្តសញ្ញាណតែប៉ុណ្ណោះ ហើយមិនបង្ហាញថាបុគ្គលនោះកំពុងចុះហត្ថលេខាក្នុងនាមអង្គការនោះទេ ។

បទប្បញ្ញត្តិថ្មី ឬភាសាដែលបានបន្ថែមទៅផ្នែកធម្មនុញ្ញ ឬផ្នែកធម្មនុញ្ញដែលមានស្រាប់ត្រូវបានបង្ហាញជាប្រភេទគូសបន្ទាត់ពីក្រោម។ ពាក្យដែលបានលុបចេញពីធម្មនុញ្ញ ឬពីផ្នែកធម្មនុញ្ញ ដែលមានស្រាប់ត្រូវបានបង្ហាញជាប្រភេទការ~~គូសចេញ~~។

វិសោធនកម្មធម្មនុញ្ញ EE
(ក្រមសីលធម៌ទីក្រុង ការបោះឆ្នោត និងអភិបាលកិច្ច)

អត្ថបទនៃវិធានការសន្លឹកឆ្នោតដែលបានស្នើឡើង

មាត្រា 1. មាត្រា 103 នៃធម្មនុញ្ញនៃទីក្រុង Los Angeles ត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោម ៖

ការិយាល័យ និងនាយកដ្ឋានក្រុងនីមួយៗ ព្រមទាំងមន្ត្រីក្រុង និងនិយោជិតក្រុងនីមួយៗ ត្រូវបំពេញមុខងាររបស់ខ្លួនដោយខុស្សាហ៍ព្យាយាម និងការលះបង់ ដើម្បីបម្រើប្រជាជននៃទីក្រុង Los Angeles ។ ក្នុងការផ្តល់សេវារបស់ក្រុង និងការបំពេញការកិច្ចរបស់ខ្លួន រដ្ឋាភិបាលត្រូវខិតខំប្រឹងប្រែងឱ្យសម្រេចបាននូវកម្រិតខ្ពស់បំផុតនៃសមិទ្ធផល រួមមាន ប្រសិទ្ធភាពភាពងាយស្រួលក្នុងការទទួលបានសេវា គណនេយ្យភាព គុណភាព ការប្រើប្រាស់វិធីសាស្ត្របច្ចេកវិទ្យាទំនើប និងការឆ្លើយតបចំពោះកង្វល់របស់សាធារណជន ក្នុងដែនកំណត់នៃថវិកា ។ ការវិភាគ និងការពិនិត្យឡើងវិញនូវការអនុវត្តរបស់រដ្ឋាភិបាល និងមន្ត្រីរបស់ខ្លួននីមួយៗ ត្រូវមានគោលបំណងកំណត់ថា តើស្តង់ដារខ្ពស់ទាំងនេះត្រូវបានបំពេញឬអត់ ហើយប្រសិនបើមិនបានបំពេញទេ ត្រូវផ្តល់អនុសាសន៍អំពីវិធីសាស្ត្រកែលម្អ ។ ទីក្រុងត្រូវអនុម័ត និងរក្សាបទបញ្ញត្តិ និងគោលនយោបាយ ដើម្បីធានាឱ្យបានសមហេតុផលថា ការប្រាស្រ័យទាក់ទង កម្មវិធី និងការចូលរួមជាសាធារណៈរបស់ខ្លួនអាចប្រើប្រាស់បានជាភាសាដែលប្រជាពលរដ្ឋរបស់ខ្លួននិយាយ ហើយការផ្សព្វផ្សាយ និងការចូលទៅដល់សហគមន៍ឆ្ទុះបញ្ចាំងពីសហគមន៍វប្បធម៌ និងភាសារបស់ទីក្រុង ។

មាត្រា 2. មាត្រា 242 នៃធម្មនុញ្ញនៃទីក្រុង Los Angeles ដែលទាក់ទងនឹងការប្រព្រឹត្តកិច្ចការរបស់ក្រុមប្រឹក្សាក្រុងត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោម ៖

មាត្រា 242. ការប្រព្រឹត្តកិច្ចការ ។

ក្រុមប្រឹក្សាក្រុងត្រូវជាអ្នកសម្រេចតែម្នាក់ឯងលើការបោះឆ្នោតជ្រើសរើស និងលក្ខណសម្បត្តិរបស់សមាជិករបស់ខ្លួន ។ កិច្ចប្រជុំ និងកំណត់ត្រានៃកិច្ចដំណើរការរបស់ក្រុមប្រឹក្សា និងគណៈកម្មការរបស់ក្រុមប្រឹក្សា ត្រូវបើកចំហជាសាធារណៈលើកលែងតែកិច្ចប្រជុំបិទទ្វារអាចត្រូវបានធ្វើឡើងតាមដែលច្បាប់អនុញ្ញាត ។ ក្រុមប្រឹក្សាត្រូវមានអំណាចផ្តាច់មុខក្នុងការរៀបចំកិច្ចការងាររបស់ខ្លួន កំណត់វិធាននៃកិច្ចដំណើរការរបស់ខ្លួន និងរក្សាសណ្តាប់ធ្នាប់នៅក្នុងកិច្ចប្រជុំរបស់ខ្លួន ដោយស្ថិតក្រោមលក្ខខណ្ឌដូចខាងក្រោម ៖

(a) ក្រុមប្រឹក្សាត្រូវរៀបចំកិច្ចប្រជុំ~~យ៉ាងហោចណាស់ប្រចាំសប្តាហ៍~~~~យ៉ាងហោចណាស់មីថ្ងៃក្នុងមួយសប្តាហ៍~~ ។ កិច្ចប្រជុំអាចធ្វើឡើងនៅសាលាក្រុង ឬនៅកន្លែងផ្សេងទៀតក្នុងទីក្រុង ។ តាមរយៈសេចក្តីសម្រេច ក្រុមប្រឹក្សាអាចកំណត់រយៈពេលដែលក្រុមប្រឹក្សា ឬគណៈកម្មការរបស់ខ្លួននឹងសម្រាកពីការប្រជុំ ។ ក្រុមប្រឹក្សា និងគណៈកម្មការរបស់ខ្លួន ក៏អាចរៀបចំកិច្ចប្រជុំពិសេសរៀងៗខ្លួនបានផងដែរ ដោយមានសេចក្តីជូនដំណឹងត្រឹមត្រូវ ។

(b) តាមរយៈបទបញ្ញត្តិ ឬសេចក្តីសម្រេច ក្រុមប្រឹក្សាត្រូវបង្កើតគណៈកម្មការក្នុងចំនួនគ្រប់គ្រាន់ ដើម្បីឱ្យខ្លួនអាចបំពេញការណីយកិច្ចរបស់ខ្លួនបាន ។ ការណីយកិច្ចរបស់ក្រុមប្រឹក្សា និងគណៈកម្មការរបស់ខ្លួន គឺត្រូវទទួលបានព័ត៌មានឱ្យបានពេញលេញអំពីកិច្ចការងាររបស់ទីក្រុង ដើម្បីត្រួតពិនិត្យមើលមុខងារទាំងអស់របស់រដ្ឋាភិបាលទីក្រុង និងរាយការណ៍ជូនក្រុមប្រឹក្សានូវព័ត៌មាន ឬអនុសាសន៍ទាំងឡាយដែលចាំបាច់ ដើម្បីឱ្យក្រុមប្រឹក្សាអាចធ្វើច្បាប់បានត្រឹមត្រូវ ។ គណៈកម្មការត្រូវមានអំណាចក្នុងការស៊ើបអង្កេត ប៉ុន្តែមិនត្រូវមានការគ្រប់គ្រងផ្នែករដ្ឋបាលលើមុខងារផ្សេងៗរបស់រដ្ឋាភិបាលទីក្រុងនោះឡើយ ។ ការគ្រប់គ្រងរដ្ឋាភិបាលទីក្រុងត្រូវស្ថិតនៅក្នុងសមត្ថកិច្ចរបស់មន្ត្រីដែលបានកំណត់នៅក្នុងធម្មនុញ្ញ ដើម្បីបំពេញមុខងារទាំងនោះ ។ ប្រធានក្រុមប្រឹក្សាត្រូវចាត់តាំងសមាជិក និងប្រធាននៃគណៈកម្មការ ហើយសមាជិកក្រុមប្រឹក្សានីមួយៗត្រូវចាត់តាំងឱ្យចូលរួមក្នុងគណៈកម្មការយ៉ាងហោចណាស់មួយ ។

មាត្រា 3. កថាខណ្ឌទីមួយនៃមាត្រា 245 នៃធម្មនុញ្ញនៃទីក្រុង Los Angeles ដែលពាក់ព័ន្ធនឹងពេលវេលានៃការវេតូរបស់ក្រុមប្រឹក្សាក្រុងលើសកម្មភាពរបស់គណៈកម្មការ ត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោម ៖

មាត្រា 245. ការធ្វើវេតូរបស់ក្រុមប្រឹក្សាក្រុងលើសកម្មភាពរបស់គណៈកម្មការ ។

វិធានការនានារបស់គណៈកម្មការស្នងការ ត្រូវចាត់ទុកជាស្ថាពរនៅពេលផុតកំណត់រយៈពេល 15 ថ្ងៃតាមប្រតិទិន ~~គ្រាំម្ងៃនៃម្ងៃប្រជុំក្រុមប្រឹក្សា~~បន្ទាប់ ដែលក្នុងអំឡុងពេលនោះ ក្រុមប្រឹក្សា បានកោះប្រជុំក្នុងសម័យប្រជុំធម្មតា លើកលែងតែក្រុមប្រឹក្សា អនុវត្តសកម្មភាពក្នុងអំឡុងពេលនោះដោយសំឡេងឆ្នោតពីរភាគបី ដើម្បីយកវិធានការនោះមកពិចារណា ឬដើម្បីបោះបង់ការពិនិត្យឡើងវិញលើវិធានការនោះ ប៉ុន្តែទាក់ទងនឹងវិធានការណាមួយរបស់គណៈកម្មការស្នងការប៉ូលិស អំពីការដកតំណែងនាយកប៉ូលីស រយៈពេលដែលក្រុមប្រឹក្សា អាចអនុវត្តសកម្មភាពបាន មុនពេលវិធានការរបស់គណៈកម្មការក្លាយជាស្ថាពរ ត្រូវមានរយៈពេល 21 ថ្ងៃតាមប្រតិទិន ~~ដប់ម្ងៃនៃម្ងៃប្រជុំ~~ ដែលក្នុងអំឡុងពេលនោះ ក្រុមប្រឹក្សា បានកោះប្រជុំក្នុងសម័យប្រជុំធម្មតា ។

មាត្រា 4. ផ្នែករង (a) នៃមាត្រា 461 នៃធម្មនុញ្ញនៃទីក្រុង Los Angeles ពាក់ព័ន្ធនឹងញត្តិប្រជាមតិ ត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោម ៖

(a) ញត្តិប្រជាមតិដែលត្រូវបានចែកចាយដើម្បីប្រមូលហត្ថលេខា ត្រូវមានអត្ថបទពេញលេញនៃបទបញ្ញត្តិដែលជាកម្មវត្ថុ ។ ឈ្មោះទាំងអស់ដែលបានចុះហត្ថលេខាលើញត្តិត្រូវតែប្រមូលបានក្នុងរយៈពេល 30 ថ្ងៃបន្ទាប់ពីការចោះពុម្ពផ្សាយបទបញ្ញត្តិ ។ ការចុះហត្ថលេខាណាមួយដែលបានដាក់បញ្ចូលក្រៅពីរយៈពេលនេះនឹងមិនត្រូវបានរាប់បញ្ចូលក្នុងការកំណត់ភាគគ្រប់គ្រាន់នៃញត្តិនោះទេ។ ដើម្បីមានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងការដាក់ជូនក្រុមប្រឹក្សា ញត្តិប្រជាមតិត្រូវតែមានហត្ថលេខារបស់អ្នកបោះឆ្នោតដែលបានចុះឈ្មោះក្នុងទីក្រុង ក្នុងចំនួនស្មើនឹង 15% ~~10%~~ នៃចំនួនសំឡេងឆ្នោតសរុបដែលបានបោះឱ្យបេក្ខជនទាំងអស់សម្រាប់តំណែងជាចៅហ្វាយក្រុង នៅឯការបោះឆ្នោតទូទៅថ្នាក់ក្រុងចុងក្រោយ ឬការបោះឆ្នោតជ្រើសតាំងបេក្ខជនបឋមដែលមានការជ្រើសរើសចៅហ្វាយក្រុង មុនពេលដាក់ញត្តិ ។

មាត្រា 5. កថាខណ្ឌរង (A) នៃអនុវិធីក (2) នៃផ្នែករង (o) នៃមាត្រា 470 នៃធម្មនុញ្ញនៃទីក្រុង Los Angeles ពាក់ព័ន្ធនឹងការអនុវត្តច្បាប់ហិរញ្ញប្បទានយុទ្ធនាការរបស់ទីក្រុង ត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោម ៖

(A) បុគ្គលណាដែលបំពានដោយចេតនា ឬដោយធ្វេសប្រហែសលើលក្ខខណ្ឌណាមួយនៃមាត្រានេះ ត្រូវទទួលខុសត្រូវក្នុងបណ្តឹងរដ្ឋប្បវេណីដែលប្តឹងដោយមេធាវីទីក្រុង ឬដោយបុគ្គលដែលរស់នៅក្នុងទីក្រុង ។ កន្លែងដែលមិនមានការពិន័យរដ្ឋប្បវេណីជាក់លាក់ត្រូវបានបញ្ញត្តិ បុគ្គលម្នាក់អាចត្រូវទទួលខុសត្រូវចំពោះការរំលោភបំពាននីមួយៗក្នុងចំនួនទឹកប្រាក់រហូតដល់ចំនួនដែលច្រើនជាងរវាងដប់ប្រាំពាន់ដុល្លារ ($15,000) ~~ពីរពាន់ដុល្លារ ($2,000) សម្រាប់ការរំលោភបំពាននីមួយៗ~~ ដែលត្រូវបានកែសម្រួលជារៀងរាល់ឆ្នាំ ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរនៅក្នុងសន្ទស្សន៍តម្លៃទំនិញប្រើប្រាស់ ឬបីដងនៃចំនួនទឹកប្រាក់ដែលបុគ្គលនោះបានរាយការណ៍មិនត្រឹមត្រូវ ឬបានបរិច្ចាគ ចំណាយ ផ្តល់ ឬទទួលដោយខុសច្បាប់ ។

មាត្រា 6. ផ្នែករង (b) នៃមាត្រា 514 នៃធម្មនុញ្ញនៃទីក្រុង Los Angeles ពាក់ព័ន្ធនឹងការផ្ទេរអំណាចរបស់នាយកដ្ឋាន ការិយាល័យ និងក្រុមប្រឹក្សា ត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោម ៖

(b) **ការលើកលែង** ។ អំណាចរបស់ចៅហ្វាយក្រុង និងក្រុមប្រឹក្សាក្នុងការអនុវត្តដូចមានចែងក្នុងមាត្រានេះ មិនត្រូវអនុវត្តចំពោះ៖

(1) ការិយាល័យជាប់ឆ្នោត

(2) នាយកដ្ឋានកម្មសិទ្ធិ

(3) ប្រព័ន្ធចូលនិវត្តន៍របស់និយោជិតទីក្រុង Los Angeles

(4) នាយកដ្ឋានប្រាក់សោធននិវត្តន៍របស់ប៉ូលិស និងពន្លត់អគ្គីភ័យ

(5) គណៈកម្មការសីលធម៌ទីក្រុង

(6) មុខងារផ្នែកវិនិយោគរបស់ក្រសួងពន្លត់អគ្គិភ័យ និងនាយកដ្ឋានប៉ូលិស ដូចដែលមានចែងក្នុងមាត្រា 1060 និង 1070 និង

(7) នាយកដ្ឋានប៉ូលីស និងក្រសួងពន្លត់អគ្គិភ័យ ប្រសិនបើការផ្ទេរ ឬការរួមបញ្ចូលគ្នានឹងធ្វើឱ្យមានការផ្លាស់ប្តូរ ឬប៉ះពាល់យ៉ាងខ្លាំងដល់គោលបំណងចម្បងរ~~ួមសកម្ម~~ភ~~ណ~~ៈនៃនាយកដ្ឋានទាំងនោះ ។

(8) គណៈកម្មការចែកជាតំបន់ឡើងវិញឯករាជ្យ ។

មាត្រា 7. មាត្រា 523 នៃធម្មនុញ្ញនៃទីក្រុង Los Angeles ពាក់ព័ន្ធនឹងអ្នកវាយតម្លៃឯករាជ្យរបស់ក្រសួងពន្លត់អគ្គិភ័យ ត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោម ៖

មាត្រា 523. អ្នកវាយតម្លៃឯករាជ្យ ។

អ្នកវាយតម្លៃឯករាជ្យ ត្រូវរាយការណ៍ជូនគណៈកម្មការស្នងការអគ្គិភ័យ ហើយត្រូវមានសិទ្ធិចូលប្រើប្រាស់ព័ត៌មានរបស់ក្រសួងពន្លត់អគ្គិភ័យដូចគ្នានឹងគណៈកម្មការស្នងការអគ្គិភ័យដែរ ។ អ្នកវាយតម្លៃឯករាជ្យ ត្រូវមានអំណាច និងភារកិច្ចក្នុងការ ៖

(a) ក្រោមច្បាប់ដែលត្រូវបានបង្កើតឡើងដោយគណៈកម្មការស្នងការអគ្គីភ័យ ត្រូវធ្វើសវនកម្ម វាយតម្លៃ និងពិនិត្យឡើងវិញនូវការដោះស្រាយរបស់នាយកដ្ឋានពន្លត់អគ្គីភ័យលើបណ្តឹងអំពីការប្រព្រឹត្តខុសដែលប្រព្រឹត្តដោយនិយោជិតរបស់ក្រសួងពន្លត់អគ្គិភ័យ មិនថាជាមន្ត្រីដែលបានស្បថចូលកាន់តំណែង ឬនិយោជិតស៊ីវិល

(b) ធ្វើសវនកម្ម ឬការវាយតម្លៃណាមួយដែលបានស្នើសុំដោយសំឡេងឆ្នោតភាគច្រើនរបស់គណៈកម្មការ

(c) ផ្ទួចផ្តើមការវាយតម្លៃ ឬសវនកម្មណាមួយលើក្រសួងពន្លត់អគ្គីភ័យ ឬផ្នែកណាមួយនៃក្រសួងពន្លត់អគ្គីភ័យ ដោយមានការជូនដំណឹងជាមុនដល់គណៈកម្មការស្នងការអគ្គីភ័យ ~~និងស្ថិតក្រោមសិទ្ធិអំណាចរបស់គណៈកម្មការគាមរយៈសំឡេងឆ្នោតភាគច្រើន ដើម្បីណែនាំអ្នកវាយតម្លៃឯករាជ្យមិនឱ្យចាប់ផ្តើម ឬបន្តការវាយតម្លៃ ឬសវនកម្ម~~

(d) ជូនដំណឹងដល់គណៈកម្មការអំពីស្ថានភាពនៃការវាយតម្លៃ និងសវនកម្មទាំងអស់ដែលកំពុងដំណើរការ និង

(e) តែងតាំង បញ្ឈប់ពីការងារ ដាក់វិន័យ ផ្ទេរ និងចេញសេចក្តីណែនាំដល់និយោជិតដែលស្ថិតក្រោមការដឹកនាំរបស់ខ្លួន ។

មាត្រា 8. មាត្រា 573 នៃធម្មនុញ្ញនៃទីក្រុង Los Angeles ពាក់ព័ន្ធនឹងអគ្គមន្ត្រីអធិការកិច្ចនៃក្រសួងប៉ូលិស ត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោម ៖

មាត្រា 573. អគ្គមន្ត្រីអធិការកិច្ច ។

អគ្គមន្ត្រីអធិការកិច្ច ត្រូវរាយការណ៍ជូនគណៈកម្មការស្នងការប៉ូលិស ហើយត្រូវមានសិទ្ធិចូលប្រើប្រាស់ព័ត៌មានរបស់ក្រសួងប៉ូលិសដូចគ្នានឹងគណៈកម្មការស្នងការប៉ូលិសដែរ ។ អគ្គមន្ត្រីអធិការកិច្ច ត្រូវមានអំណាច និងភារកិច្ចក្នុងការ ៖

(a) ក្រោមវិធានដែលត្រូវបានបង្កើតឡើងដោយគណៈកម្មការស្នងការប៉ូលិស ត្រូវធ្វើសវនកម្ម ស៊ើបអង្កេត និងត្រួតពិនិត្យការដោះស្រាយរបស់ក្រសួងប៉ូលិសលើបណ្តឹងអំពីការប្រព្រឹត្តខុសដោយមន្ត្រីប៉ូលិស និងនិយោជិតស៊ីវិល ហើយបំពេញការកិច្ចផ្សេងទៀតតាមដែលអាចត្រូវបានប្រគល់ដោយគណៈកម្មការ

(b) ធ្វើសវនកម្ម ឬការស៊ើបអង្កេតណាមួយដែលបានស្នើសុំដោយសំឡេងឆ្នោតភាគច្រើនរបស់គណៈកម្មការ

(c) ផ្តួចផ្តើមការស៊ើបអង្កេត ឬសវនកម្មណាមួយលើក្រសួងប៉ូលិស ដោយគ្មានការអនុញ្ញាតជាមុនពីគណៈកម្មការ~~ស្នងការប៉ូលិស ដោយស្ថិតក្រោមសិទ្ធិអំណាចរបស់គណៈកម្មការតាមរយៈសំឡេងឆ្នោតភាគច្រើន ដើម្បីណែនាំអគ្គមន្ត្រីអធិការកិច្ចមិនឱ្យចាប់ផ្តើម ឬបន្តការស៊ើបអង្កេត ឬសវនកម្ម~~

(d) ជូនដំណឹងដល់គណៈកម្មការអំពីស្ថានភាពនៃការស៊ើបអង្កេត និងសវនកម្មទាំងអស់ដែលកំពុងដំណើរការ និង

(e) តែងតាំង បញ្ឈប់ពីការងារ ដាក់វិន័យ ផ្ទេរ និងចេញសេចក្តីណែនាំដល់និយោជិតដែលស្ថិតក្រោមការដឹកនាំរបស់ខ្លួន ។

មាត្រា 9. ផ្នែករង (d) នៃមាត្រា 700 នៃធម្មនុញ្ញនៃទីក្រុង Los Angeles ពាក់ព័ន្ធនឹងគណៈកម្មការសីលធម៌ទីក្រុងត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោម ៖

(d) **គុណសម្បត្តិ ។** សមាជិកគណៈកម្មការម្នាក់ៗត្រូវតែជាអ្នកបោះឆ្នោតដែលបានចុះឈ្មោះរបស់ទីក្រុង។ <u>សមាជិក ឬអតីតសមាជិកនៃគណៈកម្មការ មិនត្រូវជាបេក្ខជនសម្រាប់តំណែងណាមួយរបស់ទីក្រុង ឬតំណែងក្នុងគណៈកម្មការអប់រំមណ្ឌលសិក្សាធិការរួបរួម Los Angeles ឡើយ លុះត្រាតែការបោះឆ្នោតសម្រាប់តំណែងនោះត្រូវធ្វើឡើងយ៉ាងហោចណាស់ប្រាំឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទចុងក្រោយនៃការបំពេញតួនាទីរបស់សមាជិកគណៈកម្មការ ។ នាយកប្រតិបត្តិ ឬអតីតនាយកប្រតិបត្តិនៃគណៈកម្មការ មិនត្រូវជាបេក្ខជនសម្រាប់តំណែងសាលាក្រុងណាមួយ ឬតំណែងគណៈកម្មការអប់រំនៃមណ្ឌលសិក្សាធិការរួបរួម Los Angeles ឡើយ លើកលែងតែការបោះឆ្នោតសម្រាប់តំណែងនោះ នឹងត្រូវរៀបចំឡើងយ៉ាងហោចណាស់ប្រាំឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទនៃការបម្រើការងារចុងក្រោយរបស់នាយកប្រតិបត្តិ ។ ~~ទាំងសមាជិកនៃគណៈកម្មការ ទាំងនាយកប្រតិបត្តិរបស់ខ្លួន មិនត្រូវស្វែងរកការបោះឆ្នោតសម្រាប់តំណែងសាលាក្រុង ឬតំណែងគណៈកម្មការអប់រំនៃមណ្ឌលសិក្សាធិការរួបរួម Los Angeles ណាមួយ ដែលគណៈកម្មការបានធ្វើការសម្រេចចិត្តពាក់ព័ន្ធក្នុងអំឡុងពេលអាណត្តិរបស់ស្នងការ ឬនាយកប្រតិបត្តិនោះទេ លើកលែងតែការបោះឆ្នោតសម្រាប់តំណែងនោះ នឹងត្រូវរៀបចំឡើងយ៉ាងហោចណាស់ពីរឆ្នាំ បន្ទាប់ពីការផុតកំណត់អាណត្តិក្នុងតំណែងរបស់ស្នងការ ឬនាយកប្រតិបត្តិ ។~~ ក្នុងអំឡុងពេលកាន់តំណែងរបស់ពួកគេ ទាំងសមាជិកគណៈកម្មការ ទាំងនាយកប្រតិបត្តិរបស់ខ្លួន មិនត្រូវ ៖</u>

(1) កាន់តំណែងសាធារណៈផ្សេងទៀតណាមួយឡើយ

(2) ចូលរួម ឬផ្តល់វិភាគទានដល់យុទ្ធនាការបោះឆ្នោតសាលាក្រុង

(3) ចូលរួម ឬផ្តល់វិភាគទានដល់យុទ្ធនាការបោះឆ្នោត សម្រាប់សមាជិកនៃគណៈកម្មការអប់រំនៃមណ្ឌលសិក្សាធិការរួបរួម Los Angeles

(4) ចូលរួម ឬផ្តល់វិភាគទានដល់មន្ត្រីសាលាក្រុង ឬសមាជិកនៃគណៈកម្មការអប់រំនៃមណ្ឌលសិក្សាធិការរួបរួម Los Angeles ដែលឈរឈ្មោះសម្រាប់មុខតំណែងជាប់ឆ្នោតណាមួយ

(5) ជួល ឬត្រូវបានគេជួលជាបុគ្គលដែលតម្រូវឱ្យចុះឈ្មោះជាអ្នកបញ្ជុះបញ្ចូលជាមួយទីក្រុង Los Angeles

(6) មានចំណែកកម្មសិទ្ធិនៅក្នុងអាជីវកម្ម (ក្រៅពីភាគហ៊ុននៅក្នុងក្រុមហ៊ុនដែលជួញដូរជាសាធារណៈ) ដែលចុះកិច្ចសន្យាជាមួយ ឬស្វែងរកការអនុម័តដោយឆន្ទានុសិទ្ធិពីទីក្រុង ឬផ្តល់សេវាកម្មដែលមានសំណងដោយផ្ទាល់ដល់ទីក្រុង ក្រោមកិច្ចសន្យាណាមួយ

(7) ផ្តល់ដំបូន្មាន ឬសេវាកម្មដែលមានសំណង ដល់យុទ្ធនាការនយោបាយ ឬដល់គណៈកម្មការមួយដែលគ្រប់គ្រងដោយអ្នកកាន់តំណែងសាលាក្រុង ឬ

(8) ផ្តល់វិភាគទានដល់គណៈកម្មការនានា ដែលធ្វើឱ្យបុគ្គលនោះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាម្ចាស់ជំនួយធំ ដូចមានចែងនៅក្រោមច្បាប់កែទម្រង់នយោបាយ ។

មាត្រា 10. វិសោធនកម្មដែលបានធ្វើឡើងចំពោះផ្នែករង (d) នៃមាត្រា 700 នៃធម្មនុញ្ញនៃទីក្រុង Los Angeles ត្រូវអនុវត្តតែចំពោះសមាជិក ឬនាយកប្រតិបត្តិនៃគណៈកម្មការសីលធម៌ទីក្រុង ដែលកាលបរិច្ឆេទនៃការបម្រើការងារទីក្រុងចុងក្រោយរបស់ខ្លួន គឺនៅចំថ្ងៃ ឬក្រោយកាលបរិច្ឆេទចូលជាធរមាននៃវិសោធនកម្មធម្មនុញ្ញនេះ ។

មាត្រា 11. មាត្រា 900 ដល់ 914 នៃធម្មនុញ្ញនៃទីក្រុង Los Angeles ពាក់ព័ន្ធនឹងក្រុមប្រឹក្សាសង្កាត់ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖

មាត្រា 900. គោលបំណង ។

ដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាជន~~ពលរដ្ឋ~~ក្នុងរដ្ឋាភិបាលឱ្យកាន់តែច្រើន និងធ្វើឱ្យរដ្ឋាភិបាលកាន់តែមានការឆ្លើយតបទៅនឹងតម្រូវការមូលដ្ឋាន ប្រព័ន្ធទូទាំងក្រុងនៃក្រុមប្រឹក្សា សង្កាត់ និងនាយកដ្ឋានពង្រឹងអំណាចសង្កាត់ត្រូវបានបង្កើតឡើង ។ ក្រុមប្រឹក្សា សង្កាត់ត្រូវរួមបញ្ចូលអ្នកតំណាងនៃអត្ថប្រយោជន៍ចម្រុះជាច្រើននៅក្នុងសហគមន៍នានា ហើយត្រូវមានតួនាទីផ្តល់ឱវាទលើបញ្ហាដែលជាក្តីព្រួយបារម្ភដល់សង្កាត់ ។

មាត្រា 901. នាយកដ្ឋានពង្រឹងអំណាចសង្កាត់

នាយកដ្ឋានពង្រឹងអំណាចសង្កាត់ត្រូវមានភារកិច្ច និងការទទួលខុសត្រូវដែលមានចែងក្នុងមាត្រានេះ និងនៅកន្លែងផ្សេងទៀតក្នុងធម្មនុញ្ញ ដើម្បីអនុវត្ត និងត្រួតពិនិត្យបទបញ្ញត្ត និងបទបញ្ជាដែលបង្កើតប្រព័ន្ធនៃ ក្រុមប្រឹក្សាសង្កាត់ ដែលបានអនុម័តដោយអនុលោមតាមមាត្រា 905 ។ ភារកិច្ច និងការទទួលខុសត្រូវត្រូវរួមមាន ៖

(a) រៀបចំផែនការសម្រាប់ការបង្កើតប្រព័ន្ធនៃ-ក្រុមប្រឹក្សា-សង្កាត់ដើម្បីធានាថាគ្រប់ផ្នែកទាំងអស់នៃទីក្រុង គឺស្ថិតនៅក្នុងព្រំប្រទល់នៃ -ក្រុមប្រឹក្សាសង្កាត់ ហើយមានឱកាសដើម្បីបង្កើត-ក្រុមប្រឹក្សាសង្កាត់ (ផែនការ)

(b) ជួយសង្កាត់នានាក្នុងការរៀបចំញត្តិសម្រាប់ការទទួលស្គាល់ ឬការបញ្ជាក់ ការកំណត់ព្រំប្រទល់ដែលមិនបំបែកសហគមន៍នានា និងការរៀបចំចាត់ចែងខ្លួនពួកគេ ស្របតាមផែនការ

(c) រៀបចំកិច្ចប្រជុំសមាជនៃសង្កាត់ ប្រសិនបើមានការស្នើសុំឱ្យធ្វើដូច្នេះដោយ ក្រុមប្រឹក្សា-សង្កាត់

(d) ជួយក្រុមប្រឹក្សា-សង្កាត់ជាមួយនឹងការបោះឆ្នោត ឬការជ្រើសរើ<u>សសមាជិក</u> <u>គណៈកម្មការ</u> ~~មន្ត្រី~~<u>មន្ត្រី</u>របស់ពួកគេ

(e) រៀបចំការបណ្តុះបណ្តាលសម្រាប់មន្ត្រី និងបុគ្គលិករបស់ ក្រុមប្រឹក្សាសង្កាត់

(f) ជួយ-ក្រុមប្រឹក្សា-សង្កាត់ដើម្បីចែករំលែកធនធាន រួមទាំងការិយាល័យ ឧបករណ៍ និងទម្រង់នៃការគាំទ្រផ្សេងៗទៀត សម្រាប់ពួកគេដើម្បីទំនាក់ទំនងជាមួយអ្នកបោះឆ្នោតក្នុងមណ្ឌល ជាមួយក្រុមប្រឹក្សា-សង្កាត់ផ្សេងទៀត និងជាមួយមន្ត្រីរដ្ឋាភិបាល និង

(g) អនុវត្តការកិច្ចផ្សេងទៀត ដូចដែលបានផ្តល់ជូនដោយបទបញ្ញត្ត។

មាត្រា 902. ក្រុមប្រឹក្សាគណៈកម្មការសង្កាត់។

(a) ត្រូវមានគណៈកម្មការមួយដែលមានស្នងការប្រាំពីររូប ដែលត្រូវបានគេស្គាល់ថាជា ក្រុមប្រឹក្សាគណៈកម្មការសង្កាត់ (គណៈកម្មការ) ។ ស្នងការត្រូវតែតាំងដោយចៅហ្វាយក្រុង ហើយត្រូវមកពីតំបន់ភូមិសាស្ត្រចម្រុះ ដូចដែលបានបញ្ជាក់បន្ថែមដោយបទបញ្ញត្ត ។ ការតែងតាំង និងការដកតំណែងស្នងការ ត្រូវអនុលោមតាមមាត្រា 502 ។

(b) គណៈកម្មការត្រូវទទួលខុសត្រូវលើការកំណត់គោលនយោបាយ និងការត្រួតពិនិត្យគោលនយោបាយ រួមទាំងការអនុម័តលើកិច្ចសន្យា និងកិច្ចសន្យាជួល និងការប្រកាសឱ្យប្រើប្រាស់នូវវិធាន និងបទបញ្ជា ប៉ុន្តែមិនត្រូវទទួលខុសត្រូវលើការគ្រប់គ្រងប្រចាំថ្ងៃឡើយ ។

(c) គណៈកម្មការត្រូវប្រតិបត្តិការស្របតាមមាត្រា 503 ដល់ 508 និង 510 នៃធម្មនុញ្ញ ។

មាត្រា 903. នាយកគ្រប់គ្រងទូទៅ ។

(a) ត្រូវមាននាយកគ្រប់គ្រងទូទៅមួយរូបនៃនាយកដ្ឋានពង្រឹងអំណាចសង្កាត់ ដែលត្រូវតែងតាំងដោយ ចៅហ្វាយក្រុង ក្រោមការយល់ព្រមពីក្រុមប្រឹក្សាទីក្រុង ហើយអាចត្រូវបានដកតំណែងដូចមានចែងក្នុងមាត្រា 508។

(b) នាយកគ្រប់គ្រងទូទៅត្រូវមានអំណាច និងភារកិច្ចដូចមានចែងក្នុងមាត្រា 510។

(c) នាយកគ្រប់គ្រងទូទៅត្រូវតែងតាំង បញ្ឈប់ និងកំណត់ភារកិច្ចរបស់បុគ្គលិក ស្របតាមបទប្បញ្ញត្តិសេវាស៊ីវិលនៃ ធម្មនុញ្ញ។

មាត្រា 904. ការអភិវឌ្ឍ<u>និងការថែរក្សា</u>ផែនការក្រុមប្រឹក្សាសង្កាត់។

នាយកដ្ឋានពង្រឹងអំណាចសង្កាត់ត្រូវបង្កើតផែនការមួយសម្រាប់ប្រព័ន្ធទូទាំងក្រុងនៃ-ក្រុមប្រឹក្សា-សង្កាត់ដោយ អនុលោមតាមចំណុចដូចខាងក្រោម ៖

(a) នាយកដ្ឋានពង្រឹងអំណាចសង្កាត់ត្រូវស្វែងរកមតិយោបល់សាធារណៈក្នុងការបង្កើតផែនការនេះ ។

(b) ផែនការត្រូវមានសេចក្តីថ្លែងការណ៍អំពីគោលដៅ គោលនយោបាយ និងវត្ថុបំណងនៃប្រព័ន្ធក្រុមប្រឹក្សាសង្កាត់ ហើយត្រូវមានបទបញ្ជាជាក់លាក់ ក្នុងទម្រង់ជាសេចក្តីព្រាងបទបញ្ញត្តិ (បទបញ្ជា) ដែលប្រសិនបើត្រូវបានអនុម័តដោយបទ បញ្ញត្តិ នោះវានឹងមានភាពគ្រប់គ្រាន់ដើម្បីអនុវត្តផែនការនេះ ។

(c) បទបញ្ជាត្រូវបង្កើតវិធីសាស្ត្រដែលព្រំប្រទល់នៃ-ក្រុមប្រឹក្សា-សង្កាត់នឹងត្រូវបានកំណត់ ។ ប្រព័ន្ធសម្រាប់កំណត់ ព្រំប្រទល់ត្រូវរក្សាព្រំប្រទល់សង្កាត់ដល់កម្រិតអតិបរមាដែលអាចធ្វើទៅបាន ហើយអាចពិចារណាលើព្រំប្រទល់មណ្ឌលផែនការ សហគមន៍ ក្នុងករណីដែលសមស្រប ។

(d) បទបញ្ជាត្រូវធានាថាគ្រប់តំបន់ទាំងអស់នៃទីក្រុង ត្រូវបានផ្តល់ឱកាសស្មើៗគ្នា ដើម្បីបង្កើតក្រុមប្រឹក្សាសង្កាត់ ។

(e) បទបញ្ជាត្រូវបង្កើតនីតិវិធី និងលក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលស្គាល់ ឬការបញ្ជាក់នៃ-ក្រុមប្រឹក្សា-សង្កាត់ ។

(f) បទបញ្ជាមិនត្រូវរឹតត្បិតវិធីសាស្ត្រដែលសមាជិកនៃ-ក្រុមប្រឹក្សាសង្កាត់ត្រូវបានជ្រើសរើសនោះទេ ប្រសិនបើ ដំណើរការនេះបំពេញតាមតម្រូវការនៃមាត្រានេះ ។

(g) បទបញ្ជាត្រូវតម្រូវឱ្យ-ក្រុមប្រឹក្សាសង្កាត់អនុម័តនីតិវិធីដោយយុត្តិធម៌ និងបើកចំហ សម្រាប់ការដឹកនាំកិច្ចការ របស់ពួកគេ។

(h) ចៅហ្វាយក្រុង និងក្រុមប្រឹក្សា<u>ទីក្រុង</u>ត្រូវគាំទ្រការបង្កើតនាយកដ្ឋានពង្រឹងអំណាចសង្កាត់ និងការតែងតាំង នាយកគ្រប់គ្រងទូទៅ ក្នុងរយៈពេល 120 ថ្ងៃ នៃកាលបរិច្ឆេទចូលជាធរមាននៃមាត្រានេះ។

មាត្រា 905. ការ<u>អនុវត្ត</u>ដ<u>ំ</u>ប<u>ូ</u>ង<u>នៃ</u>ផែនការ ។

នាយកដ្ឋានពង្រឹងអំណាចសង្កាត់ត្រូវបញ្ចប់ការអភិវឌ្ឍផែនការ ហើយបង្ហាញផែនការ និងបទបញ្ជាចាំបាច់ ទាំងអស់សម្រាប់ប្រព័ន្ធក្រុមប្រឹក្សាសង្កាត់ជូនដល់ក្រុមប្រឹក្សាក្រុង និងចៅហ្វាយក្រុងក្នុងរយៈពេលមួយឆ្នាំ បន្ទាប់ពីការបង្កើត ក្រសួង និងគណៈកម្មការ ។ ក្រុមប្រឹក្សាក្រុងត្រូវពិចារណាលើបទបញ្ជា ហើយក្នុងរយៈពេលប្រាំមួយខែ បន្ទាប់ពីការបង្ហាញ ផែនការដល់ក្រុមប្រឹក្សាក្រុងអាចអនុម័តបទបញ្ញត្តិ ដើម្បីអនុវត្តបទបញ្ជាដូចដែលបានស្នើឡើង ឬដូចដែលបានកែប្រែដោយក្រុម ប្រឹក្សាក្រុងស្របតាមតម្រូវការនៃផែនការដែលមានចែងក្នុងមាត្រា 904 ។ ប្រសិនបើបទបញ្ញត្តិសម្រាប់អនុវត្តមិនត្រូវបានអនុម័ត

ក្នុងអំឡុងពេលនេះទេ បទបញ្ជានឹងចូលជាធរមាន ហើយក្នុងកម្រិតដែលមិនផ្ទុយនឹងច្បាប់ វានឹងត្រូវអនុវត្តជាកាតព្វកិច្ចលើរាល់ក្រសួង និងការិយាល័យទាំងអស់របស់សាលាក្រុង។

មាត្រា 906. ការបញ្ជាក់នៃក្រុមប្រឹក្សាសង្កាត់។

(a) **លក្ខន្តិក:** រាល់ក្រុមប្រឹក្សាសង្កាត់ មួយៗ ដែលស្វែងរកការបញ្ជាក់ ឬការទទួលស្គាល់ជាផ្លូវការពីសាលាក្រុង ត្រូវដាក់ជូននូវផែនការរៀបចំ និងលក្ខន្តិក:ទៅនាយកដ្ឋានពង្រឹងអំណាចសង្កាត់ដោយបង្ហាញយ៉ាងហោចណាស់នូវ ៖

(1) វិធីសាស្ត្រដែលសមាជិកគណ:កម្មការ~~មន្ត្រី~~របស់ពួកគេត្រូវបានជ្រើសរើស

(2) សមាជិកភាពនៃក្រុមប្រឹក្សាសង្កាត់នឹងត្រូវបានបើកចំហសម្រាប់អ្នកពាក់ព័ន្ធទាំងអស់ ដូចដែលបានកំណត់ដោយបទបញ្ញត្តិ~~អ្នកគ្រប់គ្នាដែលរស់នៅ ធ្វើការ ឬជាម្ចាស់កម្មសិទ្ធិទ្រព្យសម្បត្តិនៅក្នុងតំបន់នោះ (អ្នកពាក់ព័ន្ធ)~~

(3) ការធានាថាសមាជិកនៃក្រុមប្រឹក្សាសង្កាត់នឹងឆ្លុះបញ្ចាំងពីអត្ថប្រយោជន៍ចម្រុះនៅក្នុងតំបន់របស់ពួកគេ

(4) ប្រព័ន្ធមួយដែលក្រុមប្រឹក្សាសង្កាត់នឹងទាក់ទងជាមួយអ្នកពាក់ព័ន្ធជាប្រចាំ

(5) ប្រព័ន្ធសម្រាប់គណនេយ្យភាពហិរញ្ញវត្ថុនៃមូលនិធិរបស់ខ្លួន និង

(6) ការធានាថារាល់កិច្ចប្រជុំទាំងអស់នឹងត្រូវបើកចំហ និងជាសាធារណ: ហើយអនុញ្ញាតឱ្យអ្នកពាក់ព័ន្ធគ្រប់រូបចូលរួមក្នុងការប្រព្រឹត្តកិច្ចការ ការពិភាក្សា និងការសម្រេចចិត្ត ក្នុងកម្រិតដែលអាចធ្វើទៅបាន។

(b) **ការដាក់ញត្តិសុំការបញ្ជាក់ និងការអនុម័ត ។** ក្រុមប្រឹក្សាសង្កាត់អាចដាក់ញត្តិសុំការបញ្ជាក់ ឬការទទួលស្គាល់ ស្របតាមវិធាន និងនីតិវិធីដែលមានចែងនៅក្នុងផែនការ។

មាត្រា 907. <u>សេចក្តីជូនដំណឹងជាមុន និងឱកាសសម្រាប់មតិយោបល់ ~~ប្រព័ន្ធព្រមានជាមុន~~</u> ។

បទប្បញ្ញត្តិនេះត្រូវបង្កើតនីតិវិធីសម្រាប់ការទទួលធាតុចូលពីក្រុមប្រឹក្សាសង្កាត់ មុនពេលការសម្រេចចិត្តដោយក្រុមប្រឹក្សាក្រុង គណ:កម្មការរបស់ក្រុមប្រឹក្សាក្រុងនិងគណ:កម្មាធិការគ្រប់គ្រងរបស់ក្រុមប្រឹក្សា និងស្នងការ ។ នីតិវិធីត្រូវរួមបញ្ចូលជាអាទ៍ទាំង សេចក្តីជូនដំណឹងដល់ក្រុមប្រឹក្សាសង្កាត់ឱ្យបានឆាប់តាមដែលអាចអនុវត្តបាន និងឱកាសសមហេតុផលក្នុងការផ្តល់ធាតុចូលមុនពេលការសម្រេចចិត្តត្រូវបានធ្វើឡើង ។ សេចក្តីជូនដំណឹងដែលត្រូវផ្តល់ជូនរួមមានបញ្ហាដែលត្រូវពិចារណាដោយក្រុមប្រឹក្សាក្រុង គណ:កម្មការរបស់ក្រុមប្រឹក្សាក្រុង និងគណ:កម្មាធិការគ្រប់គ្រងរបស់ក្រុមប្រឹក្សា ឬស្នងការ។

មាត្រា 908. អំណាចនៃក្រុមប្រឹក្សាសង្កាត់ ។

ដោយអាស្រ័យលើច្បាប់ជាធរមាន ក្រុមប្រឹក្សាក្រុងអាចផ្ទេរសិទ្ធិអំណាចរបស់ខ្លួនទៅឱ្យក្រុមប្រឹក្សាសង្កាត់ ដើម្បីធ្វើសវនាការជាសាធារណ: មុនពេលក្រុមប្រឹក្សាក្រុងធ្វើការសម្រេចចិត្តលើបញ្ហាការព្រួយបារម្ភក្នុងតំបន់។

មាត្រា 909. អាទិភាពថវិកាសាលាក្រុងប្រចាំឆ្នាំ ។

ក្រុមប្រឹក្សាសង្កាត់នីមួយៗអាចបង្ហាញដល់ចៅហ្វាយក្រុង និងក្រុមប្រឹក្សាក្រុង នូវបញ្ជីអាទិភាពប្រចាំឆ្នាំសម្រាប់ថវិកាក្រុង។ ចៅហ្វាយក្រុងត្រូវជូនដំណឹងដល់ក្រុមប្រឹក្សាសង្កាត់ដែលបានបញ្ជាក់អំពីកាលបរិច្ឆេទកំណត់សម្រាប់ការដាក់ស្នើ ដូច្នេះការបញ្ចូលអាចត្រូវបានពិចារណាក្នុងលក្ខណ:ទាន់ពេលវេលា។

មាត្រា 910. ការត្រួតពិនិត្យសេវាកម្មទីក្រុង ។

ក្រុមប្រឹក្សាសង្កាត់ត្រូវត្រួតពិនិត្យការផ្តល់សេវាកម្មទីក្រុងនៅក្នុងតំបន់ទទួលខុសត្រូវរៀងៗខ្លួន និងមានកិច្ចប្រជុំជាទៀងទាត់ជាមួយមន្ត្រីទទួលខុសត្រូវពីនាយកដ្ឋានទីក្រុង ដោយអាស្រ័យលើលទ្ធភាពជួបប្រជុំបានដោយសមហេតុផលរបស់ពួកគេ។

មាត្រា 911. ការប្រើប្រាស់កញ្ចប់ថវិកា ។

ចៅហ្វាយក្រុង និងក្រុមប្រឹក្សាក្រុងត្រូវផ្តល់ថវិកាឱ្យបានសមស្របសម្រាប់នាយកដ្ឋានពង្រឹងអំណាចសង្កាត់ និងការចាប់ផ្តើម និងដំណើរការរបស់ ក្រុមប្រឹក្សាសង្កាត់ សម្រាប់រយៈពេលពីរឆ្នាំដំបូងបន្ទាប់ពីកាលបរិច្ឆេទចូលជាធរមាននៃមាត្រានេះ ។ ថវិកានេះនឹងត្រូវបែងចែកទៅជាថវិកាពិសេសមួយ ដែលត្រូវបង្កើតឡើងដោយបទបញ្ញត្តិ ។ បន្ទាប់មក ចៅហ្វាយក្រុង និងក្រុមប្រឹក្សាក្រុងត្រូវផ្តល់ថវិកាសមស្របសម្រាប់នាយកដ្ឋាន និងក្រុមប្រឹក្សាសង្កាត់យ៉ាងហោចណាស់មួយឆ្នាំមុននៃឆ្នាំសារពើពន្ធនីមួយៗជាបន្តបន្ទាប់។

មាត្រា 912. ការត្រួតពិនិត្យ ។

ចៅហ្វាយក្រុង និងក្រុមប្រឹក្សាក្រុងត្រូវតែងតាំងស្នងការដូចដែលបានកំណត់ដោយបទប្បញ្ញត្តិ ដើម្បីវាយតម្លៃបទប្បញ្ញត្តិនៃមាត្រានេះ បទប្បញ្ញត្តិដែលបានអនុម័តដោយអនុលោមតាមមាត្រានេះ និងប្រសិទ្ធភាពនៃប្រព័ន្ធក្រុមប្រឹក្សាសង្កាត់មិនលើសពីប្រាំពីរឆ្នាំបន្ទាប់ពីការអនុម័តធម្មនុញ្ញនេះ។ ស្នងការត្រូវផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាក្រុងទាក់ទងនឹងការផ្លាស់ប្តូរធម្មនុញ្ញ ឬបទប្បញ្ញត្តិ តាមដែលខ្លួនយល់ថាសមស្រប។

មាត្រា 913. ផ្ទេរអំណាច ។

ទោះបីជាមានបទប្បញ្ញត្តិផ្សេងទៀតណាមួយនៃធម្មនុញ្ញនេះក៏ដោយ ក៏ចៅហ្វាយក្រុង និងក្រុមប្រឹក្សាក្រុងមិនត្រូវផ្ទេរអំណាច ភារកិច្ច ឬមុខងាររបស់នាយកដ្ឋានពង្រឹងអំណាចសង្កាត់ទៅនាយកដ្ឋាន ការិយាល័យ ឬទីភ្នាក់ងារផ្សេងទៀតដោយអនុលោមតាមមាត្រា 514 ក្នុងអំឡុងពេលប្រាំឆ្នាំដំបូងបន្ទាប់ពីការអនុវត្តផែនការដោយអនុលោមតាមមាត្រា 905 នោះទេ។

មាត្រា 914. ប្រសិទ្ធភាពនៃបទបញ្ញត្តិ ។

ក្រុមប្រឹក្សាក្រុងអាចអនុម័តបទបញ្ញត្តិដែលទាក់ទងនឹងក្រុមប្រឹក្សាសង្កាត់ ស្របតាមតម្រូវការសម្រាប់ផែនការដែលមានចែងក្នុងមាត្រា 904 នៅពេលណាក៏បាន ដែលបទបញ្ញត្តិទាំងនោះនឹងជំនួសបទបញ្ញត្តិមិនស៊ីសង្វាក់គ្នាណាមួយដែលបានចូលជាធរមានដោយអនុលោមតាមមាត្រា 905។

មាត្រា 12. សុពលភាពដាច់ដោយឡែក ។ ប្រសិនបើមាត្រា ផ្នែករង ខ ចែង ប្រយោគ ឃ្លា ឬការអនុវត្តនៃវិសោធនកម្មធម្មនុញ្ញនេះ ឬផ្នែកណាមួយនៃវិសោធនកម្មនេះ ត្រូវបានតុលាការ ឬសាលាជម្រះក្តីដែលមានយុត្តាធិការ និងដែនមានសមត្ថកិច្ចសម្រេចថាមិនស្របតាមរដ្ឋធម្មនុញ្ញ ឬមិនមានសុពលភាព នោះមាត្រា ផ្នែករង ខ ចែង ប្រយោគ ឃ្លា ផ្នែក ឬការអនុវត្តវិសោធនកម្មធម្មនុញ្ញដែលនៅសល់ត្រូវបន្តនៅមាន និងមានប្រសិទ្ធភាពពេញលេញ ហើយគិតដល់ចំណុចនេះ លក្ខខណ្ឌនៃវិសោធនកម្មធម្មនុញ្ញនេះគឺអាចបំបែកចេញពីគ្នាបាន ។ លើសពីនេះ អ្នកបោះឆ្នោតប្រកាសថាពួកគេនឹងអនុម័តតាល់មាត្រា ផ្នែករង ខ ចែង ប្រយោគ ឃ្លា ផ្នែក និងការអនុវត្តនៃវិសោធនកម្មធម្មនុញ្ញនេះដោយគ្មានមាត្រា ផ្នែករង ខ ចែង ប្រយោគ ឃ្លា ផ្នែក ឬការអនុវត្តដែលត្រូវបានសម្រេចថាមិនស្របតាមរដ្ឋធម្មនុញ្ញ ឬមិនមានសុពលភាពនោះឡើយ ។

PRK ថវិកានាយកដ្ឋានកម្សាន្ត និងសួនច្បារទីក្រុង។ វិសោធនកម្មធម្មនុញ្ញ PRK។

តើធម្មនុញ្ញក្រុងគួរត្រូវបានធ្វើវិសោធនកម្មដើម្បីបង្កើនថវិកាអប្បបរមាដែលបានបម្រុងទុកសម្រាប់នាយកដ្ឋានកម្សាន្ត និងសួនច្បារ ដោយធ្វើជាដំណាក់កាលក្នុងរយៈពេលដប់ឆ្នាំ រហូតដល់វាមានចំនួនទ្វេដងនៃកញ្ចប់ថវិកាអប្បបរមាបច្ចុប្បន្ន ដោយមានការលើកលែងសម្រាប់ភាពអាសន្នផ្នែកសារពើពន្ធដែរឬទេ?

សេចក្តីសង្ខេបតតលម្ងៀង
ដោយ SHARON M. TSO ប្រធានអ្នកវិភាគនិតិបញ្ញត្តិ

មូលនិធិទូទៅជាមូលនិធិប្រតិបត្តិការចម្បងរបស់ទីក្រុង។ ចំណូលពីមូលនិធិទូទៅត្រូវបានប្រើប្រាស់ដើម្បីផ្តល់ហិរញ្ញប្បទានដល់សេវាកម្មក្រុងដូចជា ប៉ូលីស ការពន្លត់អគ្គីភ័យ សាធារណការ ដឹកជញ្ជូន បណ្ណាល័យ និងឧទ្យាន។ ចំណូលមូលនិធិទូទៅបានមកពីពន្ធ អាជ្ញាបណ្ណ លិខិតអនុញ្ញាត ថ្លៃសេវា ពិន័យ និងប្រភពផ្សេងៗទៀត។

ធម្មនុញ្ញក្រុងកំណត់ការបែងចែកថវិកាអប្បបរមាសម្រាប់នាយកដ្ឋានកម្សាន្ត និងឧទ្យានពីមូលនិធិទូទៅ។ ថវិកាអប្បបរមានោះគឺជាចំនួនទឹកប្រាក់ស្មើនឹង 0.0325% នៃតម្លៃដែលបានវាយតម្លៃនៃអចលនទ្រព្យទាំងអស់ ដែលត្រូវបានវាយតម្លៃសម្រាប់ពន្ធទីក្រុង។ អត្រាភាគរយនៃការបែងចែកធម្មនុញ្ញក្រុងបច្ចុប្បន្ន និងការបែងចែកថវិកាដែលជាលទ្ធផលមិនបានតាមទាន់កំណើនប្រជាជន ការពង្រីកប្រព័ន្ធឧទ្យាន និងការកើនឡើងនៃថ្លៃថែទាំ និងប្រតិបត្តិការនោះទេ។ ការធ្វើបែបនេះបានរួមចំណែកដល់ការថយចុះនៃសេវាកម្មកម្សាន្ត និងឧទ្យានតាមពេលវេលា។

ក្នុងឆ្នាំ 1996 អ្នកបោះឆ្នោតនៃទីក្រុងបានអនុម័តសំណើ K: LA សម្រាប់កម្មវិធីកុមារ (សំណើ K) ដែលបានបង្កើតការវាយតម្លៃទូទាំងទីក្រុងដែលបានបង្កើត $25 លានដុល្លារជារៀងរាល់ឆ្នាំសម្រាប់ការទទួលបាន ការអភិវឌ្ឍន៍ ការកែលម្អ និងការស្តារឡើងវិញនូវឧទ្យាន និងកន្លែងកម្សាន្ត។ កម្មវិធីសំណើ K នឹងផុតកំណត់ក្នុងឆ្នាំសារពើពន្ធ 2026-27 ហើយនឹងបណ្តាលឱ្យបាត់បង់មូលនិធិសម្រាប់គាំទ្រឧទ្យាន និងកន្លែងកម្សាន្ត។

វិធានការនេះនឹងបង្កើនចំនួនទឹកប្រាក់អប្បបរមានៃថវិកាទូទៅដែលត្រូវបានបែងចែកទៅឱ្យកន្លែងកម្សាន្ត និងឧទ្យាន។ ធនធានបន្ថែមទាំងនេះនឹងជួយស្តារកម្រិតសេវាកម្មកម្សាន្ត និងឧទ្យានឡើងវិញ ដោះស្រាយគម្លាតសមធម៌ឧទ្យាន និងអនុញ្ញាតឱ្យក្រសួងរ៉ាប់រងថ្លៃដើមប្រតិបត្តិការ និងកម្មវិធីនានា។ ភាគរយនេះនឹងកើនឡើងជាលំដាប់ពី 0.0325% បច្ចុប្បន្នដល់ 0.065% នៃតម្លៃវាយតម្លៃនៃអចលនទ្រព្យទាំងអស់ ដែលត្រូវបានវាយតម្លៃសម្រាប់ពន្ធក្រុង ដែលបែងចែកជាដំណាក់កាលក្នុងរយៈពេលដប់ឆ្នាំ ដូចខាងក្រោម៖

- ឆ្នាំសារពើពន្ធ 2026-2027 និងមុនៗ៖ 0.0325%
- ឆ្នាំសារពើពន្ធ 2027-2028៖ 0.03575%
- ឆ្នាំសារពើពន្ធ 2028-2029៖ 0.039%
- ឆ្នាំសារពើពន្ធ 2029-2030៖ 0.04225%
- ឆ្នាំសារពើពន្ធ 2030-2031៖ 0.0455%
- ឆ្នាំសារពើពន្ធ 2031-2032៖ 0.04875%
- ឆ្នាំសារពើពន្ធ 2032-2033៖ 0.052%
- ឆ្នាំសារពើពន្ធ 2033-2034៖ 0.05525%
- ឆ្នាំសារពើពន្ធ 2034-2035៖ 0.0585%
- ឆ្នាំសារពើពន្ធ 2035-2036៖ 0.06175%
- ឆ្នាំសារពើពន្ធ 2036-2037 និងជាបន្តបន្ទាប់៖ 0.065%

វិធានការនេះនឹងមិនបង្កើតពន្ធថ្មី ឬបង្កើតប្រាក់ចំណូលបន្ថែមរបស់ទីក្រុងទេ។ វានឹងតម្រូវឱ្យមានថវិកាមូលនិធិទូទៅបន្ថែមទៀតដើម្បីផ្តល់ជូនដល់កន្លែងកម្សាន្ត និងឧទ្យាន។ ជាលទ្ធផល បរិមាណចំណូលមូលនិធិទូទៅដែលមានសម្រាប់សេវាកម្មផ្សេងទៀតរបស់ក្រុងនឹងត្រូវបានកាត់បន្ថយ។

ក្នុងអំឡុងពេលនៃគ្រាអាសន្នសារពើពន្ធដែលបានប្រកាស ក្រុមប្រឹក្សាក្រុងអាចកាត់បន្ថយថវិកាដែលបានកើនឡើងដែលត្រូវការនៅក្នុងវិធានការនេះរហូតដល់ 30 ភាគរយសម្រាប់រយៈពេលនៃភាពអាសន្នសារពើពន្ធ។ ទោះជាយ៉ាងណាក៏ដោយ ការបែងចែកថវិកាអប្បបរមារបស់ផ្នែកកម្សាន្ត និងឧទ្យានមិនអាចកាត់បន្ថយឱ្យនៅក្រោមកម្រិតបច្ចុប្បន្ន 0.0325% នៃតម្លៃវាយតម្លៃនៃអចលនទ្រព្យទាំងអស់ដែលបានវាយតម្លៃសម្រាប់ពន្ធទីក្រុងបានទេ។

វិធានការនេះនឹងមានប្រសិទ្ធភាព ប្រសិនបើត្រូវបានយល់ព្រមដោយអ្នកបោះឆ្នោតភាគច្រើន។

របាយការណ៍ផលប៉ះពាល់ហិរញ្ញវត្ថុ
ដោយ MATTHEW W. SZABO មន្ត្រីរដ្ឋបាលទីក្រុង

វិធានការនេះបង្កើនទ្វេដងនូវការបែងចែកដោយផ្អែកលើតម្លៃទ្រព្យសម្បត្តិរបស់ក្រសួងកម្សាន្ត និងឧទ្យាន (RAP) ពី 0.0325 ដល់ 0.065 ភាគរយក្នុងរយៈពេលដប់ឆ្នាំ។ ដោយសន្មតថាតម្លៃអចលនទ្រព្យមានកំណើនជាមធ្យម មូលនិធិរបស់ RAP នឹងកើនឡើងពី $303 លានដុល្លារដល់ $995 លានដុល្លារនៅឆ្នាំ 2036-37 ដោយការកើនឡើងប្រចាំឆ្នាំដែលបានប៉ាន់ប្រមាណថាបណ្តាលមកពីវិធានការដូចខាងក្រោម៖ 2027-28 ($32 លានដុល្លារ), 2028-29 ($66 លានដុល្លារ), 2029-30 ($105 លានដុល្លារ), 2030-31 ($147 លានដុល្លារ), 2031-32 ($193 លានដុល្លារ), 2032-33 ($244 លានដុល្លារ), 2033-34 ($299 លានដុល្លារ), 2034-35 ($359 លានដុល្លារ), 2035-36 ($426 លានដុល្លារ), និង 2036-37 ($497 លានដុល្លារ)។ ការកើនឡើងទាំងអស់ក្នុងអំឡុងពេលនេះគឺអាស្រ័យលើកំណើនតម្លៃអចលនទ្រព្យដែលបានវាយតម្លៃជាក់ស្តែង។

ដោយសារតែវិធានការនេះមិនបង្កើនប្រាក់ចំណូលថ្មី ក្រុងត្រូវតែរៀបចំធនធានឡើងវិញពីសេវាកម្មផ្សេងទៀត រួមទាំងសុវត្ថិភាពសាធារណៈ ការងារសាធារណៈ និងសេវាកម្មជនអនាថា ដើម្បីបំពេញតាមអាណត្តិផ្តល់មូលនិធិដែលបានកើនឡើង។ សាលាក្រុងអាចផ្អាកការដំឡើងថ្លៃដែលបានកំណត់ក្នុងអំឡុងពេលមានអាសន្នផ្នែកហិរញ្ញវត្ថុដែលបានប្រកាស។ RAP នៅតែទទួលខុសត្រូវក្នុងការសងប្រាក់វិញដល់មូលនិធិទូទៅសម្រាប់អត្ថប្រយោជន៍និយោជិត និងការចំណាយពាក់ព័ន្ធផ្សេងទៀត។

សេចក្តីអះអាងគាំទ្រនៃវិសោធនកម្មធម្មនុញ្ញ PRK

វិសោធនកម្មធម្មនុញ្ញ PRK នឹងថែរក្សាសួនច្បារ ប្រភពទឹក និងឆ្នេរសមុទ្ររបស់យើងឱ្យមានអនាម័យស្អាតបាត, ជួសជុល និងថែទាំសម្ភារៈបរិក្ខារក្នុងសួន, ព្រមទាំងបើកដំណើរការមជ្ឈមណ្ឌលកម្សាន្ត និងមជ្ឈមណ្ឌលមនុស្សចាស់ ដោយមិនដំឡើងពន្ធសូម្បីតែមួយសេនឡើយ។

នាយកដ្ឋានសួនច្បាររបស់ LA គ្រប់គ្រងសួនច្បារជាង 500 កន្លែង, មជ្ឈមណ្ឌលកម្សាន្ត និងមជ្ឈមណ្ឌលមនុស្សចាស់ចំនួន 123 កន្លែង និងអាងហែលទឹកចំនួន 52 កន្លែង។ ទីទាំងនេះគឺជាកន្លែងដែលមានតម្លៃសមរម្យសម្រាប់កុមារក្នុងការលេងកីឡា និងមានសុវត្ថិភាពបន្ទាប់ពីវ៉ែលម៉ោងសិក្សា និងនាដកាលវិស្សមកាលរដូវក្តៅ ជាកន្លែងសម្រាប់មនុស្សចាស់ស្វែងរកសេវាផ្សេងៗ និងជាកន្លែងសម្រាប់គ្រួសារជួបជុំគ្នា។ សួនច្បារ និងមជ្ឈមណ្ឌលកម្សាន្ត គឺជាកន្លែងរៀបចំកម្មវិធីអន្តរាគមន៍ទប់ស្កាត់អំពើហិង្សា ព្រមទាំងផ្តល់សេវាកម្ម និងជម្រកបណ្តោះអាសន្ន ក្នុងអំឡុងពេលមានអគ្គិភ័យឆេះព្រៃ និងគ្រោះអាសន្នផ្សេងៗ។

សួនច្បាររបស់ LA បានធ្លាក់ចុះមកចំណាត់ថ្នាក់ទី 93 ក្នុងចំណោមទីក្រុងធំបំផុតទាំង 100 របស់អាមេរិក នៅក្នុងការវាយតម្លៃ ParkScore ឆ្នាំ 2026 របស់អង្គការ Trust for Public Land។ ការវាយតម្លៃលើសួនច្បាររបស់ក្រុងបានរកឃើញថា LA ផ្តល់ថវិកាលើសួនច្បារតិចជាងទីក្រុងស្រដៀងគ្នានានាដល់ទៅពីរភាគបី។ ការកាត់បន្ថយបុគ្គលិកយ៉ាងច្រើន បានធ្វើឱ្យសួនច្បារកាត់បន្ថយសុវត្ថិភាព និងអនាម័យ។ សម្ភារៈបរិក្ខារនានាត្រូវការថវិកាជិត $3 ពាន់លាន សម្រាប់ការជួសជុល ហើយអាងហែលទឹក មជ្ឈមណ្ឌលកម្សាន្ត និងមជ្ឈមណ្ឌលមនុស្សចាស់ ត្រូវបានកាត់បន្ថយម៉ោងប្រតិបត្តិការ។ ប្រសិនបើគ្មានសកម្មភាពដោះស្រាយទេ កន្លែងបន្ថែមទៀតអាចនឹងត្រូវបិទទ្វារ។ មួយភាគបីនៃប្រជាជន Angelenos មិនមានសួនច្បារនៅជិតផ្ទះក្នុងចម្ងាយដើរដប់នាទីនោះទេ។

សួនច្បារគឺជាសេវាដ៏សំខាន់បំផុតសម្រាប់ប្រជាជន Angelenos។

ថវិកាការពារសម្រាប់សួនច្បារមិនត្រូវបានដំឡើងឡើយចាប់តាំងពីឆ្នាំ 1937 ហើយថវិកាដែលហូរដោយផ្ទាល់ទៅកាន់សួនច្បារត្រូវបានកាត់បន្ថយបន្ថែមទៀតចាប់តាំងពីឆ្នាំ 2009។

PRK បង្កើនថវិកាសួនច្បារក្នុងរយៈពេលជាង 10 ឆ្នាំ ដោយមានការការពារសម្រាប់ស្ថានភាពអាសន្នផ្ទៃកហិរញ្ញវត្ថុ។

PRK នឹងធ្វើឱ្យសួនច្បារ បន្ទប់ទឹក អាងហែលទឹក និងសម្ភារៈបរិក្ខារនានា មានអនាម័យ និងភាពល្អប្រសើរឡើង, កសាងកម្លាំងពលកម្មសួនច្បារ និងឆ្នាំសួនឡើងវិញ, ការពារឆ្នេរសមុទ្រ និងផ្ទៃទឹកតំបន់ឆ្នេរ, កសាងសួនច្បារថ្មីនៅកន្លែងដែលត្រូវការ, ស្តារតំបន់ធម្មជាតិឡើងវិញ ព្រមទាំងវិនិយោគលើដើមឈើផ្តល់មម្លប់ ការទប់ស្កាត់អគ្គិភ័យឆេះព្រៃ និងដំណោះស្រាយផ្អែកលើធម្មជាតិ ដើម្បីការពារប្រភពទឹករបស់យើង។

វាថែរក្សាអាងហែលទឹក មជ្ឈមណ្ឌលកម្សាន្ត និងមជ្ឈមណ្ឌលមនុស្សចាស់ឱ្យនៅបើកទ្វារដំណើរការ និងធ្វើឱ្យសួនសាលារៀនក្នុងសហគមន៍មានសកម្មភាពរស់រវើក។

ការផ្តល់ថវិកានេះទាមទារឱ្យមានគណនេយ្យភាពហិរញ្ញវត្ថុយ៉ាងម៉ឹងម៉ាត់ ហើយត្រូវតែប្រើប្រាស់សម្រាប់តែគោលបំណងសួនច្បារដែលស្របច្បាប់ប៉ុណ្ណោះ ដោយមានផែនការចំណាយ និងរបាយការណ៍ប្រចាំឆ្នាំ ត្រូវបានពិនិត្យឡើងវិញនៅក្នុងកិច្ចប្រជុំសាធារណៈ និងផ្សព្វផ្សាយតាមអ៊ីនធឺណិត។

សូមចូលរួមជាមួយថ្នាក់ដឹកនាំសហគមន៍ និងបរិស្ថាន ដើម្បីបោះឆ្នោតគាំទ្រលើ PRK ដើម្បីកែលម្អសួនច្បារដោយមិនចាំបាច់ដំឡើងពន្ធ។

បុគ្គលដែលចុះហត្ថលេខាលើសេចក្តីអះអាងគាំទ្រនៃវិសោធនកម្មធម្មនុញ្ញ PRK

MONICA RODRIGUEZ
សមាជិកក្រុមប្រឹក្សាភិបាល
City of Los Angeles

YSABEL JURADO
សមាជិកក្រុមប្រឹក្សាភិបាល
City of Los Angeles

IMELDA PADILLA
សមាជិកក្រុមប្រឹក្សាភិបាល
City of Los Angeles

KENNETH MEJIA
អ្នកគ្រប់គ្រង
City of Los Angeles

លោកឌីពុក GREGORY BOYLE
ស្ថាបនិក
Homeboy Industries

TEFARAI BAYNE
ស្នងការ
LA Department of Recreation and Parks

BRUCE SAITO
ស្ថាបនិក
Conservation and Youth Workforce
អ្នកដឹកនាំការអភិវឌ្ឍ

NICOLE CHASE
ប្រធាន និងជានាយកប្រតិបត្តិ
Boys & Girls Club of San Fernando Valley

TORI KJER
នាយកប្រតិបត្តិ
LA Neighborhood Land Trust

BRUCE REZNIK
នាយកប្រតិបត្តិ
LA Waterkeeper

គ្មានសេចក្តីអះអាងប្រឆាំងវិធានការនេះត្រូវបានដាក់ជូនទេ ។

សេចក្តីអះអាងដែលបានបោះពុម្ព គឺជាមតិរបស់អ្នកនិពន្ធ ហើយមិនត្រូវបានត្រួតពិនិត្យភាពត្រឹមត្រូវដោយទីភ្នាក់ងារក្រុងណាមួយឡើយ ។ លើសពីនេះ មុខតំណែងនៅក្រោមឈ្មោះអ្នកចុះហត្ថលេខា គឺសម្រាប់គោលបំណងកំណត់អត្តសញ្ញាណតែប៉ុណ្ណោះ ហើយមិនបង្ហាញថាបុគ្គលនោះកំពុងចុះហត្ថលេខាក្នុងនាមអង្គការនោះទេ ។

អំណះអំណាងបដិសេធចំពោះវិសោធនកម្មច្បាប់ធម្មនុញ្ញ PRK

វិសោធនកម្មធម្មនុញ្ញ PRK គឺជាការវិនិយោគប្រកបដោយការទទួលខុសត្រូវនៅក្នុងឧទ្យាន ដោយមិនដំឡើងពន្ធ។ ក្នុងរយៈពេល 10 ឆ្នាំ, PRK នឹងបង្កើនមូលនិធិដែលបានកំណត់ទុកសម្រាប់ឧទ្យាន ខណៈពេលដែលតម្រូវឱ្យមានការទទួលខុសត្រូវយ៉ាងតឹងរ៉ឹងចំពោះរាល់ប្រាក់ដុល្លារដែលបានចំណាយ។

ឧទ្យានគឺជាការវិនិយោគដ៏ល្អ។

ឧទ្យានជួយប្រជាជន Los Angeles មានសុខភាពល្អ សកម្ម និងមានទំនាក់ទំនងគ្នា។ ភាពអសកម្មផ្នែករាងកាយមានចំនួន 12.6% នៃការចំណាយលើការថែទាំសុខភាព។ ការស្រាវជ្រាវបង្ហាញថា សហគមន៍ដែលវិនិយោគលើឧទ្យានមានអត្រាទាបនៃជំងឺដាច់សរសៃឈាមខួរក្បាល ជំងឺបេះដូង ភាពធាត់ និងជំងឺទឹកនោមផ្អែម។ រាល់ការចំណាយ $1 ដុល្លារលើកម្មវិធីឧទ្យានទាបជាងការចំណាយលើការថែទាំសុខភាពចំនួន $11 ដុល្លារ។

លើសពីនេះ រាល់ការចំណាយ $1 ដុល្លារសម្រាប់ការថែទាំឧទ្យាន នឹងទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ចយ៉ាងទូលំទូលាយយ៉ាងហោចណាស់ $3 ដុល្លារ។ វិស័យទេសចរណ៍បានបង្កើតការចំណាយចំនួន $35.1 ពាន់លានដុល្លារកាលពីឆ្នាំមុននៅ Los Angeles ដោយគាំទ្រដល់ការងារជាង 224,000 កន្លែង។ ឧទ្យានក្នុងទីក្រុងចំនួនពីរ Griffith Park និង Venice Beach គឺជាការទាក់ទាញដ៏ធំបំផុតរបស់យើង។

PRK នឹងបង្កើតការងារល្អៗក្នុងស្រុក កែលម្អសុខភាពសាធារណៈ: ថែរក្សាកន្លែងលេងរបស់កុមារឱ្យមានសុវត្ថិភាព បើកមជ្ឈមណ្ឌលកម្សាន្ត និងមជ្ឈមណ្ឌលសម្រាប់មនុស្សចាស់ឡើងវិញទាំងស្រុង រក្សាឆ្នេរឱ្យស្អាត និងជួសជុលបង្គន់ទូទាំងទីក្រុង។

សូមបោះឆ្នោតគាំទ្រលើ PRK។

បុគ្គលដែលចុះហត្ថលេខាលើសេចក្តីអំណះអំណាងបដិសេធចំពោះវិសោធនកម្មច្បាប់ធម្មនុញ្ញ PRK

MONICA RODRIGUEZ
សមាជិកាក្រុមប្រឹក្សាទីក្រុង LA

IMELDA PADILLA
សមាជិកក្រុមប្រឹក្សាទីក្រុង LA

YSABEL JURADO
សមាជិកក្រុមប្រឹក្សាទីក្រុង LA

KENNETH MEJIA
អ្នកគ្រប់គ្រងទីក្រុង LA

LUIS A SANCHEZ
ប្រធាន
LA Rec and Parks Board of Commissioners

JIMMY KIM
នាយកគ្រប់គ្រងទូទៅ
LA Department of Recreation and Parks

JON CHRISTENSEN
សាស្ត្រាចារ្យជំនួយក្រៅម៉ោង
UCLA

AMBER MARTINEZ
ប្រធាន និងជានាយកប្រតិបត្តិ
Los Angeles Parks Foundation

DEBORAH COHEN, MD, MPH
សុខភាពសាធារណៈ និងវេជ្ជសាស្ត្របង្ការ

MONA FIELD
អតីតប្រធាន
Greater Los Angeles League of Women Voters

សេចក្តីអះអាងដែលបានបោះពុម្ព គឺជាមតិរបស់អ្នកនិពន្ធ ហើយមិនត្រូវបានត្រួតពិនិត្យភាពត្រឹមត្រូវដោយទីភ្នាក់ងារក្រុងណាមួយឡើយ ។ លើសពីនេះ មុខតំណែងនៅក្រោមឈ្មោះអ្នកចុះហត្ថលេខា គឺសម្រាប់គោលបំណងកំណត់អត្តសញ្ញាណតែប៉ុណ្ណោះ ហើយមិនបង្ហាញថាបុគ្គលនោះកំពុងចុះហត្ថលេខាក្នុងនាមអង្គការនោះទេ ។

វិសោធនកម្មធម្មនុញ្ញ PRK
(ថវិកានាយកដ្ឋានកម្សាន្តនិងឧទ្យានទីក្រុង)

អត្ថបទនៃវិធានការសន្ធឹកឆ្នោតដែលបានស្នើឡើង

ផ្នែកទី 1. ផ្នែកទី 593 នៃធម្មនុញ្ញទីក្រុង Los Angeles ត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោម៖

ផ្នែកទី 593. ការគាំទ្រផ្នែកហិរញ្ញវត្ថុ។

(a) សម្រាប់ការគាំទ្រផ្នែកហិរញ្ញវត្ថុរបស់នាយកដ្ឋានកម្សាន្តនិងឧទ្យាន នឹងត្រូវបែងចែកចំនួនទឹកប្រាក់ប្រចាំឆ្នាំមិនកិចជាងភាគរយដូចខាងក្រោម ~~0.0325%~~ នៃតម្លៃដែលបានវាយតម្លៃនៃអចលនទ្រព្យទាំងអស់ដែលត្រូវបានវាយតម្លៃសម្រាប់កំណត់ពន្ធរបស់ទីក្រុង~~៖~~។

សារពើពន្ធ ឆ្នាំ 2026-2027 និងមុនៗ៖ 0.0325%
សារពើពន្ធ ឆ្នាំ 2027-2028៖ 0.03575%
សារពើពន្ធ ឆ្នាំ 2028-2029៖ 0.039%
សារពើពន្ធ ឆ្នាំ 2029-2030៖ 0.04225%
សារពើពន្ធ ឆ្នាំ 2030-2031៖ 0.0455%
សារពើពន្ធ ឆ្នាំ 2031-2032៖ 0.04875%
សារពើពន្ធ ឆ្នាំ 2032-2033៖ 0.052%
សារពើពន្ធ ឆ្នាំ 2033-2034៖ 0.05525%
សារពើពន្ធ ឆ្នាំ 2034-2035៖ 0.0585%
សារពើពន្ធ ឆ្នាំ 2035-2036៖ 0.06175%
សារពើពន្ធ ឆ្នាំ 2036-2037 និងបន្តបន្ទាប់៖ 0.065%

(b) អាចនឹងមានការបែងចែកបន្ថែមពីមូលនិធិទូទៅ។

(c) ប្រាក់ទាំងអស់ដែលទទួលបានពី (a) ឬ (b) បូករួមទាំងចំនួនទឹកប្រាក់ផ្សេងទៀតទាំងអស់ដែលនាយកដ្ឋានទទួលបាន នឹងត្រូវដាក់បញ្ចូលទៅក្នុងឥណទានរបស់មូលនិធិកម្សាន្តនិងឧទ្យាន។

(d) លើកលែងតែមានចែងក្នុងផ្នែកទី 342 ទាក់ទងនឹងមូលនិធិដែលបានបែងចែកពីមូលនិធិទូទៅទៅមូលនិធិកម្សាន្តនិងឧទ្យាន ប្រាក់នៅក្នុងមូលនិធិកម្សាន្តនិងឧទ្យាននឹងត្រូវប្រើប្រាស់សម្រាប់តែការគាំទ្រផ្នែកហិរញ្ញវត្ថុរបស់នាយកដ្ឋានកម្សាន្តនិងឧទ្យានប៉ុណ្ណោះ។

(e) ក្នុងករណីដែលក្រុមប្រឹក្សាទីក្រុង តាមរយៈការបោះឆ្នោតពីរភាគបី ប្រកាសពីភាពអាសន្នផ្នែកហិរញ្ញវត្ថុដោយសេចក្តីសម្រេច ការគាំទ្រផ្នែកហិរញ្ញវត្ថុដែលត្រូវបានតម្រូវក្រោមកថាភាគ (a) អាចត្រូវបានកាត់បន្ថយត្រឹមរហូតដល់សាមសិបភាគរយ (30%) នៃចំនួនសរុបនៃភាគរយដែលបានបញ្ជាក់នៃតម្លៃវាយតម្លៃនៃទ្រព្យសម្បត្តិទាំងអស់ដែលត្រូវបានវាយតម្លៃសម្រាប់កំណត់ពន្ធរបស់ទីក្រុង ក្រោយពីការប្រកាសបែបនេះ ហើយការកាត់បន្ថយបែបនេះអាចនៅតែមានប្រសិទ្ធភាពរហូតដល់ការផុតកំណត់នៃភាពអាសន្នផ្នែកហិរញ្ញវត្ថុនេះ ដរាបណាការកាត់បន្ថយបែបនេះមិនបន្ថយការគាំទ្រផ្នែកហិរញ្ញវត្ថុសរុបដែលតម្រូវផ្សេងពីនេះដោយកថាភាគ (a) ឱ្យទាបជាង 0.0325% នៃតម្លៃវាយតម្លៃនៃទ្រព្យសម្បត្តិទាំងអស់ដែលត្រូវបានវាយតម្លៃសម្រាប់កំណត់ពន្ធរបស់ទីក្រុងឡើយ។

ផ្នែកទី 2. ភាពអាចបំបែកបាន. ប្រសិនបើផ្នែក កថាភាគ ខចែង ប្រយោគ ឃ្លា ឬការអនុវត្តនៃវិសោធនកម្មធម្មនុញ្ញនេះ ឬផ្នែកណាមួយនៃវិសោធនកម្មនេះ ត្រូវបានតុលាការឬសាលាជម្រះក្តីនៃដែនយុត្តាធិការដែលមានសមត្ថកិច្ចសម្រេចថា មិនស្របតាមរដ្ឋធម្មនុញ្ញ ឬមិនមានសុពលភាព នោះផ្នែក កថាភាគ ខចែង ប្រយោគ ឃ្លា ផ្នែក ឬការអនុវត្តវិសោធនកម្មធម្មនុញ្ញដែលនៅសល់ត្រូវបន្តនៅមាននិងមានប្រសិទ្ធភាពពេញលេញ ហើយគិតដល់ចំណុចនេះ លក្ខខណ្ឌនៃវិសោធនកម្មធម្មនុញ្ញនេះគឺអាចបំបែកចេញពីគ្នាបាន។ លើសពីនេះ អ្នកបោះឆ្នោតប្រកាសថា ពួកគេនឹងអនុម័តរាល់ផ្នែក កថាភាគ ខចែង ប្រយោគ ឃ្លា ផ្នែក និងការអនុវត្តនៃវិសោធនកម្មធម្មនុញ្ញនេះ ដោយគ្មានផ្នែក កថាភាគ ខចែង ប្រយោគ ឃ្លា ផ្នែក ឬការអនុវត្តដែលត្រូវបានសម្រេចថា មិនស្របតាមរដ្ឋធម្មនុញ្ញ ឬមិនមានសុពលភាពនោះទេ។

PRT នាយកដ្ឋានអាកាសយានដ្ឋាន កំពង់ផែ និងទឹក និងអគ្គិសនីទីក្រុង។ វិសោធនកម្មធម្មនុញ្ញ PRT។

តើធម្មនុញ្ញក្រុងគួរត្រូវបានធ្វើវិសោធនកម្មដើម្បី៖ តម្រូវឱ្យនាយកដ្ឋានកំពង់ផែបែងចែកមូលនិធិសម្រាប់គម្រោងច្រកចូលសាធារណៈនៅតាមមាត់ទឹក តម្រូវឱ្យមានការបង្ហាញពីផលប៉ះពាល់កម្លាំងពលកម្មសម្រាប់កិច្ចសន្យាជួល និងកិច្ចព្រមព្រៀងនាយកដ្ឋានកំពង់ផែមួយចំនួន បង្កើនរយៈពេលអតិបរមាសម្រាប់កិច្ចសន្យាជួលមួយចំនួន និងផ្លាស់ប្តូរតម្រូវការសមាសភាពសម្រាប់គណៈកម្មការអាកាសយានដ្ឋានដែរឬទេ?

សេចក្តីសង្ខេបឥតលម្អៀង
ដោយ SHARON M. TSO ប្រធានអ្នកវិភាគនិតិបញ្ញត្តិ

មាត្រា 607 នៃធម្មនុញ្ញក្រុង ដាក់កម្រិតលើសិទ្ធិផ្តាច់មុខ សម្បទាន លិខិតអនុញ្ញាត អាជ្ញាបណ្ណ និងកិច្ចសន្យាជួលសម្រាប់នាយកដ្ឋានកម្មសិទ្ធិនីមួយៗ (នាយកដ្ឋានអាកាសយានដ្ឋាន នាយកដ្ឋានកំពង់ផែ និងនាយកដ្ឋានទឹក និងថាមពល)។ មាត្រា 607(a) ចែងថា ក្រុមប្រឹក្សាក្រុងអាចអនុញ្ញាតឱ្យមានកិច្ចសន្យាជួលរហូតដល់ 50 ឆ្នាំសម្រាប់នាយកដ្ឋានអាកាសយានដ្ឋាន និងនាយកដ្ឋានកែច្នៃទឹក និងថាមពល និង 66 ឆ្នាំសម្រាប់នាយកដ្ឋានកំពង់ផែ។

មាត្រា 630 នៃធម្មនុញ្ញក្រុង ចែងថា ក្រុមប្រឹក្សាកិបាលនៃគណៈកម្មការអាកាសយានដ្ឋានត្រូវមានសមាជិកប្រាំពីរនាក់ ហើយសមាជិកម្នាក់ត្រូវរស់នៅក្នុងតំបន់ជុំវិញអាកាសយានដ្ឋានអន្តរជាតិ Los Angeles និងសមាជិកម្នាក់ត្រូវរស់នៅក្នុងតំបន់ជុំវិញអាកាសយានដ្ឋាន Van Nuys។ តំបន់ទាំងនេះត្រូវបានកំណត់ដោយអនុក្រឹត្យ។

មាត្រា 651 នៃធម្មនុញ្ញក្រុង ចែងថា ក្រុមប្រឹក្សាកិបាលនៃគណៈកម្មការស្នងការកំពង់ផត្រូវមានកម្មសិទ្ធិ ការគ្រប់គ្រង និងការត្រួតពិនិត្យទ្រព្យសម្បត្តិរបស់នាយកដ្ឋានកំពង់ផែ។ នេះបញ្ជាក់បន្ថែមទៀតថា ដីធ្លី និងដែនទឹកដែលស្ថិតនៅក្រោមការកាន់កាប់ ការគ្រប់គ្រង និងការត្រួតពិនិត្យរបស់គណៈកម្មការស្នងការកំពង់ផ នឹងត្រូវបានគេស្គាល់ថាជាមណ្ឌលកំពង់ផែ។ មាត្រា 651 នៃធម្មនុញ្ញក្រុងក៏រក្សាផ្នែកខាងមុខទឹកសម្រាប់ការប្រើប្រាស់ជាសាធារណៈ និងហាមឃាត់ការលក់ដីជំនោរ និងដីលិចទឹកនៃមណ្ឌលកំពង់ផែ។ មាត្រា 652 នៃធម្មនុញ្ញក្រុង ចែងអំពីអំណាច និងកាតព្វកិច្ចរបស់គណៈកម្មការស្នងការកំពង់ផែ រួមទាំងអំណាច និងកាតព្វកិច្ចក្នុងការបង្កើតច្បាប់ និងបទប្បញ្ញត្តិទាក់ទងនឹងមណ្ឌលកំពង់ផែ។

ច្បាប់ដូតម្រូវឱ្យមានលិខិតអនុញ្ញាតអភិវឌ្ឍន៍ឆ្នេរសមុទ្រសម្រាប់ការអភិវឌ្ឍជាច្រើននៅក្នុងមណ្ឌលកំពង់ផែ។ វារួមបញ្ចូលទាំងគម្រោងសាងសង់ និងគម្រោងដែលបង្កើន ឬផ្លាស់ប្តូរកម្រិត ឬប្រភេទសកម្មភាពនៅលើទីតាំង ឬក្នុងទឹក ឬដែលផ្លាស់ប្តូរការចូលទៅកាន់វារបស់សាធារណជន ទោះបីជាគ្មានអ្វីត្រូវបានសាងសង់ក៏ដោយ។

វិធានការនេះនឹងកែប្រែធម្មនុញ្ញក្រុងដើម្បី៖

- អនុញ្ញាតឱ្យក្រុមប្រឹក្សាក្រុងអនុញ្ញាតឱ្យនាយកដ្ឋានអាកាសយានដ្ឋាន និងនាយកដ្ឋានធនធានទឹក និងថាមពលជួលរយៈពេលរហូតដល់ 66 ឆ្នាំ ឬរយៈពេលអតិបរមាដែលត្រូវបានអនុញ្ញាតដោយច្បាប់សហព័ន្ធ ឬរដ្ឋណាមួយ អាស្រ័យលើចំនួនណាដែលតិចជាង ប្រសិនបើក្រុមប្រឹក្សាក្រុងធ្វើការរកឃើញថា រយៈពេលលើសពី 30 ឆ្នាំនឹងស្ថិតនៅក្នុងផលប្រយោជន៍ល្អបំផុតរបស់ទីក្រុង។ ធម្មនុញ្ញក្រុងអនុញ្ញាតឱ្យក្រុមប្រឹក្សាក្រុងអនុញ្ញាតឱ្យមានការជួលពីនាយកដ្ឋានកំពង់ផែសម្រាប់រយៈពេលរហូតដល់ 66 ឆ្នាំ។
- បង្កើនតម្រូវការស្នាក់នៅក្នុងតំបន់សម្រាប់ក្រុមប្រឹក្សាកិបាលអាកាសយានដ្ឋាន ដោយទាមទារឱ្យសមាជិកបីនាក់ក្នុងចំណោមសមាជិកទាំងប្រាំពីរនាក់នៃក្រុមប្រឹក្សាកិបាលអាកាសយានដ្ឋានរស់នៅក្នុងតំបន់ជុំវិញអាកាសយានដ្ឋានអន្តរជាតិ Los Angeles និងសមាជិកពីរនាក់ក្នុងចំណោមសមាជិកទាំងប្រាំពីរនាក់រស់នៅ

ក្នុងតំបន់ជុំវិញអាកាសយានដ្ឋាន Van Nuys។ វិធានការនេះក៏នឹងអនុញ្ញាតឱ្យក្រុមប្រឹក្សាក្រុង តាមរយៈបទបញ្ញា បែងចែកតំបន់ទាំងនេះបន្ថែមទៀតទៅជាតំបន់រង និងបង្កើតតម្រូវការស្នាក់នៅរបស់ស្នងការ។

- គណៈកម្មការស្នងការកំពង់ផែ ត្រូវបែងចែកភាគរយនៃប្រាក់ចំណូលប្រតិបត្តិការរបស់នាយកដ្ឋានកំពង់ផែប្រចាំឆ្នាំ ដើម្បីវិនិយោគលើគម្រោងចូលប្រើប្រាស់ជាសាធារណៈនៅតំបន់ឆ្នេរ និងគម្រោង និងកម្មវិធីបម្រើសាធារណៈផ្សេងទៀតដែលបានអភិវឌ្ឍដោយមានមតិយោបល់ពីសាធារណជន ជាផ្នែកនៃផែនការវិនិយោគសម្រាប់ការចូលប្រើប្រាស់ជាសាធារណៈ។ គណៈកម្មការស្នងការកំពង់ផែនឹងមានសិទ្ធិអំណាចតែមួយគត់ក្នុងការកំណត់ចំនួនទឹកប្រាក់ដែលត្រូវបែងចែកជារៀងរាល់ឆ្នាំ។
- តម្រូវឱ្យបេក្ខជនទាំងអស់ដែលស្វែងរកការយល់ព្រមលើកិច្ចសន្យាជួល ការបន្តកិច្ចសន្យាជួល ឬវិសោធនកម្មកិច្ចសន្យាជួល ឬការអភិវឌ្ឍអចលនទ្រព្យណាមួយដែលបានស្នើឡើងនៅក្នុងមណ្ឌលកំពង់ផែ ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតអភិវឌ្ឍន៍ឆ្នេរសមុទ្រ ត្រូវដាក់ជូនការបង្ហាញព័ត៌មានអំពីផលប៉ះពាល់កម្លាំងពលកម្ម ដែលផ្តល់នូវការវាយតម្លៃអំពីផលប៉ះពាល់កម្លាំងពលកម្មដែលបានប៉ាន់ប្រមាណទាក់ទងនឹងសកម្មភាពដែលបានស្នើឡើង រួមទាំងផលប៉ះពាល់ការងារ និងសេដ្ឋកិច្ច។ គណៈកម្មការស្នងការកំពង់ផែអាចលើកលែងអាជីវកម្មខ្នាតតូច និងអង្គការមិនស្វែងរកប្រាក់ចំណេញពីការផ្តល់ការវិភាគផលប៉ះពាល់សេដ្ឋកិច្ច។

វិធានការនេះនឹងមានប្រសិទ្ធភាព ប្រសិនបើត្រូវបានយល់ព្រមដោយអ្នកបោះឆ្នោតភាគច្រើន។

រចនាសម្ព័ន្ធផលប៉ះពាល់ហិរញ្ញវត្ថុ
ដោយ MATTHEW W. SZABO មន្ត្រីរដ្ឋបាលទីក្រុង

វិធានការនេះធ្វើវិសោធនកម្មធម្មនុញ្ញក្រុងដូចខាងក្រោម៖

រយៈពេលជួល - ពន្យារយៈពេលជួលអតិបរមាសម្រាប់អាកាសយានដ្ឋានពិភពលោក Los Angeles និងនាយកដ្ឋានធនធានទឹក និងថាមពលពី 50 ឆ្នាំ ទៅ 66 ឆ្នាំ ដោយធ្វើឱ្យពួកគេស្របគ្នាជាមួយនាយកដ្ឋានកំពង់ផែ។ វិសោធនកម្មនេះគឺអព្យាក្រឹតភាពថ្លៃដើម។

សមាសភាពគណៈកម្មការអាកាសយានដ្ឋាន – បង្កើនតំណាងអ្នកស្នាក់នៅក្នុងតំបន់ពីមួយទៅបីនាក់ និងមួយទៅពីរនាក់សម្រាប់តំបន់ជុំវិញអាកាសយានដ្ឋាន LAX និង Van Nuys រៀងៗខ្លួន។ វិសោធនកម្មនេះគឺអព្យាក្រឹតភាពថ្លៃដើម។

ផែនការវិនិយោគសម្រាប់ច្រកចូលសាធារណៈនៅកំពង់ផែ (PAIP) - កំណត់ក្រមនៃការអនុវត្តប្រចាំឆ្នាំរបស់នាយកដ្ឋានកំពង់ផែក្នុងការបែងចែក 10 ភាគរយនៃប្រាក់ចំណូលប្រតិបត្តិការរបស់ខ្លួនទៅឱ្យ PAIP សម្រាប់គម្រោង និងកម្មវិធីនានាតាមមាត់ទឹក។ ការបែងចែកប្រចាំឆ្នាំជាប្រវត្តិសាស្ត្រទៅឱ្យ PAIP គឺប្រហែល $28.6 លានដុល្លារ។

ផលប៉ះពាល់កម្លាំងពលកម្ម - តម្រូវឱ្យបេក្ខជនទាំងអស់ដែលកំពុងស្វែងរកការអនុម័តការជួល ការបន្ត ការធ្វើវិសោធនកម្ម ឬលិខិតអនុញ្ញាតអភិវឌ្ឍន៍ឆ្នេរសមុទ្ររបស់មណ្ឌលកំពង់ផែ ដាក់ស្នើការបង្ហាញព័ត៌មានអំពីផលប៉ះពាល់កម្លាំងពលកម្មដែលផ្តល់មូលនិធិដោយខ្លួនឯង ដើម្បីវាយតម្លៃផលប៉ះពាល់សេដ្ឋកិច្ច និងការងារក្នុងតំបន់។ វិសោធនកម្មនេះគឺអព្យាក្រឹតភាពថ្លៃដើម។

សេចក្តីអះអាងគាំទ្រនៃវិសោធនកម្មធម្មនុញ្ញ PRT

សូមបោះឆ្នោតគាំទ្រវិធានការ PRT ដើម្បីពង្រឹងការតំណាងសហគមន៍ ការពារ ការវិនិយោគក្នុងមូលដ្ឋាន និងធានាគណនេយ្យ ភាពកាន់តែខ្លាំងពីក្រសួងកម្មសិទ្ធិរបស់ Los Angeles ។

ពី East Los Angeles ដល់ Westside និងពី Port ដល់ Valley ការតំណាងមានសារៈសំខាន់យ៉ាងជ្រាលជ្រៅចំពោះសហគមន៍ដែលពួកយើងបម្រើ – និងជាពិសេសចំពោះអ្នកដែលរស់នៅ និងធ្វើការនៅក្បែរអាកាសយានដ្ឋាន និងតំបន់មាត់ទឹករបស់យើង ។

វិធានការ PRT ធានាថាសង្កាត់ដែលរងផលប៉ះពាល់ខ្លាំងបំផុតដោយសារប្រតិបត្តិការអាកាសយានដ្ឋានមាន សំឡេងកាន់តែខ្លាំងក្នុងការសម្រេចចិត្តក្នុងមូលដ្ឋាន ។ តាមរយៈការបង្កើនចំនួនតំណាងតាមភូមិសាស្ត្រ នៃស្នងការអាកាសយានដ្ឋានពីពីរ ដល់ប្រាំ វិធានការនេះផ្តល់ឱ្យអ្នករស់នៅដែលរងផលប៉ះពាល់ដោយសំឡេងយន្តហោះ ចរាចរណ៍ និងការកកកុញ នូវការតំណាងផ្ទាល់ដែលពួកគេសមនឹងទទួលបាននៅលើស្នងការអាកាសយានដ្ឋាន ។

នៅ Port of Los Angeles វិធានការ PRT រំលឹកឡើងវិញនូវការប្តេជ្ញាចិត្តដែលមានស្រាប់ដ៏សំខាន់នៅក្នុងធម្មនុញ្ញក្រុង ។ វាចងក្រងជាក្រមលក្ខខណ្ឌតម្រូវដើម្បីពិចារណា និងបង្ហាញពីរបៀបដែលការជួល និងកិច្ចសន្យាអាច ប៉ះពាល់ដល់ការងារក្នុងមូលដ្ឋាន និងកម្លាំងពលកម្មរបស់យើង ដោយធានាថាផលវិបាកទាំងនោះនៅតែជាផ្នែកមួយនៃសាធារណៈ ដំណើរការធ្វើសេចក្តីសម្រេច ។ វាក៏ការពារការប្តេជ្ញាចិត្តរបស់ Port ក្នុងការវិនិយោគលើការចូលទៅកាន់តំបន់មាត់ទឹក សាធារណៈ ដោយចងក្រងជាក្រមនូវផែនការវិនិយោគដែលមានស្រាប់នៅក្នុងធម្មនុញ្ញ ។ ការវិនិយោគទាំងនេះជួយធានា ថាសហគមន៍ដែលជាម្ចាស់ផ្ទះនៃកំពង់ផែដែលរវល់បំផុតមួយរបស់ប្រទេសបន្តទទួលបានផលចំណេញពីតំបន់មាត់ទឹកការងាររបស់យើង ។

វិធានការ PRT ក៏ធ្វើទំនើបកម្មអំណាចក្នុងការជួលសម្រាប់ក្រសួងទឹក និងថាមពល និង Los Angeles World Airports ដោយផ្តល់ភាពបត់បែនកាន់តែខ្លាំងសម្រាប់ការវិនិយោគរយៈពេលវែងប្រកបដោយការទទួលខុសត្រូវ និងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ខណៈពេលដែលរក្សាបាននូវការត្រួតពិនិត្យសាធារណៈ។

សហគមន៍ដែលជាទីតាំងរបស់អាកាសយានដ្ឋាន និងប្រតិបត្តិការកំពង់ផែរបស់យើង ចូលរួមចំណែកយ៉ាងធំធេងដល់ Los Angeles ។ សហគមន៍ទាំងនោះសមនឹងទទួលបានការតំណាង តម្លាភាព និងការប្តេជ្ញាចិត្តដ៏យូរអង្វែងចំពោះការវិនិយោគក្នុងមូលដ្ឋាន ។

សូមបោះឆ្នោតគាំទ្រវិធានការ PRT – ពី East Los Angeles ដល់ Westside ពី Port ដល់ Valley ការតំណាង និងគណនេយ្យ ភាពសហគមន៍មានសារៈសំខាន់ ។

បុគ្គលដែលចុះហត្ថលេខាលើសេចក្តីអះអាងគាំទ្រនៃវិសោធនកម្មធម្មនុញ្ញ PRT

TIM MCOSKER
សមាជិកក្រុមប្រឹក្សា, មណ្ឌលទី 15
City of LA

TRACI PARK
សមាជិកាក្រុមប្រឹក្សា, មណ្ឌលទី 11
City of LA

PAULA GEREZ
ប្រធាន
Westchester/Playa Neighborhood Council

IMELDA PADILLA
សមាជិកាក្រុមប្រឹក្សា, មណ្ឌលទី 6
City of LA

GINA MARTINEZ
អ្នកគាំពារសហគមន៍ Wilmington

DAVID YANOWITZ
អ្នកគាំពារសហគមន៍ Van Nuys

គ្មានសេចក្តីអះអាងប្រឆាំងវិធានការនេះត្រូវបានដាក់ជូនទេ ។

សេចក្តីអះអាងដែលបានបោះពុម្ព គឺជាមតិរបស់អ្នកនិពន្ធ ហើយមិនត្រូវបានត្រួតពិនិត្យភាពត្រឹមត្រូវដោយទីភ្នាក់ងារក្រុងណាមួយឡើយ ។ លើសពីនេះ មុខតំណែងនៅក្រោមឈ្មោះអ្នកចុះហត្ថលេខា គឺសម្រាប់គោលបំណងកំណត់អត្តសញ្ញាណតែប៉ុណ្ណោះ ហើយមិនបង្ហាញថាបុគ្គលនោះកំពុងចុះហត្ថលេខាក្នុងនាមអង្គការនោះទេ ។

បទប្បញ្ញត្តិថ្មី ឬភាសាដែលបានបន្ថែមទៅផ្នែកធម្មនុញ្ញ ឬផ្នែកធម្មនុញ្ញដែលមានស្រាប់ត្រូវបានបង្ហាញជាប្រភេទគ្មសបន្ទាត់ពីក្រោម។ ពាក្យដែលបានលុបចេញពីធម្មនុញ្ញ ឬពីផ្នែកធម្មនុញ្ញ ដែលមានស្រាប់ត្រូវបានបង្ហាញក្នុងប្រភេទការ~~គូសចេញ~~។

វិសោធនកម្មធម្មនុញ្ញ PRT
(នាយកដ្ឋានអាកាសយានដ្ឋាន កំពង់ផែ និងទឹក និងអគ្គិសនីទីក្រុង)

អត្ថបទនៃវិធានការសន្លឹកឆ្នោតដែលបានស្នើឡើង

ផ្នែក 1. ផ្នែករង (a) នៃផ្នែក 607 នៃធម្មនុញ្ញនៃទីក្រុង Los Angeles ពាក់ព័ន្ធនឹងការកម្រិតលើសិទ្ធិប្រើយីហោ, សម្បទាន, លិខិតអនុញ្ញាត, អាជ្ញាប័ណ្ណ និងកិច្ចសន្យាជួលដីឬអាគាររបស់នាយកដ្ឋានកម្មសិទ្ធិ ត្រូវបានកែប្រែដើម្បីអានដូចខាងក្រោម៖

(a) **រយៈពេល**។ រយៈពេលមិនត្រូវលើសពី 30 ឆ្នាំ ឬរយៈពេលដែលបានកំណត់ដោយច្បាប់សហព័ន្ធ ឬរដ្ឋដែលពាក់ព័ន្ធឡើយ ដោយយកមួយណាតិចជាង។ ប្រសិនបើក្រុមប្រឹក្សាក្រុងរកឃើញថារយៈពេលវែងជាង 30 ឆ្នាំ នឹងបំរើផលប្រយោជន៍ល្អបំផុតរបស់ទីក្រុង ក្រុមប្រឹក្សាក្រុងអាច តាមរយៈការបោះឆ្នោតពីរភាគបី ដោយយោងតាមវេតូរបស់អភិបាលក្រុង ឬការបោះឆ្នោតបីភាគបួនលើសពីវេតូរបស់អភិបាលក្រុង ផ្តល់សិទ្ធិអំណាច~~រយៈពេលរហូតដល់ 50 ឆ្នាំសម្រាប់នាយកដ្ឋានព្រលានយន្តហោះ និងនាយកដ្ឋានទឹក និងអគ្គិសនី និង~~រយៈពេលរហូតដល់ 66 ឆ្នាំសម្រាប់នាយកដ្ឋានអាកាសយានដ្ឋាន, នាយកដ្ឋានកំពង់ផែ, និងនាយកដ្ឋានធនធានទឹក និងថាមពល ឬរយៈពេលអតិបរមាដែលត្រូវបានអនុញ្ញាតដោយច្បាប់សហព័ន្ធ ឬរដ្ឋណាមួយ អាស្រ័យលើចំនួនណាដែលតិចជាង។

ផ្នែកទី 2. ផ្នែក 630 នៃធម្មនុញ្ញរបស់ទីក្រុង Los Angeles ទាក់ទងនឹងស្នងការក្រុមប្រឹក្សាភិបាលអាកាសយានដ្ឋានត្រូវបានធ្វើវិសោធនកម្មដើម្បីអានដូចខាងក្រោម៖

ក្រុមប្រឹក្សាភិបាលស្នងការអាកាសយានដ្ឋានត្រូវមានសមាជិកចំនួនប្រាំពីរនាក់ដែលត្រូវបានតែងតាំង និងដកចេញដូចមានចែងក្នុងផ្នែកទី 502។ យ៉ាងហោចណាស់ សមាជិកបីនាក់ ~~សមាជិកម្នាក់~~ ត្រូវតែរស់នៅក្នុងតំបន់ជុំវិញអាកាសយានដ្ឋានអន្តរជាតិ Los Angeles និងយ៉ាងហោចណាស់ សមាជិកពីរនាក់ ~~សមាជិកម្នាក់~~ នឹងស្ថិតនៅក្នុងតំបន់ជុំវិញអាកាសយានដ្ឋាន Van Nuys ដោយសារតំបន់ទាំងនោះត្រូវបានកំណត់ដោយបទបញ្ញត្តិ។ ក្រុមប្រឹក្សាក្រុងអាច បែងចែកបន្ថែមទៀតនូវតំបន់ជុំវិញអាកាសយានដ្ឋានអន្តរជាតិ Los Angeles និងអាកាសយានដ្ឋាន Van Nuys ទៅជាតំបន់រង ដោយបង្កើតតម្រូវការស្នាក់នៅរបស់ស្នងការក្នុងចំណោមតំបន់រងទាំងនោះ។ទៅជាតំបន់រង តាមរយៈបទបញ្ញត្តិ ដោយបង្កើតតម្រូវការទីលំនៅរបស់ស្នងការក្នុងចំណោមតំបន់រងទាំងនោះ។

ផ្នែកទី 3. ផ្នែករងថ្មី (d) ត្រូវបានបន្ថែមទៅផ្នែកទី 651 នៃធម្មនុញ្ញនៃទីក្រុង Los Angeles ទាក់ទងនឹងកម្មសិទ្ធិ, ការរៀបចំ និងការគ្រប់គ្រងលើសម្បត្តិរបស់នាយកដ្ឋានកំពង់ផែ ដើម្បីអានដូចខាងក្រោម៖

(d) **ផែនការវិនិយោគសម្រាប់ចូលប្រើប្រាស់ជាសាធារណៈ**។ គណៈកម្មការអាជ្ញាធរកំពង់ផែ ត្រូវបែងចែកភាគរយនៃប្រាក់ចំណូលប្រតិបត្តិការរបស់នាយកដ្ឋានកំពង់ផែប្រចាំឆ្នាំ ដើម្បីវិនិយោគលើគម្រោងចូលប្រើប្រាស់ជាសាធារណៈនៅតំបន់ឆ្នេរ និងគម្រោង និងកម្មវិធីបម្រើសាធារណៈផ្សេងទៀតដែលបានអភិវឌ្ឍដោយមានមតិយោបល់ពីសាធារណជន ជាផ្នែកនៃផែនការវិនិយោគសម្រាប់ការចូលប្រើប្រាស់ជាសាធារណៈ។ គណៈកម្មការអាជ្ញាធរកំពង់ផែ ត្រូវមានអាជ្ញាធរតែមួយគត់ក្នុងការកំណត់ចំនួនទឹកប្រាក់សមរម្យដែលត្រូវបែងចែកទៅឱ្យផែនការវិនិយោគសម្រាប់ការចូលប្រើប្រាស់ជាសាធារណៈរៀងរាល់ឆ្នាំសារពើពន្ធ ស្របតាមកាតព្វកិច្ចទទួលខុសត្រូវលើទ្រព្យសម្បត្តិរបស់ខ្លួនក្រោមក្រមធនធានសាធារណៈ California ផ្នែក 6005, 6009.1, និង 6306 និងច្បាប់ពាក់ព័ន្ធផ្សេងទៀត។

ផ្នែកទី 4. ផ្នែករងថ្មី (g) ត្រូវបានបន្ថែមទៅផ្នែកទី 652 នៃធម្មនុញ្ញនៃទីក្រុង Los Angeles ដែលទាក់ទងនឹងគណៈកម្មការស្នងការកំពង់ផែ ដើម្បីអានដូចខាងក្រោម៖

ផ្នែកទី 652. អំណាច និងកាតព្វកិច្ចរបស់គណៈកម្មការ។

គណៈកម្មការត្រូវមានអំណាច និងការកិច្ចដើម្បី៖

(a) **ច្បាប់ និងបទប្បញ្ញត្តិ**។ បង្កើត និងអនុវត្តវិធាន និងបទប្បញ្ញត្តិចាំបាច់ទាំងអស់ដែលគ្រប់គ្រងលើការថែទាំ ការប្រតិបត្តិការ និងការប្រើប្រាស់មណ្ឌលកំពង់ផែ និងអនុវត្តទោសទណ្ឌសម្រាប់ការរំលោភលើវិធាន និងបទប្បញ្ញត្តិទាំងនោះ។

(b) **ចរាចរណ៍កំពង់ផែ**។ រៀបចំ និងត្រួតពិនិត្យការបើកបរ ការបោះយុថ្កា ការចងខ្សែ ការអូស និងការចូលចតនៃនាវា និងកប៉ាល់ទាំងអស់នៅក្នុងមណ្ឌលកំពង់ផែ។

(c) **ការត្រួតពិនិត្យលើបរិក្ខារកំពង់ផែ**។ រៀបចំ និងត្រួតពិនិត្យការសាងសង់ ការថែទាំ ការប្រតិបត្តិការ និងការប្រើប្រាស់ផ្លូវថភ្លើង ផែ ឃ្លាំង ឬបរិក្ខារ ប្រយោជន៍សាធារណៈ រចនាសម្ព័ន្ធ ឬការកែលម្អផ្សេងទៀតដែលប្រើប្រាស់ពាក់ព័ន្ធនឹងមណ្ឌលកំពង់ផែ។

(d) **ការកាយស្តារ**។ រៀបចំ និងត្រួតពិនិត្យការកាយស្តារ ការចាក់ដីបំពេញ និងការជីកកាយទាំងអស់នៅក្នុងមណ្ឌលកំពង់ផែ។

(e) **អត្រាតម្លៃ**។ កំណត់ និងប្រមូលអត្រាតម្លៃ និងការគិតថ្លៃសម្រាប់ការប្រើប្រាស់ទ្រព្យសកម្មកំពង់ផែ ការនាំផ្លូវនាវា និងការអូសនាវា និងសេវាកម្មផ្សេងទៀតដែលផ្តល់ដោយនាយកដ្ឋាន។

(f) **ការអភិវឌ្ឍមណ្ឌលកំពង់ផែ**។ ទិញ ផ្តល់ជូន សាងសង់ ថែទាំ និងប្រតិបត្តិការរាល់ការកែលម្អ ប្រយោជន៍សាធារណៈ រចនាសម្ព័ន្ធ កប៉ាល់ បរិក្ខារ និងសេវាកម្មសម្រាប់គោលបំណងនាយកដ្ឋាន និងទទួលបាន និងយក ដោយការទិញ ការជួល ការរឹបអូស ឬតាមវិធីផ្សេងទៀត ក្នុងនាមទីក្រុង នូវទ្រព្យសម្បត្តិ អចលនវត្ថុ ឬចលនវត្ថុ ឬផលប្រយោជន៍ណាមួយនៅក្នុងនោះ និងកំណត់ទីតាំងសម្រាប់អគារ រចនាសម្ព័ន្ធ ឬបរិក្ខារសាធារណៈណាមួយនៅក្នុងមណ្ឌលកំពង់ផែ។ អំណាចនៃការរឹបអូសត្រូវអនុវត្តបានតែជាមួយនឹងការយល់ព្រមពីក្រុមប្រឹក្សាក្រុងប៉ុណ្ណោះ។

(g) **ផលប៉ះពាល់លើកម្លាំងពលកម្ម**។ តម្រូវឱ្យបេក្ខជនទាំងអស់ដែលស្វែងរកការអនុម័តលើកិច្ចសន្យាជួល ការពន្យារកិច្ចសន្យាជួល ឬការកែប្រែកិច្ចសន្យាជួល ឬការអភិវឌ្ឍអចលនទ្រព្យដែលបានស្នើឡើងណាមួយនៅក្នុងមណ្ឌលកំពង់ផែដែលទាមទារលិខិតអនុញ្ញាតអភិវឌ្ឍន៍តំបន់ឆ្នេរ ដាក់ការបកស្រាយបង្ហាញពីផលប៉ះពាល់លើកម្លាំងពលកម្ម ដែលផ្តល់នូវការវាយតម្លៃអំពីផលប៉ះពាល់លើកម្លាំងពលកម្មដែលបានប៉ាន់ប្រមាណ រួមជាអាទិ៍ ផលប៉ះពាល់ដែលមានសក្តានុពលលើការងារដែលពាក់ព័ន្ធនឹងទីតាំង និងផលប៉ះពាល់សេដ្ឋកិច្ចដែលបានប៉ាន់ប្រមាណលើតំបន់ Los Angeles ទាំងមូលរហូតដល់កម្រិតដែលបានដឹង។ អាជីវកម្មខ្នាតតូច និងអង្គការមិនស្វែងរកប្រាក់ចំណេញ ដូចដែលបានកំណត់ដោយគណៈកម្មការអាជ្ញាធរកំពង់ផែ អាចត្រូវបានលើកលែងពីការផ្តល់ការវិភាគផលប៉ះពាល់សេដ្ឋកិច្ច។ គណៈកម្មការអាជ្ញាធរកំពង់ផែ ត្រូវពិចារណាលើការបកស្រាយបង្ហាញដែលបានដាក់ជូនដោយបេក្ខជននៅក្រោមផ្នែករងនេះ ស្របតាមកាតព្វកិច្ចទទួលខុសត្រូវលើទ្រព្យសម្បត្តិរបស់គណៈកម្មការក្រោមក្រមធនធានសាធារណៈ California ផ្នែក 6005, 6009.1, និង 6306 និងច្បាប់ពាក់ព័ន្ធផ្សេងទៀត។

ផ្នែកទី 5. ភាពអាចបំបែកបាន។ ប្រសិនបើផ្នែក អនុភាគ ខ១ចង ប្រយោគ ឃ្លា ឬការអនុវត្តនៃបទបញ្ញត្តិនេះ ឬផ្នែកណាមួយនៃវិសោធនកម្មនេះ ត្រូវបានចាត់ទុកថាផ្ទុយនឹងរដ្ឋធម្មនុញ្ញ ឬមិនត្រឹមត្រូវដោយតុលាការ ឬសាលាក្តីណាមួយនៃដែនយុត្តាធិការនោះ ផ្នែក អនុភាគ ខ១ចង ប្រយោគ ឃ្លា ផ្នែក ឬការអនុវត្តដែលនៅសល់នៃបទបញ្ញត្តិនេះ នឹងត្រូវរក្សានូវប្រសិទ្ធភាពអនុវត្តពេញលេញ ហើយដើម្បីសម្រេចបាននូវគោលបំណងនេះ លក្ខខណ្ឌនៃវិសោធនកម្មនេះអាចបំបែកចេញពីគ្នាបាន។ លើសពីនេះ អ្នកបោះឆ្នោតប្រកាសថា ពួកគេនឹងបានអនុម័តគ្រប់ផ្នែក អនុភាគ ខ១ចង ប្រយោគ ឃ្លា ចំណែក និងការអនុវត្តទាំងអស់នៃវិសោធនកម្មនេះ ដោយគ្មានផ្នែក អនុភាគ ខ១ចង ប្រយោគ ឃ្លា ចំណែក ឬការអនុវត្តណាមួយត្រូវបានចាត់ទុកថាផ្ទុយនឹងរដ្ឋធម្មនុញ្ញ ឬមិនមានសុពលភាពឡើយ។

SC ច្បាប់ហិរញ្ញវត្ថុសម្រាប់យុទ្ធនាការទាក់ទងនឹងការបោះឆ្នោតគណៈកម្មការអប់រំ។ វិសោធនកម្មធម្មនុញ្ញ SC។

តើធម្មនុញ្ញក្រុង Los Angeles គួរត្រូវបានធ្វើវិសោធនកម្មដើម្បីបញ្ជាក់ឱ្យច្បាស់ពីវិហិរញ្ញវត្ថុយុទ្ធនាការសម្រាប់ការបោះឆ្នោតគណៈកម្មការអប់រំ និងអនុញ្ញាតឱ្យមានការផ្លាស់ប្តូរដោយបញ្ញត្តិដែរឬទេ?

សេចក្តីសង្ខេបតតលម្ងៀង
ដោយ SHARON M. TSO ប្រធានអ្នកវិភាគនិតិបញ្ញត្តិ

មាត្រា 803 នៃធម្មនុញ្ញក្រុង កំណត់ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត ដែលបេក្ខជនសម្រាប់គណៈកម្មការអប់រំមណ្ឌលសិក្សាធិការរួបរួម Los Angeles ត្រូវតែអនុវត្តតាមក្នុងអំឡុងពេលដំណើរការបោះឆ្នោត។ មាត្រា 470 និង 471 នៃធម្មនុញ្ញក្រុង និងមាត្រា 9.7 នៃក្រមសាលាក្រុង Los Angeles កំណត់ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត ដែលបេក្ខជនសម្រាប់តំណែងចៅហ្វាយក្រុងត្រូវតែអនុវត្តតាមក្នុងអំឡុងពេលដំណើរការបោះឆ្នោត។ ច្បាប់ទាំងនេះបំពេញបន្ថែមច្បាប់កំណែទម្រង់នយោបាយរដ្ឋ California ឆ្នាំ 1974។ ច្បាប់ស្តីពីហិរញ្ញប្បទានយុទ្ធនាការឃោសនាបោះឆ្នោតសម្រាប់បេក្ខជនសម្រាប់គណៈកម្មការអប់រំ និងចៅហ្វាយក្រុងគឺស្រដៀងគ្នា ប៉ុន្តែមានចែងក្នុងផ្នែកផ្សេងៗគ្នានៃធម្មនុញ្ញក្រុង ក៏ដូចជាក្រមសាលាក្រុង Los Angeles ផងដែរ។

វិធានការនេះនឹងបញ្ជាក់ឱ្យច្បាស់អំពីច្បាប់ហិរញ្ញវត្ថុយុទ្ធនាការឃោសនាបោះឆ្នោតសម្រាប់បេក្ខជនក្រមសាលាក្រុងដោយការធ្វើវិសោធនកម្មធម្មនុញ្ញក្រុង ដើម្បីលុបភាសាដដែលៗនៅក្នុងមាត្រា 803 នៃធម្មនុញ្ញ និងទាមទារឱ្យបេក្ខជនគណៈកម្មការអប់រំអនុវត្តតាមច្បាប់ហិរញ្ញវត្ថុយុទ្ធនាការឃោសនាបោះឆ្នោតសម្រាប់បេក្ខជនចៅហ្វាយក្រុង ដូចដែលបានបញ្ជាក់នៅក្នុងមាត្រា 470 និង 471 នៃធម្មនុញ្ញក្រុង និងមាត្រា 9.7 នៃក្រមសាលាក្រុង Los Angeles។ វិធានការនេះនឹងអនុវត្តបទប្បញ្ញត្តិដូចគ្នាសម្រាប់បេក្ខជនចៅហ្វាយក្រុង ចំពោះបេក្ខជនសម្រាប់គណៈកម្មការអប់រំ លើកលែងតែបទប្បញ្ញត្តិទាំងនោះដែលអនុវត្តចំពោះតែបេក្ខជនសម្រាប់តំណែងជាប់ឆ្នោតរបស់ទីក្រុង ដូចជាការិយាល័យចៅហ្វាយក្រុង និងការកំណត់លើការចូលរួមវិភាគទានពីអ្នកម៉ៅការ និងអ្នកតំណាងរបស់ក្រុង។

ប្រសិនបើវិសោធនកម្មនេះត្រូវបានអនុម័ត ច្បាប់យុទ្ធនាការឃោសនាបោះឆ្នោតដែលមានស្រាប់សម្រាប់ទាំងបេក្ខជនគណៈកម្មការអប់រំ និងបេក្ខជនចៅហ្វាយក្រុងនឹងមានដូចខាងក្រោម៖

- បេក្ខជន និងអ្នកបរិច្ចាគរបស់ពួកគេនឹងត្រូវបានកំណត់ដោយដែនកំណត់នៃការចូលរួមចំណែក ដែលអាចត្រូវបានកែតម្រូវជាប្រចាំ ដោយមូលដ្ឋានសម្រាប់ដែនកំណត់ទាំងនេះត្រូវបានក្សានៅ $1,000 ដុល្លារសម្រាប់ការិយាល័យនីមួយៗ ហើយគ្មានដែនកំណត់លើបេក្ខជនក្នុងការចូលរួមចំណែកថវិកាផ្ទាល់ខ្លួនដល់បេក្ខភាពរបស់ពួកគេឡើយ។
- លក្ខខណ្ឌតម្រូវសម្រាប់គណនេយ្យភាពហិរញ្ញវត្ថុ និងរតនាគារ ដូចជាការបណ្តុះបណ្តាល ថ្ងៃផុតកំណត់នៃការដាក់ពាក្យ ការបង្ហាញព័ត៌មានជាសាធារណៈ គណនីយុទ្ធនាការដែលត្រូវបានត្រួតពិនិត្យ និងមូលនិធិសាច់ប្រាក់តិចតួច
- ដែនកំណត់ពេលវេលាលើការរួមចំណែក និងការចំណាយ រួមទាំងចន្លោះពេលរវាងអង្គាសថវិកា និងការប្រើប្រាស់មូលនិធិដែលទទួលបានក្នុងរយៈពេលទាំងនោះ និង
- អំណាចសវនកម្ម និងស៊ើបអង្កេតរបស់គណៈកម្មការសីលធម៌ទីក្រុង រួមទាំងបទប្បញ្ញត្តិអនុវត្តច្បាប់ព្រហ្មទណ្ឌ និងរដ្ឋប្បវេណី។

វិធានការនេះនឹងអនុញ្ញាតឱ្យមានការរឹតបន្តឹង ឬករណីលើកលែងបន្ថែមដោយច្បាប់។

វិធានការនេះនឹងមានប្រសិទ្ធភាព ប្រសិនបើត្រូវបានយល់ព្រមដោយអ្នកបោះឆ្នោតភាគច្រើន។

របាយការណ៍ផលប៉ះពាល់ហិរញ្ញវត្ថុ
ដោយ MATTHEW W. SZABO មន្ត្រីរដ្ឋបាលទីក្រុង

វិធានការនេះធ្វើវិសោធនកម្មបទប្បញ្ញត្តិហិរញ្ញវត្ថុយុទ្ធនាការឃោសនាបោះឆ្នោតដែលមានស្រាប់សម្រាប់គណៈកម្មការអប់រំមណ្ឌលសិក្សាធិការរួបរួម Los Angeles (LAUSD) ដោយអនុវត្តបទប្បញ្ញត្តិដូចគ្នាចំពោះបេក្ខជនគណៈកម្មការសាលាដែលបេក្ខជនចៅហ្វាយក្រុងសម្រាប់ទីក្រុង Los Angeles ត្រូវតែអនុវត្តតាម។ បេក្ខជនសម្រាប់គណៈកម្មការអប់រំ LAUSD មិនត្រូវទទួលរងនូវបទប្បញ្ញត្តិមួយចំនួនទាក់ទងនឹងការចូលរួមវិភាគទាន និងការរៃអង្គាសប្រាក់ (មាត្រា 470(c)(11) និង 470(c)(12)) បទប្បញ្ញត្តិទាក់ទងនឹងមូលនិធិផ្ទូផ្ទងសាធារណៈ (មាត្រា 471) និងដូចដែលបានលើកលែងដោយច្បាប់។ វិធានការនេះមិនត្រូវបានគេរំពឹងថានឹងមានផលប៉ះពាល់ផ្ទែកហិរញ្ញវត្ថុលើទីក្រុងនោះទេ។

សេចក្តីអះអាងគាំទ្រនៃវិសោធនកម្មច្បាប់ធម្មនុញ្ញ SC

សូមបោះឆ្នោតគាំទ្រលើវិសោធនកម្មច្បាប់ធម្មនុញ្ញ SC

ទីក្រុង Los Angeles តម្រូវឱ្យបេក្ខជនសម្រាប់មណ្ឌលសិក្សាធិការរួមបញ្ចូល Los Angeles (LAUSD) គណៈកម្មការអប់រំ អនុវត្តតាមបទបញ្ញត្តិហិរញ្ញវត្ថុយុទ្ធនាការ - ដូចជាកម្រិតភាគទាន ការបញ្ចេញព័ត៌មានអ្នកបរិច្ចាគ និងការត្រួតពិនិត្យដោយគណៈកម្មការសីលធម៌ក្រុង ។ បទបញ្ញត្តិទាំងនេះអនុវត្តចំពោះបេក្ខជនគណៈកម្មការអប់រំ LAUSD ស្រដៀងគ្នាទៅនឹងរបៀបដែលវាអនុវត្តចំពោះបេក្ខជនសម្រាប់តំណែងជាប់ឆ្នោតផ្សេងទៀតរបស់ក្រុង ។

ភាពខុសគ្នាមិនចាំបាច់ស្ថិតនៅលើវិធានទាំងនោះផ្ទាល់នោះទេ ប៉ុន្តែស្ថិតនៅត្រង់ថាតើបទបញ្ញត្តិទាំងនោះ លេចឡើងនៅកន្លែងណានៅក្នុងធម្មនុញ្ញក្រុង ។ សព្វថ្ងៃនេះ បទបញ្ញត្តិដែលគ្រប់គ្រងបេក្ខជនសម្រាប់គណៈកម្មការអប់រំត្រូវបាន បង្កើតឡើងនៅក្នុងផ្នែកដាច់ដោយឡែកមួយនៃធម្មនុញ្ញក្រុង ។ ពួកវាលេចឡើងដោយឡែកជាជាងនៅក្នុង ផ្នែកតែមួយនៃធម្មនុញ្ញដែលគ្រប់គ្រងបេក្ខជនសម្រាប់តំណែងជាប់ឆ្នោតផ្សេងទៀត ដូចជាចៅហ្វាយក្រុងជាដើម ។

វិសោធនកម្មធម្មនុញ្ញ SC គឺជាការកែទម្រង់អភិបាលកិច្ចល្អដែលជួយសម្រួលធម្មនុញ្ញ និងកាត់បន្ថយភាពស្មុគស្មាញ និងភាពជាន់គ្នានៃការិយាធិបតេយ្យ ។ វាលុបបំបាត់ការផ្តល់ជូនហិរញ្ញវត្ថុយុទ្ធនាការដែលជាន់គ្នា សម្រាប់ការបោះឆ្នោតគណៈកម្មការអប់រំ និងបញ្ជាក់ឱ្យច្បាស់ថាបេក្ខជនទាំងនោះត្រូវស្ថិតនៅក្រោម ក្របខ័ណ្ឌហិរញ្ញវត្ថុយុទ្ធនាការទូទៅដូចគ្នាដែលកំពុងគ្រប់គ្រងបេក្ខជនសម្រាប់តំណែងចៅហ្វាយក្រុងរួចជាស្រេច ។

នេះគឺជាការកែទម្រង់រដ្ឋាភិបាលល្អដែលងាយយល់ ហើយវាសមនឹងទទួលបានការគាំទ្រដោយសារមូលហេតុនេះឯង ។

សូមបោះឆ្នោតគាំទ្រវិសោធនកម្មធម្មនុញ្ញ SC ។

បុគ្គលដែលចុះហត្ថលេខាលើសេចក្តីអះអាងគាំទ្រនៃវិសោធនកម្មច្បាប់ធម្មនុញ្ញ SC

ADRIN NAZARIAN
សមាជិកក្រុមប្រឹក្សាក្រុង Los Angeles, មណ្ឌលទី 2

NICK MELVOIN
សមាជិកគណៈកម្មការ LAUSD

DIEGO ANDRADES
អតីតស្នងការកំណែទម្រង់ធម្មនុញ្ញ

CALIFORNIA COMMON CAUSE

LEAGUE OF WOMEN VOTERS OF GREATER LOS ANGELES

គ្មានសេចក្តីអះអាងប្រឆាំងវិធានការនេះត្រូវបានដាក់ជូនទេ ។

សេចក្តីអះអាងដែលបានបោះពុម្ព គឺជាមតិរបស់អ្នកនិពន្ធ ហើយមិនត្រូវបានត្រួតពិនិត្យភាពត្រឹមត្រូវដោយទីភ្នាក់ងារក្រុងណាមួយឡើយ ។ លើសពីនេះ មុខតំណែងនៅក្រោមឈ្មោះអ្នកចុះហត្ថលេខា គឺសម្រាប់គោលបំណងកំណត់អត្តសញ្ញាណតែប៉ុណ្ណោះ ហើយមិនបង្ហាញថាបុគ្គលនោះកំពុងចុះហត្ថលេខាក្នុងនាមអង្គការនោះទេ ។

បទប្បញ្ញត្តិថ្មី ឬភាសាដែលបានបន្ថែមទៅមាត្រាធម្មនុញ្ញ ឬមាត្រាធម្មនុញ្ញដែលមានស្រាប់ត្រូវបានបង្ហាញជាប្រភេទ ~~ធ្វសបន្ទាត់ពីក្រោម~~។ ពាក្យដែលបានលុបចេញពីធម្មនុញ្ញ ឬពីមាត្រាធម្មនុញ្ញ ដែលមានស្រាប់ត្រូវបានបង្ហាញក្នុងប្រភេទ~~ការ ធ្វសចេញ~~ ។

វិសោធនកម្មធម្មនុញ្ញ SC
(ច្បាប់ហិរញ្ញវត្ថុយុទ្ធនាការដែលពាក់ព័ន្ធនឹងការបោះឆ្នោត LAUSD)

អត្ថបទនៃវិធានការសន្លឹកឆ្នោតដែលបានស្នើឡើង

មាត្រា 1. មាត្រា 803 នៃធម្មនុញ្ញទីក្រុង Los Angeles ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មការអប់រំ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖

ផ្នែក 803. ការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មការ ។

ការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មការអប់រំនៃមណ្ឌលសិក្សាធិការរួបរួម Los Angeles ត្រូវរៀបចំឡើងស្របតាមមាត្រា 400 ដល់ 440 នៃធម្មនុញ្ញ និងបទបញ្ញត្តិជាធរមានដែលស៊ីសង្វាក់គ្នាជាមួយធម្មនុញ្ញ ។ ដើម្បីលើកទឹកចិត្តឱ្យមានការចូលរួមកាន់តែទូលំទូលាយនៅក្នុងដំណើរការនយោបាយ ដោយដាក់កម្រិតលើចំនួនទឹកប្រាក់ដែលបុគ្គលណាម្នាក់អាចចូលរួមចំណែក ឬបណ្តាលឱ្យមានសម្រាប់បេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសរើសគណៈកម្មការអប់រំ ~~បេក្ខជនសម្រាប់គណៈកម្មការ អប់រំនឹងត្រូវទទួលរងនូវលក្ខខណ្ឌហិរញ្ញវត្ថុយុទ្ធនាការដូចគ្នាដែលអនុវត្តចំពោះបេក្ខជនសម្រាប់តំណែងចៅហ្វាយក្រុង រួមទាំងនៅក្នុងមាត្រា 470 និងលក្ខខណ្ឌណាមួយដែលត្រូវបានអនុម័តស្របតាមមាត្រា 470(c) ឬមាត្រាផ្សេងទៀតនៃធម្មនុញ្ញ ដែលអាចអនុវត្តបាន លើកលែងតែបេក្ខជនសម្រាប់គណៈកម្មការអប់រំមិនត្រូវទទួលរងនូវលក្ខខណ្ឌទាក់ទងនឹងវិភាគទាន និងការរៃអង្គាសថវិកានៅក្នុងមាត្រា 470(c)(11) និង 470(c)(12) លក្ខខណ្ឌទាក់ទងនឹងមូលនិធិផ្ទូផ្ទងសាធារណៈនៅក្នុងមាត្រា 471 និងដូចដែលត្រូវបានលើកលែងដោយបញ្ញត្តិ ។ លក្ខខណ្ឌហិរញ្ញវត្ថុសម្រាប់យុទ្ធនាការដូចខាងក្រោមនេះអនុវត្តចំពោះការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មការអប់រំ ។ មាត្រានេះមានបំណងបំពេញបន្ថែមលើច្បាប់កែទម្រង់នយោបាយឆ្នាំ 1974 ។~~

~~**(a) និយមន័យ ។**~~

~~(1) "តាមការស្នើសុំ" មានន័យ និងត្រូវចាត់ទុកតាមរបៀបដូចខាងក្រោមសម្រាប់គោលបំណងនៃមាត្រានេះ ៖~~

~~(A) ការចំណាយដែលធ្វើឡើងតាមស្នើសុំ ឬតាមការចាត់ចែងដោយបេក្ខជន ឬគណៈកម្មាធិការគ្រប់គ្រងដោយបេក្ខជន បិនមែនជាការចំណាយឯកវាជ្យទេ ហើយត្រូវចាត់ទុកជាវិភាគទានដល់បេក្ខជន ឬគណៈកម្មាធិការដែលធ្វើការស្នើសុំ ឬចាត់ចែងការចំណាយនោះ ។ ការទូទាត់ប្រាក់មួយត្រូវចាត់ទុកថាបានធ្វើឡើងតាមការស្នើសុំ ប្រសិនបើវាត្រូវបានធ្វើឡើង ៖~~

~~(i) តាមការស្នើសុំ ឬការចង្អុលបង្ហាញរបស់បេក្ខជន គណៈកម្មាធិការ ឬភ្នាក់ងាររបស់បេក្ខជន ឬគណៈកម្មាធិការ ៖~~

~~(ii) ដោយមានការព្រមព្រៀងគ្នា តាមកិច្ចសហការជាមួយ ឬដោយមានការពិគ្រោះយោបល់ជាមួយបេក្ខជន គណៈកម្មាធិការ ឬភ្នាក់ងាររបស់បេក្ខជន ឬគណៈកម្មាធិការ ឬ~~

~~(iii) ក្រោមការរៀបចំ ការសម្របសម្រួល ឬការចាត់ចែងណាមួយរវាងបេក្ខជន គណៈកម្មាធិការ ឬភ្នាក់ងាររបស់បេក្ខជន ឬគណៈកម្មាធិការ ។~~

~~(B) ការចំណាយមួយត្រូវចាត់ទុកថាបានធ្វើឡើងតាមការស្នើសុំដោយគ្មានការកម្រិត ក្រោមស្ថានភាពដូចខាងក្រោម ៖~~

~~(i) ការចូលរួមយ៉ាងសកម្ម ឬការចូលរួមដោយបេក្ខជនក្នុងការបង្កើត ឬការរៀបចំទម្រង់នៃការទំនាក់ទំនងដែលផ្តល់ហិរញ្ញប្បទានដោយអ្នកចំណាយ រួមទាំងការពិគ្រោះយោបល់រវាងអ្នកចំណាយ និងបេក្ខជនអំពីខ្លឹមសារ ។~~

~~(ii) ការរៀបរៀងស/ស្នើសុំដោយអ្នកចំណាយ និង/ឬការផ្តល់សម្ភារៈដោយបេក្ខជនជាពិសេសសម្រាប់ប្រើប្រាស់ក្នុងការទំនាក់ទំនង ឬការទទួលបានការយល់ព្រមពីបេក្ខជនដើម្បីបញ្ចូលសម្ភារៈជាក់លាក់ក្នុងការទំនាក់ទំនង ឬ~~

~~(iii) ការរៀបចំជាបួយបេក្ខជនសម្រាប់ការរៀបចំសម្ភារៈណាមួយដែលបានប្រើប្រាស់ក្នុងការទំនាក់ទំនង ។~~

~~(C) មានការសន្មតដែលអាចផ្លាស់ប្តូរបានថា ការចំណាយមួយត្រូវបានធ្វើឡើងតាមការស្នើសុំ លើកលែងតែមិនមានការចំណាយឯកជនផ្សេង ប្រសិនបើ ៖~~

~~(i) វាត្រូវបានធ្វើឡើងដោយ ឬតាមរយៈគ្នាក់ងារណាម្នាក់របស់បេក្ខជនដែលរងផលប៉ះពាល់ ឬសមាជិកនៃគណៈកម្មាធិការគ្រប់គ្រងរបស់បេក្ខជន នៅក្នុងអំឡុងពេលនៃការចូលរួមរបស់គាត់នៅក្នុងយុទ្ធនាការបច្ចុប្បន្ន~~

~~(ii) នៅក្នុងវគ្គនៃការបោះឆ្នោតដែលការចំណាយនោះត្រូវបានធ្វើឡើង ទាំងអ្នកចំណាយ ឬក្នុងនាមរបស់អ្នកចំណាយ និងបេក្ខជនដែលទទួលបានផលប្រយោជន៍ពីការចំណាយនោះ ជួលបុគ្គល ឬរង្គភាពតែមួយដើម្បីផ្តល់សេវាកម្មវិជ្ជាជីវៈ ទាក់ទងនឹងយុទ្ធនាការដែលមិនមានជារដ្ឋបាលសុទ្ធសាធ (សេវាកម្មវិជ្ជាជីវៈ ទាក់ទងនឹងយុទ្ធនាការដែលមិនមានជារដ្ឋបាលសុទ្ធសាធ រួមមាន ប៉ុន្តែមិនកំណត់ចំពោះ ៖ ការស្វង់មតិ ឬការស្រាវជ្រាវយុទ្ធនាការផ្សេងទៀត ការពិគ្រោះយោបល់ ឬការផលិតប្រព័ន្ធផ្សព្វផ្សាយ ការពិគ្រោះយោបល់លើសំបុត្រផ្ញើផ្ទាល់ និងការរៀបរៀងស្ថិតិ)~~

~~(iii) ការចំណាយនោះផ្តល់ហិរញ្ញប្បទានដល់ការទំនាក់ទំនងដែលចម្លង ផលិតឡើងវិញ ចោះពុម្ពផ្សាយឡើងវិញ ចែកចាយ ឬផ្សព្វផ្សាយទាំងស្រុង ឬភាគច្រើននូវការផ្សាយ សំណេរ រូបភាព ឬទម្រង់ផ្សេងទៀតនៃសម្ភារៈយុទ្ធនាការដែលបានចម្លង ផលិត បង់ប្រាក់ ឬចែកចាយដោយបេក្ខជនដែលរងផលប៉ះពាល់ គណៈកម្មាធិការ ឬភ្នាក់ងាររបស់គាត់~~

~~(iv) ការចំណាយនោះផ្អែកលើព័ត៌មានអំពីផែនការ គម្រោង ឬតម្រូវការយុទ្ធនាការរបស់បេក្ខជនដែលមិនត្រូវបានបង្ហាញជាសាធារណៈជាទូទៅ ឬព័ត៌មានដែលបានផ្តល់ដោយផ្ទាល់ ឬប្រយោលដោយបេក្ខជន គណៈកម្មាធិការ ឬភ្នាក់ងាររបស់ពួកគេទៅកាន់អ្នកចំណាយ ឬភ្នាក់ងាររបស់អ្នកចំណាយ ដោយមានការយល់ព្រមច្បាស់លាស់ ឬដោយស្មៀបស្ងាត់ថាការចំណាយនោះកំពុងត្រូវបានពិចារណា~~

~~(v) អ្នកចំណាយ ឬភ្នាក់ងាររបស់អ្នកចំណាយ ពិភាក្សា ឬចរចារអំពីខ្លឹមសារ ពេលវេលា ទីតាំង វិធីសាស្ត្រ ក្រុមគោលដៅ បរិមាណនៃការចែកចាយ ឬកញ្ចប់ទាក់ទងនៃការទំនាក់ទំនងដែលផ្តល់ហិរញ្ញប្បទានដោយអ្នកចំណាយ ជាមួយបេក្ខជនដែលការចោះឆ្នោត ឬការស្នើឈ្មោះរបស់គាត់ត្រូវបានគាំទ្រដោយអ្នកចំណាយ ឬដែលមាជ័យរបស់គូប្រជែងរបស់គាត់ត្រូវបានគាំទ្រដោយអ្នកចំណាយ~~

~~(vi) នៅក្នុងវគ្គនៃការបោះឆ្នោតដែលការចំណាយនោះត្រូវបានធ្វើឡើង អ្នកចំណាយ ឬភ្នាក់ងាររបស់អ្នកចំណាយ កំពុងម

(vii) ~~ការចំណាយនោះត្រូវបានធ្វើឡើងបន្ទាប់ពីមានការស្នើសុំទៅកាន់អ្នកចំណាយ ឬភ្នាក់ងាររបស់អ្នកចំណាយ ដោយបេក្ខជន គណៈកម្មាធិការគ្រប់គ្រងរបស់បេក្ខជន ឬភ្នាក់ងាររបស់ពួកគេ សម្រាប់ការចំណាយក្នុងនាមបេក្ខជន ឬ~~

(viii) ~~ការចំណាយនោះត្រូវបានធ្វើឡើងទាក់ទងនឹង ឬជាផលវិបាកនៃព្រឹត្តិការណ៍អង្គាសថវិកា ឬសកម្មភាពយុទ្ធនាការដែលឧបត្ថម្ភរួមគ្នាដោយបេក្ខជន និងអ្នកចំណាយ ឬភ្នាក់ងាររបស់អ្នកចំណាយ ។~~

~~(D) ការចំណាយមួយនឹងមិនត្រូវបានចាត់ទុកថាធ្វើឡើងតាមការស្នើសុំ គ្រាន់តែដោយសារតែ ៖~~

~~(i) អ្នកចំណាយ ឬភ្នាក់ងាររបស់អ្នកចំណាយ សម្គាសបេក្ខជនលើជំហរនីតិបញ្ញត្តិ ឬគោលនយោបាយ ឬបញ្ហាដែលប៉ះពាល់ដល់អ្នកចំណាយ ឬពិភាក្សាអំពីបញ្ហាទាក់ទងនឹងយុទ្ធនាការជាមួយបេក្ខជន ដូចជាវេទិកាយុទ្ធនាការ ព័ត៌មានស្នង់បត្តិ អង្គការណាដែលគាំទ្របេក្ខជន និងអង្គការណាដែលគាំទ្រគូប្រជែងរបស់គាត់ ឬអត្តសញ្ញាណរបស់អ្នកប្រឹក្សាយោបល់ដែលបេក្ខជនមានគម្រោងជួល ដោយផ្តល់ថា បុនពេលធ្វើការចំណាយជាបន្តបន្ទាប់ដោយផ្អែកលើព័ត៌មាននោះ អ្នកចំណាយ ឬភ្នាក់ងាររបស់គាត់មិនបានចំនាក់ចំនងជាមួយបេក្ខជន គណៈកម្មាធិការគ្រប់គ្រងដោយបេក្ខជន ឬភ្នាក់ងាររបស់ពួកគេទាក់ទងនឹងការចំណាយនោះទេ~~

~~(ii) អ្នកចំណាយស្នើសុំ និង/ឬទទួលបានរូបថត ជីវប្រវត្តិ ឯកសារជំហរ សេចក្តីប្រកាសព័ត៌មាន ឬសម្ភាសៈស្រដៀងគ្នាពីបេក្ខជន គណៈកម្មាធិការគ្រប់គ្រងដោយបេក្ខជន ឬភ្នាក់ងាររបស់ពួកគេ ហើយដោយមិនមានការដឹងមុន ការគ្រប់គ្រង ឬការចូលរួមពីបេក្ខជន គណៈកម្មាធិការគ្រប់គ្រងដោយបេក្ខជន ឬភ្នាក់ងាររបស់ពួកគេ ក្រោយមកប្រើប្រាស់ ឬបញ្ចូលព័ត៌មាននោះដើម្បីបង្កើតការចំនាក់ចំនងគាំទ្របេក្ខជន ឬប្រឆាំងនឹងគូប្រជែងរបស់គាត់~~

~~(iii) អ្នកចំណាយបានផ្តល់វិភាគទានពីមុនដល់បេក្ខជន~~

~~(iv) អ្នកចំណាយចំនាក់ចំនងទៅកាន់បេក្ខជន គណៈកម្មាធិការគ្រប់គ្រងដោយបេក្ខជន ឬភ្នាក់ងាររបស់ភាគីណាមួយ អំពីចេតនាធ្វើការចំណាយឯកជាផ្ស ដោយមិនពិភាក្សាអំពីចំណុចណាមួយដែលបានរៀបរាប់នៅក្នុងកថាខណ្ឌរង (C)(v) នៃមាត្រានេះ~~

~~(v) សមាជិកនៃអង្គការដែលធ្វើការចំណាយផ្តល់សេវាផ្ទាល់ខ្លួនដោយស្ម័គ្រចិត្តដល់ ឬធ្វើការសម្រាប់យុទ្ធនាការរបស់បេក្ខជនដែលរងផលប៉ះពាល់ លុះត្រាតែអ្នកស្ម័គ្រចិត្ត ឬអ្នកធ្វើការយុទ្ធនាការនោះក៏បានចូលរួមក្នុងសកម្មភាពរបស់គណៈកម្មាធិការសកម្មភាពនយោបាយរបស់អង្គការអ្នកចំណាយ ឬធ្វើការចូទាត់ប្រាក់ក្នុងនាមអង្គការអ្នកចំណាយ ឬកំពុងបម្រើ ឬបានបម្រើយុទ្ធនាការរបស់បេក្ខជនដែលរងផលប៉ះពាល់ក្នុងសមត្ថភាពមួយដែលបានពិពណ៌នានៅក្នុងកថាខណ្ឌរង (C)(vi) នៃមាត្រានេះ~~

~~(vi) ការចំណាយនោះត្រូវបានធ្វើឡើងដើម្បីឆ្លើយតបទៅនឹងសំណើដែលមិនបានស្វែងរកពីបេដឹកនាំគណបក្សនយោបាយ ឬភ្នាក់ងាររបស់ពួកគេ ឱ្យគណៈកម្មាធិការ "គាំទ្រ" បេក្ខជន ឬធ្វើការចំណាយទាក់ទងនឹងបេក្ខជន~~

~~(vii) ការចំណាយនោះផ្តល់ហិរញ្ញប្បទានដល់ការចំណាយលើការរៀបចំ ឬការផ្សព្វផ្សាយការអាងតម្លៃបេក្ខជនជូនដល់អ្នកបោះឆ្នោត ឬការធ្វើការស្នង់បត្តិនយោបាយ ឬ~~

~~(viii) អ្នកចំណាយជួល ឬស្ថិតនៅក្រោមកិច្ចសន្យាជាមួយអ្នកប្រឹក្សាយោបល់នយោបាយ ឬអ្នកស្នង់បត្តិដែលបានផ្តល់សេវាកម្មដល់បេក្ខជនក្នុងឆ្នាំមុនៗ ។~~

~~(2) "ការិយាល័យគណៈកម្មការអប់រំ" មានន័យថា ការិយាល័យរបស់សមាជិកគណៈកម្មការអប់រំនៃមណ្ឌលសិក្សាធិការរួមរួម Los Angeles ។~~

~~(3) "ភ្នាក់ងារបេក្ខជន ឬគណៈកម្មាធិការ" មានន័យថា បុគ្គលណាម្នាក់ដែលមានសិទ្ធិអំណាចច្បាស់លាស់ ឬ ដោយប្រយោលក្នុងការធ្វើ ឬអនុញ្ញាតឱ្យធ្វើការចំណាយក្នុងនាមបេក្ខជន ។ ត្រូវមានការសន្មតដែលអាចប្រកែកបានថា បុគ្គលដូចខាងក្រោមនេះមានសិទ្ធិអំណាចនោះ ៖ បន្ត្រីបច្ចុប្បន្ន ឬអតីតបន្ត្រីនៃគណៈកម្មាធិការគ្រប់គ្រងដោយបេក្ខជន បុគ្គលិកនៃយុទ្ធនាការ បុគ្គលដែលបានទទួលប្រាក់បំណាច់ ឬសំណងពីយុទ្ធនាការ ឬបុគ្គលណាម្នាក់ដែលត្រូវបានដាក់ក្នុងតំណែងណាមួយនៅក្នុងអង្គការយុទ្ធនាការ ដែលបើលទៅសមហេតុផលថា នៅក្នុងដំណើរការធម្មតានៃសកម្មភាពទាក់ទងនឹងយុទ្ធនាការ គាត់ ឬនាងអាចអនុញ្ញាតឱ្យមានការចំណាយ ។ ភ្នាក់ងាររបស់បេក្ខជនក៏ជាបុគ្គលណាម្នាក់ដែលកំពុងបម្រើការ ឬបានបម្រើការក្នុងតួនាទីប្រឹក្សាយោបល់ ការធ្វើសេចក្តីសម្រេច ឬយុទ្ធសាស្ត្រជាមួយយុទ្ធនាការរបស់បេក្ខជន ដោយមាន ឬគ្មានប្រាក់បំណាច់ ដែលកាតព្វកិច្ច និង/ឬសកម្មភាពរបស់បុគ្គលនោះឆ្លុះបញ្ចាំង ឬតម្រូវឱ្យមានចំណេះដឹងដោយផ្ទាល់អំពីយុទ្ធសាស្ត្រ ផែនការ ឬតម្រូវការយុទ្ធនាការរបស់បេក្ខជន ។~~

~~(4) "ការបោះឆ្នោត" មានន័យថា ការបោះឆ្នោតជ្រើសរើសបេក្ខជនបឋម ការបោះឆ្នោតទូទៅ ការបោះឆ្នោតពិសេស និងការបោះឆ្នោតដកហូតតំណែង ។~~

~~(5) "ការចំណាយឯកវាជ្ស" មានន័យថា ការចំណាយដែលធ្វើឡើងដោយបុគ្គលណាម្នាក់ទាក់ទងនឹងការទំនាក់ទំនងដែលគាំទ្រយ៉ាងច្បាស់លាស់ដល់ការបោះឆ្នោត ឬការបរាជ័យរបស់បេក្ខជនដែលបានកំណត់អត្តសញ្ញាណយ៉ាងច្បាស់ ឬ ដោយពិនិត្យសរុបជារូប និងក្នុងបរិបទ ជំរុញយ៉ាងច្បាស់លាស់ឱ្យមានលទ្ធផលជាក់លាក់បួយនៅក្នុងការបោះឆ្នោត ប៉ុន្តែបិនត្រូវបានធ្វើឡើងជូន ឬតាមការស្នើសុំរបស់បេក្ខជន ឬគណៈកម្មាធិការដែលរងផលប៉ះពាល់នោះទេ ។~~

~~(6) "ប្រាក់កម្ចី" មានន័យ និងត្រូវចាត់ទុកតាមរបៀបដូចខាងក្រោមសម្រាប់គោលបំណងនៃមាត្រានេះ ៖~~

~~(A) ប្រាក់កម្ចីត្រូវចាត់ទុកថាជាវិភាគទានពីអ្នកផ្តល់ប្រាក់កម្ចី និងអ្នកធានាប្រាក់កម្ចី ហើយត្រូវស្ថិតនៅក្រោមដែនកំណត់វិភាគទាននៃមាត្រានេះ ។~~

~~(B) ប្រាក់ចំណូលពីប្រាក់កម្ចីដែលផ្តល់ជូនបេក្ខជនដោយស្ថាប័នផ្តល់ប្រាក់កម្ចីពាណិជ្ជកម្មក្នុងដំណើរការអាជីវកម្មធម្មតាលើលក្ខខណ្ឌដូចគ្នាដែលមានសម្រាប់សាធារណជន ហើយដែលត្រូវ បានធានា បិនត្រូវចាត់ទុកថាជាវិភាគទានក្នុងន័យនៃដែនកំណត់វិភាគទាននៃមាត្រានេះទេ ។~~

~~(C) ការពន្យារពេលឥណទាន (ក្រៅពីប្រាក់កម្ចីដែលបានយោងនៅក្នុងផ្នែកអង (6)(B)) សម្រាប់រយៈពេលលើសពី 30 ថ្ងៃ គឺស្ថិតនៅក្រោមដែនកំណត់វិភាគទាននៃមាត្រានេះ ។~~

~~(7) "ការទំនាក់ទំនងរបស់សមាជិក" មានន័យថា ការទូទាត់ប្រាក់ដែលត្រូវបានធ្វើឡើងអនុលោមតាមក្រមរដ្ឋាភិបាល មាត្រា 85312 ។~~

~~(A) សម្រាប់គោលបំណងនៃមាត្រានេះ ការទូទាត់ប្រាក់សម្រាប់ការទំនាក់ទំនងជាមួយសមាជិកដែលត្រូវបានធ្វើឡើងតាមការស្នើសុំរបស់បេក្ខជន ដោយលើកលែងតែការទូទាត់ប្រាក់សម្រាប់ព្រឹត្តិបត្រព័ត៌មាន ឬទស្សនាវដ្តីដែលចេញផ្សាយជាទៀងទាត់ដែលកប្រិតសម្រាប់តែសមាជិកម្នាក់ៗ និងបិនលើសពីចំនួនទឹកប្រាក់ទូទាត់ដែលត្រូវបានធ្វើឡើងជាទៀងទាត់ដើប្បីបោះពុម្ពផ្សាយព្រឹត្តិបត្រព័ត៌មាន ឬទស្សនាវដ្តីជាទៀងទាត់ ត្រូវចាត់ទុកថាជាវិភាគទានដល់បេក្ខជននោះ ឬគណៈកម្មាធិការគ្រប់គ្រងដោយបេក្ខជន សម្រាប់គោលបំណងនៃលក្ខខណ្ឌតម្រូវក្នុងការរាយការណ៍អំពីដែនកំណត់វិភាគទានដែលមាននៅក្នុងមាត្រានេះ ។~~

~~(B) សម្រាប់គោលបំណងនៃមាត្រានេះ ការទំនាក់ទំនងជាមួយសមាជិកដែលបិនត្រូវបានធ្វើឡើងតាមការស្នើសុំរបស់បេក្ខជន គណៈកម្មាធិការគ្រប់គ្រងដោយបេក្ខជន ឬភ្នាក់ងាររបស់បេក្ខជន ឬគណៈកម្មាធិការគ្រប់គ្រងដោយបេក្ខជន បិនត្រូវចាត់ទុកថាជាវិភាគទានដល់បេក្ខជនឡើយ ។~~

~~(C) ការទំនាក់ទំនងជាមួយសមាជិកដែលបិនត្រូវបានធ្វើឡើងតាមការស្នើសុំរបស់បេក្ខជន គណៈកម្មាធិការគ្រប់គ្រងដោយបេក្ខជន ឬភ្នាក់ងាររបស់បេក្ខជន ឬគណៈកម្មាធិការគ្រប់គ្រងដោយបេក្ខជន ហើយបិនបំនជាការ~~

ទូទាត់ប្រាក់សប្រាប់ព្រឹត្តិបត្រព័ត៌មាន ឬទស្សនាវដ្ដីដែលចេញផ្សាយជាទៀងទាត់ដែលកប្រិតសប្រាប់តែសមាជិកម្នាក់ៗ និងបិនលើសពីចំនួនទឹកប្រាក់ទូទាត់ដែលត្រូវបានធ្វើឡើងជាទៀងទាត់ដើម្បីបោះពុម្ពផ្សាយព្រឹត្តិបត្រព័ត៌មាន ឬទស្សនាវដ្ដីជាទៀងទាត់ ត្រូវចាត់ទុកថាជាការចំណាយ និងតម្រូវឱ្យរាយការណ៍អនុលោបតាមវាក្យខណ្ឌរង ។

(8) "ការចំណាយរបស់បិនបែនបេក្ខជន" មានន័យថា បន្សំណាមួយនៃការចំណាយឯកវាជ្យ និង/ឬការទំនាក់ទំនងជាមួយសមាជិកដែលបិនត្រូវបានធ្វើឡើងតាមការស្នើសុំរបស់បេក្ខជន ។

(b) ដែនកំណត់វិភាគទានយុទ្ធនាការ ។

(1) គ្មានបេក្ខជនដែលមានបំណងឈរឈ្មោះសប្រាប់គណៈកម្មការអប់រំ និងគ្មានគណៈកម្មាធិការដែលធ្វើសកម្មភាពក្នុងនាបបេក្ខជននោះ ត្រូវស្នើសុំ ឬទទួលយក ឬបង្កឱ្យមានការស្នើសុំ ឬទទួលយក វិភាគទានណាមួយសប្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតណាមួយសប្រាប់តំណែងនោះឡើយ លុះត្រាតែ និងរហូតទាល់តែបេក្ខជននោះបានដាក់លិខិតប្រកាសបំណងស្នើសុំ និងទទួលវិភាគទានទាក់ទងនឹងបេក្ខភាពសប្រាប់តំណែងគណៈកម្មការអប់រំជាក់លាក់មួយ ។ លិខិតប្រកាសនោះត្រូវដាក់ជូនគណៈកម្មាការសីលធម៌ក្រុងលើទប្រង់បែបបទដែលបានកំណត់ដោយគណៈកម្មាការសីលធម៌ក្រុង ។ នៅពេលការបោះឆ្នោតប្រព្រឹត្តទៅ លិខិតប្រកាសនោះត្រូវចាត់ទុកជានិរាការណ៍បន្ទាប់ពីនោះ ។ គ្មានបុគ្គលណាម្នាក់អាចមានលិខិតប្រកាសលើសពី មួយ នៅក្នុងសំណុំឯកសារក្នុងពេលតែមួយសប្រាប់សកម្មភាពបោះឆ្នោតទោលណាមួយឡើយ ។ ទោះជាយ៉ាងណាក៏ដោយ បេក្ខជនអាចដាក់ទប្រង់បែបបទលុបចោលលិខិតប្រកាស មួយ ហើយបន្ទាប់ពីនោះអាចដាក់លិខិតប្រកាសថ្មីមួយទៀតបាន ។

(2) បេក្ខជន និងបេឡាធិការនៃគណៈកម្មាធិការគ្រប់គ្រងដោយបេក្ខជន ត្រូវដាក់ជូនគណៈកម្មាការសីលធម៌ក្រុងលើទប្រង់បែបបទដែលបានកំណត់ដោយគណៈកម្មាការសីលធម៌ក្រុង នូវសេចក្តីថ្លែងការណ៍ក្រោមការស្បថថាតែបេក្ខជន និងបេឡាធិការបានអាន និងយល់ព្រមតាម មាត្រា 803 ។ សេចក្តីថ្លែងការណ៍នេះត្រូវដាក់ក្នុងពេលដំណាលគ្នាជាមួយនឹងការដាក់លិខិតប្រកាសបំណងស្នើសុំ និងទទួលវិភាគទាន ។

(3) គ្មានបុគ្គលណាម្នាក់ត្រូវផ្តល់វិភាគទានសរុបលើសពី $1,000 ដល់បេក្ខជនណាម្នាក់សប្រាប់គណៈកម្មការអប់រំ និងដល់គណៈកម្មាធិការគ្រប់គ្រងដោយបេក្ខជនសប្រាប់សកម្មភាពបោះឆ្នោតទោលណាមួយឡើយ ។ បេក្ខជនសប្រាប់គណៈកម្មការអប់រំបិនត្រូវទទួលយកវិភាគទាន ឬវិភាគទានសរុបលើសពី $1,000 ពីបុគ្គលណាម្នាក់សប្រាប់សកម្មភាពបោះឆ្នោតទោលណាមួយឡើយ ។ គ្មានអ្វីនៅក្នុងមាត្រានេះមានបំណងកប្រិតចំនួនទឹកប្រាក់ដែលបេក្ខជនអាចផ្តល់វិភាគទានដល់បេក្ខភាពរបស់គាត់សប្រាប់គណៈកម្មការអប់រំចេញពីមូលនិធិផ្ទាល់ខ្លួនរបស់គាត់ឡើយ ។

(4) [ត្រូវបានលុបចោល ។]

(5) គ្មានបុគ្គលណាម្នាក់ត្រូវផ្តល់វិភាគទានទាក់ទងនឹងការបោះឆ្នោតទោលណាមួយសប្រាប់តំណែងគណៈកម្មការអប់រំ ដែលនឹងធ្វើឱ្យចំនួនសរុបនៃវិភាគទានទាំងនោះដោយបុគ្គលរូបនោះលើសពីចំនួនស្មើនឹង $1,000 គុណនឹងចំនួនតំណែងគណៈកម្មការអប់រំដែលបង្ហាញនៅលើសន្លឹកឆ្នោតនៅក្នុងការបោះឆ្នោតនោះឡើយ ប៉ុន្តែក្នុងការណីណាក៏ដោយបិនត្រូវតិចជាង $2,000 ឡើយ ទាក់ទងនឹងបេក្ខជនទាំងអស់នៅក្នុងការបោះឆ្នោតនោះដែលស្វែងរកការបោះឆ្នោតជ្រើសរើសចូលកាន់តំណែងគណៈកម្មការអប់រំទាំងអស់ ដោយផ្តល់ថា ទោះជាយ៉ាងណាក៏ដោយ បេក្ខជនបិនត្រូវកប្រិតដោយផ្នែករង (5) នេះនៅក្នុងចំនួនទឹកប្រាក់ដែលគាត់អាចផ្តល់វិភាគទាន ឬចំណាយទាក់ទងនឹងយុទ្ធនាការផ្ទាល់ខ្លួនរបស់គាត់ឡើយ ។

(6) គ្មានបុគ្គលណាម្នាក់ត្រូវផ្តល់ ហើយគ្មានបុគ្គល ឬបេក្ខជនណាម្នាក់ត្រូវស្នើសុំ ឬទទួលយកប្រាក់កម្ចីលើសពី $1,000 សប្រាប់ប្រើប្រាស់ទាក់ទងនឹងការបោះឆ្នោតសប្រាប់គណៈកម្មការអប់រំឡើយ ។ លើសពីនេះ គ្មានបុគ្គលណាម្នាក់ត្រូវផ្តល់ ហើយគ្មានបុគ្គល ឬបេក្ខជនណាម្នាក់ត្រូវស្នើសុំ ឬទទួលយកប្រាក់កម្ចីសប្រាប់ប្រើប្រាស់ទាក់ទងនឹងការបោះឆ្នោតសប្រាប់តំណែងគណៈកម្មការអប់រំសប្រាប់រយៈពេលលើសពី 30 ថ្ងៃឡើយ ។ ប្រាក់កម្ចីដល់បេក្ខជន ឬដល់គណៈកម្មាធិការគ្រប់គ្រងដោយបេក្ខជន ត្រូវរាប់បញ្ចូលក្នុងដែនកំណត់វិភាគទានដែលអាចអនុវត្តបានចំពោះបេក្ខជន ។ បេក្ខជនបិនត្រូវហាមឃាត់បិនឱ្យទទួលបានប្រាក់កម្ចីផ្ទាល់ខ្លួននៃចំនួនទឹកប្រាក់ណាមួយពីស្ថាប័នផ្តល់ប្រាក់កម្ចីហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណក្នុងដំណើរការអាជីវកម្មធម្មតាឡើយ លុះត្រាតែប្រាក់កម្ចីនោះត្រូវធ្វើឡើងសប្រាប់គោលបំណង

~~នយោបាយ ។ រាល់ប្រាក់កម្ចីដល់បេក្ខជន ឬគណៈកម្មាធិការគ្រប់គ្រងដោយបេក្ខជន ត្រូវធ្វើឡើងដោយកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ ដែលត្រូវដាក់ជូនជាបូយនឹងរបាយការណ៍យុទ្ធនាការរបស់បេក្ខជន ឬគណៈកម្មាធិការដែលប្រាក់កម្ចីនោះត្រូវរាយការណ៍ជាលើកដំបូង ។ ផ្នែករង (6) នេះ បិនត្រូវកប្រិតចំនួនទឹកប្រាក់ ឬរយៈពេលនៃប្រាក់កម្ចីពីបេក្ខជនដល់យុទ្ធនាការផ្ទាល់ខ្លួនរបស់គាត់ឡើយ ។~~

~~(7) រិភាគទានណាបូយដែលបានស្នើសុំ ឬទទួលយកអនុលោមតាមបាត្រានេះ ត្រូវចំណាយតែទាក់ទងនឹងបេក្ខភាពសម្រាប់តំណែងដែលបានបញ្ជាក់នៅក្នុងលិខិតប្រកាសបំណងស្នើសុំ និងទទួលរិភាគទានរបស់បេក្ខជនប៉ុណ្ណោះ ។ រិភាគទានដែលបានស្នើសុំ ឬទទួលយកអនុលោមតាមបាត្រានេះសម្រាប់បុគ្គល បូយ រូប បិនត្រូវចំណាយសម្រាប់បេក្ខភាពរបស់បុគ្គលផ្សេងទៀតដែលស្វែងរកតំណែងគណៈកម្មការអប់រំផ្សេងទៀត ឬក្នុងការគាំទ្រ ឬការប្រឆាំងនឹងរិធានការនៃសន្លឹកឆ្នោតបណ្ឌលសិក្សាធិការរួបរួប Los Angeles ណាបូយឡើយ ។ គ្មានបេក្ខជន គណៈកម្មាធិការគ្រប់គ្រងដោយបេក្ខជន ឬសមាជិកជាប់ឆ្នោតនៃគណៈកម្មការអប់រំណាម្នាក់ ត្រូវប្រើប្រាស់បូលនិធិរិភាគទានដើម្បីផ្គល់រិភាគទានណាបូយដល់បេក្ខជនផ្សេងទៀតដែលឈរឈ្មោះសម្រាប់តំណែង ឬដល់គណៈកម្មាធិការណាបូយដែលគាំទ្រ ឬប្រឆាំងនឹងបេក្ខជនសម្រាប់តំណែងឡើយ ។ ដោយផ្គល់ថា ទោះជាយ៉ាងណាក៏ដោយ បេក្ខជនបិនត្រូវហាមយាត់បិនឱ្យផ្គល់រិភាគទានពីបូលនិធិផ្ទាល់ខ្លួនរបស់គាត់ដល់បេក្ខភាពផ្ទាល់ខ្លួនរបស់គាត់ ដល់បេក្ខភាពរបស់បេក្ខជនផ្សេងទៀត ឬក្នុងការគាំទ្រ ឬការប្រឆាំងនឹងរិធានការសន្លឹកឆ្នោតបណ្ឌលសិក្សាធិការរួបរួប Los Angeles ណាបូយឡើយ ។~~

~~**(c) ការកែសប្រួលដែនកំណត់ ។** រៀងរាល់បួនឆ្នាំម្តង គណៈកម្មាការសីលធប៍ក្រុងត្រូវពិនិត្យឡើងវិញថាតើដែនកំណត់រិភាគទានដែលមាននៅក្នុងបាត្រានេះគួរតែត្រូវកែសប្រួលដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរនៅក្នុងសន្ទស្សន៍តម្លៃចំនិញប្រើប្រាស់ (CPI) សម្រាប់តំបន់ស្ថិតិប្រជុំជន Los Angeles-Long Beach ដែរឬទេ ។ ការពិនិត្យឡើងវិញលើកដំបូងត្រូវចាប់ផ្តើបនៅចុងឆ្នាំប្រតិទិន 2011 ។ ប្រសិនបើដែនកំណត់រិភាគទានបិនត្រូវបានកែសប្រួលក្នុងរំឡុងពេលពិនិត្យឡើងវិញណាបូយទេ ដែនកំណត់នោះអាចត្រូវកែសប្រួលនៅក្នុងរយៈពេលពិនិត្យឡើងវិញបួនឆ្នាំបន្ទាប់ទៀត រហូតដល់ការកើនឡើងសរុបនៅក្នុង CPI ចាប់តាំងពីការកែសប្រួលលើកចុងក្រោយ ។ ការផ្លាស់ប្តូរណាបូយចំពោះដែនកំណត់រិភាគទានត្រូវមានប្រសិទ្ធភាពសម្រាប់ការបោះឆ្នោតបន្ទាប់បន្សំ ដែលរយៈពេលរៃអង្គាសថវិកាបិនទាន់បើកដំណើរការដូចមានចែងនៅក្នុងវាក្យខណ្ឌរង (q) ឡើយ ។ គណៈកម្មាការសីលធប៍ក្រុងត្រូវបញ្ជូនរបាយការណ៍ជាបូយនឹងរកឃើញរបស់ខ្លួនទៅកាន់ក្រុបប្រឹក្សាត្រឹបថ្ងៃទី 1 ខែបីនា បន្ទាប់ពីការពិនិត្យឡើងវិញនីបូយៗ ។ ក្នុងរយៈពេល 60 ថ្ងៃបន្ទាប់ពីគណៈកម្មាការសីលធប៍ក្រុងបញ្ជូនរបាយការណ៍របស់ខ្លួនទៅកាន់ក្រុបប្រឹក្សាក្រុបប្រឹក្សាត្រូវរៀបចំការស្តាប់បតិសាធារណៈអំពីបញ្ហានេះ និងអនុវត្តដើម្បីអនុម័ត ឬបដិសេធរបាយការណ៍នោះ ។ ប្រសិនបើក្រុបប្រឹក្សាបិនបានបដិសេធក្នុងរយៈពេល 60 ថ្ងៃទេ របាយការណ៍នោះត្រូវដាក់ជូនចៅហ្វាយក្រុងដើម្បីអនុម័ត ឬបដិសេធ និងជូនក្រុបប្រឹក្សាដើម្បីបដិសេធការបដិសេធរបស់ចៅហ្វាយក្រុង ។ ប្រសិនបើត្រូវបានអនុម័តដោយចៅហ្វាយក្រុង ឬប្រសិនបើចៅហ្វាយក្រុងបិនបានអនុវត្ត ឬប្រសិនបើត្រូវបានអនុម័តដោយក្រុបប្រឹក្សាលើការបដិសេធការបដិសេធរបស់ចៅហ្វាយក្រុង ចំនួនដែលបានបញ្ជាក់នៅក្នុងរបាយការណ៍ត្រូវមានកម្លាំងច្បាប់ជាដែនកំណត់រិភាគទានដែលអាចអនុវត្តបានចំពោះមាត្រានេះ ដោយស្ថិតនៅក្រោមទោសទណ្ឌ និងដំណោះស្រាយទាំងអស់នៅក្នុងមាត្រានេះ ។~~

~~**(d) រិភាគទានសាច់ប្រាក់ និងរិភាគទានបិនបញ្ចេញឈ្មោះ ។** គ្មានបុគ្គលណាម្នាក់ត្រូវផ្គល់ ហើយគ្មានបេក្ខជន ឬគណៈកម្មាធិការណាម្នាក់ត្រូវស្នើសុំ ឬទទួលយក រិភាគទានសាច់ប្រាក់លើសពី $25 ឡើយ ។ រិភាគទានបិនបញ្ចេញឈ្មោះសរុបចំពោះបេក្ខជន ឬគណៈកម្មាធិការដែលលើសពីចំនួនសរុប $200 ទាក់ទងនឹងការបោះឆ្នោតទោលណាបូយ បិនត្រូវប្រើប្រាស់ដោយបេក្ខជន ឬគណៈកម្មាធិការដែលរិភាគទានទាំងនោះត្រូវ បានបំណងផ្គល់ជូនឡើយ ប៉ុន្តែជំនួសបកវិញ ចំនួនលើសនោះត្រូវទូទាត់ប្រាក់ភ្លាមៗទៅកាន់បេឡាធិការក្រុងសម្រាប់ការតម្កល់នៅក្នុងបូលនិធិទូទៅនៃក្រុង ។~~

~~**(e) គណនីបូលប្បទានប័ត្រវិភាគទានយុទ្ធនាការ ។** បិនត្រូវបង្កើតគណនីបូលប្បទានប័ត្រវិភាគទានយុទ្ធនាការលើសពី បូយ ឡើយដោយបេក្ខជនម្នាក់ៗសម្រាប់តំណែងគណៈកម្មការអប់រំ និងដោយគណៈកម្មាធិការម្នាក់ៗដែលគាំទ្រ ឬប្រឆាំងនឹងបេក្ខជននោះ ។ គណនីនោះត្រូវបង្កើតឡើងនៅការិយាល័យធនាគារ ឬស្ថាប័នសន្សំ និងប្រាក់កម្ចីដែលមានទីតាំងនៅក្នុងទីក្រុង Los Angeles ។ នៅពេលបើកគណនីនោះ បេក្ខជនត្រូវដាក់ជូនគណៈកម្មាការសីលធប៍ក្រុងក្នុងរយៈពេលដប់ថ្ងៃបន្ទាប់ពីការបើកគណនីធនាគារយុទ្ធនាការ នូវឈ្មោះធនាគារ ឬស្ថាប័នសន្សំ និងប្រាក់កម្ចី និងលេខគណនី ។ បូលនិធិត្រូវបើកផ្គល់ពីគណនីនោះបានតែតាមរយៈបូលប្បទានប័ត្រដែលបានចុះហត្ថលេខាដោយបេក្ខជន បេឡាធិការ ឬភ្នាក់ងារដែលបានកំណត់~~

របស់បេឡាធិការប៉ុណ្ណោះ ។ បេក្ខជន បេឡាធិការ ឬភ្នាក់ងារដែលបានកំណត់របស់បេឡាធិការ ត្រូវតម្កល់ចូលក្នុងគណនីបូលប្បទានប័ត្រយុទ្ធនាការនូវវិភាគទានទាំងអស់ដែលបានទទួលទាក់ទងនឹងការបោះឆ្នោតគណៈកម្មការអប់រំ ។ បេក្ខជន បេឡាធិការ ឬភ្នាក់ងារដែលបានកំណត់របស់បេឡាធិការ ត្រូវទូទាត់ប្រាក់សប្រាប់ការចំណាយយុទ្ធនាការទាំងអស់សប្រាប់ការបោះឆ្នោតគណៈកម្មការអប់រំជាបួយនឹងប្រាក់ពីគណនីបូលប្បទានប័ត្រយុទ្ធនាការនេះ ។

ប្រសិនបើបេក្ខជនមានគណៈកម្មាធិការគ្រប់គ្រងផ្សេងទៀត ហើយគណៈកម្មាធិការទាំងនោះមានគណនីបូលប្បទានប័ត្រ បេក្ខជនត្រូវជូនដំណឹងទៅគណៈកម្មាការសីលធម៌ក្រុងជាលាយលក្ខណ៍អក្សរអំពីគណៈកម្មាធិការទាំងនេះ និងឈ្មោះ ព្រមទាំងអាសយដ្ឋាននៃធនាគារ ឬស្ថាប័នសន្សំ និងប្រាក់កម្ចី និងលេខគណនីនៃគណនីណាបួយទាំងនោះ ។ បេក្ខជនត្រូវជូនដំណឹងទៅគណៈកម្មាការសីលធម៌ក្រុងអំពីគណៈកម្មាធិការទាំងនេះ ធនាគារ ឬស្ថាប័នសន្សំ និងប្រាក់កម្ចី និងលេខគណនីក្នុងពេលដំណាលគ្នាជាបួយនឹងការដាក់លិខិតប្រកាសបំណងស្នើសុំ និងទទួលវិភាគទាន ។ ប្រសិនបើគណៈកម្មាធិការត្រូវបានបង្កើតឡើងបន្ទាប់ពីនោះ ឬគណនីត្រូវបានបើកបន្ទាប់ពីនោះ បន្ទាប់បកបេក្ខជនត្រូវជូនដំណឹងទៅគណៈកម្មាការសីលធម៌ក្រុងនៅថ្ងៃធ្វើការធម្មតាបន្ទាប់ដែលការិយាល័យគណៈកម្មាការសីលធម៌ក្រុងបើកដំណើរការ ។ ត្មានវិភាគទានណាបួយត្រូវប្រមូកប្រមល់ជាបួយនឹងបូលនិធិផ្ទាល់ខ្លួនរបស់បេក្ខជន ឬបុគ្គលផ្សេងទៀតឡើយ ។

ផ្នែកអងនេះបិនត្រូវហាបយាត់ការបង្កើតគណនីសន្សំ ឬវិញ្ញាបនបត្រប្រាក់បញ្ញើឡើយ ដោយផ្តល់ថា ត្មានការចំណាយយុទ្ធនាការណាបួយអាចត្រូវធ្វើឡើងពីគណនីទាំងនោះបានឡើយ ។

(f) ហិរញ្ញិក ។ បេក្ខជនដែលមានគណៈកម្មាធិការយុទ្ធនាការសប្រាប់ការបោះឆ្នោតជ្រើសរើសក្រុបប្រឹក្សារអប់រំ ត្រូវចាត់តាំងហិរញ្ញិក បួយ រូបសប្រាប់គណៈកម្មាធិការនីបួយៗ ។ ត្មានការចំណាយណាបួយត្រូវធ្វើឡើងដោយ ឬក្នុងនាបគណៈកម្មាធិការដោយត្មានការអនុញ្ញាតពីហិរញ្ញិក ឬពីភ្នាក់ងារដែលបានកំណត់របស់គាត់ឡើយ ។ ត្មានវិភាគទាន ឬការចំណាយណាបួយត្រូវទទួលយក ឬធ្វើឡើងដោយ ឬក្នុងនាបគណៈកម្មាធិការនៅពេលដែលមានតំណែងទំនេរនៃតំណែងហិរញ្ញិកឡើយ ។ វាជាការពត្វកិច្ចរបស់បេក្ខជន និងហិរញ្ញិកក្នុងការអនុប័ត និងអនុញ្ញាតការទូទាត់ប្រាក់ទាំងនោះ និងរក្សាទុកនូវការអនុញ្ញាត គណនីលម្អិត កំណត់ត្រា វិក័យប័ត្រ និងប័ណ្ណសារពើភ័ណ្ឌទាំងនោះ ។

(g) ការបណ្តុះបណ្តាលសប្រាប់បេក្ខជន និងហិរញ្ញិក ។ បេក្ខជនគ្រប់រូបសប្រាប់ក្រុបប្រឹក្សារអប់រំ និងហិរញ្ញិកគ្រប់រូបនៃគណៈកម្មាធិការគ្រប់គ្រងដោយបេក្ខជននោះ ត្រូវចូលរួបកម្មវិធីបណ្តុះបណ្តាលដែលរៀបចំ ឬឧបត្ថម្ភដោយគណៈកម្មាការសីលធម៌ក្រុង បុនពេលការបោះឆ្នោតដែលឈ្មោះរបស់បេក្ខជននឹងបង្ហាញនៅលើសន្លឹកឆ្នោត ។

(h) គណនេយ្យភាព ។ បេក្ខជន និងហិរញ្ញិកត្រូវរក្សាទុកនូវគណនីលម្អិត កំណត់ត្រាវិក័យប័ត្រ និងប័ណ្ណសារពើភ័ណ្ឌទាំងនោះ តាបការចាំបាច់ដើម្បីរៀបចំរបាយការណ៍យុទ្ធនាការ ។ បេក្ខជន និងហិរញ្ញិកត្រូវរក្សាទុកនូវគណនីលម្អិត កំណត់ត្រាវិក័យប័ត្រ និងប័ណ្ណសារពើភ័ណ្ឌសប្រាប់រយៈពេលដែលបានបញ្ជាក់នៅក្នុងច្បាប់កំណែទប្រង់នយោបាយឆ្នាំ 1974 ដែលបានកែប្រែ ។ បេក្ខជន និងគណៈកម្មាធិការគ្រប់រូបត្រូវផ្តល់ជូនតាបការទាបទារដល់បន្ត្រីសាធារណៈណាម្នាក់ដែលមានសិទ្ធិអំណាចផ្លូវច្បាប់ក្នុងការអនុវត្តមាត្រានេះ នូវព័ត៌មានលម្អិតនៃគណនីបូលប្បទានប័ត្រ និងគណនីហិរញ្ញវត្ថុនៃគណៈកម្មាធិការនីបួយៗ ដែលគ្រប់គ្រងដោយបេក្ខជន និងកំណត់ត្រាទាំងអស់ដែលគាំទ្រព័ត៌មានលម្អិតទាំងនោះ ។

(i) បូលនិធិសាច់ប្រាក់បន្តិចបន្តួច ។ ទោះបីជាមានចែងក្នុងផ្នែកអង (e) ក៏ដោយ បេក្ខជន ហិរញ្ញិកយុទ្ធនាការ និងភ្នាក់ងារដែលបានកំណត់ផ្សេងទៀតដែលមានសិទ្ធិអំណាចក្នុងការចេញបូលប្បទានប័ត្រលើគណនីបូលប្បទានប័ត្រវិភាគទានយុទ្ធនាការអាចបើកផ្តល់ជូនបេក្ខជន ឬគណៈកម្មាធិការដែលបង្កើតគណនីបូលប្បទានប័ត្រនូវចំនួនទឹកប្រាក់បិនលើសពី $50 ក្នុង បួយសប្តាហ៍ ដើម្បីប្រើប្រាស់សប្រាប់គោលបំណងសាច់ប្រាក់តូចតាចដោយបេក្ខជន ឬគណៈកម្មាធិការ ។

(j) វិភាគទានឈ្មោះក្លែងក្លាយ ។ ត្មានវិភាគទានណាបួយត្រូវធ្វើឡើងដោយផ្ទាល់ ឬដោយប្រយោល ដោយបុគ្គលណាម្នាក់ ឬបន្សំនៃបុគ្គល ធ្វើសកម្មភាពរួបគ្នាក្នុងឈ្មោះផ្សេងពីឈ្មោះដែលពួកគេត្រូវបានកំណត់អត្តសញ្ញាណសប្រាប់គោលបំណងផ្លូវច្បាប់ ឬក្នុងឈ្មោះបុគ្គលផ្សេងទៀត ឬបន្សំនៃបុគ្គលឡើយ ។ ត្មានបុគ្គលណាម្នាក់ត្រូវផ្តល់វិភាគទានក្នុងឈ្មោះរបស់គាត់ នាង ឬឈ្មោះខ្លួនឯង នូវអ្វីដែលជាកម្មសិទ្ធិរបស់បុគ្គលផ្សេងទៀត ឬទទួល បានពីបុគ្គលផ្សេងទៀតក្នុងលក្ខខណ្ឌថា វាត្រូវប្រើប្រាស់ជាវិភាគទានឡើយ ។ នៅក្នុងករណីដែលបេក្ខជន ឬហិរញ្ញិកគណៈកម្មាធិការអកយើញថា វិភាគទានបួយត្រូវបានទទួលដោយ

រំលោភលើផ្នែកអងនេះ បេក្ខជន ឬហិរញ្ញិកត្រូវទូទាត់ប្រាក់ភ្លាមៗនូវចំនួនដែលបានទទួលដោយរំលោភលើផ្នែកអងនេះទៅកាន់ហេរញ្ញិកក្រុងសម្រាប់ការតម្កល់នៅក្នុងបូលនិធិទូទៅនៃក្រុង ។

~~(k) ការចំណាយយុទ្ធនាការ - បិនត្រប់ត្រងដោយបេក្ខជន ឬគណៈកម្មាធិការ ។~~ បុគ្គល ឬអង្គការដែលបិនស្ថិតនៅក្រោមការត្រប់ត្រងរបស់បេក្ខជន ឬគណៈកម្មាធិការ ប៉ុន្តែធ្វើការចំណាយឯកវាផ្សសម្រាប់ ឬប្រឆាំងនឹងបេក្ខជន ឬគណៈកម្មាធិការ ត្រូវបញ្ជាក់យ៉ាងច្បាស់នៅលើសម្ភារណាបួយដែលបានបោះពុម្ពផ្សាយ បង្ហាញ ឬផ្សព្វផ្សាយថា វាត្រូវបានធ្វើឡើងដោយគ្មានការអនុញ្ញាតពីបេក្ខជន ឬគណៈកម្មាធិការដែលត្រប់ត្រងដោយបេក្ខជនឡើយ ។

~~(l) ញត្តិទាបទារអោយដកតំណែង ។~~ នៅក្នុងករណីដែលញត្តិទាបទារអោយដកតំណែងត្រូវបានដាក់ គណៈកម្មាធិការ ឬបុគ្គលដែលដាក់ញត្តិនោះត្រូវស្ថិតនៅក្រោមលក្ខខណ្ឌបង្ហាញព័ត៌មានយុទ្ធនាការដូចគ្នា ដែលអាចអនុវត្តបានចំពោះបេក្ខជន សម្រាប់គណៈកម្មការអប់រំ ។

~~(m) អ្នកផ្គត់ផ្គង់ទំនិញ និងសេវាកម្ម - ការបង្ហាញកំណត់ត្រាដែលតម្រូវ ។~~ គ្មានបុគ្គលណាម្នាក់ដែលផ្គត់ផ្គង់ទំនិញ ឬសេវាកម្ម ឬទាំងទំនិញ និងសេវាកម្មដល់បេក្ខជន ឬគណៈកម្មាធិការសម្រាប់ប្រើប្រាស់ទាក់ទងនឹងយុទ្ធនាការសម្រាប់តំណែង គណៈកម្មការអប់រំ ត្រូវបដិសេធដោយចេតនាក្នុងការទម្លាយ ឬបង្ហាញដូនគណៈកម្មាការសីលធម៌ក្រុង ឬជូនបន្ត្រីសាធារណៈណាម្នាក់ដែលបានសិទ្ធិអំណាចផ្លូវច្បាប់ក្នុងការអនុវត្តមាត្រានេះ នូវព័ត៌មានលម្អិត និងកំណត់ត្រាដែលគាំទ្រព័ត៌មានលម្អិតទាំងនោះនៃការចំណាយណាបួយដែលធ្វើឡើងដោយបេក្ខជន ឬគណៈកម្មាធិការក្នុងការទូទាត់ប្រាក់សម្រាប់ទំនិញ ឬសេវាកម្ម ឬទាំងពីរនោះឡើយ ។

~~(n) ការបូកសរុបការទូទាត់ប្រាក់ ។~~ សម្រាប់គោលបំណងនៃដែនកំណត់វិភាគទានដែលបាននៅក្នុងមាត្រានេះ វិភាគទាន និង/ឬការចំណាយពីបុគ្គលពីរ ឬច្រើនរូបនឹងត្រូវបូកសរុបចូលគ្នា និងចាត់ទុកថាធ្វើឡើងដោយបុគ្គលតែ បួយ រូបសម្រាប់គោលបំណងនៃដែនកំណត់វិភាគទាន និងលក្ខខណ្ឌរាយការណ៍ដែលបាននៅក្នុងមាត្រានេះ ប្រសិនបើកាលៈទេសៈណាបួយដែលបានចុះបញ្ជីខាងក្រោមអាចអនុវត្តបាន ៖

~~(1) វិភាគទាន និង/ឬការចំណាយពីបុគ្គលម្នាក់នឹងត្រូវបូកសរុបចូលគ្នាជាបួយនឹងវិភាគទាន និង/ឬការចំណាយពីបុគ្គលផ្សេងទៀតណាបួយដែលគ្រប់ត្រងសកម្មភាពវិភាគទាន ឬការចំណាយរបស់គាត់ នាង ឬរបស់ខ្លួន~~

~~(2) វិភាគទាន និង/ឬការចំណាយពីគណៈកម្មាធិការដែលទទួលបានការឧបត្ថម្ភ ដូចដែលបានកំណត់នៅក្នុងក្របរដ្ឋាភិបាល មាត្រា 82048.7 ត្រូវបូកសរុបចូលគ្នាជាបួយនឹងវិភាគទាន និង/ឬការចំណាយពីអង្គការឧបត្ថម្ភរបស់ខ្លួន~~

~~(3) វិភាគទាន និង/ឬការចំណាយពីអង្គភាពបួយត្រូវបូកសរុបចូលគ្នាជាបួយនឹងវិភាគទាន និង/ឬការចំណាយពីអង្គភាពផ្សេងទៀតណាបួយដែលបានបុគ្គលដូចគ្នាបង្កើតបានជាភាគច្រើននៃសមាជិកក្រុបប្រឹក្សាភិបាលនៃអង្គភាពនីបួយ ។~~

~~(4) វិភាគទាន និង/ឬការចំណាយពីអង្គភាពបួយត្រូវបូកសរុបចូលគ្នាជាបួយនឹងវិភាគទាន និង/ឬការចំណាយពីអង្គភាពផ្សេងទៀតណាបួយដែលបានបន្ត្រីដូចគ្នា ឬជាបួយអង្គភាពដែលខ្លួនចែកវំលែកភាគច្រើននៃបន្ត្រី ។ សម្រាប់គោលបំណងនៃផ្នែកអងនេះ បន្ត្រីបិនរាប់បញ្ចូលបុគ្គលដែលបម្រើការត្រឹមតែជាសមាជិកក្រុបប្រឹក្សាភិបាលនៃអង្គភាពនោះឡើយ~~

~~(5) វិភាគទាន និង/ឬការចំណាយពីក្រុបហ៊ុនសាជីវកម្ម ឬក្រុបហ៊ុនទទួលខុសត្រូវបានកម្រិត ត្រូវបូកសរុបចូលគ្នាជាបួយនឹងវិភាគទាន និង/ឬការចំណាយពីក្រុបហ៊ុនសាជីវកម្ម ឬក្រុបហ៊ុនទទួលខុសត្រូវបានកម្រិតផ្សេងទៀតណាបួយដែលបានម្ចាស់ភាគហ៊ុនភាគច្រើន និង/ឬសមាជិកដូចគ្នា ឬដែលកាន់កាប់ភាគច្រើននៃសិទ្ធិបោះឆ្នោតនៅក្នុងក្រុបហ៊ុនសាជីវកម្ម ឬក្រុបហ៊ុនទទួលខុសត្រូវបានកម្រិតនោះ~~

~~(6) វិភាគទាន និង/ឬការចំណាយពីក្រុបហ៊ុនសាជីវកម្មត្រូវបូកសរុបចូលគ្នាជាបួយនឹងវិភាគទាន និង/ឬការចំណាយពីក្រុបហ៊ុនសាជីវកម្មបេ ឬក្រុបហ៊ុនបុត្រសម្ព័ន្ធណាបួយ ដោយផ្តល់ថា យ៉ាងហោចណាស់ក្រុបហ៊ុនសាជីវកម្មបួយ មិនត្រូវបានផ្ទញដូរសាធារណៈឡើយ~~

~~(7) វិភាគទាន និង/ឬការចំណាយពីបុគ្គលម្នាក់ត្រូវបូកសរុបចូលគ្នាជាបួយនឹងវិភាគទាន និង/ឬការចំណាយពីក្រុមហ៊ុនសាជីវកម្ម ក្រុមហ៊ុនទទួលខុសត្រូវបានកម្រិត ក្រុមហ៊ុន អាជីវកម្មរួមគ្នាសហការ ក្រុមបណ្តាញ អាណាព្យាបាលអាជីវកម្ម ក្រុមហ៊ុន ឬអង្គភាពអាជីវកម្មផ្សេងទៀតដែលមិនបានពិពណ៌នានៅក្នុងផ្នែកអង (8) ឬ (9) ខាងក្រោម ដែលបុគ្គលនោះកាន់កាប់ការវិនិយោគ 50% ឬច្រើនជាងនេះ ឬកាន់កាប់ភាគច្រើននៃសិទ្ធិបោះឆ្នោត~~

~~(8) វិភាគទាន និង/ឬការចំណាយពីបុគ្គលម្នាក់ត្រូវបូកសរុបចូលគ្នាជាបួយនឹងវិភាគទាន និង/ឬការចំណាយពីអាជីវកម្មម្ចាស់ផ្ទាល់ខ្លួនណាបួយដែលបុគ្គលនោះកាន់កាប់ ឬ~~

~~(9) វិភាគទាន និង/ឬការចំណាយពីដៃគូទូទៅត្រូវបូកសរុបចូលគ្នាជាបួយនឹងវិភាគទាន និង/ឬការចំណាយពីក្រុមហ៊ុនដៃគូទូទៅ ឬក្រុមហ៊ុនដៃគូមានកម្រិតណាបួយដែលដៃគូទូទៅនោះកាន់កាប់ការវិនិយោគ 50% ឬច្រើនជាងនេះ ឬដែលដៃគូទូទៅនោះកាន់កាប់ភាគច្រើននៃសិទ្ធិបោះឆ្នោត ។~~

~~**(o) វិភាគទានគ្រួសារ ។** វិភាគទានដោយប្តី និងប្រពន្ធត្រូវចាត់ទុកជាវិភាគទានដាច់ដោយឡែកពីគ្នា ។ វិភាគទានដោយកុមារដែលមានអាយុក្រោម ដប់ប្រាំបី ឆ្នាំ ត្រូវចាត់ទុកជាវិភាគទានដោយឪពុកម្តាយរបស់ពួកគេ និងត្រូវបានប្រគល់ជូនតាមសមាបាត្រដល់ឪពុកម្តាយម្នាក់ៗ (បួយភាគពីរ ដល់ឪពុកម្តាយម្នាក់ៗ ឬចំនួនសរុបដល់ឪពុកម្តាយដែលគ្រប់គ្រងថែរក្សាតែ បួយរូប) ។~~

~~**(p) ការប្រគល់វិភាគទានវិញ ។** វិភាគទានមិនត្រូវចាត់ទុកថាត្រូវបានទទួលឡើយ ប្រសិនបើវាមិនត្រូវបានចរចា តម្កល់ ឬប្រើប្រាស់ ហើយត្រូវបានប្រគល់ជូនម្ចាស់ជំនួយវិញក្នុងរយៈពេល 14 ថ្ងៃបន្ទាប់ពីទទួលបាន ។~~

~~**(q) ការកម្រិតលើពេលវេលាដែលអាចទទួលវិភាគទានបាន ។** គ្មានបេក្ខជនសម្រាប់គណៈកម្មការរៈប់រំ ឬគណៈកម្មាធិការគ្រប់គ្រងរបស់បេក្ខជននោះ ត្រូវស្នើសុំ ឬទទួលយក ឬបណ្តាលឱ្យមានការស្នើសុំ ឬទទួលយកវិភាគទានណាបួយលើសពី 18 ខែបុនកាលបរិច្ឆេទនៃការបោះឆ្នោតដែលបេក្ខជនស្វែងរកតំណែងឡើយ ។ គ្មានបេក្ខជនសម្រាប់គណៈកម្មការរៈប់រំ ឬគណៈកម្មាធិការគ្រប់គ្រងរបស់គាត់ ត្រូវស្នើសុំ ឬទទួល ឬបណ្តាលឱ្យមានការស្នើសុំ ឬទទួលវិភាគទានដល់គណៈកម្មាធិការយុទ្ធនាការផ្ទាល់ខ្លួនរបស់គាត់ពីបុគ្គលណាម្នាក់ក្រោយជាងប្រាំបួនខែបន្ទាប់ពីកាលបរិច្ឆេទនៃការបោះឆ្នោតឡើយ ។ វិភាគទានដែលបានស្នើសុំ ឬបានទទួល ឬបានបណ្តាលឱ្យមានការស្នើសុំ ឬទទួលដោយបេក្ខជនសម្រាប់គណៈកម្មការរៈប់រំ ឬគណៈកម្មាធិការគ្រប់គ្រងរបស់គាត់ បន្ទាប់ពីការបោះឆ្នោតរបស់គាត់ ត្រូវប្រើប្រាស់ដើម្បីទូទាត់បំណុលយុទ្ធនាការ ។~~

~~**(r) ការបង្ហាញព័ត៌មានយុទ្ធនាការ ការរាយការណ៍ និងការរក្សាកំណត់ត្រា ។**~~

~~(1) បន្ថែមលើរបាយការណ៍យុទ្ធនាការដែលតម្រូវឱ្យដាក់ជូនអនុលោមតាមច្បាប់កំណែទប្រង់នយោបាយចាប់ផ្តើមពីក្របរដ្ឋាភិបាល មាត្រា 81000 ដែលបានកែប្រែ បេក្ខជនសម្រាប់គណៈកម្មការរៈប់រំ គណៈកម្មាធិការគ្រប់គ្រងរបស់ពួកគេ និងគណៈកម្មាធិការដែលបង្កើតឡើងជាចម្បងដើម្បីគាំទ្រ ឬប្រឆាំងនឹងបេក្ខជនទាំងនេះ ត្រូវដាក់ជូនរបាយការណ៍បុនការបោះឆ្នោតនៅថ្ងៃសុក្របុនការបោះឆ្នោត ។ របាយការណ៍នេះត្រូវមានកាលបរិច្ឆេទបញ្ចប់នៅថ្ងៃពុធបុនការបោះឆ្នោត និងត្រូវគ្របដណ្តប់លើសកម្មភាព និងការទូទាត់ប្រាក់ដែលកើតឡើងរហូតដល់ថ្ងៃនោះ ។ បេក្ខជនសម្រាប់គណៈកម្មការរៈប់រំ គណៈកម្មាធិការគ្រប់គ្រងរបស់ពួកគេ និងគណៈកម្មាធិការដែលបង្កើតឡើងជាចម្បងដើម្បីគាំទ្រ ឬប្រឆាំងនឹងបេក្ខជនទាំងនេះ ក៏ត្រូវដាក់ជូនរបាយការណ៍យុទ្ធនាការដូចខាងក្រោមផងដែរ ទាក់ទងនឹងការបោះឆ្នោតតែងតាំងបឋមដែលប្រព្រឹត្តទៅនៅក្នុងខែបីនា ៖~~

~~(A) សម្រាប់រយៈពេលដែលបញ្ចប់នៅថ្ងៃទី 30 ខែកញ្ញានៃឆ្នាំបុនការបោះឆ្នោត របាយការណ៍បួយត្រូវដាក់ជូនយ៉ាងយូរត្រឹមថ្ងៃទី 10 ខែតុលា សម្រាប់រយៈពេលចាប់ពីថ្ងៃទី 1 ខែកក្កដា ដល់ថ្ងៃទី 30 ខែកញ្ញា ។~~

~~(B) សម្រាប់រយៈពេលដែលបញ្ចប់នៅថ្ងៃទី 31 ខែធ្នូនៃឆ្នាំបុនការបោះឆ្នោត របាយការណ៍បួយត្រូវដាក់ជូនយ៉ាងយូរត្រឹមថ្ងៃទី 10 ខែបករា នៃឆ្នាំបោះឆ្នោត សម្រាប់រយៈពេលចាប់ពីថ្ងៃទី 1 ខែតុលា ដល់ថ្ងៃទី 31 ខែធ្នូ ។~~

~~(2) ត្មានវិភាគទានណាបួយត្រូវតម្កល់ចូលក្នុងគណនីបូលឃ្យទានប័ត្រយុទ្ធនាការរបស់បេក្ខជនសម្រាប់គណៈកម្មការរវប់រំទ្បើយ លុះត្រាតែឈ្មោះ អាសយដ្ឋាន បុខរបរ និងនិយោជករបស់អ្នកបរិច្ចាគបាននៅក្នុងកំណត់ត្រារបស់អ្នកទទួលវិភាគទាន ។~~

~~(3) បេក្ខជនម្នាក់ៗ និងគណៈកម្មាធិការនីបួយៗដែលធ្វើការចំណាយឯកវាជ្យ ឬការទំនាក់ទំនងសមាជិកដើម្បីគាំទ្រ ឬប្រឆាំងនឹងបេក្ខជន ដែលផ្ទើសារតាបប្រែសណីយ៍ ឬចែកចាយឯកសារយុទ្ធនាការដែលបានខ្លឹបសារស្រដៀងគ្នាច្រើនជាង 200 ច្បាប់ ត្រូវផ្ទើច្បាប់ចម្លងនៃសារប្រែសណីយ៍ ឬឯកសារផ្សេងទៀតនោះទៅកាន់គណៈកម្មាការសើលធប៍ក្រុង ក្នុងពេលដំណាលគ្នានឹងសារប្រែសណីយ៍ ឬឯកសារផ្សេងទៀតត្រូវផ្តល់ជូនការិយាល័យប្រែសណីយ៍ ឬត្រូវបានចែកចាយ ។ ក្នុងអំឡុងពេលយុទ្ធនាការបោះឆ្នោត គណៈកម្មាធិការត្រូវត្រាន់តែបម្រើការជាកន្លែងរក្សាទុកសម្រាប់ឯកសារនេះ ហើយមិនត្រូវវិនិច្ឆ័យ ឬអធិប្បាយលើខ្លឹបសារនៃឯកសារនោះឡើយ ។~~

~~(4) បេក្ខជនណាម្នាក់សម្រាប់គណៈកម្មការរវប់រំ និងគណៈកម្មាធិការគ្រប់គ្រងរបស់បេក្ខជនដែលតម្រូវឱ្យដាក់ជូនរបាយការណ៍យុទ្ធនាការជាបួយគណៈកម្មាការសើលធប៍ក្រុង ត្រូវដាក់ជូនរបាយការណ៍យុទ្ធនាការទាំងនោះតាបអនឡាញដោយប្រើប្រាស់ប្រព័ន្ធដាក់ជូនតាបអេឡិចត្រូនិក (EFS) របស់គណៈកម្មាធិការ បន្ទាប់ពីបេក្ខជន និង/ឬគណៈកម្មាធិការបានទទួលវិភាគទាន ឬធ្វើការចំណាយ $25,000 ឬច្រើនជាងនេះ ទាក់ទងនឹងការបោះឆ្នោតជ្រើសរើសចូលកាន់តំណែងគណៈកម្មការរវប់រំ ។~~

~~(A) នៅពេលដែលបេក្ខជន ឬគណៈកម្មាធិការត្រូវបានតម្រូវឱ្យដាក់លិខិតថ្លែងការណ៍យុទ្ធនាការតាបអនឡាញ បេក្ខជន ឬគណៈកម្មាធិការនោះត្រូវបន្តដាក់លិខិតថ្លែងការណ៍តាបអនឡាញរហូតដល់គណៈកម្មាធិការនោះបានបញ្ចប់ជាផ្លូវការ ។ គណៈកម្មាធិការ និងបុគ្គលផ្សេងទៀតដែលបិនតម្រូវឱ្យដាក់តាបអនឡាញដោយផ្នែករងនេះ អាចធ្វើដូចនេះដោយស្ម័គ្រចិត្ត ។~~

~~(B) បុគ្គលដែលតម្រូវឱ្យដាក់តាបអនឡាញ ត្រូវបន្តដាក់ច្បាប់ចម្លងជាក្រដាសនៃលិខិតថ្លែងការណ៍យុទ្ធនាការនីបួយៗ ដូចដែលបានតម្រូវដោយ ច្បាប់កែប្រែចប្រង់នយោបាយ California និងបាត្រានេះ រហូតដល់បុគ្គលនោះលែងតម្រូវឱ្យដាក់លិខិតថ្លែងការណ៍យុទ្ធនាការជាបួយ គណៈកម្មការសើលធប៍ក្រុង ។ ច្បាប់ចម្លងជាក្រដាសត្រូវបន្តធ្វើជាលិខិតថ្លែងការណ៍យុទ្ធនាការដើបសម្រាប់ការសវនកម្ម និងគោលបំណងផ្លូវច្បាប់ផ្សេងទៀត ។~~

~~(C) បន្ថែបលើការពិន័យចំពោះការដាក់យឺតយ៉ាវណាបួយដែលអាចត្រូវបានដាក់ទោសសម្រាប់ការដាក់ច្បាប់ចម្លងជាក្រដាសយឺតយ៉ាវយោងតាម ច្បាប់កែប្រែចប្រង់នយោបាយ California ឬបាត្រានេះ បុគ្គលទាំងឡាយណាដែលខកខានបិនបានអនុវត្តតាមតម្រូវការដាក់តាបអនឡាញនៃផ្នែករងនេះ នឹងត្រូវរងការពិន័យលើការដាក់យឺតយ៉ាវបន្ថែបចំនួន $25 ក្នុងបួយថ្ងៃបន្ទាប់ពីកាលបរិច្ចេទផុតកំណត់សម្រាប់ការដាក់ច្បាប់ចម្លងតាបអនឡាញយឺតយ៉ាវ ។~~

~~(D) ព័ត៌មានដែលបានទៅលើលិខិតថ្លែងការណ៍យុទ្ធនាការដែលបានដាក់តាបអនឡាញ ត្រូវតែដូចគ្នាទៅនឹងព័ត៌មានដែលបានទៅលើច្បាប់ចម្លងជាក្រដាសនៃលិខិតថ្លែងការណ៍ដូចគ្នានេះ ដែលបានដាក់ជូនគណៈកម្មការសើលធប៍ក្រុង ។~~

~~(s) ការបង្ហាញរំពីការទូទាត់សម្រាប់ការចំណាយឯកវាជ្យ និងការទាក់ទងសមាជិកដែលបិនបែនជាការស្នើសុំ ។~~

~~(1) បុគ្គលណាក៏ដោយ រាប់បញ្ចូលទាំងគណៈកម្មាធិការណាបួយ ដែលធ្វើ ឬរ៉ាប់រងការចំណាយឯកវាជ្យចាប់ពី $1,000 ឡើងទៅ ដើម្បីគាំទ្រ ឬប្រឆាំងនឹងបេក្ខជនណាម្នាក់សម្រាប់គណៈកម្មការរវប់រំ ឬការទូទាត់ បួយ ឬច្រើនសម្រាប់ការទាក់ទងសមាជិកដូចដែលបានកំណត់ដោយមាត្រានេះ ដែលបានសរុបចាប់ពី $1,000 ឡើងទៅ ដើម្បីគាំទ្រ ឬប្រឆាំងនឹងបេក្ខជនសម្រាប់គណៈកម្មការរវប់រំ ត្រូវជូនដំណឹងទៅ គណៈកម្មការសើលធប៍ក្រុង ក្នុងរយៈពេល 24 ម៉ោងតាបរយៈលិខិតបញ្ជាក់ ឬទូរសារ ឬអ៊ីបែល រាល់ពេលដែលការទូទាត់ បួយ ឬច្រើន ដែលគ្រប់លក្ខខណ្ឌកំណត់នេះ ត្រូវបានធ្វើឡើង ។~~

~~(2) ការជូនដំណឹងត្រូវរួបបានការប្រកាសដែលបញ្ជាក់យ៉ាងច្បាស់អំពីបេក្ខជនម្នាក់ៗដែលទទួលបានការគាំទ្រ ឬប្រឆាំងដោយសារការចំណាយនោះ ចំនួនទឹកប្រាក់ដែលបានចំណាយដើម្បីគាំទ្រ ឬប្រឆាំងបេក្ខជនម្នាក់ៗ ថាតើបេក្ខជនត្រូវបានគាំទ្រ ឬប្រឆាំង និងថាការចំណាយនោះបិនបែនជាការស្នើសុំដោយបេក្ខជន ឬបេក្ខជនទាំងឡាយដែលទទួលបានប្រយោជន៍ពីការចំណាយនោះឡើយ ។ ការប្រកាសនេះត្រូវធ្វើឡើងក្រោបការពិន័យពីបទក្លែងបន្លំ ហើយត្រូវចុះហត្ថលេខាដោយបុគ្គល ឬបន្ត្រី និងបេឡាធិការនៃក្រុមដែលធ្វើការចំណាយ ។ បន្ថែមពីនេះ កាលបរិច្ចេទ និងចំនួនទឹកប្រាក់នៃការទូទាត់ ការពិពណ៌នារំពីប្រភេទនៃការទាក់ទងដែលការទូទាត់ត្រូវបានធ្វើឡើង ឬរ៉ាប់រង ឈ្មោះ និងអាសយដ្ឋានរបស់បុគ្គលដែលធ្វើការទូទាត់ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកទទួលការទូទាត់ និងច្បាប់ចម្លងនៃលិខិតផ្ទើ ឬការផ្សាយពាណិជ្ជកម្ម ឬច្បាប់ចម្លងនៃអត្ថបទ ឬការថតសំឡេងនៃការហៅទូរសព្ទ ការបញ្ជូន ឬការផ្សាយពាណិជ្ជកម្ម ក៏ត្រូវផ្តល់ជូន គណៈកម្មការសីលធម៌ក្រុង ជងដែរ ។ ការជូនដំណឹងនេះក៏ត្រូវរួបបញ្ចូលទាំងការបង្ហាញអំពីការភាគទានចាប់ពី $100 ឡើងទៅដែលទទួលបានដោយគណៈកម្មាធិការ ចាប់តាំងពីថ្ងៃបន្ទាប់ពីកាលបរិច្ចេទបិទនៃរបាយការណ៍បង្ហាញព័ត៌មានយុទ្ធនាការចុងក្រោយរបស់គណៈកម្មាធិការដែលបានដាក់ក្នុងគណៈកម្មការ ឬចាប់តាំងពីថ្ងៃដំបូងនៃឆ្នាំប្រតិទិនបច្ចុប្បន្ន ដោយយកកាលបរិច្ចេទណាបួយដែលកើតឡើងក្រោយ ។ ទោះជាយ៉ាងណាក៏ដោយ ការភាគទានដែលទទួលបាន ប៉ុន្តែត្រូវបានកំណត់ទុកសប្រាប់បេក្ខជនផ្សេងទៀតនៅខាងក្រៅ បណ្ឌលសិក្សាធិការរួបរួប Los Angeles បិនចាំបាច់ត្រូវបង្ហាញនោះទេ ។ ការជូនដំណឹងនេះក៏ត្រូវរួបបញ្ចូលទាំងការបង្ហាញអំពីការភាគទានចាប់ពី $100 ឡើងទៅ ដែលបានធ្វើឡើងនៅក្នុងឆ្នាំប្រតិទិនបច្ចុប្បន្នដោយបុគ្គលនោះ ជូនចំពោះបេក្ខជន គណៈកម្មការអប់រំ ឬគណៈកម្មាធិការដែលគ្រប់គ្រងដោយពួកគេ ។~~

~~(3) បុគ្គលិក គណៈកម្មការសីលធម៌ក្រុង នឹងជូនដំណឹងដល់បេក្ខជនទាំងអស់តាបរយៈទូរសព្ទ ទូរសារ ឬ អ៊ីបែលនៅក្នុងការប្រកួតប្រជែងដែលប៉ះពាល់ក្នុងរយៈពេល បួយ ថ្ងៃធ្វើការ បន្ទាប់ពីទទួលបានការជូនដំណឹងអំពីការទូទាត់សប្រាប់ការចំណាយឯកវាជ្ស និងការទាក់ទងសមាជិកដែលបិនមានការសប្របសប្រួលចាប់ពី $1,000 ឡើងទៅ ។ ការជូនដំណឹងនឹងបញ្ជាក់ពីបេក្ខជនដែលទទួលបានការគាំទ្រ ឬប្រឆាំងដោយសារការចំណាយ ដូចដែលបានបញ្ជាក់នៅលើការប្រកាសដែលបានចុះហត្ថលេខា និងរួបបញ្ចូលច្បាប់ចម្លងនៃការទាក់ទងដែលផ្តល់ដោយបុគ្គល ឬក្រុបដែលធ្វើការចំណាយ ។~~

~~(4) សប្រាប់គោលបំណងនៃការជូនដំណឹងដែលបានតប្រូវនៅក្នុង ផ្នែករង (1) ការទូទាត់ដោយអង្គភាពសប្រាប់ព្រឹត្តិបត្រព័ត៌មាន ឬទស្សនាវដ្តីដែលចេញផ្សាយជាទៀងទាត់របស់ខ្លួន ប្រសិនបើការចែកចាយត្រូវបានកប្រិតត្រឹមតែសមាជិក និយោជិត ភាគហ៊ុនិក បុគ្គលពាក់ព័ន្ធផ្សេងទៀតរបស់អង្គភាព និងអ្នកដែលស្នើសុំ ឬទិញការចេញផ្សាយនោះបិនតម្រូវឱ្យរាយការណ៍នោះទេ ។~~

~~(5) គណៈកម្មាធិការណាបួយ រាប់បញ្ចូលទាំង ប៉ុន្តែបិនកប្រិតត្រឹមតែគណៈកម្មាធិការគ្រប់គ្រងដោយបេក្ខជន និងគណៈកម្មាធិការចំណាយឯកវាជ្ស ដែលធ្វើ ឬរ៉ាប់រងការទូទាត់សប្រាប់ការហៅទូរសព្ទដែលបានថតសំឡេងចាប់ពី 1,000 ដងឡើងទៅ ឬទប្រង់ផ្សេងទៀតនៃទូរលេខ ឬការបញ្ជូនតាបអេឡិចត្រូនិកដែលមានខ្លឹមសារស្រដៀងគ្នាច្រើន ឬដែលធ្វើ ឬរ៉ាប់រងការចំណាយចាប់ពី $1,000 ឡើងទៅសប្រាប់ការផ្សាយពាណិជ្ជកម្មតាបវិទ្យុ ឬទូរទស្សន៍ ដើម្បីគាំទ្រ ឬប្រឆាំងនឹងបេក្ខជនណាម្នាក់សប្រាប់តំណែង គណៈកម្មការអប់រំ ត្រូវផ្ទើច្បាប់ចម្លងនៃអត្ថបទ ឬការថតសំឡេងដែលបានប្រើសប្រាប់ការទាក់ទងនីមួយៗទៅ គណៈកម្មការសីលធម៌ ក្នុងរយៈពេល 24 ប៉ោងនៃលើកទី បួយ ដែលការហៅទូរសព្ទ ការបញ្ជូន ឬការផ្សាយពាណិជ្ជកម្មត្រូវបានធ្វើឡើង ឬផ្សាយ ។~~

~~**(t) ការផ្ទៀងផ្ទាត់ ។** ការប្រកាស របាយការណ៍ និងលិខិតថ្លែងការណ៍ទាំងអស់ដែលបានដាក់ក្រោបមាត្រានេះ ត្រូវតែចុះហត្ថលេខា និងផ្ទៀងផ្ទាត់ដោយអ្នកដាក់ក្រោបការពិន័យពីបទក្លែងបន្លំ ។ បេក្ខជន និងបុគ្គលណាក៏ដោយដែលចុះហត្ថលេខាលើការប្រកាស របាយការណ៍ និងលិខិតថ្លែងការណ៍ក្រោបលក្ខខណ្ឌនេះ ត្រូវតែអាន ដឹង និងយល់ពីខ្លឹមសារនៃការប្រកាស របាយការណ៍ និងលិខិតថ្លែងការណ៍ទាំងនេះទាំងអស់ ។~~

~~**(u) កាតព្វកិច្ចរបស់ គណៈកម្មការសីលធម៌ក្រុង ។** គណៈកម្មការសីលធម៌ក្រុង ត្រូវគ្រប់គ្រងលក្ខខណ្ឌនៃមាត្រានេះ ។ បន្ថែបលើកាតព្វកិច្ចផ្សេងទៀតដែលតម្រូវក្រោបលក្ខខណ្ឌនៃមាត្រានេះ គណៈកម្មការសីលធម៌ក្រុង ត្រូវ ៖~~

~~(1) ធ្វើការសវនកម្ម និងការស៊ើបអង្កេតលើរបាយការណ៍ និងលិខិតថ្លែងការណ៍ដែលបានដាក់ដោយបេក្ខជន និងគណៈកម្មាធិការដែលគាំទ្រ ឬប្រឆាំងបេក្ខជនសម្រាប់តំណែង គណៈកម្មការអប់រំ ដូចដែលបានតម្រូវក្រោម ច្បាប់កែទម្រង់នយោបាយឆ្នាំ 1974 ដែលត្រូវបានកែប្រែ និងមាត្រា VII និងផ្នែកនេះនៃធម្មនុញ្ញ ។ គណៈកម្មការសីលធម៌ក្រុង ត្រូវផ្ទូលអ្នកស៊ើបអង្កេតនៅពេលចាំបាច់ដើម្បីស៊ើបអង្កេតយ៉ាងពេញលេញលើបុគ្គលណាក៏ដោយដែលស្ថិតក្រោមមាត្រានេះ ។~~

~~(2) អនុវត្ត ឬធ្វើឱ្យមានការអនុវត្តលក្ខខណ្ឌនៃមាត្រានេះអនុវត្តតាមមាត្រា 90002(c) នៃក្រមរដ្ឋាភិបាល ស្របតាមមាត្រា VII នៃធម្មនុញ្ញ ។~~

~~(3) រាយការណ៍អំពីការល្មើសដែលលេចឡើងនៃមាត្រានេះ និងច្បាប់រដ្ឋដែលអាចអនុវត្តបានទៅកាន់ បេធាវីក្រុង ឬភ្នាក់ងារអនុវត្តច្បាប់សមស្របផ្សេងទៀត ។~~

~~(v) ការអនុវត្តច្បាប់ ។~~

~~(1) **ការអនុវត្តច្បាប់ព្រហ្មទណ្ឌ** - បុគ្គលណាក៏ដោយដែលល្មើសលក្ខខណ្ឌណាបួយនៃមាត្រានេះដោយដឹងខ្លួន ឬដោយចេតនា ត្រូវមានទោសពីបទល្មើសបជ្ឈិប ។ បុគ្គលណាក៏ដោយដែលធ្វើឱ្យបុគ្គលផ្សេងទៀតល្មើសលក្ខខណ្ឌណាបួយនៃមាត្រានេះដោយដឹងខ្លួន ឬដោយចេតនា ឬអ្នកដែលផ្ទយ និងអូសទាញបុគ្គលផ្សេងទៀតក្នុងការល្មើសលក្ខខណ្ឌណាបួយនៃមាត្រានេះ ត្រូវទទួលខុសត្រូវក្រោមលក្ខខណ្ឌនៃមាត្រានេះ ។ ការចោទប្រកាន់ចំពោះការល្មើសលក្ខខណ្ឌណាបួយនៃមាត្រានេះ ត្រូវតែចាប់ផ្តើមក្នុងរយៈពេលបួនឆ្នាំបន្ទាប់ពីកាលបរិច្ចេទដែលការល្មើសនោះបានកើតឡើង ។ គ្មានបុគ្គលណាដែលត្រូវបានផ្តន្ទាទោសពីបទល្មើសបជ្ឈិបក្រោមមាត្រានេះ ត្រូវធ្វើសកម្មភាពជាអ្នកតំណាងផលប្រយោជន៍ ឬជាអ្នកម៉ៅការរបស់ក្រុង ក្នុងរយៈពេលបួនឆ្នាំបន្ទាប់ពីកាលបរិច្ចេទនៃការផ្តន្ទាទោសឡើយ លើកលែងតែតុលាការនៅពេលផ្តន្ទាទោសកំណត់យ៉ាងជាក់លាក់ថាលក្ខខណ្ឌនេះបិនត្រូវយកបកអនុវត្ត ។ សម្រាប់គោលបំណងនៃមាត្រានេះ ការសារភាពថាបិនតវ៉ា ត្រូវចាត់ទុកថាជាការផ្តន្ទាទោស ។~~

~~(2) **ការអនុវត្តច្បាប់រដ្ឋប្បវេណី ។**~~

~~(A) បុគ្គលណាក៏ដោយដែលល្មើសលក្ខខណ្ឌបួយនៃមាត្រានេះដោយចេតនា ឬដោយការធ្វេសប្រហែស ត្រូវទទួលខុសត្រូវនៅក្នុងបណ្តឹងរដ្ឋប្បវេណីដែលបានប្តឹងដោយ បេធាវីក្រុង គណៈកម្មការសីលធម៌ក្រុង ឬដោយបុគ្គលដែលរស់នៅក្នុងព្រំប្រទល់នៃបណ្ឌលសិក្សាធិការរួបរួប Los Angeles សម្រាប់ចំនួនទឹកប្រាក់បិនលើសពី $5,000 ក្នុងបួយការល្មើស ឬច្រើនជាងបីដងនៃចំនួនទឹកប្រាក់ដែលបុគ្គលនោះខកខានបិនបានរាយការណ៍ឱ្យបានត្រឹមត្រូវ ឬបានភាគទាន ផ្តល់ ឬទទួលបានដោយខុសច្បាប់ ។~~

~~(B) បុគ្គលណាក៏ដោយដែលធ្វើ ឬទទួលបានវិភាគទាន ឬធ្វើការចំណាយ ដោយចេតនា ឬដោយការធ្វេសប្រហែស ដោយរំលោភលើលក្ខខណ្ឌណាបួយនៃមាត្រានេះ ត្រូវទទួលខុសត្រូវនៅក្នុងបណ្តឹងរដ្ឋប្បវេណីដែលបានប្តឹងដោយ បេធាវីក្រុង ឬដោយបុគ្គលដែលរស់នៅក្នុងក្រុង សម្រាប់ចំនួនទឹកប្រាក់រហូតដល់បីដងនៃចំនួនទឹកប្រាក់នៃវិភាគទាន ឬការចំណាយខុសច្បាប់ ។~~

~~(C) ប្រសិនបើបុគ្គលចាប់ពីពីរនាក់ឡើងទៅទទួលខុសត្រូវចំពោះការល្មើសណាបួយ ពួកគេត្រូវទទួលខុសត្រូវរួបគ្នា និងដោយឡែកពីគ្នា ។~~

~~(D) បុគ្គលណាក៏ដោយ ក្រៅពីបេធាវីក្រុង បុននឹងដាក់ពាក្យបណ្តឹងរដ្ឋប្បវេណីស្របតាមផ្នែកអងនេះ ត្រូវដាក់សំណើជាលាយលក្ខណ៍អក្សរជាមុនសិនទៅកាន់ គណៈកម្មការសីលធម៌ក្រុង ដើម្បីឱ្យ គណៈកម្មការសីលធម៌ក្រុង ចាប់ផ្តើមសកម្មភាព ។ សំណើនេះត្រូវមានលិខិតថ្លែងការណ៍អំពីបូលដ្ឋានសម្រាប់ការជឿថាបូលហេតុនៃសកម្មភាពផ្លូវច្បាប់មាន ។ គណៈកម្មការសីលធម៌ក្រុង ត្រូវឆ្លើយតបក្នុងរយៈពេល 40 ថ្ងៃបន្ទាប់ពីទទួលបានសំណើដោយបញ្ជាក់ថាតើខ្លួនមានបំណងដាក់ពាក្យបណ្តឹងរដ្ឋប្បវេណីឬយ៉ាងណា ។ ប្រសិនបើ គណៈកម្មការសីលធម៌ក្រុង ឆ្លើយតបក្នុងន័យយល់ព្រម ហើយដាក់ពាក្យប្តឹងក្នុងរយៈពេល 40 ថ្ងៃបន្ទាប់ពីនោះ គ្មានសកម្មភាពផ្លូវច្បាប់~~

~~ផ្សេងទៀតអាចត្រូវ បាននាំយកបកចោទប្រកាន់ឡើយ លើកលែងតែសកម្មភាពផ្លូវច្បាប់ដែលបាននាំយកបកដោយ គណៈកម្មការសីលធម៌ក្រុង ត្រូវបានបដិសេធចោលដោយមិនប៉ះពាល់ដល់សិទ្ធិប្តឹងសារជាថ្មី ។~~

~~(E) គ្មានសាលក្រមលើអង្គហេតុលើសពី បួយ ឡើយចំពោះការល្មើសណាបួយដែលអាចទទួលបានក្រោបផ្នែកអងនេះ ។ សកម្មភាពផ្លូវច្បាប់ដែលបាននាំយកបកចោទប្រកាន់សម្រាប់ការល្មើស ឬការល្មើសដូចគ្នា ត្រូវហាន អាទិភាពសម្រាប់គោលបំណងនៃការជំនុំជម្រះតាមលំដាប់នៃពេលវេលាដែលបានដាក់ ។ សកម្មភាពផ្លូវច្បាប់ទាំងនោះត្រូវតែបដិសេធចោល នៅពេលដែលសាលក្រមត្រូវបានចូលជាធរហាន ឬការសម្រុះសម្រួលត្រូវបានអនុម័តដោយតុលាការនៅក្នុងសកម្មភាពផ្លូវច្បាប់ដែលបានដាក់ពីមុន ។ តុលាការអាចបដិសេធសកម្មភាពផ្លូវច្បាប់ដែលកំពុងរង់ចាំដោយមិនប៉ះពាល់ដល់សិទ្ធិប្តឹងសារជាថ្មីចំពោះសកម្មភាពផ្លូវច្បាប់ផ្សេងទៀត សម្រាប់ការខកខានដើមចោទក្នុងការបន្តដោយយកចិត្តទុកដាក់ និងដោយស្មោះត្រង់ សកម្មភាពផ្លូវច្បាប់អាចត្រូវបានបដិសេធចោលបែបនេះ តាមញត្តិដោយ បេធាវីក្រុង ឬដើមចោទណាម្នាក់នៅក្នុងសកម្មភាពផ្លូវច្បាប់ផ្តែកលើការល្មើសដូចគ្នា ។~~

~~(F) ក្នុងការកំណត់ចំនួនទឹកប្រាក់នៃកាតព្វកិច្ចទទួលខុសត្រូវក្រោបផ្នែកអងនេះ តុលាការអាចពិចារណាលើភាពធ្ងន់ធ្ងរនៃការល្មើស និងកម្រិតនៃកំហុសរបស់ចុងចោទ ។ ប្រសិនបើសាលក្រមត្រូវបានចូលជាធរហាន ប្រឆាំងនឹងចុងចោទ ឬចុងចោទទាំងឡាយនៅក្នុងសកម្មភាពផ្លូវច្បាប់ ដើមចោទឯកជនត្រូវទទួលបាន 50% នៃចំនួនទឹកប្រាក់ដែលទារបាន ។ 50% ដែលនៅសល់ ត្រូវដាក់ប្រាក់ចូលទៅក្នុងបូលនិធិទូទៅរបស់ក្រុង ។ នៅក្នុងសកម្មភាពផ្លូវច្បាប់ដែលបាននាំយកបកចោទប្រកាន់ដោយ បេធាវីក្រុង ឬ គណៈកម្មការសីលធម៌ក្រុង ចំនួនទឹកប្រាក់ទាំងបូលត្រូវតែបង់ជូនបូលនិធិទូទៅ ។~~

~~(G) គ្មានវិធានការសុីវិលដែលចោទប្រកាន់ពីការល្មើសមាត្រានេះ ត្រូវដាក់ពាក្យបណ្តឹងលើសពីបួនឆ្នាំ បន្ទាប់ពីកាលបរិច្ចេទដែលការល្មើសបានកើតឡើងឡើយ ។~~

~~(H) បុគ្គលណាក៏ដោយដែលរស់នៅក្នុងបណ្ឌលសិក្សាធិការរួបរួប Los Angeles រាប់បញ្ចូលទាំង បេធាវីក្រុង Los Angeles អាចប្តឹងទាបទារការសង្ត្រោះតាបដីកាបង្គាប់ ដើប្បីហាបយាត់ការល្មើស ឬដើប្បីបង្ខំឱ្យមានការអនុលោមតាមលក្ខខណ្ឌនៃមាត្រានេះ ។ តុលាការអាចប្រគល់ជូនភាគី ក្រៅពីភ្នាក់ងារ ដែលឈ្នះនៅក្នុងសកម្មភាពរដ្ឋប្បវេណីណាបួយដែលបានអនុញ្ញាតដោយមាត្រានេះ នូវចំណាយនៃការតវ៉ាក្តីរបស់គាត់ រាប់បញ្ចូលទាំងកម្រៃ បេធាវីសមរម្យ ទោះជាយ៉ាងណាក៏ដោយ គ្មានការប្រគល់ជូនបែបនេះអាចត្រូវបានអនុញ្ញាតប្រឆាំងនឹងទីក្រុង Los Angeles ឡើយ ។~~

~~(w) ផលប៉ះពាល់នៃការល្មើសលើលទ្ធផលនៃការបោះឆ្នោត ។~~

~~(1) ប្រសិនបើបេក្ខជនត្រូវបានផ្តន្ទាទោសពីបទល្មើសបញ្ឆិបនៃការល្មើសលក្ខខណ្ឌណាបួយនៃមាត្រានេះ តុលាការត្រូវធ្វើការកំណត់ថាតើការល្មើសនេះមានផលប៉ះពាល់សំខាន់លើលទ្ធផលនៃការបោះឆ្នោតឬយ៉ាងណា ។ ប្រសិនបើតុលាការអកឃើញផលប៉ះពាល់សំខាន់បែបនេះ បន្ទាប់បក ៖~~

~~(A) ប្រសិនបើការផ្តន្ទាទោសបែបនេះក្លាយជាស្ថាពរបុនកាលបរិច្ចេទនៃការបោះឆ្នោត សំឡេងឆ្នោតសម្រាប់បេក្ខជនរូបនោះមិនត្រូវរាប់បញ្ចូលឡើយ ហើយការបោះឆ្នោតត្រូវកំណត់នៅលើបូលដ្ឋាននៃសំឡេងឆ្នោតដែលបានបោះសម្រាប់បេក្ខជនផ្សេងទៀតនៅក្នុងការប្រកួតប្រជែងនោះ~~

~~(B) ប្រសិនបើការផ្តន្ទាទោសបែបនេះក្លាយជាស្ថាពរបន្ទាប់ពីកាលបរិច្ចេទនៃការបោះឆ្នោត ហើយប្រសិនបើបេក្ខជនរូបនោះត្រូវបានប្រកាសថាបានជាប់ឆ្នោត បន្ទាប់បកបេក្ខជនរូបនោះមិនត្រូវកាន់តំណែងឡើយ តំណែងត្រូវចាត់ទុកថាទំនេរ ហើយត្រូវបំពេញដូចដែលបានបែងចែកផ្សេងទៀតនៅក្នុងធម្មនុញ្ញ~~

~~(C) ប្រសិនបើការផ្តន្ទាទោសបែបនេះក្លាយជាស្ថាពរបន្ទាប់ពីបេក្ខជនបានកាន់តំណែង បន្ទាប់បកបេក្ខជនត្រូវដកចេញពីតំណែង តំណែងត្រូវចាត់ទុកថាទំនេរ ហើយត្រូវបំពេញដូចដែលបានបែងចែកផ្សេងទៀតនៅក្នុងធម្មនុញ្ញ និង~~

~~(D) បុគ្គលដែលត្រូវបានផ្តន្ទាទោសបែបនេះ បិនត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការកាន់តំណែងជ្រើសរើសដោយការបោះឆ្នោតណាមួយរបស់ក្រុង ឬតំណែងជាសមាជិកនៃគណៈកម្មការរបស់រំឡើយ ក្នុងរយៈពេលប្រាំឆ្នាំបន្ទាប់ពីកាលបរិច្ចេទនៃការផ្តន្ទាទោសបែបនេះ ។~~

~~(2) ស្មៀនក្រុងបិនត្រូវចេញវិញ្ញាបនបត្រនៃការស្នើឈ្មោះ ឬការបោះឆ្នោតជូនចំពោះបេក្ខជនណាម្នាក់ឡើយ រហូតដល់លិខិតថ្លែងការណ៍យុទ្ធនាការបុនការបោះឆ្នោតរបស់គាត់ដែលបានតប្រូវដោយច្បាប់កែទប្រង់នយោបាយឆ្នាំ 1974 ដែលត្រូវបានកែប្រែ ឬប្រសិនបើគ្មានលិខិតថ្លែងការណ៍យុទ្ធនាការត្រូវ បានតប្រូវ ការប្រកាសជាលាយលក្ខណ៍អក្សរដែលបានអនុញ្ញាតក្រោមមាត្រា 84205 នៃក្រមរដ្ឋាភិបាល ត្រូវបានដាក់ក្នុងទប្រង់ និងនៅកន្លែងដែលបានតប្រូវដោយច្បាប់កែទប្រង់នយោបាយឆ្នាំ 1974 ។~~

~~(x) ការពិន័យលើការដាក់យឺតយ៉ាវ ។ ប្រសិនបើបុគ្គលណាក៏ដោយដាក់លិខិតថ្លែងការណ៍ ឬរបាយការណ៍ដើមបន្ទាប់ពីកាលបរិច្ចេទផុតកំណត់ណាមួយដែលបានកំណត់ដោយមាត្រានេះ បុគ្គលនោះ បន្ថែមលើការពិន័យ ឬដំណោះស្រាយផ្សេងទៀតដែលបានបង្កើតឡើងដោយមាត្រា ត្រូវទទួលខុសត្រូវចំពោះ គណៈកម្មការសីលធម៌ក្រុង នូវចំនួនទឹកប្រាក់ $25 ក្នុងមួយថ្ងៃបន្ទាប់ពីកាលបរិច្ចេទផុតកំណត់ រហូតដល់លិខិតថ្លែងការណ៍ ឬរបាយការណ៍ត្រូវបានដាក់ ។ គណៈកម្មការមិនចាំបាច់អនុវត្តការទទួលខុសត្រូវនោះទេ ប្រសិនបើគណៈកម្មការកំណត់ដោយមិនលម្អៀងថា ការដាក់ឯកសារយឺតយ៉ាវនោះបិនបែនជាចេតនា ហើយការអនុវត្តការទទួលខុសត្រូវនោះនឹងមិនផ្លូយលើកកម្ពស់គោលបំណងនៃមាត្រានេះទេ លើកលែងតែការទទួលខុសត្រូវបិនអាចត្រូវបានលើកលែងឡើយ ប្រសិនបើលិខិតថ្លែងការណ៍ ឬរបាយការណ៍បិនត្រូវបានដាក់ក្នុងរយៈពេល 30 ថ្ងៃ ។~~

~~(y) ភាពអាចបំបែកបាន ។ ប្រសិនបើលក្ខខណ្ឌ ឬផ្នែកណាមួយនៃមាត្រានេះ ឬការអនុវត្តរបស់វាចំពោះបុគ្គល ឬកាលៈទេសៈណាមួយ ត្រូវបានកាន់កាប់ថាបិនមានសុពលភាពដោយតុលាការណាមួយ មាត្រាដែលនៅសល់នៃមាត្រានេះ ឬការអនុវត្តលក្ខខណ្ឌបែបនេះចំពោះបុគ្គល ឬកាលៈទេសៈផ្សេងទៀតក្រៅពីអ្វីដែលត្រូវបានកាន់កាប់ថាបិនមានសុពលភាព បិនត្រូវប៉ះពាល់ឡើយ ។~~

មាត្រា 2. ភាពអាចបំបែកបាន ។ ប្រសិនបើមាត្រា ផ្នែករង ខច្បាប់ ប្រយោគ ឃ្លា ឬការអនុវត្តណាមួយនៃវិសោធនកម្មធម្មនុញ្ញនេះ ឬផ្នែកណាមួយនៃវិសោធនកម្មនេះ ត្រូវបានចាត់ទុកថាផ្ទុយនឹងរដ្ឋធម្មនុញ្ញ ឬមិនត្រឹមត្រូវដោយតុលាការ ឬសាលាក្តីណាមួយនៃដែនយុត្តាធិការនោះ មាត្រា ផ្នែករង ខច្បាប់ ប្រយោគ ឃ្លា ផ្នែក ឬការអនុវត្តដែលនៅសល់នៃវិសោធនកម្មធម្មនុញ្ញនេះ នឹងត្រូវរក្សានូវប្រសិទ្ធភាពអនុវត្តពេញលេញ ហើយដើម្បីសម្រេចគោលបំណងនេះ លក្ខខណ្ឌនៃវិសោធនកម្មធម្មនុញ្ញនេះអាចបំបែកចេញពីគ្នាបាន។ បន្ថែមពីនេះ អ្នកបោះឆ្នោតប្រកាសថា ពួកគេនឹងបានអនុម័តគ្រប់មាត្រា ផ្នែករង ខច្បាប់ ប្រយោគ ឃ្លា ផ្នែក និងការអនុវត្តទាំងអស់នៃការកែប្រែធម្មនុញ្ញនេះ ដោយគ្មានមាត្រា ផ្នែករង ខច្បាប់ ប្រយោគ ឃ្លា ផ្នែក ឬការអនុវត្តដែលត្រូវបានកាន់កាប់ថាផ្ទុយនឹងរដ្ឋធម្មនុញ្ញ ឬមិនមានសុពលភាពឡើយ ។

FD

មូលនិធិសម្រាប់នាយកដ្ឋានពន្លត់អគ្គិភ័យ LOS ANGELES តាមរយៈពន្ធលើការលក់ពាក់កណ្តាលភាគរយ។ បទបញ្ញត្តិផ្ទួចផ្តើម FD។

តើគួរតែអនុម័តបទបញ្ញត្តិដែលផ្តល់មូលនិធិសម្រាប់នាយកដ្ឋានពន្លត់អគ្គិភ័យ Los Angeles រួមទាំងសម្រាប់ការជួលអ្នកពន្លត់អគ្គិភ័យ បុគ្គលិកពេទ្យសង្គ្រោះបន្ទាន់ និងបុគ្គលិកផ្សេងទៀត ការទិញ និងការថែទាំយានយន្ត និងឧបករណ៍ ការសាងសង់ និងការធ្វើឱ្យប្រសើរឡើងនូវស្ថានីយពន្លត់អគ្គិភ័យ និងការសម្អាតគុម្ពោតព្រៃ តាមរយៈការដាក់ពន្ធលើការលក់ចំនួនពាក់កណ្តាលភាគរយ (0.5%) នៅក្នុងទីក្រុង Los Angeles ដោយមានសវនកម្មប្រចាំឆ្នាំ និងគណៈកម្មាធិការត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ ដែលបង្កើតប្រាក់ចំណូលប្រមាណ $345 លានជារៀងរាល់ឆ្នាំ រហូតដល់ត្រូវបានបញ្ចប់ដោយអ្នកបោះឆ្នោត ដែរឬទេ?

សេចក្តីសង្ខេបតតលម្ងៀង
ដោយ SHARON M. TSO ប្រធានអ្នកវិភាគនិតិបញ្ញត្តិ

គំនិតផ្ទួចផ្តើមសន្ទឹកឆ្នោតគាំទ្រដោយពលរដ្ឋនេះ ប្រសិនបើត្រូវបានអនុម័ត នឹងតម្រូវឱ្យក្រុងអនុម័តច្បាប់មួយដើម្បីដាក់ពន្ធលើប្រតិបត្តិការលក់រាយ និងការប្រើប្រាស់ថ្មីចំនួនកន្លះភាគរយ (0.5%) (ពន្ធលើការលក់) នៅក្នុងទីក្រុង Los Angeles។ ប្រាក់ចំណូលដែលបានបង្កើតដោយពន្ធលើការលក់ថ្មីនេះនឹងត្រូវបានប្រើប្រាស់ដើម្បីផ្តល់មូលនិធិបន្ថែមសម្រាប់នាយកដ្ឋានពន្លត់អគ្គីភ័យ Los Angeles (LAFD)។ បច្ចុប្បន្ន អត្រាពន្ធលើការលក់របស់ក្រុងគឺ 10.25%។ ពន្ធថ្មីនេះនឹងនៅតែមានសុពលភាព លើកលែងតែត្រូវបានលុបចោលដោយអ្នកបោះឆ្នោត ឬប្រសិនបើកាតព្វកិច្ចវិកាក្រុងមិនត្រូវបានបំពេញដូចដែលបានបញ្ជាក់នៅក្នុងគំនិតផ្ទួចផ្តើមនេះ។

បច្ចុប្បន្ននេះ LAFD ទទួលបានមូលនិធិជាចម្បងតាមរយៈមូលនិធិទូទៅរបស់ក្រុង។ មូលនិធិទូទៅគឺជាមូលនិធិប្រតិបត្តិការចម្បងរបស់ក្រុង ហើយទទួលបានចំណូលពីពន្ធ លិខិតអនុញ្ញាត ថ្លៃសេវា ពិន័យ និងប្រភពផ្សេងៗទៀតដែលមានសម្រាប់ការប្រើប្រាស់តាមការសម្រេចចិត្ត។ មូលនិធិទូទៅមានធនធានមានកំណត់ ហើយត្រូវបានប្រើប្រាស់ដើម្បីផ្តល់មូលនិធិដល់នាយកដ្ឋានភាគច្រើននៃក្រុងដែលផ្តល់សេវាកម្មដល់សាធារណជន។

ប្រសិនបើត្រូវបានអនុម័ត ប្រាក់ចំណូលបន្ថែមនឹងត្រូវដាក់ចូលទៅក្នុងមូលនិធិពិសេសថ្មីមួយ។ មូលនិធិទាំងនេះនឹងត្រូវបានប្រើប្រាស់សម្រាប់គោលបំណងជាក់លាក់របស់ LAFD រួមមានជាអាទិ៍៖

- ការជួល និងការរក្សាបុគ្គលិកពន្លត់អគ្គីភ័យ បុគ្គលិកសង្គ្រោះបន្ទាន់ និងបុគ្គលិកស៊ីវិល LAFD,
- ការទិញ និងថែទាំយានយន្តដើម្បីគាំទ្រដល់តម្រូវការពន្លត់អគ្គីភ័យ និងជួយសង្គ្រោះ ដូចជារថយន្តពន្លត់អគ្គីភ័យ រថយន្តពន្លត់អគ្គីភ័យ រថយន្តសង្គ្រោះបន្ទាន់ យន្តហោះ និងឧទ្ធម្ភាគចក្រ។
- ការទិញ និងថែទាំឧបករណ៍ដើម្បីគាំទ្រដល់សេវាពន្លត់អគ្គីភ័យ និងជួយសង្គ្រោះ,
- ការប្តូរ ការធ្វើឱ្យប្រសើរឡើង ឬការសាងសង់ស្ថានីយពន្លត់អគ្គីភ័យថ្មី និងកន្លែងផ្តល់សេវាសង្គ្រោះបន្ទាន់ ដែលការសាងសង់នឹងត្រូវស្ថិតនៅក្រោមកិច្ចព្រមព្រៀងការងាររបស់គម្រោង និងតម្រូវការប្រាក់ឈ្នួលជាធរមាន។
- ការទិញ និងការថែទាំប្រព័ន្ធទំនាក់ទំនងសង្គ្រោះបន្ទាន់ និង
- ការកែលម្អការកាប់បំផ្លាញគុម្ពឈើ និងការត្រៀមបង្ការភ្លើងឆេះព្រៃ។

ដើម្បីប្រមូលពន្ធនេះ ក្រុងនឹងត្រូវបានតម្រូវឱ្យរក្សាថវិកាតាមការសម្រេចចិត្តរបស់ LAFD តាមភាគរយជាមធ្យមដែលបានផ្តល់ជូនសម្រាប់រយៈពេលដប់ឆ្នាំមុនកាលបរិច្ឆេទអនុវត្តនៃច្បាប់។ វិធានការនេះក៏នឹងបង្កើតគណៈកម្មាធិការត្រួតពិនិត្យប្រជាពលរដ្ឋ (COC) ដើម្បីត្រួតពិនិត្យការចំណាយចំណូលដែលបង្កើតឡើងដោយពន្ធលើការលក់នេះផងដែរ។ COC នឹងមានសមាជិកប្រាំរូប ដែលជ្រើសរើសចេញពីប្រជាពលរដ្ឋនៅក្នុងទីក្រុង។ ចៅហ្វាយក្រុង ប្រធានក្រុមពន្លត់អគ្គិភ័យ អគ្គ

ធិការហិរញ្ញវត្ថុក្រុង មន្ត្រីរដ្ឋបាលទីក្រុង និងប្រធានគណៈកម្មាធិការសុវត្ថិភាពសាធារណៈរបស់ក្រុមប្រឹក្សាក្រុង ម្នាក់ៗមានសិទ្ធិអំណាចតែងតាំងសមាជិកម្នាក់ទៅក្នុង COC។ COC នឹងតម្រូវឱ្យពិនិត្យការចំណាយឡើងវិញ និងចេញរបាយការណ៍ទៅចៅហ្វាយក្រុង គណៈកម្មការស្នងការអគ្គីភ័យ ក្រុមប្រឹក្សាក្រុង និងសាធារណជនយ៉ាងហោចណាស់មួយឆ្នាំម្តង។

សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាក្រុងក្នុងការធ្វើវិសោធនកម្មបទបញ្ញត្តិដោយមិនចាំបាច់មានការយល់ព្រមពីអ្នកបោះឆ្នោតត្រូវបានកំណត់ចំពោះវិសោធនកម្មដែលចាំបាច់យ៉ាងតឹងរ៉ឹងដើម្បីអនុវត្ត ឬគ្រប់គ្រងបទបញ្ញត្តិ, កំណ្លាស់ប្តូរអត្រា ឬរយៈពេលនៃពន្ធលើការលក់ ឬជំរុញគោលបំណងនៃបទបញ្ញត្តិ។ វិសោធនកម្មណាមួយដែលផ្តួចផ្តើមឡើងដោយក្រុមប្រឹក្សានឹងតម្រូវឱ្យមានការយល់ព្រមពីពីរភាគបីនៃក្រុមប្រឹក្សាបន្ទាប់ពីការជូនដំណឹងជាសាធារណៈរយៈពេល 30 ថ្ងៃ។

ពន្ធលើការលក់កន្លះភាគរយដែលស្នើឡើងដោយគំនិតផ្តួចផ្តើមនេះនឹងត្រូវបានដាក់ចេញប្រហែល 110 ថ្ងៃបន្ទាប់ពីការយល់ព្រមពីអ្នកបោះឆ្នោត។

វិធានការនេះអាចនឹងមានប្រសិទ្ធភាព ប្រសិនបើត្រូវបានយល់ព្រមដោយអ្នកបោះឆ្នោតភាគច្រើន។

របាយការណ៍ផលប៉ះពាល់ហិរញ្ញវត្ថុ
ដោយ MATTHEW W. SZABO មន្ត្រីរដ្ឋបាលទីក្រុង

វិធានការនេះបង្កើនពន្ធលើការលក់របស់ក្រុងចំនួន 0.5 ភាគរយ (ពី 10.25 ដល់ 10.75 ភាគរយ)។ វាបង្កើតចំណូលប្រហែល $345 លានដុល្លារជារៀងរាល់ឆ្នាំសម្រាប់មូលនិធិពិសេសមួយដែលកំណត់ដល់ការគាំទ្រដល់ប្រតិបត្តិការ និងសេវាកម្មរបស់នាយកដ្ឋានពន្លត់អគ្គីភ័យ Los Angeles (LAFD) រួមទាំងមុខងារស្នូលរបស់ខ្លួន៖ ការជួល និងរក្សាបុគ្គលិក ការទិញ និងការថែទាំយានយន្ត និងឧបករណ៍ពន្លត់អគ្គីភ័យ ការសាងសង់ស្ថានីយពន្លត់អគ្គីភ័យថ្មី និងកែលម្អឱ្យប្រសើរឡើង និងកែលម្អស្ថានីយពន្លត់អគ្គីភ័យដែលមានស្រាប់ឱ្យប្រសើរឡើង និងបង្កើនការត្រៀមខ្លួនសម្រាប់ភ្លើងឆេះព្រៃ និងការគ្រប់គ្រងគុម្ពឈើ។ ចំណូល និងចំណាយនឹងត្រូវបានត្រួតពិនិត្យដោយគណៈកម្មាធិការត្រួតពិនិត្យប្រជាពលរដ្ឋ និងត្រូវបានធ្វើសវនកម្មជារៀងរាល់ឆ្នាំ។ វិធានការនេះតម្រូវឱ្យមាន “ការរក្សាកិច្ចខិតខំប្រឹងប្រែង” ដែលក្រុងត្រូវតែផ្តល់មូលនិធិដល់ LAFD ក្នុងកម្រិតមូលដ្ឋានស្មើនឹងភាគរយជាមធ្យមនៃមូលនិធិសម្រេចសរុបដល់ LAFD ក្នុងអំឡុងពេលដប់ឆ្នាំសារពើពន្ធភ្លាមៗមុនកាលបរិច្ឆេទអនុវត្តវិធានការ។ ប្រសិនបើកម្រិតថវិកានេះមិនត្រូវបានបំពេញ ពន្ធនឹងមិនអាចត្រូវបានដាក់បង់ក្នុងឆ្នាំសារពើពន្ធនោះទេ។

សេចក្តីអះអាងគាំទ្រគំនិតផ្តួចផ្តើមបទបញ្ញត្តិ FD

រាល់ពេលដែលអ្នកទូរស័ព្ទទៅ 911 អ្នករំពឹងថាយើងនឹងនៅទីនោះ ។ យើងក៏ដូច្នោះដែរ ។

ក្នុងនាមជាអ្នកពន្លត់អគ្គិភ័យ និងភ្នាក់ងារគិលានសង្គ្រោះនៃក្រសួងពន្លត់អគ្គិភ័យនៃទីក្រុង Los Angeles យើងបានលះបង់ជីវិតរបស់យើងដើម្បីការពារទីក្រុងនេះ ។ យើងឆ្លើយតបទៅនឹងថ្ងៃដ៏អាក្រក់បំផុតរបស់អ្នក៖ អគ្គិភ័យឆេះផ្ទះ ការគាំងបេះដូង គ្រោះថ្នាក់ចរាចរណ៍ ហេតុការណ៍ពាក់ព័ន្ធនឹងសារធាតុគ្រោះថ្នាក់ ការណីសង្គ្រោះ និងអគ្គិភ័យឆេះព្រៃដែលកាន់តែបំផ្លិចបំផ្លាញឡើងៗ ។ រាល់វិនាទីសុទ្ធតែសំខាន់ ហើយអាចជាភាពខុសគ្នារវាងជីវិត និងសេចក្តីស្លាប់ ។

ប៉ុន្តែឥឡូវនេះ ដោយសារការខ្វះខាតអ្នកពន្លត់អគ្គិភ័យ ភ្នាក់ងារគិលានសង្គ្រោះ ឧបករណ៍ និងធនធាន ពួកយើងចំណាយពេលស្ទើរតែពីរដងនៃពេលវេលាដែលគួរតែចំណាយ ដើម្បីទៅដល់ទីតាំងកើតហេតុក្នុងស្ថានភាពសង្គ្រោះបន្ទាន់ ។ នៅពេលដែលយើងយឺតយ៉ាវ យើងដឹងថាអ្វីអាចកើតឡើង ។ យើងបានឃើញអគ្គិភ័យរាលដាលហួសពីការគ្រប់គ្រង បានតស៊ូដើម្បីជួយសង្គ្រោះអ្នកជំងឺដែលឱកាសរស់រានមានជីវិតរបស់ពួកគេថយចុះជាមួយនឹងរាល់នាទីដែលកន្លងផុតទៅ ហើយបានឈរនៅក្បែរគ្រួសារនានា ដោយដឹងថាការឆ្លើយតបបានលឿនជាងមុនអាចផ្លាស់ប្តូរលទ្ធផលបាន ។

ដើម្បីមើលថាតើអ្នកពន្លត់អគ្គិភ័យ និងភ្នាក់ងារគិលានសង្គ្រោះនៃ LAFD អាចទៅដល់ទីតាំងរបស់អ្នកទាន់ពេលវេលាឬយ៉ាងណាសូមចូលទៅកាន់គេហទំព័រ FundLAFire.com ។

បន្ទាប់ពីការមិនយកចិត្តទុកដាក់អស់ជាច្រើនទសវត្សរ៍មក យើងមិនអាចទុកចិត្តសាលាក្រុងក្នុងការដោះស្រាយបញ្ហារបស់ LAFD បានឡើយ ។ នោះហើយជាមូលហេតុដែលអ្នកពន្លត់អគ្គិភ័យ និងភ្នាក់ងារគិលានសង្គ្រោះនៃ LAFD បានបង្កើតវិធានការ FD ឡើង៖ ដើម្បីធានាថាការឆ្លើយតបទៅនឹងការសង្គ្រោះបន្ទាន់តាមលេខ 911 កាន់តែលឿន ការពារអគ្គិភ័យឆេះព្រៃ និងការពារសហគមន៍របស់យើង ។

រយៈពេលឆ្លើយតបចំពោះការសង្គ្រោះបន្ទាន់តាមលេខ 911

លើសពី 80% នៃការហៅទូរស័ព្ទទៅលេខ 911 របស់ LAFD ទាំងអស់ គឺជាការណីសង្គ្រោះបន្ទាន់ផ្នែកវេជ្ជសាស្ត្រ ដូចជា ជំងឺគាំងបេះដូង ជំងឺដាច់សរសៃឈាមខួរក្បាល និងគ្រោះថ្នាក់ចរាចរណ៍ ។ ស្តង់ដាជាតិសម្រាប់ភ្នាក់ងារគិលានសង្គ្រោះទៅដល់ទីតាំងកើតហេតុក្នុងការណីសង្គ្រោះបន្ទាន់ផ្នែកវេជ្ជសាស្ត្រ គឺរយៈពេលបួននាទី ប៉ុន្តែនៅទីក្រុង Los Angeles វាច្រើនតែចំណាយពេលជិតពីរដងនៃពេលវេលានេះ ។

នៅពេលដែលមនុស្សម្នាក់ជួបប្រទះការគាំងបេះដូង ពួកគេមានពេលត្រឹមតែ 4-6 នាទីប៉ុណ្ណោះ មុនពេលការខូចខាតខួរក្បាលដែលមិនអាចស្តារឡើងវិញបានកើតឡើង ។ នាទីបន្ថែមទាំងនេះដែលបណ្តាលមកពីការខ្វះខាតបុគ្គលិក នាំឱ្យកើតមានលទ្ធផលដ៏សោកសៅដែលពួកយើងចងចាំ និងផ្ទុកជាប់ក្នុងចិត្តរហូតមក ។ នោះហើយជាមូលហេតុដែលពួកយើងបានបង្កើតវិធានការ FD ឡើង។

<u>វិធានការ FD នឹងអនុញ្ញាតឱ្យ LAFD ជួលភ្នាក់ងារគិលានសង្គ្រោះបន្ថែម និងកាត់បន្ថយរយៈពេលឆ្លើយតបចំពោះការសង្គ្រោះបន្ទាន់តាមលេខ 911 ។</u>

ការបង្ការភ្លើងឆេះព្រៃ

ហានិភ័យនៃភ្លើងឆេះព្រៃនៅ Los Angeles គឺស្ថិតក្នុងកម្រិតខ្ពស់បំផុតមិនធ្លាប់មានពីមុនមក ។ វិធានការ FD មានសារៈសំខាន់បំផុតក្នុងការកាត់បន្ថយហានិភ័យនេះ ៖ <u>វានឹងបង្កើនថវិកាសម្រាប់កម្មវិធីកាប់ឆ្តារព្រៃស៊ុបទ្រូប និងកម្មវិធីបង្ការអគ្គិភ័យឆេះព្រៃរបស់ក្រសួង</u> ព្រមទាំងធ្វើទំនើបកម្មឧទ្ធម្ភាគចក្រទម្លាក់ទឹក ទិញយន្តហោះឯកទេស និងផ្តល់អ្នកពន្លត់អគ្គិភ័យដែលចាំបាច់ដើម្បីប្រយុទ្ធប្រឆាំងនឹងអគ្គិភ័យទាំងនេះ ។

ធនធាន LAFD ឆ្នាំ 1965 សម្រាប់ទីក្រុងឆ្នាំ 2026

ចាប់តាំងពីឆ្នាំ 1965 មក ចំនួនប្រជាជននៅ LA បានកើនឡើងជាង 50% ប៉ុន្តែចំនួនអ្នកពន្លត់អគ្គិភ័យ ឬភ្នាក់ងារគិលានសង្គ្រោះមិនបានកើនឡើងនោះទេ ហើយបច្ចុប្បន្ននេះ ទីក្រុងមានស្ថានីយពន្លត់អគ្គិភ័យតាមសង្កាត់តិចជាងមុន ដែលធ្វើឱ្យមិនអាចឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះការហៅសុំសេវាចំនួន 500,000 ដងក្នុងមួយឆ្នាំ ។

<u>តាមរយៈវិធានការ FD, LAFD នឹងអាចជួលអ្នកពន្លត់អគ្គិភ័យ និងភ្នាក់ងារគិលានសង្គ្រោះបន្ថែមយ៉ាងហោចណាស់ 1,000 នាក់ ដើម្បីឱ្យពួកយើងអាចទៅដល់ទាន់ពេលវេលា នៅពេលដែលអ្នកត្រូវការពួកយើងបំផុត ។</u>

មូលនិធិទាំងអស់ត្រូវបានបម្រុងទុកសម្រាប់ LAFD

<u>វិធានការ FD ផ្តល់នូវប្រភពមូលនិធិដែលបម្រុងទុកជាក់លាក់ និងគ្រប់គ្រងដោយមូលដ្ឋាន ដោយតម្រូវឱ្យ 100% នៃមូលនិធិត្រូវយកទៅប្រើប្រាស់លើសេវាកម្មសុំលរបស់ LAFD ដែលមិនអាចបង្វែរទៅប្រើប្រាស់សម្រាប់គោលបំណងផ្សេងទៀតបានឡើយ ។</u>

មូលនិធិនេះមានសារៈសំខាន់បំផុត ពីព្រោះយើងកំពុងប្រឹងប្រែងប្រើប្រាស់រាល់ធនធានដែលយើងមានឱ្យអស់លទ្ធភាព៖ ផ្លាស់ទីពីករណីសង្គ្រោះបន្ទាន់មួយទៅករណីមួយទៀតដោយមិនឈប់សម្រាក បញ្ជូនរថយន្តពន្លត់អគ្គិភ័យឆ្លងកាត់ទីក្រុង ពីព្រោះរថយន្តដែលនៅជិតបំផុតកំពុងជាប់បំពេញការកិច្ចរួចហើយ និងកំពុងខ្វះខាតរថយន្តសង្គ្រោះបន្ទាន់ ខណៈដែលតម្រូវការកើនលើសចំនួនបុគ្គលិក—ទាំងអស់នេះកើតឡើងស្របពេលដែលស្ថានីយ និងបរិក្ខាររបស់យើងចេះតែចាស់ទ្រុឌទ្រោម ។

តើមូលនិធិពន្ធនៃវិធានការ FD ទៅទីណា?

យោងតាមច្បាប់ <u>100% នៃមូលនិធិត្រូវយកទៅប្រើប្រាស់លើសេវាកម្មសុំលរបស់ LAFD</u> រួមមាន ការជ្រើសរើស និងការរក្សាទុកអ្នកពន្លត់អគ្គិភ័យ និងភ្នាក់ងារគិលានសង្គ្រោះដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ការបង្កើនកម្មវិធីកាប់ឆ្ការព្រៃស៊ីបទ្រុប និងកម្មវិធីបង្ការអគ្គិភ័យឆេះព្រៃ និងការផ្តល់បរិក្ខារទាន់សម័យដល់អ្នកពន្លត់អគ្គិភ័យ ។ វាត្រូវបានដាក់បញ្ចូលទៅក្នុងមូលនិធិដែលបម្រុងទុកជាក់លាក់ និងការពារដោយច្បាប់ ហើយច្បាប់ហាមឃាត់អ្នកនយោបាយនៅសាលាក្រុងមិនឱ្យបង្វែរប្រាក់សូម្បីតែមួយដុល្លារទៅកន្លែងផ្សេងទៀតឡើយ ។

តើវិធានការ FD ខុសពីវិធានការពន្ធផ្សេងទៀតរបស់ Los Angeles យ៉ាងដូចម្តេច?

ពីព្រោះវិធានការ FD ត្រូវបានរៀបចំឡើងខុសស្លេកពីគេ ។ វាបង្កើតមូលនិធិតែមួយដែលបម្រុងទុកជាក់លាក់ ដែលអាចចំណាយបានតែទៅលើបុគ្គលិក យានយន្ត គ្រឿងបរិក្ខារ និងស្ថានីយរបស់ LAFD ប៉ុណ្ណោះ ។ វាតម្រូវឱ្យមានការបង្ហាញពីការចំណាយជាសាធារណៈ ការធ្វើសវនកម្មឯករាជ្យប្រចាំឆ្នាំ និងត្រូវបានត្រួតពិនិត្យដោយគណៈកម្មាធិការត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ ។ គ្មានភាពស្រពិចស្រពិលឡើយអំពីកន្លែងដែលថវិកានេះត្រូវយកទៅប្រើប្រាស់ ពីព្រោះបទបញ្ញត្តិមិនអនុញ្ញាតឱ្យបង្វែរវាទៅប្រើប្រាស់សម្រាប់គោលបំណងផ្សេងទៀតឡើយ ។

តើវិធានការ FD រារាំងសាលាក្រុងមិនឱ្យកាត់បន្ថយមូលនិធិដែលមានស្រាប់របស់ LAFD ដែរឬទេ ?

<u>វិធានការ FD ហាមឃាត់អ្នកនយោបាយ និងមន្ត្រីរាជការក្រុងមិនឱ្យបង្វែរមូលនិធិដែលមានស្រាប់របស់ LAFD ឡើយ ។</u>

វិធានការ FD រួមបញ្ចូលទាំងតម្រូវការរក្សាកិច្ចខិតខំប្រឹងប្រែង៖ ទីក្រុងត្រូវបន្តផ្តល់មូលនិធិដល់ LAFD យ៉ាងហោចណាស់ស្មើនឹងចំណែកជាមធ្យមរបស់ខ្លួននៃថវិកាដែលអាចសម្រេចចិត្តលើការប្រើប្រាស់បានក្នុងរយៈពេលដប់ឆ្នាំកន្លងមកនេះ ។ ប្រសិនបើក្រុងមិនអាចបំពេញតាមបន្ទាត់មូលដ្ឋាននោះបានទេ ក្រុងនឹងត្រូវបានហាមឃាត់ដោយផ្លូវច្បាប់មិនឱ្យប្រមូលពន្ធថ្មីនៅឆ្នាំនោះ។ មូលនិធិនេះត្រូវតែបន្ថែម មិនមែនជំនួសទៅនឹងធនធាន LAFD ដែលមានស្រាប់នោះទេ។

តើអ្នកជាប់ពន្ធនឹងត្រូវចំណាយប្រាក់ប៉ុន្មានសម្រាប់វិធានការ FD ?

វិធានការ FD គឺជាពន្ធលើការលក់ក្នុងអត្រាកន្លះសេន៖ ប្រាំសេន លើការទិញតម្លៃ $10 ។ នោះមានន័យថា ជំនួយនឹងទៅដល់កាន់តែលឿន នៅពេលដែលមនុស្សជាទីស្រឡាញ់របស់អ្នកទូរស័ព្ទទៅលេខសង្គ្រោះបន្ទាន់ 911 ។

តើវិធានការ FD ផ្តល់មូលនិធិសម្រាប់កម្មវិធី និងគ្រឿងបរិក្ខារ LAFD ជាក់លាក់អ្វីខ្លះ ?

ការជ្រើសរើសបុគ្គលិកជាអ្នកពន្លត់អគ្គិភ័យ និងភ្នាក់ងារគិលានសង្គ្រោះបន្ថែម ដើម្បីកាត់បន្ថយរយៈពេលឆ្លើយតបចំពោះការសង្គ្រោះបន្ទាន់តាមលេខ 911 និងការពង្រីកការកាប់ឆ្ការព្រៃស៊ីបទ្រុប ក៏ដូចជាកម្មវិធីបង្ការអគ្គិភ័យឆេះព្រៃ ។ ក្នុងឆ្នាំ 2025 ភ្លើងភ័យឆេះព្រៃបានធ្វើឱ្យអ្នកបង់ពន្ធនៅ LA ខាតបង់ប្រាក់រាប់រយលានដុល្លារដោយសារការខូចខាតហេដ្ឋារចនាសម្ព័ន្ធ គ្រឿងបរិក្ខារ ការឆ្លើយតបចំពោះការសង្គ្រោះបន្ទាន់ និងការបាត់បង់ចំណូល ការចំណាយលើការបង្ការអគ្គិភ័យឆេះព្រៃមានតម្លៃទាបជាងឆ្ងាយ បើធៀបនឹងការចំណាយដើម្បីស្តារឡើងវិញពីអគ្គិភ័យឆេះព្រៃ ។ វិធានការនេះក៏អនុញ្ញាតឱ្យ LAFD បំពេញតាមស្តង់ដារបុគ្គលិកជាតិ ធ្វើឱ្យប្រសើរឡើងនូវស្ថានីយពន្លត់អគ្គិភ័យ ផ្តល់ឧបករណ៍ការពារដូចជា សម្លៀកបំពាក់ធន់នឹងភ្លើង និងវិទ្យុទាក់ទង និងធ្វើទំនើបកម្មបច្ចេកវិទ្យាទំនាក់ទំនង 911 របស់យើងផងដែរ ។

វិធានការ FD មកជាមួយនូវគណនេយ្យភាពដែលអាចអនុវត្តបាន ដែលត្រូវបានបង្កើតឡើងដោយផ្ទាល់នៅក្នុងច្បាប់៖ សវនកម្ម ឯករាជ្យ ការរាយការណ៍ជាសាធារណៈ និងការត្រួតពិនិត្យដោយប្រជាពលរដ្ឋ ដូច្នេះអ្នកបង់ពន្ធដឹងយ៉ាងច្បាស់ពីរបៀបដែលរាល់ដុល្លារត្រូវបានចំណាយ ។ នោះហើយជាមូលហេតុដែលវិធានការ FD ទទួលបានការគាំទ្រពីអ្នកពន្លត់អគ្គិភ័យ និងភ្នាក់ងារគិលានសង្គ្រោះក្នុងតំបន់របស់អ្នក គ្រូពេទ្យបន្ទាប់សង្គ្រោះបន្ទាន់ និងម្ចាស់អាជីវកម្មខ្នាតតូច ។

រាល់ឆ្នាំដែលយើងរង់ចាំ គឺស្មើនឹងមួយឆ្នាំទៀតនៃពេលវេលាឆ្លើយតបដែលស្វើរតែទ្វេដងនៃស្តង់ដាជាតិ និងមួយឆ្នាំទៀតដែលបុគ្គលិកពន្លត់អគ្គិភ័យ និងភ្នាក់ងារគិលានសង្គ្រោះត្រូវខិតខំប្រឹងប្រែងដើម្បីបំពេញតម្រូវការរបស់ទីក្រុង ដែលទំហំ និងតម្រូវការរបស់ទីក្រុងនេះបានកើនឡើងលើសពីសមត្ថភាពរបស់ពួកគេអស់ជាច្រើនទសវត្សរ៍មកហើយ ។ LA បានកីកចម្រើន ។ ដល់ពេលដែល LAFD ត្រូវធ្វើដូចគ្នាដែរហើយ ។

នៅទីក្រុង Los Angeles វាមិនមែនជាបញ្ហាថា តើអ្នកនឹងហៅលេខសង្គ្រោះបន្ទាន់ 911 សម្រាប់មនុស្សជាទីស្រឡាញ់របស់អ្នកឬអត់នោះទេ ប៉ុន្តែវាគឺជាបញ្ហាថា តើអ្នកនឹងហៅនៅពេលណាវិញ ។

នៅពេលអ្នកបោះឆ្នោតគាំទ្រវិធានការ FD អ្នកកំពុងវិនិយោគលើអ្វីមួយដែលប្រជាពលរដ្ឋគ្រប់រូបពឹងផ្អែកលើ មិនថាពួកគេដឹងពីរឿងនេះនៅថ្ងៃនេះឬអត់នោះទេ ពីព្រោះថ្ងៃណាមួយ ជីវិតដែលយើងជួយសង្គ្រោះអាចជាជីវិតរបស់អ្នកផ្ទាល់ ។

ចូលរួមជាមួយអ្នកពន្លត់អគ្គិភ័យ និងភ្នាក់ងារគិលានសង្គ្រោះរបស់ LAFD សមាគមមន្ត្រីអគ្គិភ័យ LAFD អ្នកពន្លត់អគ្គិភ័យអាជីព California និងសមាគមអន្តរជាតិនៃអ្នកពន្លត់អគ្គិភ័យ ដោយបោះឆ្នោតគាំទ្រវិធានការ FD ។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់ FundLAFire.com ។

បុគ្គលដែលចុះហត្ថលេខា សេចក្តីអះអាងគាំទ្រគំនិតផ្តួចផ្តើមបទបញ្ញត្តិ FD

DOUG COATES
ប្រធាន
United Firefighters of LA City

JAIME MOORE
ប្រធានក្រុមពន្លត់អគ្គិភ័យ
Los Angeles Fire Department

ERIC GONZALEZ
អ្នកពន្លត់អគ្គិភ័យ
LAFD, Pacific Palisades

OMAR VELASQUEZ
អ្នកពន្លត់អគ្គិភ័យ/ភ្នាក់ងារគិលានសង្គ្រោះ
LAFD, Boyle Heights

LEON DUNN
ប្រធានក្រុម
LAFD, Skid Row

DAVID RILES
ប្រធានក្រុម
LAFD, Chatsworth

GERARDO PUGA
ប្រធានក្រុម
LAFD, Panorama City

MIRANDA MCOSKER
អ្នកពន្លត់អគ្គិភ័យ
LAFD, Lincoln Heights

KIMBERLY HERRING
អ្នកពន្លត់អគ្គិភ័យ/ភ្នាក់ងារគិលានសង្គ្រោះ
LAFD, South Los Angeles

CHRIS MIYASATO
អ្នកពន្លត់អគ្គិភ័យ
LAFD, Echo Park

សេចក្តីអះអាងដែលបានបោះពុម្ព គឺជាមតិរបស់អ្នកនិពន្ធ ហើយមិនត្រូវបានត្រួតពិនិត្យភាពត្រឹមត្រូវដោយទីភ្នាក់ងារក្រុងណាមួយឡើយ ។ លើសពីនេះ មុខតំណែងនៅក្រោមឈ្មោះអ្នកចុះហត្ថលេខា គឺសម្រាប់គោលបំណងកំណត់អត្តសញ្ញាណតែប៉ុណ្ណោះ ហើយមិនបង្ហាញថាបុគ្គលនោះកំពុងចុះហត្ថលេខាក្នុងនាមអង្គការនោះទេ ។

ការបដិសេធទៅនឹងសេចក្តីអះអាងគាំទ្រនឹងគំនិតផ្តួចផ្តើមបទបញ្ញត្តិ FD

វិធានការ FD គឺជាការដំឡើងពន្ធលើការលក់។ <u>វាដំឡើងពន្ធលើការលក់រហូតដល់ 10.75%</u>

ប្រសិនបើវិធានការ FD ត្រូវបានអនុម័ត **វានឹងដំឡើងពន្ធលើការលក់នៅក្នុងទីក្រុង Los Angeles រហូតដល់ 10.75%**។ វានឹងក្លាយជាការដំឡើងពន្ធលើការលក់លើកទីបីក្នុងរយៈពេលពីរឆ្នាំ បន្ទាប់ពីការដំឡើងពន្ធលើការលក់របស់ខោនធីសម្រាប់បញ្ហាជនអនាថា (វិធានការ A ក្នុងឆ្នាំ 2024) និងការថែទាំសុខភាព (វិធានការ ER ក្នុងខែមិថុនា)។ ប៉ុន្តែវិធានការ FD មួយមុខ នឹងធ្វើឱ្យអ្នកបង់ពន្ធចំណាយអស់ប្រមាណ $345 លានក្នុងមួយឆ្នាំ។ ចែកនឹងចំនួនប្រជាជនរបស់ L.A. ប្រមាណ 4 លាននាក់ វាស្មើនឹងជាមធ្យមជាង $86 ក្នុងម្នាក់ក្នុងមួយឆ្នាំ <u>លើពន្ធលើការលក់បន្ថែម</u>, **$345 សម្រាប់គ្រួសារដែលមានសមាជិក 4 នាក់**។ <u>ជារៀងរាល់ឆ្នាំ</u>។

ការដំឡើងពន្ធនេះគឺជាគំនិតផ្តួចផ្តើមបទបញ្ញត្តិ ដើម្បីទាញយកប្រយោជន៍ពីប្រហោងច្បាប់។

រដ្ឋធម្មនុញ្ញរបស់រដ្ឋចែងថា ពន្ធពិសេសដែលថវិកាត្រូវ បានបម្រុងទុកសម្រាប់គោលបំណងជាក់លាក់ណាមួយ ទាមទារឱ្យមានសំឡេងគាំទ្រពីរភាគបី – 66.67% – ដើម្បីអនុម័ត។ ទោះជាយ៉ាងណាក៏ដោយ កាលពីពេលថ្មីៗនេះ តុលាការបានសម្រេចថា ពន្ធពិសេសត្រូវការសំឡេងគាំទ្រតិចជាងមុន – ត្រឹមតែជាង 50% មួយប៉ុណ្ណោះ – ប្រសិនបើវាត្រូវបានដាក់ចូលក្នុងសន្លឹកឆ្នោតដោយគំនិតផ្តួចផ្តើមរបស់ប្រជាពលរដ្ឋ។ អ្នកគាំទ្រឱ្យមានការដំឡើងពន្ធនេះ បានសរសេរវាយ៉ាងលម្អិតដោយខ្លួនឯង សម្រេចលើទីតាំងដែលថវិកានឹងត្រូវយកទៅប្រើប្រាស់ ប្រមូលស្នាមដៃ ហើយឥឡូវនេះអាចដំឡើងពន្ធលើការលក់ដោយមិនចាំបាច់មានសំឡេងគាំទ្រពីរភាគបីឡើយ។ **វាមិនត្រឹមត្រូវទាល់តែសោះដែលតុលាការបានធ្វើឱ្យការដំឡើងពន្ធមានភាពងាយស្រួលបែបនេះ។**

ប្រហោងច្បាប់នឹងត្រូវបិទ ប្រសិនបើម្ចាស់ឆ្នោតអនុម័តសំណើលេខ 43 នៅក្នុងខែវិច្ឆិកា

គំនិតផ្តួចផ្តើមបទបញ្ញត្តិ FD គឺជាពន្ធពិសេសដែលTargetអាចជ្រៀតចូលតាមប្រហោងច្បាប់ ដើម្បីអនុម័តដោយប្រើសំឡេងគាំទ្រតិចជាង 66.67% ដែលរដ្ឋធម្មនុញ្ញតម្រូវ។ ប្រសិនបើម្ចាស់ឆ្នោតអនុម័តសំណើលេខ 43 នៅក្នុងខែវិច្ឆិកា ប្រហោងច្បាប់នឹងត្រូវបិទនៅថ្ងៃទី 1 ខែមករា ហើយពន្ធពិសេសនាពេលអនាគតទាំងអស់ នឹងតម្រូវឱ្យមានសំឡេងគាំទ្រពីរភាគបីដើម្បីអនុម័ត។

ថ្នាក់ដឹកនាំក្រុងគួរតែផ្តល់ថវិកាពេញលេញដល់នាយកដ្ឋានពន្លត់អគ្គិភ័យ ដោយមិនចាំបាច់ដំឡើងពន្ធ

នៅក្នុងឆ្នាំថវិកា 2025-26 ចំណូលសរុបនៃមូលនិធិទូទៅរបស់ក្រុងមានចំនួនជាង $8.1 ពាន់លាន។ ហេតុអ្វីបានជាចាំបាច់ត្រូវដំឡើងពន្ធលើការលក់ ដើម្បីចំណាយលើសេវាក្រុងដែលចាំបាច់បំផុតបែបនេះ? តើមានអ្វីខ្លះនៅក្នុងថវិកាដែលមានអាទិភាពខ្ពស់ជាងការផ្តល់ថវិកាពេញលេញដល់នាយកដ្ឋានពន្លត់អគ្គិភ័យ?

បញ្ហាភាពគ្មានផ្ទះសម្បែងបានបង្កសម្ពាធលើធនធាននាយកដ្ឋានពន្លត់អគ្គិភ័យ ថវិកាគួរតែឆ្លុះបញ្ចាំងពីបញ្ហានោះ

នៅក្នុងឆ្នាំ 2025-26 ក្រុងបានចំណាយប្រមាណ $350 លាន ពីមូលនិធិទូទៅលើបញ្ហាភាពគ្មានផ្ទះសម្បែង។ នោះគឺត្រឹមតែប្រហែលមួយភាគបីនៃថវិកាសរុបរបស់ក្រុងសម្រាប់បញ្ហាជនអនាថា ដែលមានប្រមាណ $1 ពាន់លាន។ ដោយផ្អែកលើចំនួនគ្រោះអគ្គិភ័យដែលពាក់ព័ន្ធនឹងជម្រកបណ្តោះអាសន្នរបស់ជនអនាថា ក្រុងអាចយកផ្នែកខ្លះនៃថវិកាជនអនាថា ទៅផ្តល់ថវិកាពេញលេញដល់នាយកដ្ឋានពន្លត់អគ្គិភ័យ ដោយមិនចាំបាច់ដំឡើងពន្ធបន្ថែម។

ហេតុអ្វីបានជាការកែលម្អមជ្ឈមណ្ឌលសន្និបាត ត្រូវបានផ្តល់អាទិភាពខ្ពស់ជាងនាយកដ្ឋានពន្លត់អគ្គិភ័យ?

នៅក្នុងលិខិតផ្ញើជូនក្រុមប្រឹក្សាក្រុង កាលពីថ្ងៃទី 18 ខែកញ្ញា ឆ្នាំ 2025 អគ្គធិការហិរញ្ញវត្ថុក្រុងបានព្រមានថា ការកែលម្អមជ្ឈមណ្ឌលសន្និបាតតម្លៃ $2.7 ពាន់លាន នឹងតម្រូវឱ្យមាន "ថវិកាបន្ថែមជាមធ្យម $116 លាន ពីមូលនិធិទូទៅក្នុងមួយឆ្នាំ សម្រាប់រយៈពេល 28 ឆ្នាំខាងមុខ...." នោះគឺជាទឹកប្រាក់ $116 លាន ក្នុងមួយឆ្នាំ ដែលដើមឡើយអាចយកទៅប្រើប្រាស់សម្រាប់ជួលអ្នកពន្លត់អគ្គិភ័យបន្ថែមបាន។

ពន្ធលើការលក់គឺខ្ពស់ហួសហេតួចទៅហើយ សូមបោះឆ្នោតប្រឆាំងនឹងគំនិតផ្តួចផ្តើមបទបញ្ញត្តិ FD

អ្នកបង់ពន្ធគ្រប់គ្រាន់ហើយ។ ទីក្រុងកំពុងខ្ជះខ្ជាយថវិកា។ **បោះឆ្នោតប្រឆាំងនឹងវិធានការ FD**។

បុគ្គលដែលចុះហត្ថលេខាប្រឆាំងនឹងសេចក្តីអះអាងគាំទ្រនឹងគំនិតផ្តួចផ្តើមបទបញ្ញត្តិ FD

HOWARD JARVIS TAXPAYERS ASSOCIATION
Jon Coupal
ប្រធាន

សេចក្តីអះអាងដែលបានបោះពុម្ព គឺជាមតិរបស់អ្នកនិពន្ធ ហើយមិនត្រូវបានត្រួតពិនិត្យភាពត្រឹមត្រូវដោយទីភ្នាក់ងារក្រុងណាមួយឡើយ ។ លើសពីនេះ មុខតំណែងនៅក្រោមឈ្មោះអ្នកចុះហត្ថលេខា គឺសម្រាប់គោលបំណងកំណត់អត្តសញ្ញាណតែប៉ុណ្ណោះ ហើយមិនបង្ហាញថាបុគ្គលនោះកំពុងចុះហត្ថលេខាក្នុងនាមអង្គការនោះទេ ។

សេចក្តីអះអាងប្រឆាំងគំនិតផ្តួចផ្តើមបទបញ្ញត្តិ FD

ចោះឆ្នោតប្រឆាំងនឹងគំនិតផ្តួចផ្តើមបទបញ្ញត្តិ FD។ <u>រ៉ាដំឡើងពន្ធលើការលក់ដល់ 10.75%</u>

គិតត្រឹមថ្ងៃទី 1 ខែតុលា ពន្ធលើការលក់នៅក្នុងទីក្រុង Los Angeles គឺ 10.25%។ ប្រសិនបើបទបញ្ញត្តិគំនិតផ្តួចផ្តើម FD ត្រូវបានអនុម័ត ពន្ធលើការលក់នៅ LA នឹងមាន **10.75%**។ នេះនឹងជាការដំឡើងពន្ធលើការលក់លើកទីបីក្នុងរយៈពេលពីរឆ្នាំសម្រាប់ប្រជាជននៅក្នុងទីក្រុង Los Angeles បន្ទាប់ពីការដំឡើងពន្ធលើការលក់របស់ខោនធីសម្រាប់ភាពគ្មានផ្ទះសម្បែង (វិធានការ A ក្នុងឆ្នាំ 2024) និងការថែទាំសុខភាព (វិធានការ ER ក្នុងខែមិថុនា)។

គំនិតផ្តួចផ្តើមបទបញ្ញត្តិ FD ព្យាយាមបញ្ចូលទៅតាមចន្លោះប្រហោងមួយដែលអ្នកចោះឆ្នោតអាចបិទ

រដ្ឋធម្មនុញ្ញរដ្ឋ California តម្រូវឱ្យពន្ធពិសេស (នៅពេលដែលប្រាក់ត្រូវបានកំណត់ទុកសម្រាប់គោលបំណងពិសេស) ត្រូវបានអនុម័តដោយសំឡេងពីរភាគបីនៃអ្នកចោះឆ្នោត ដើម្បីអនុម័ត។ ទោះជាយ៉ាងណាក៏ដោយ ចាប់តាំងពីឆ្នាំ 2017 តុលាការរដ្ឋបានធ្វើឱ្យមានចន្លោះប្រហោងមួយនៅក្នុងការការពារសំណើលេខ 13 ដ៏សំខាន់នេះ។ ចៅក្រមបានអនុញ្ញាតឱ្យពន្ធដែលបានកំណត់ទុកមួយចំនួនក្នុងការត្រូវបានអនុម័តជាមួយនឹងសំឡេងឆ្នោតតិចជាង ប្រសិនបើវាត្រូវបានដាក់នៅលើសន្លឹកឆ្នោតដោយការប្រមូលហត្ថលេខានៅលើញត្តិ។ អ្នកចោះឆ្នោតអាចបិទចន្លោះប្រហោងនេះដោយតាមរយៈសំណើលេខ 43 នៅលើសន្លឹកឆ្នោតខែវិច្ឆិកា ដោយស្តារឡើងវិញនូវសំឡេងឆ្នោតពីរភាគបី ដើម្បីអនុម័តពន្ធពិសេស។ សំណើលេខ 43 នឹងចូលជាធរមាននៅក្នុងខែមករា ឆ្នាំ 2027។ ការដំឡើងពន្ធលើការលក់របស់គំនិតផ្តួចផ្តើមបទបញ្ញត្តិ FD នឹងបញ្ចូលទៅតាមចន្លោះប្រហោង ដើម្បីចៀសពីតម្រូវការចោះឆ្នោតពីរភាគបី។

ថ្នាក់ដឹកនាំក្រុងគួរតែផ្តល់មូលនិធិពេញលេញដល់នាយកដ្ឋានពន្លត់អគ្គីភ័យដោយមិនចាំបាច់ដំឡើងពន្ធ

គំនិតផ្តួចផ្តើមបទបញ្ញត្តិ FD គឺជា**ការដំឡើងពន្ធលើការលក់** ដើម្បីរៃអង្គាសប្រាក់ប្រមាណ $345 លានជារៀងរាល់ឆ្នាំសម្រាប់នាយកដ្ឋានពន្លត់អគ្គីភ័យ។ នៅក្នុងឆ្នាំថវិកានៃឆ្នាំ 2025-26 ចំណូលសរុបពីមូលនិធិទូទៅរបស់ទីក្រុងមានចំនួនជាង $8.1 ពាន់លាន។ ហេតុអ្វីបានជាការដំឡើងពន្ធលើការលក់ជាមធ្យោបាយតែមួយគត់ក្នុងការបង់ថ្លៃសេវាកម្មសំខាន់ៗនេះ? តើនៅក្នុងថវិកាមានអ្វីខ្លះដែលមានអាទិភាពខ្ពស់ជាងការផ្តល់មូលនិធិពេញលេញដល់នាយកដ្ឋានពន្លត់អគ្គីភ័យ?

ភាពគ្មានផ្ទះសម្បែងប៉ះពាល់ដល់ធនធានរបស់នាយកដ្ឋានពន្លត់អគ្គីភ័យ ដូច្នេះថវិកាគួរតែឆ្លុះបញ្ចាំងពីចំណុចនោះ

នៅឆ្នាំ 2025-26 ទីក្រុងបានចំណាយប្រហែល $350 លានពីមូលនិធិទូទៅលើភាពគ្មានផ្ទះសម្បែង។ ចំនួននោះគឺប្រហែលមួយភាគបីនៃថវិកាសរុបរបស់ទីក្រុងសម្រាប់ភាពគ្មានផ្ទះសម្បែង ដែលមានប្រមាណ $1 ពាន់លាន។ ដោយផ្អែកលើចំនួនអគ្គិភ័យដែលពាក់ព័ន្ធនឹងជម្រករបស់ជនអនាថា វាគួរតែត្រូវបានលើកយកមកពិចារណាថា តើថវិកាចំណាយភាគច្រើននៃមូលនិធិទូទៅដែលប្រើប្រាស់លើបញ្ហាភាពគ្មានផ្ទះសម្បែង គួរស្តារយកមកប្រើប្រាស់លើនាយកដ្ឋានពន្លត់អគ្គិភ័យវិញដែរឬទេ ដោយមិនចាំបាច់មានការដំឡើងពន្ធ។

អាទិភាពនៃការចំណាយរបស់ក្រុងគឺគ្មានការទទួលខុសត្រូវ

កាលពីថ្ងៃទី 18 ខែកញ្ញា ឆ្នាំ 2025 នៅក្នុងលិខិតផ្ញើជូនក្រុមប្រឹក្សាក្រុង អគ្គធិការហិរញ្ញវត្ថុក្រុងបានព្រមានប្រឆាំងនឹងការអនុម័តគម្រោងកែលម្អមជ្ឈមណ្ឌលសន្និបាត ដែលមានតម្លៃ $2.7 ពានលាន។ អគ្គធិការហិរញ្ញវត្ថុរូបនេះបានសរសេរថា "ប្រសិនបើផែនការនេះត្រូវបានអនុម័ត ក្រុងត្រូវបានរំពឹងថានឹងត្រូវការពឹងផ្អែកលើថវិកាបន្ថែមជាមធ្យម $116 លានក្នុងមួយឆ្នាំពីមូលនិធិទូទៅ សម្រាប់រយៈពេល 28 ឆ្នាំខាងមុខ ដោយចាប់ផ្តើមពីឆ្នាំថវិកា 2029។ ទឹកប្រាក់ $116 លាននេះ គឺស្មើនឹងតម្លៃពលកម្មនៃការងាររដ្ឋបាលក្រុងជិត 1,000 កន្លែង"។ គាត់បានបញ្ជាប់លិខិតរបស់លោកដោយបញ្ជាក់ថា៖ "ដរាបណាក្រុងនៅតែបរាជ័យក្នុងការផ្លាស់ប្តូរជាមូលដ្ឋានលើរបៀបគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួន ហើយបន្តផ្តល់ថវិកាមិនគ្រប់គ្រាន់លើសេវាសាធារណៈសម្រាប់ប្រជាពលរដ្ឋជិត 4 លាននាក់របស់យើង យើងមិនអាចទម្លាក់អនុសាសន៍ឱ្យទទួលយកគម្រោងនេះនៅពេលនេះបានទេ"។ ទោះជាយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាក្រុងនៅតែបន្តអនុម័តគម្រោងដ៏ចំណាយច្រើនមួយនេះដដែល។ នោះគឺជាទឹកប្រាក់ $116 លានដុល្លារក្នុងមួយឆ្នាំ ដែលដើមឡើយអាចយកទៅប្រើប្រាស់សម្រាប់ជួលអ្នកពន្លត់អគ្គិភ័យបន្ថែមបាន។

ពន្ធលើការលក់គឺខ្ពស់ហួសហេតួចទៅហើយ ដែលវាបានហួសកម្រិតកំណត់ក្នុងច្បាប់រដ្ឋ

ច្បាប់នៃរដ្ឋ California បានកំណត់ពន្ធលើការលក់នៅថ្នាក់មូលដ្ឋានត្រឹម 2% ប៉ុណ្ណោះ បន្ថែមលើពន្ធលើការលក់របស់រដ្ឋចំនួន 7.25%។ ទោះជាយ៉ាងណាក៏ដោយ អ្នកបង្កើតច្បាប់របស់រដ្ឋតែងតែអនុម័តច្បាប់ថ្មីៗជាហូរហែ ដើម្បីលើកលែងពន្ធលើការលក់ថ្មីៗ និងពន្ធដែលខ្ពស់ជាងមុនចេញពីកម្រិតកំណត់នេះ។ កិច្ចការពារដ៏សំខាន់សម្រាប់អ្នកបង់ពន្ធមួយនេះ ត្រូវបានគេបំផ្លាញចោលទាំងស្រុង។ ពន្ធលើការលក់កំពុងតែក្លាយជាបន្ទុកកាន់តែធ្ងន់ធ្ងរទៅៗសម្រាប់ប្រជាជន California ដែលជាអ្នកខ្សត់ខ្សោយ និងមិនសូវមានលទ្ធភាពទប់ទល់នឹងទំនិញឡើងថ្លៃ។

បោះឆ្នោតប្រឆាំងនឹងគំនិតផ្ទួចផ្តើមបទបញ្ញត្តិ FD

កុំបណ្តោយឱ្យរដ្ឋបាលក្រុងគេចផុតពីការទទួលខុសត្រូវក្នុងការខ្ជះខ្ជាយថវិកា ដែលគួរតែត្រូវយកទៅចំណាយលើកិច្ចការអាទិភាពខ្ពស់បំផុតមុនគេនោះឡើយ។ គ្មានអាទិភាពណាខ្ពស់ជាងការផ្តល់ថវិកាពេញលេញដល់ក្រុមសង្គ្រោះបឋមនោះទេ។ សូមបោះឆ្នោតប្រឆាំងនឹងគំនិតផ្ទួចផ្តើមបទបញ្ញត្តិ FD ហើយប្រាប់ទៅថ្នាក់ដឹកនាំក្រុងឱ្យរៀបចំអាទិភាពរបស់ពួកគេឱ្យបានត្រឹមត្រូវ។

បុគ្គលដែលចុះហត្ថលេខាលើសេចក្តីអះអាងប្រឆាំងនឹងបទបញ្ញត្តិគំនិតផ្ទួចផ្តើម FD

HOWARD JARVIS TAXPAYERS ASSOCIATION
Jon Coupal
ប្រធាន

សេចក្តីអះអាងដែលបានបោះពុម្ព គឺជាមតិរបស់អ្នកនិពន្ធ ហើយមិនត្រូវបានត្រួតពិនិត្យភាពត្រឹមត្រូវដោយទីភ្នាក់ងារក្រុងណាមួយឡើយ ។ លើសពីនេះ មុខតំណែងនៅក្រោមឈ្មោះអ្នកចុះហត្ថលេខា គឺសម្រាប់គោលបំណងកំណត់អត្តសញ្ញាណតែប៉ុណ្ណោះ ហើយមិនបង្ហាញថាបុគ្គលនោះកំពុងចុះហត្ថលេខាក្នុងនាមអង្គការនោះទេ ។

ការបដិសេធទៅនឹងសេចក្តីអះអាងដែលបានប្រឆាំងនឹងគំនិតផ្តួចផ្តើមបទបញ្ញត្តិ FD

ក្រុមអ្នកប្រឆាំងនិយាយត្រូវលើរឿងមួយ៖ សាលាក្រុងគួរតែផ្តល់ថវិកាពេញលេញដល់នាយកដ្ឋានពន្លត់អគ្គិភ័យ។ យើងយល់ស្របលើរឿងនេះ។ ក្នុងនាមជាអ្នកពន្លត់អគ្គិភ័យ និងគ្រូពេទ្យសង្គ្រោះបន្ទាន់នៃ LAFD យើងបានធ្វើការតស៊ូមតិលើរឿងនេះអស់រយៈពេលជាច្រើនទសវត្សរ៍មកហើយនៅក្នុងសាលាក្រុង ក្រោមអាណាត្តិអភិបាលក្រុង និងក្រុមប្រឹក្សាក្រុងគ្រប់និន្នាការនយោបាយ។ ប៉ុន្តែវាមិនដែលកើតឡើងនោះទេ។

ចាប់តាំងពីទសវត្សរ៍ឆ្នាំ 1960 មក ទីក្រុង Los Angeles បានកើនឡើងជាង 50% គឺមានប្រជាជនបន្ថែមជាង 1.4 លាននាក់ ខណៈដែលចំនួនអ្នកពន្លត់អគ្គិភ័យមិនបានកើនឡើងទាល់តែសោះ ហើយស្ថានីយពន្លត់អគ្គិភ័យតាមសហគមន៍នាពេលបច្ចុប្បន្នមានចំនួនតិចជាងកាលពីពេលនោះទៅទៀត។ នោះមិនមែនជាបញ្ហាថវិកាមិនល្អតែមួយឆ្នាំនោះទេ។ <u>នោះគឺជាការបដិសេធរបស់សាលាក្រុងក្នុងការយក LAFD ធ្វើជាអាទិភាពអស់រយៈពេលជាង 60 ឆ្នាំមកហើយ។ ការរង់ចាំអ្នកនយោបាយឱ្យ "រៀបចំអាទិភាពរបស់ពួកគេឱ្យបានត្រឹមត្រូវ" គឺជាផែនការដែលយើងបានសាកល្បងរួចហើយ។ មនុស្សរង់ចាំដល់ស្លាប់។</u>

នោះហើយជាមូលហេតុដែលអ្នកពន្លត់អគ្គិភ័យ និងគ្រូពេទ្យសង្គ្រោះបន្ទាន់នៃ LAFD បានរៀបចំវិធានការ FD ហើយជាមូលហេតុដែលអ្នកបោះឆ្នោត មិនមែនអ្នកនយោបាយឡើយ គឺជាអ្នកដាក់វាចូលទៅក្នុងសន្លឹកឆ្នោត។

យើងក៏យល់ដែរថា ការចំណាយលើការសង់នៅគឺមានកម្រិតខ្ពស់។ យើងក៏បង់ពន្ធដូចគ្នា។ នោះហើយជាមូលហេតុដែលវិធានការ FD កំណត់ត្រឹមតែពាក់កណ្តាលសេន៖ គឺស្មើនឹងប្រាំសេនលើការទិញទំនិញតម្លៃ $10។ ទោះបីជាវិធានការ FD ត្រូវបានអនុម័តក៏ដោយ ទីក្រុង LA នៅតែមានអត្រាពន្ធទាបជាងអ្នកជិតខាងរបស់យើងនៅ Long Beach, Santa Monica, Pasadena, Burbank និងក្រុងភាគច្រើនក្នុងខោនធី LA។

ប្រាំសេននោះ ទិញបាននូវអ្វីដែលថវិការបស់ក្រុងមិនដែលផ្តល់ជូនសោះអស់រយៈពេលជាច្រើនជំនាន់មកហើយ។ នោះគឺការបន្ថែមអ្នកពន្លត់អគ្គិភ័យ និងគ្រូពេទ្យសង្គ្រោះបន្ទាន់យ៉ាងហោចណាស់ 1,000 នាក់ ការឆ្លើយតបរបស់សេវា 911 កាន់តែរហ័ស និងការទប់ស្កាត់អគ្គិភ័យឆេះព្រៃពិតប្រាកដ៖ ការកាប់ឆ្ការព្រៃ និងឧទ្ធម្ភាគចក្របាញ់ទឹកទំនើបៗ។

ជាង 80% នៃការហៅទូរសព្ទមកកាន់ LAFD គឺជាគ្រោះអាសន្នផ្ទៃកវេជ្ជសាស្ត្រ ហើយបច្ចុប្បន្ន គ្រូពេទ្យសង្គ្រោះបន្ទាន់ចំណាយពេលស្ទើរតែទ្វេដងនៃស្តង់ដារជាតិបួននាទី ដើម្បីទៅដល់ទីតាំងរបស់អ្នក។ ក្នុងករណីគាំងបេះដូង ការខូចខាតខួរក្បាលចាប់ផ្តើមក្នុងរយៈពេលពី 4 ទៅ 6 នាទី។ <u>ក្រុមអ្នកប្រឆាំងមិនបានផ្តល់សំណើណាមួយដំណោះស្រាយណាមួយដើម្បីដោះស្រាយបញ្ហានេះឡើយ។</u>

ក្រុមអ្នកប្រឆាំងព្រមានថាក្រុងខ្ជះខ្ជាយថវិកាលើអាទិភាពផ្សេងទៀត។ ម្តងទៀត យើងយល់ស្របលើរឿងនេះ។ នោះហើយជាមូលហេតុយ៉ាងជាក់ច្បាស់ដែលវិធានការ FD ត្រូវបានសរសេរឡើងដោយពួកយើង ដើម្បីកុំឱ្យសាលាក្រុងអាចប៉ះពាល់លុយសូម្បីតែមួយកាក់។ តាមច្បាប់ 100% នៃថវិកាទាំងអស់នឹងត្រូវចាក់ចូលទៅក្នុងគណនីបម្រុងប្រកបដោយសុវត្ថិភាព ដែលអាចចំណាយបានតែលើអ្នកពន្លត់អគ្គិភ័យ និងគ្រូពេទ្យសង្គ្រោះបន្ទាន់នៃ LAFD សម្ភារៈបរិក្ខារ និងស្ថានីយប៉ុណ្ណោះ ដោយមានការអនុវត្តតាមរយៈការសវនកម្មប្រចាំឆ្នាំឯករាជ្យ និងការផ្ទៀងផ្ទាត់ការចំណាយជាសាធារណៈ។ ហើយវិធានការ FD រួមបញ្ចូលទាំងការធានារក្សាកាតព្វកិច្ចរក្សាកម្រិតចំណាយ៖ <u>ប្រសិនបើសាលាក្រុងកាត់បន្ថយភាគរយថវិកាដែលមានស្រាប់របស់ LAFD នោះក្រុងត្រូវបានហាមឃាត់តាមផ្លូវច្បាប់មិនឱ្យប្រមូលពន្ធនេះទាល់តែសោះ។</u>

អ្នកនយោបាយមិនអាចបង្វែរថវិកានេះទៅកិច្ចការផ្សេងទៀតបានឡើយ។ នោះគឺជាគណនេយ្យភាពដ៏រឹងមាំជាងអ្វីដែលដំណើរការថវិការបស់ក្រុងធ្លាប់បានផ្តល់ជូននាពេលកន្លងមក ហើយនោះជាមូលហេតុដែលជាគំនិតពិតប្រាកដរបស់ក្រុមប្រឆាំង គឺជាមួយសាលាក្រុង មិនមែនជាមួយអ្នកពន្លត់អគ្គិភ័យរបស់អ្នកនោះទេ។

ក្រុមអ្នកប្រឆាំងនិយាយថា ឱ្យប្រាប់ទៅថ្នាក់ដឹកនាំក្រុងឱ្យរៀបចំអាទិភាពរបស់ពួកគេឱ្យបានត្រឹមត្រូវ។ យើងបានប្រាប់ពួកគេអស់រយៈពេល 60 ឆ្នាំមកហើយ។ ឥឡូវនេះ ដល់វេនរបស់អ្នកក្នុងការបញ្ជូនសំឡេង។

ថ្ងៃណាមួយ អ្នកនឹងត្រូវហៅទៅសេវា 911 ជាមិនខាន — មិនថាជាគ្រោះអគ្គិភ័យ គ្រោះថ្នាក់ចរាចរណ៍ ឬគ្រោះអាសន្នផ្នែកវេជ្ជសាស្ត្រដែលកើតមានលើរូបអ្នក ឬមនុស្សដែលអ្នកស្រឡាញ់។ នៅពេលថ្ងៃនោះមកដល់ អ្នកត្រូវការឱ្យពួកយើងទៅដល់ទីនោះឱ្យបានឆាប់។ គ្មានអ្វីសំខាន់ជាងនេះឡើយ។ វិធានការ FD ជួយឱ្យពួកយើងទៅដល់ទីនោះបានកាន់តែរហ័ស។

សូមបោះឆ្នោតគាំទ្រវិធានការ FD។

បុគ្គលដែលចុះហត្ថលេខាប្រឆាំងនឹងសេចក្តីអះអាងប្រឆាំងនឹងការផ្ទួចផ្តើមនៃបទប្បញ្ញត្តិ FD

BRENT KNEISLER
មន្ត្រីអធិការកិច្ច
LAFD Brush Clearance & Wildfire Prevention

TANYA CRABBE
ប្រធាន
Los Angeles Women in the Fire Service

MARK MCLEAN
អ្នកពន្លត់អគ្គិភ័យ
LAFD, San Pedro

ANGELO PITILLO
អ្នកពន្លត់អគ្គិភ័យ/ភ្នាក់ងារគិលានសង្គ្រោះ
LAFD, West Adams

DAVID RILES
ប្រធានក្រុម
LAFD, Chatsworth

LUCIA LIMA
អ្នកពន្លត់អគ្គិភ័យ
LAFD, Watts

JAVIER HONLES
ប្រធានក្រុម
LAFD, Encino

GARY IZQUIERDO
អ្នកពន្លត់អគ្គិភ័យ/ភ្នាក់ងារគិលានសង្គ្រោះ
LAFD, Hollywood

KYLE CAWDREY
អ្នកពន្លត់អគ្គិភ័យ
LAFD, Pico-Robertson

FERNANDO PIZANO
អ្នកពន្លត់អគ្គិភ័យ
LAFD, North Hollywood

សេចក្តីអះអាងដែលបានបោះពុម្ព គឺជាមតិរបស់អ្នកនិពន្ធ ហើយមិនត្រូវបានត្រួតពិនិត្យភាពត្រឹមត្រូវដោយទីភ្នាក់ងារក្រុងណាមួយឡើយ ។ លើសពីនេះ មុខតំណែងនៅក្រោមឈ្មោះអ្នកចុះហត្ថលេខា គឺសម្រាប់គោលបំណងកំណត់អត្តសញ្ញាណតែប៉ុណ្ណោះ ហើយមិនបង្ហាញថាបុគ្គលនោះកំពុងចុះហត្ថលេខាក្នុងនាមអង្គការនោះទេ ។

បទប្បញ្ញត្តិថ្មី ឬភាសាដែលបានបន្ថែមទៅក្រមសាលាក្រុង ឬទៅផ្នែកនៃក្រមសាលាក្រុងដែលមានស្រាប់ត្រូវបានបង្ហាញជាប្រភេទ <u>ធ្ងន់ធ្ងរ</u>ជាមុន ។ ពាក្យដែលបានលុបចេញពីក្រមសាលាក្រុង ឬពីផ្នែកនៃក្រមសាលាក្រុងដែលមានស្រាប់ត្រូវបានបង្ហាញជាប្រភេទ~~ភ្ជាប់ចោល~~ ។

បទបញ្ញត្តិគំនិតផ្តួចផ្តើម FD

ការផ្តល់ថវិកាសម្រាប់នាយកដ្ឋានពន្លត់អគ្គិភ័យ LOS ANGELES តាមរយៈពន្ធលើការលក់ក្នុងកម្រិតកន្លះភាគរយ ។ បទបញ្ញត្តិផ្តួចផ្តើម

បទបញ្ញត្តិដែលបានស្នើឡើងនឹងដាក់ពន្ធលើការលក់បន្ថែមកន្លះភាគរយ (0.5%) នៅក្នុងទីក្រុង Los Angeles ។ ប្រាក់ចំណូលពីពន្ធនឹងត្រូវបានប្រើដើម្បីផ្តល់ថវិកាបន្ថែមដែលផ្តោតលើការគាំទ្រដល់នាយកដ្ឋានពន្លត់អគ្គិភ័យទីក្រុង Los Angeles (LAFD) រួមទាំងសម្រាប់ ៖ ការជួលមន្ត្រីពន្លត់អគ្គិភ័យ ក្រុមសង្គ្រោះបឋម និងបុគ្គលិកផ្សេងទៀត ការទិញ និងថែទាំយានយន្ត និងឧបករណ៍ ការសាងសង់ និងការកែលម្អស្ថានីយ៍ពន្លត់អគ្គិភ័យ និងបរិក្ខារផ្សេងទៀត និងការត្រួតត្រាយដើម្បីបង្ការការឆេះព្រៃ ។ បទបញ្ញត្តិបានចែងថា គោលបំណងរបស់វាគឺដើម្បីបំពេញបន្ថែម តែមិនមែនជំនួសមូលនិធិបច្ចុប្បន្នរបស់ទីក្រុងសម្រាប់ LAFD ដែលថាការផ្តល់មូលនិធិបន្ថែមនឹងត្រូវបានរក្សាទុកនៅក្នុងគណនីដាច់ដោយឡែកសម្រាប់គោលបំណងផ្តាច់មុខនោះ ហើយថាពន្ធនឹងមិនត្រូវបានដាក់ទេ ប្រសិនបើទីក្រុងខកខានក្នុងការរក្សាការផ្តល់មូលនិធិ LAFD នៅកម្រិតថវិកាជាប្រវត្តិសាស្ត្រ ។ បទប្បញ្ញត្តិនេះនឹងតម្រូវឱ្យមានសវនកម្មប្រចាំឆ្នាំ និងបង្កើតគណៈកម្មាធិការឃ្លាំមើលរបស់ប្រជាពលរដ្ឋដើម្បីតាមដាន និងរាយការណ៍អំពីការចំណាយនៃប្រាក់ចំណូលពន្ធ ។ បទប្បញ្ញត្តិនេះនឹងតម្រូវឱ្យគម្រោងសាងសង់ស្ថានីយ៍ពន្លត់អគ្គិភ័យ និងគម្រោងជំនួសដែលទទួលបានថវិកាពីពន្ធនេះ ស្ថិតក្រោមកិច្ចព្រមព្រៀងការងារគម្រោង និងអនុលោមតាមតម្រូវការប្រាក់ឈ្នួលដែលមានស្រាប់ ។

អត្ថបទនៃបទបញ្ញត្តិគំនិតផ្តួចផ្តើមដែលបានស្នើឡើង

បទបញ្ញត្តិលេខ_____

បទបញ្ញត្តិដែលស្នើឡើងដោយបទបញ្ញត្តិគំនិតផ្តួចផ្តើមដើម្បីបន្ថែមមាត្រា 1.20 ទៅជំពូកទី II នៃក្រមសាលាក្រុង Los Angeles ដោយបង្កើត "បទបញ្ញត្តិអំពីការត្រៀមខ្លួន និងការឆ្លើយតបអគ្គិភ័យ និងការសង្គ្រោះបន្ទាន់នៅ Los Angeles" ។

ប្រជាជននៃទីក្រុង LOS ANGELES
សូមបញ្ជាក់ដូចតទៅ៖

មាត្រា 1. ឈ្មោះ

វិធានការនេះនឹងត្រូវបានគេស្គាល់ថាជា "បទបញ្ញត្តិអំពីការត្រៀមខ្លួន និងការឆ្លើយតបអគ្គីភ័យ និងការសង្គ្រោះបន្ទាន់នៅទីក្រុង Los Angeles" ។

មាត្រា 2. មាត្រា 1.20 ត្រូវបានបន្ថែមទៅក្នុងជំពូកទី II នៃក្រមសាលាក្រុង Los Angeles ដូចខាងក្រោម ៖

<u>មាត្រា 21.20.1 - ចំណងជើង ។</u>

<u>អត្ថបទនេះនឹងត្រូវបានស្គាល់ថាជា "បទបញ្ញត្តិអំពីការត្រៀមខ្លួន និងការឆ្លើយតបអគ្គិភ័យ និងការសង្គ្រោះបន្ទាន់នៅទីក្រុង Los Angeles" ("បទបញ្ញត្តិ") ។ ទីក្រុង Los Angeles ដែលតទៅនេះហៅថា "ទីក្រុង" ។ សម្រាប់គោលបំណងនៃអត្ថបទនេះ នាយកដ្ឋានពន្លត់អគ្គិភ័យទីក្រុង Los Angeles នឹងត្រូវបានហៅថា "LAFD" ។ បទបញ្ញត្តិនេះត្រូវអនុវត្តនៅក្នុងទឹកដីដែលបានបញ្ចូលរបស់ទីក្រុង ។</u>

<u>មាត្រា 21.20.2 - គោលបំណង ។</u>

<u>បទបញ្ញត្តិនេះត្រូវបានអនុម័តដើម្បីសម្រេចបាននូវចំណុចដូចខាងក្រោម ក្នុងចំណោមគោលបំណងផ្សេងទៀត ហើយណែនាំថាបទប្បញ្ញត្តិនៃច្បាប់នេះត្រូវបកស្រាយដើម្បីសម្រេចគោលបំណងទាំងនោះ ៖</u>

A. ដើម្បីបង្កើតប្រភពថវិកាបន្ថែមសម្រាប់ LAFD សម្រាប់គោលបំណង និងការប្រើប្រាស់ដែលមានចែងក្នុងបទបញ្ញត្តិនេះ ។

B. ដើម្បីកំណត់ពន្ធលើប្រតិបត្តិការលក់រាយ និងការប្រើប្រាស់ស្របតាមបទឃ្លាញត្តិនៃផ្នែក 1.6 (ចាប់ផ្តើមជាមួយមាត្រា 7251) នៃផ្នែកទី 2 នៃក្រមចំណូល និងពន្ធដារ និងមាត្រា 7285.91 នៃផ្នែកទី 1.7 នៃផ្នែកទី 2 នៃក្រមចំណូល និងពន្ធដារ ដែលអនុញ្ញាតឱ្យទីក្រុង Los Angeles ("ទីក្រុង") អនុម័តបទបញ្ញត្តិពន្ធនេះ លុះត្រាតែភាគច្រើននៃអ្នកបោះឆ្នោតដែលបោះឆ្នោតលើវិធានការនេះបោះឆ្នោតអនុម័តការកំណត់ពន្ធនេះនៅឯការបោះឆ្នោតដែលបានរៀបចំឡើងសម្រាប់គោលបំណងនោះ ។

C. បទបញ្ញត្តិនេះត្រូវបានអនុម័តបន្ថែមទៀតក្រោមសិទ្ធិទីក្រុងដែលគ្រប់គ្រងដោយខ្លួនឯងជាទីក្រុងស្វ័យត (Cal. អត្ថបទកុងរដ្ឋធម្មនុញ្ញ XI, § 5) ដែលអនុញ្ញាតឱ្យបង់ពន្ធក្រុងសម្រាប់គោលបំណងមូលដ្ឋានស្របតាមច្បាប់ជាធរមាន ។

D. ដើម្បីអនុម័តបទបញ្ញត្តិពន្ធលើប្រតិបត្តិការលក់រាយ និងការប្រើប្រាស់ដែលរួមបញ្ចូលបទឃ្លាញត្តិដូចគ្នាទៅនឹងច្បាប់ពន្ធលើការលក់ និងការប្រើប្រាស់នៃរដ្ឋ California ដរាបណាបទឃ្លាញត្តិទាំងនោះមិនផ្ទុយទៅនឹងតម្រូវការ និងការរឹតត្បិតដែលមាននៅក្នុងផ្នែក 1.6 នៃជំពូកទី 2 នៃក្រមចំណូល និងពន្ធដារ ។

E. ដើម្បីអនុម័តបទបញ្ញត្តិពន្ធលើប្រតិបត្តិការលក់រាយ និងការប្រើប្រាស់ដែលដាក់ពន្ធ និងផ្តល់វិធានការសម្រាប់ពន្ធនោះដែលអាចត្រូវបានគ្រប់គ្រង និងប្រមូលដោយនាយកដ្ឋានរដ្ឋបាលពន្ធ និងកម្រៃនៃរដ្ឋ California ក្នុងរបៀបមួយដែលសម្របខ្លួនយ៉ាងពេញលេញតាមដែលអាចធ្វើទៅបានទៅនឹង និងទាមទារគម្លាតតិចតួចបំផុតពី នីតិវិធីច្បាប់ និងរដ្ឋបាលដែលមានស្រាប់ដែលអនុវត្តដោយនាយកដ្ឋានរដ្ឋបាលពន្ធ និងកម្រៃនៃរដ្ឋ California ក្នុងការគ្រប់គ្រង និងប្រមូលពន្ធលើការលក់ និងការប្រើប្រាស់របស់រដ្ឋ California ។

F. ដើម្បីអនុម័តបទបញ្ញត្តិពន្ធលើប្រតិបត្តិការលក់រាយ និងការប្រើប្រាស់ដែលអាចត្រូវបានគ្រប់គ្រងក្នុងលក្ខណៈដែលនឹង មានភាពស្របគ្នាក្នុងកម្រិតអតិបរមាតាមដែលអាចធ្វើទៅបាន ជាមួយនឹងបទឃ្លាញត្តិនៃផ្នែកទី 1.6 នៃតំបន់ 2 នៃក្រមស្តីពីចំណូល និងពន្ធដារ កាត់បន្ថយចំណាយនៃការប្រមូលពន្ធលើប្រតិបត្តិការលក់រាយ និងការប្រើប្រាស់ និងក្នុងពេលតែមួយ កាត់បន្ថយបន្ទុកនៃការរក្សាកំណត់ត្រាលើបុគ្គលដែលជាប់ពន្ធក្រោមបទឃ្លាញត្តិនៃបទបញ្ញត្តិនេះ ។

G. ដើម្បីធានាថាប្រាក់ចំណូលដែលបង្កើតដោយបទបញ្ញត្តិនេះនឹងត្រូវបានប្រើប្រាស់ទាំងស្រុងសម្រាប់គោលបំណង និងការប្រើប្រាស់ដែលត្រូវបានអនុម័តដោយអ្នកបោះឆ្នោត ស្របតាមធម្មនុញ្ញទីក្រុង រដ្ឋធម្មនុញ្ញរដ្ឋ California និងច្បាប់ជាធរមាន ហើយថាប្រាក់ចំណូលបែបនេះនឹងត្រូវស្ថិតនៅក្រោមសវនកម្ម និងការត្រួតពិនិត្យឯករាជ្យប្រចាំឆ្នាំ ។

មាត្រា 21.20.3 - កិច្ចសន្យាជាមួយរដ្ឋ ។

មុនកាលបរិច្ឆេទប្រតិបត្តិ ខោនធីត្រូវចុះកិច្ចសន្យាជាមួយនាយកដ្ឋានគ្រប់គ្រងពន្ធ និងថ្លៃសេវារដ្ឋ California ដើម្បីអនុវត្តមុខងារទាំងអស់ដែលពាក់ព័ន្ធនឹងរដ្ឋបាល និងប្រតិបត្តិការនៃបទបញ្ញត្តិពន្ធលើប្រតិបត្តិការ និងការប្រើប្រាស់នេះ ។ ប៉ុន្តែ ប្រសិនបើខោនធីមិនទាន់បានចុះកិច្ចសន្យាជាមួយនាយកដ្ឋានគ្រប់គ្រងពន្ធ និងថ្លៃសេវារដ្ឋ California មុនកាលបរិច្ឆេទប្រតិបត្តិទេ ទោះជាយ៉ាងណាក៏ដោយ ខោនធីត្រូវតែចុះកិច្ចសន្យា ហើយក្នុងករណីបែបនេះ កាលបរិច្ឆេទប្រតិបត្តិគឺជាថ្ងៃទីមួយនៃត្រីមាសតាមប្រតិទិនទីមួយ បន្ទាប់ពីការចុះហត្ថលេខាលើកិច្ចសន្យាបែបនេះ ។

មាត្រា 21.20.4 - អត្រាពន្ធលើប្រតិបត្តិការ ។

សម្រាប់ឯកសិទ្ធិនៃការលក់រាយនូវចលនទ្រព្យរូបវន្ត តាមរយៈនេះ បទបញ្ញត្តិហូតពន្ធលើអាជីវករលក់រាយទាំងអស់នៅក្នុងដែនដីដែលបានបង្កើតជាក្រុងនៃខោនធីក្នុងអត្រា 0.50 ភាគរយ (0.50%) នៃប្រាក់ចំណូលសរុបរបស់អាជីវករលក់រាយណាម្នាក់ ពីការលក់នូវរាល់ចលនទ្រព្យរូបវន្តដែលបានលក់រាយនៅក្នុងដែនដីខាងលើ នៅ និងក្រោយកាលបរិច្ឆេទប្រតិបត្តិនៃបទបញ្ញត្តិនេះ ។

មាត្រា 21.20.5 - ទីកន្លែងលក់ ។

សម្រាប់គោលបំណងនៃបទបញ្ញត្តិនេះ អាជីវករសម្រេចរាល់ការលក់រាយទាំងអស់នៅទីកន្លែងអាជីវកម្មរបស់អាជីវករលក់រាយ លើកលែងតែអាជីវករលក់រាយ ឬភ្នាក់ងាររបស់ខ្លួនដឹកជញ្ជូនចលនទ្រព្យរូបវន្តដែលបានលក់នោះ ទៅកាន់គោលដៅក្រៅរដ្ឋ ឬប្រគល់ឱ្យក្រុមហ៊ុនដឹកជញ្ជូនទូទៅដើម្បីដឹកជញ្ជូនទៅកាន់គោលដៅក្រៅរដ្ឋ ។ ប្រាក់ចំណូលអាជីវកម្មពីការលក់ទាំងនេះ រួមបញ្ចូលទាំងថ្លៃសេវាចែកចាយ នៅពេលដែលថ្លៃសេវាទាំងនោះស្ថិតក្រោមពន្ធលើការលក់ និងពន្ធប្រើប្រាស់របស់រដ្ឋ ដោយមិនគិតពីទីកន្លែងដែលការចែកចាយត្រូវបានធ្វើឡើងឡើយ ។ ក្នុងករណីដែលអ្នកលក់រាយមិនមានទីកន្លែងអាជីវកម្មអចិន្ត្រៃយ៍ នៅក្នុងរដ្ឋ ឬមានច្រើនជាងមួយទីកន្លែងអាជីវកម្ម ទីកន្លែងនោះ ឬទីកន្លែងទាំងនោះដែលការលក់រាយត្រូវបានបញ្ចប់នឹងត្រូវកំណត់ក្រោមវិធាន និងបទប្បញ្ញត្តិដែលត្រូវកំណត់ និងអនុម័តដោយនាយកដ្ឋានគ្រប់គ្រងពន្ធ និងថ្លៃសេវារដ្ឋ California ។

មាត្រា 21.20.6 - ប្រើប្រាស់អត្រាពន្ធ ។

តាមរយៈនេះ បទបញ្ញត្តិហូតពន្ធអាករលើការរក្សាទុក ការប្រើប្រាស់ ឬការប្រើប្រាស់ផ្សេងៗទៀតនៅក្នុងខោនធី នូវចលនទ្រព្យរូបវន្តដែលបានទិញពីអាជីវករលក់រាយណាម្នាក់ នៅ និងក្រោយកាលបរិច្ឆេទប្រតិបត្តិនៃបទបញ្ញត្តិនេះ សម្រាប់ការរក្សាទុក ការប្រើប្រាស់ ឬការប្រើប្រាស់ផ្សេងៗទៀតនៅក្នុងដែនដីខាងលើក្នុងអត្រា 0.50 ភាគរយ (0.50%) នៃតម្លៃលក់នៃទ្រព្យសម្បត្តិនោះ ។ តម្លៃលក់ត្រូវរួមបញ្ចូលទាំងថ្លៃសេវាដឹកជញ្ជូន នៅពេលដែលថ្លៃសេវាទាំងនោះស្ថិតក្រោមពន្ធលើការលក់ ឬពន្ធប្រើប្រាស់របស់រដ្ឋ ទោះបីជាការដឹកជញ្ជូននោះត្រូវធ្វើឡើងទៅកាន់ទីកន្លែងណាក៏ដោយ ។

មាត្រា 21.20.7 - ការអនុម័តបទប្បញ្ញត្តិនៃច្បាប់រដ្ឋ ។

លើកលែងតែមានចែងផ្សេងពីនេះនៅក្នុងក្រឹត្យច្បាប់នេះ និងលើកលែងតែក្នុងកម្រិតដែលវាផ្ទុយនឹងបទប្បញ្ញត្តិនៃផ្នែកទី 1.6 នៃជំពូកទី 2 នៃក្រមស្តីពីស្តីពីចំណូល និងពន្ធដារ នោះបទប្បញ្ញត្តិទាំងអស់នៃផ្នែកទី 1 (ចាប់ផ្តើមពីមាត្រា 6001) នៃជំពូកទី 2 នៃក្រមស្តីពីចំណូល និងពន្ធដារ ត្រូវបានអនុម័តយកមកប្រើប្រាស់ និងបង្កើតជាផ្នែកមួយនៃក្រឹត្យច្បាប់នេះ ហាក់ដូចដែលមានចែងយ៉ាងពេញលេញក្នុងឯកសារនេះ ។

មាត្រា 21.20.8 - ដែនកំណត់លើការអនុម័តការប្រើប្រាស់ច្បាប់រដ្ឋ និងការប្រមូលពន្ធលើការប្រើប្រាស់ ។

ក្នុងការអនុម័តបទប្បញ្ញត្តិនៃផ្នែកទី 1 នៃជំពូកទី 2 នៃក្រមស្តីពីចំណូល និងពន្ធដារ ៖

A. នៅកន្លែងណាដែលរដ្ឋ California ត្រូវបានបញ្ជាក់ឈ្មោះ ឬសំដៅលើថាជាភ្នាក់ងារពន្ធដារ នោះឈ្មោះរបស់ក្រុងនេះត្រូវយកមកជំនួសនៅកន្លែងនោះ ។ ទោះជាយ៉ាងណាក៏ដោយ ការជំនួសនេះមិនត្រូវធ្វើឡើងទេនៅពេលដែល ៖

1. ពាក្យ "រដ្ឋ" ត្រូវបានប្រើជាផ្នែកមួយនៃគោរម្យងាររបស់អគ្គនាយកគណនេយ្យរដ្ឋ ហេរញ្ញិករដ្ឋ រតនាគាររដ្ឋ ឬរដ្ឋធម្មនុញ្ញនៃរដ្ឋ California ។

2. លទ្ធផលនៃការជំនួសនោះនឹងតម្រូវឱ្យមានចំណាត់ការដែលធ្វើឡើងដោយ ឬប្រឆាំងនឹងក្រុងនេះ ឬទីភ្នាក់ងារ មន្ត្រី ឬនិយោជិតណាម្នាក់របស់ក្រុងនេះ ជំនួសឱ្យការធ្វើឡើងដោយ ឬប្រឆាំងនឹងក្រសួងគ្រប់គ្រងពន្ធដារ និងកម្រៃសេវានៃរដ្ឋ California ក្នុងការអនុវត្តមុខងារពាក់ព័ន្ធនឹងរដ្ឋបាល ឬប្រតិបត្តិការនៃក្រឹត្យច្បាប់នេះ ។

3. នៅក្នុងផ្នែកទាំងនោះ ដែលរួមបញ្ចូលជាអាទិ៍ទាំងផ្នែកដែលសំដៅលើព្រំប្រទល់ខាងក្រៅនៃរដ្ឋ California ដែលផលនៃការជំនួសនោះនឹង ៖

a. ផ្តល់ការលើកលែងពីពន្ធនេះទាក់ទងនឹងការលក់ ការស្តុកទុក ការប្រើប្រាស់ ឬការប្រើផ្សេងទៀតនៃទ្រព្យសម្បត្តិរូបីផ្ទាល់ខ្លួនមួយចំនួន ដែលបើពុំនោះទេនឹងមិនត្រូវទទួលបានការលើកលែងពីពន្ធនេះឡើយ នៅក្នុងអំឡុងពេលដែលការលក់ ការរក្សាទុក ការប្រើប្រាស់ ឬការប្រើផ្សេងទៀតនោះ នៅតែបន្តជាប់ពន្ធដោយរដ្ឋ ក្រោមបទប្បញ្ញត្តិផ្នែកទី 1 នៃជំពូកទី 2 នៃក្រមស្តីពីចំណូល និងពន្ធដារ ឬ

b. ដាក់បន្ទុកពន្ធនេះចំពោះការលក់ ការស្តុកទុក ការប្រើប្រាស់ ឬការប្រើផ្សេងៗទៀតមួយចំនួននៃទ្រព្យសម្បត្តិរូបីផ្ទាល់ខ្លួនជាក់លាក់ ដែលរដ្ឋនឹងមិនដាក់បន្ទុកពន្ធឡើយ ក្រោមបទប្បញ្ញត្តិដែលបានចែងខាងលើនៃក្រមនោះ ។

4. ដោយសំដៅលើមាត្រា 6701, 6702 (លើកលែងតែនៅក្នុងប្រយោគចុងក្រោយនៃផ្នែកនេះ), 6711, 6715, 6737, 6797 ឬ 6828 នៃក្រមស្តីពីចំណូល និងពន្ធដារ ។

B. ពាក្យ "ទីក្រុង" ត្រូវបានជំនួសដោយពាក្យ "រដ្ឋ" នៅក្នុងឃ្លា "អាជីវករលក់រាយដែលប្រកបអាជីវកម្មនៅក្នុងរដ្ឋនេះ" នៅក្នុងមាត្រា 6203 នៃក្រមស្តីពីចំណូល និងពន្ធដារ និងនៅក្នុងនិយមន័យនៃឃ្លានោះនៅក្នុងមាត្រា 6203 ។

1. "អាជីវករលក់រាយដែលប្រកបអាជីវកម្មនៅក្នុងស្រុក" ត្រូវរួមបញ្ចូលផងដែរនូវអាជីវករលក់រាយណាដែលនៅក្នុងឆ្នាំប្រតិទិនមុន ឬឆ្នាំប្រតិទិនបច្ចុប្បន្ន មានការលក់សរុបបូកបញ្ចូលគ្នានៃទ្រព្យសម្បត្តិរូបីផ្ទាល់ខ្លួននៅក្នុងរដ្ឋនេះ ឬសម្រាប់ការដឹកជញ្ជូននៅក្នុងរដ្ឋ ដោយអាជីវករលក់រាយនោះ និងបុគ្គលទាំងឡាយដែលពាក់ព័ន្ធនឹងអាជីវករលក់រាយនោះ ដែលមានទំហំលើសពី $500,000.00 ។ សម្រាប់គោលបំណងនៃផ្នែកនេះ បុគ្គលម្នាក់មានការពាក់ព័ន្ធនឹងបុគ្គលម្នាក់ទៀត ប្រសិនបើបុគ្គលទាំងពីរមានការពាក់ព័ន្ធនឹងគ្នាទៅវិញទៅមក ដោយអនុលោមតាមមាត្រា 267(b) នៃជំពូក 26 នៃក្រមសហរដ្ឋអាមេរិក និងបទប្បញ្ញត្តិទាំងឡាយដែលស្ថិតក្រោមមាត្រានោះ ។

មាត្រា 21.20.9 - លិខិតអនុញ្ញាតដែលមិនតម្រូវ ។

ប្រសិនបើលិខិតអនុញ្ញាតសម្រាប់អ្នកលក់ត្រូវបានចេញឱ្យអាជីវករលក់រាយក្រោមមាត្រា 6067 នៃក្រមស្តីពីចំណូល និងពន្ធដារ លិខិតអនុញ្ញាតប្រតិបត្តិការបន្ថែមនឹងមិនត្រូវបានតម្រូវដោយក្រឹត្យច្បាប់នេះទេ ។

មាត្រា 21.20.10 - ការលើកលែង និងការដកចេញ ។

A. ត្រូវដកចេញពីវិធានការលើពន្ធប្រតិបត្តិការ និងពន្ធប្រើប្រាស់ នូវចំនួនទឹកប្រាក់នៃពន្ធលើការលក់ ឬពន្ធប្រើប្រាស់ណាមួយដែលដាក់បន្ទុកដោយរដ្ឋ California ឬដោយទីក្រុង ក្រុងនិងខោនធី ឬខោនធីណាមួយ ដោយយោងទៅតាមច្បាប់ឯកភាពស្តីពីពន្ធលើការលក់ និងការប្រើប្រាស់ថ្នាក់មូលដ្ឋាន Bradley-Burns ឬចំនួនទឹកប្រាក់នៃពន្ធលើប្រតិបត្តិការ ឬពន្ធលើការប្រើប្រាស់ទាំងឡាយណាដែលគ្រប់គ្រងដោយរដ្ឋ ។

B. មានការលើកលែងពីការគណនាចំនួនទឹកប្រាក់នៃពន្ធលើប្រតិបត្តិការ នូវចំណូលដុលដែលទទួលបានពី ៖

1. ការលក់ចលនទ្រព្យរូបវន្ត ក្រៅពីឥន្ធនៈ ឬផលិតផលប្រេងឆៅ ជូនដល់ប្រតិបត្តិករយន្តហោះ ដើម្បីប្រើប្រាស់ ឬប្រើជាចម្បងនៅក្រៅខោនធីដែលការលក់នោះត្រូវបានធ្វើឡើង និងដោយផ្ទាល់ ហើយផ្តាច់មុខក្នុងការប្រើប្រាស់យន្តហោះនោះ ជាអ្នកដឹកជញ្ជូនសាធារណៈនៃមនុស្ស ឬទ្រព្យសម្បត្តិ ក្រោមអាជ្ញាធរនៃច្បាប់នៃរដ្ឋនេះ សហរដ្ឋអាមេរិក ឬរដ្ឋាភិបាលបរទេសណាមួយ ។

2. ការលក់ទ្រព្យសម្បត្តិសម្រាប់ប្រើប្រាស់នៅក្រៅក្រុង ដែលត្រូវដឹកជញ្ជូនទៅកាន់ទីតាំងណាមួយនៅក្រៅក្រុង ដោយអនុលោមតាមកិច្ចសន្យាលក់ ដោយការប្រគល់ជូនទៅកាន់ទីតាំងនោះដោយអាជីវករលក់រាយ ឬតំណាងរបស់គាត់ ឬដោយការប្រគល់ជូនដោយអាជីវករលក់រាយទៅឱ្យអ្នកដឹកជញ្ជូន ដើម្បីដឹកជញ្ជូនទៅឱ្យអ្នកទទួលទំនិញនៅទីតាំងនោះ ។ សម្រាប់គោលបំណងនៃកថាខណ្ឌនេះ ការប្រគល់ជូនទៅកាន់ទីតាំងណាមួយនៅក្រៅក្រុង ត្រូវចាត់ទុកថាបានបំពេញតាមលក្ខខណ្ឌ លុះត្រាតែ ៖

a. ចំពោះយានយន្ត (ក្រៅពីយានយន្តពាណិជ្ជកម្ម) ដែលត្រូវចុះបញ្ជីអនុលោមតាមជំពូកទី 1 (ចាប់ផ្តើមពីមាត្រា 4000) នៃជំពូកទី 3 នៃក្រមស្តីពីយានយន្ត យន្តហោះដែលទទួលបានអាជ្ញាបណ្ណដែលអនុលោមតាមមាត្រា 21411 នៃក្រមស្តីពីសេវាសាធារណៈ និងនាវាដែលមិនមានឯកសារផ្លូវការ ដែលបានចុះបញ្ជីក្រោមជំពូកទី 3.5 (ចាប់ផ្តើមពីមាត្រា 9840) នៃក្រមស្តីពីយានយន្ត តាមរយៈការចុះបញ្ជីទៅកាន់អាសយដ្ឋានក្រៅក្រុង និងតាមរយៈសេចក្តីប្រកាសក្រោមទោសទណ្ឌនៃការស្បថសច្ចាដែល

អ្នកទិញចុះហត្ថលេខា ដោយថ្លែងថា អាសយដ្ឋាននោះពិតជាកន្លែងស្នាក់នៅចម្បងរបស់គាត់ប្រាកដមែន និង

b. ចំពោះយានយន្តពាណិជ្ជកម្ម តាមរយៈការចុះបញ្ជីទៅកាន់ទីកន្លែងអាជីវកម្មនៅក្រៅក្រុង និងសេចក្តីប្រកាសនៅក្រោមទោសទណ្ឌនៃការស្បថសច្ចា ដែលអ្នកទិញចុះហត្ថលេខា ដោយថ្លែងថា យានយន្តនោះនឹងត្រូវយកទៅប្រតិបត្តិការចេញពីអាសយដ្ឋាននោះ ។

3. ការលក់ទ្រព្យសម្បត្តិរូបីផ្ទាល់ខ្លួន ប្រសិនបើអ្នកលក់មានកាតព្វកិច្ចផ្តត់ផ្គង់ទ្រព្យសម្បត្តិនោះក្នុងតម្លៃថេរ ដោយអនុវត្តតាមកិច្ចសន្យាដែលបានចុះហត្ថលេខាមុនកាលបរិច្ឆេទចូលជាធរមាននៃក្រឹត្យច្បាប់នេះ ។

4. ការជួលទ្រព្យសម្បត្តិរូបីផ្ទាល់ខ្លួន ដែលជាការលក់ជាបន្តបន្ទាប់នៃទ្រព្យសម្បត្តិនោះ សម្រាប់ចិរវេលាណាមួយ ដែលម្ចាស់ជួលមានកាតព្វកិច្ចជួលទ្រព្យសម្បត្តិនោះ ក្នុងចំនួនទឹកប្រាក់ដែលបានកំណត់ដោយកិច្ចសន្យាជួល មុនកាលបរិច្ឆេទចូលជាធរមាននៃក្រឹត្យច្បាប់នេះ ។

5. សម្រាប់គោលបំណងនៃកថាខណ្ឌ (3) និង (4) នៃផ្នែកកងនេះ ការលក់ ឬការជួលទ្រព្យសម្បត្តិផ្ទាល់ខ្លួនរូបីត្រូវចាត់ទុកថាមិនជាប់កាតព្វកិច្ចស្របតាមកិច្ចសន្យា ឬការជួលសម្រាប់រយៈពេលណាមួយដែលភាគីណាមួយនៃកិច្ចសន្យា ឬការជួលមានសិទ្ធិដោយឥតលក្ខខណ្ឌក្នុងការបញ្ចប់កិច្ចសន្យា ឬការជួលតាមការជូនដំណឹង ទោះបីជាសិទ្ធិនោះត្រូវបានប្រើប្រាស់ ឬមិនប្រើប្រាស់ក៏ដោយ ។

C. ត្រូវបានលើកលែងពីពន្ធលើការប្រើប្រាស់ដែលត្រូវបានដាក់បន្ទុកដោយក្រឹត្យច្បាប់នេះ នូវការស្តុកទុក ការប្រើប្រាស់ ឬការប្រើផ្សេងទៀតនៅក្នុងក្រុងនេះ នៃទ្រព្យសម្បត្តិរូបីផ្ទាល់ខ្លួន ៖

1. ចំណូលដុលដែលទទួលបានពីការលក់ទ្រព្យសម្បត្តិនោះ ត្រូវជាប់ពន្ធលើប្រតិបត្តិការ ក្រោមក្រឹត្យច្បាប់ស្តីពីពន្ធលើប្រតិបត្តិការ និងពន្ធលើការប្រើប្រាស់ណាមួយដែលគ្រប់គ្រងដោយរដ្ឋ ។

2. ក្រៅពីផលិតផលឥន្ធនៈ ឬប្រេងឆៅដែលបានទិញដោយប្រតិបត្តិករយន្តហោះ ហើយត្រូវបានប្រើប្រាស់ ឬប្រើដោយប្រតិបត្តិករទាំងនោះដោយផ្ទាល់ និងផ្តោតមុខក្នុងការប្រើប្រាស់យន្តហោះបែបនេះក្នុងនាមជាអ្នកដឹកជញ្ជូនទូទៅសម្រាប់មនុស្ស ឬទ្រព្យសម្បត្តិ ដើម្បីទទួលបានកម្រៃ ឬសំណងនៅក្រោមវិញ្ញាបនបត្រនៃភាពងាយស្រួល និងភាពចាំបាច់ជាសាធារណៈដែលបានចេញស្របតាមច្បាប់នៃរដ្ឋនេះ សហរដ្ឋអាមេរិក ឬរដ្ឋាភិបាលបរទេសណាមួយ ។ ការលើកលែងនេះគឺបន្ថែមទៅលើការលើកលែងដែលបានចែងក្នុងមាត្រា 6366 និង 6366.1 នៃក្រមស្តីពីចំណូល និងពន្ធដារនៃរដ្ឋ California ។

3. ប្រសិនបើអ្នកទិញមានកាតព្វកិច្ចទិញទ្រព្យសម្បត្តិក្នុងតម្លៃថេរស្របតាមកិច្ចសន្យាដែលបានចុះហត្ថលេខាមុនកាលបរិច្ឆេទចូលជាធរមាននៃក្រឹត្យច្បាប់នេះ ។

4. ប្រសិនបើការកាន់កាប់ ឬការប្រើប្រាស់សិទ្ធិ ឬអំណាចណាមួយលើទ្រព្យសម្បត្តិរូបីផ្ទាល់ខ្លួន កើតឡើងនៅក្រោមការជួលដែលជាការទិញបន្តបន្ទាប់នៃទ្រព្យសម្បត្តិនេះ សម្រាប់រយៈពេលណាមួយដែលអ្នកជួលមានកាតព្វកិច្ចជួលទ្រព្យសម្បត្តិក្នុងចំនួនទឹកប្រាក់ដែលបានកំណត់ដោយការជួលមុនកាលបរិច្ឆេទចូលជាធរមាននៃក្រឹត្យច្បាប់នេះ ។

5. សម្រាប់គោលបំណងនៃកថាខណ្ឌទី (3) និង (4) នៃផ្នែកកងនេះ ការស្តុកទុក ការប្រើប្រាស់ ឬការប្រើផ្សេងទៀត ឬការកាន់កាប់ ឬការប្រើប្រាស់សិទ្ធិ ឬអំណាចណាមួយលើទ្រព្យសម្បត្តិផ្ទាល់ខ្លួនរូបីត្រូវចាត់ទុកថាមិនមានកាតព្វកិច្ចស្របតាមកិច្ចសន្យា ឬការជួល សម្រាប់រយៈពេលណាមួយដែលភាគីណាមួយនៃកិច្ចសន្យា ឬកិច្ចសន្យាជួលមានសិទ្ធិដោយគ្មានលក្ខខណ្ឌក្នុងការបញ្ចប់កិច្ចសន្យា ឬកិច្ចសន្យាជួលតាមការជូនដំណឹង ទោះបីជាសិទ្ធិនោះត្រូវបានប្រើប្រាស់ ឬមិនបានប្រើប្រាស់ក៏ដោយ ។

6. លើកលែងតែមានចែងក្នុងកថាខណ្ឌទី (7) អាជីវករលក់រាយដែលធ្វើអាជីវកម្មនៅក្នុងក្រុងមិនត្រូវបានតម្រូវឱ្យប្រមូលពន្ធលើការប្រើប្រាស់ពីអ្នកទិញទ្រព្យសម្បត្តិរូបីផ្ទាល់ខ្លួនឡើយ លុះត្រាតែអាជីវករលក់រាយដឹកជញ្ជូន ឬប្រគល់ទ្រព្យសម្បត្តិនោះចូលមកក្នុងក្រុង ឬចូលរួមនៅក្នុងក្រុងក្នុងការធ្វើការលក់ទ្រព្យសម្បត្តិ ដែលរួមមានជាអាទ៍ ការអួសទាញ ឬការទទួលការបញ្ជាទិញ មិនថាដោយផ្ទាល់ ឬដោយប្រយោល នៅទីកន្លែងអាជីវកម្មរបស់អាជីវករលក់រាយនៅក្នុងក្រុង ឬតាមរយៈអ្នកតំណាង ភ្នាក់ងារ ឬអ្នកស្វែងរកការបញ្ជាទិញ អ្នកអួសទាញការលក់ ក្រុមហ៊ុនឬត្រសម្ព័ន្ធ ឬបុគ្គលណាមួយនៅក្នុងក្រុងក្រោមអំណាចរបស់អាជីវករលក់រាយនោះ ។

7. "អាជីវករលក់រាយដែលធ្វើអាជីវកម្មនៅក្នុងក្រុង" ក៏ត្រូវរួមបញ្ចូលផងដែរនូវអ្នកលក់រាយនូវទ្រព្យណាមួយដូចខាងក្រោម ៖ យានយន្តដែលត្រូវចុះបញ្ជីស្របតាមជំពូកទី 1 (ចាប់ផ្តើមពីមាត្រា 4000) នៃជំពូកទី 3 នៃក្រមស្តីពីយានយន្ត យន្តហោះដែលបានចុះអាជ្ញាបណ្ណស្របតាមមាត្រា 21411 នៃក្រមស្តីពីសេវាសាធារណៈ ឬនាវាដែលមិនមានឯកសារផ្លូវការ ដែលបានចុះបញ្ជីនៅក្រោមជំពូកទី 3.5 (ចាប់ផ្តើមពីមាត្រា 9840) នៃក្រមស្តីពីយានយន្ត ។ អាជីវករលក់រាយនោះត្រូវតែតម្រូវឱ្យប្រមូលពន្ធលើការប្រើប្រាស់ពីអ្នកទិញណាមួយដែលចុះបញ្ជី ឬចុះអាជ្ញាបណ្ណយានយន្ត នាវា ឬយន្តហោះនៅអាសយដ្ឋានមួយនៅក្នុងក្រុង ។

D. បុគ្គលណាមួយដែលត្រូវជាប់ពន្ធលើការប្រើប្រាស់នៅក្រោមក្រឹត្យច្បាប់នេះ អាចកាត់កងជាមួយនឹងពន្ធនោះនូវពន្ធលើប្រតិបត្តិការណាមួយ ឬការបង្ហិលសងសម្រាប់ពន្ធលើប្រតិបត្តិការដែលបានបង់ទៅឱ្យក្រុងដែលបានដាក់កំហិតពន្ធ ឬបង់ទៅអាជីវករលក់រាយដែលមានកាតព្វកិច្ចបង់ពន្ធលើប្រតិបត្តិការស្របតាមផ្នែកទី 1.6 នៃជំពូកទី 2 នៃក្រមស្តីពីចំណូល និងពន្ធដារ ពាក់ព័ន្ធនឹងការលក់ទ្រព្យសម្បត្តិទៅឱ្យបុគ្គលនោះ ដែលការស្នុកទុក ការប្រើប្រាស់ ឬការប្រើផ្សេងទៀតនៃទ្រព្យសម្បត្តិនោះត្រូវជាប់ពន្ធលើការប្រើប្រាស់ ។

មាត្រា 21.20.11 - វិសោធនកម្ម ។

រាល់វិសោធនកម្មជាបន្តបន្ទាប់ បន្ទាប់ពីកាលបរិច្ឆេទចូលជាធរមាននៃក្រឹត្យច្បាប់នេះ ចំពោះផ្នែក 1 នៃជំពូកទី 2 នៃក្រមស្តីពីចំណូល និងពន្ធដារ ដែលពាក់ព័ន្ធនឹងពន្ធលើការលក់ និងការប្រើប្រាស់ ហើយដែលមិនផ្ទុយនឹងផ្នែក 1.6 និងផ្នែក 1.7 នៃជំពូកទី 2 នៃក្រមស្តីពីចំណូល និងពន្ធដារ និងរាល់វិសោធនកម្មចំពោះផ្នែក 1.6 និងផ្នែក 1.7 នៃជំពូកទី 2 នៃក្រមស្តីពីចំណូល និងពន្ធដារ ត្រូវក្លាយជាផ្នែកមួយនៃក្រឹត្យច្បាប់នេះដោយស្វ័យប្រវត្តិ ដោយមានលក្ខខណ្ឌថា រាល់វិសោធនកម្មទាំងនោះ មិនត្រូវមានប្រសិទ្ធភាពជះឥទ្ធិពលដល់អត្រាពន្ធដែលត្រូវអនុវត្តដោយក្រឹត្យច្បាប់នេះឡើយ ។

មាត្រា 21.20.12 - ការហាមឃាត់មិនឱ្យបង្អាក់ការប្រមូលពន្ធ ។

គ្មានដីកាហាមឃាត់ ឬដីកាបង្គាប់ ឬចំណាត់ការផ្លូវច្បាប់ ឬតាមគោលការន៍សមធម៌ផ្សេងទៀត ត្រូវចេញនៅក្នុងបណ្តឹង រឿងក្តី ឬនីតិវិធីណាមួយនៅក្នុងតុលាការណាមួយប្រឆាំងនឹងរដ្ឋ ឬក្រុង ឬប្រឆាំងនឹងមន្ត្រីណាម្នាក់របស់រដ្ឋ ឬក្រុង ដើម្បីរារាំង ឬបង្អាក់ការប្រមូលពន្ធណាមួយ ឬចំនួនពន្ធណាមួយដែលតម្រូវឱ្យប្រមូលនៅក្រោមក្រឹត្យច្បាប់នេះ ឬផ្នែក 1.6 នៃជំពូកទី 2 នៃក្រមស្តីពីចំណូល និងពន្ធដារឡើយ ។

មាត្រា 21.20.13 – គោលបំណង និងការប្រើប្រាស់ពន្ធ ។

A. គោលបំណងនៃពន្ធពិសេសដែលត្រូវបានអនុញ្ញាតដោយក្រឹត្យច្បាប់នេះគឺដើម្បីផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ LAFD ។ ប្រាក់ចំណូលទាំងអស់ដែលទទួលបានដោយពន្ធពិសេសនេះ ត្រូវប្រើប្រាស់សម្រាប់គោលបំណងដែលគាំទ្រដល់មុខងារស្នូលរបស់ LAFD ដែលរួមមាន ប៉ុន្តែមិនកំណត់ចំពោះអាទិភាពទាំងនេះឡើយ ៖ ការជួល និងការរក្សាបុគ្គលិកពន្លត់អគ្គីភ័យ និងពេទ្យសង្គ្រោះបបរ និងបុគ្គលិកស៊ីវិល LAFD ឱ្យបានគ្រប់គ្រាន់ ដើម្បីបំពេញតម្រូវការសុវត្ថិភាព/ការសង្គ្រោះអគ្គីភ័យរបស់ក្រុង ការទិញ និងថែទាំយានយន្តដើម្បីគាំទ្រដល់តម្រូវការពន្លត់អគ្គីភ័យ និងការសង្គ្រោះ ដូចជារថយន្តពន្លត់អគ្គីភ័យ រថយន្តពន្លត់អគ្គីភ័យធន់ធ្ងន់ រថយន្តសង្គ្រោះបន្ទាន់ យន្តហោះ និងឧទ្ធម្ភាគចក្រ ការទិញ និងថែទាំបរិក្ខារដើម្បីគាំទ្រដល់សេវាពន្លត់អគ្គីភ័យ និងការសង្គ្រោះ ការផ្លាស់ប្តូរ ការធ្វើឱ្យប្រសើរឡើង និងសាងសង់ស្ថានីយ៍ពន្លត់អគ្គីភ័យបន្ថែម និង EMS ដើម្បីបំពេញតាមតម្រូវការដែល

កំពុងកើនឡើងសម្រាប់សេវាកម្មទិញ និងថែទាំប្រព័ន្ធទំនាក់ទំនងបន្ទាន់ និងការកែលម្អការឆ្លាស់ព្រៃ និងការត្រៀមខ្លួនរួចជាស្រេចសម្រាប់ភ្លើងឆេះព្រៃ ។

B. ចំណូលទាំងអស់ដែលទទួលបានពីពន្ធដែលប្រមូលបាន ត្រូវយកទៅតម្កល់ទុកក្នុងមូលនិធិ ឬគណនីពិសេសមួយ ហើយត្រូវយកទៅប្រើប្រាស់សម្រាប់តែគោលបំណងទាំងឡាយណាដែលត្រូវបានអនុញ្ញាតដោយក្រឹត្យច្បាប់នេះប៉ុណ្ណោះ ។ សមតុល្យដែលមិនបានចំណាយត្រូវតែរក្សាទុកនៅក្នុងមូលនិធិ ឬគណនី ហើយត្រូវបន្តមានសម្រាប់ការប្រើប្រាស់ដែលមានការអនុញ្ញាតនៅក្នុងឆ្នាំសារពើពន្ធបន្ទាប់ រហូតដល់ត្រូវបានប្រើប្រាស់អស់ទាំងស្រុង ។

មាត្រា 21.20.14 - គណៈកម្មាធិការឃ្លាំមើលរបស់ប្រជាពលរដ្ឋ ។

A. ការបង្កើតគណៈកម្មាធិការ ។ តាមរយៈក្រឹត្យច្បាប់នេះ គណៈកម្មាធិការឃ្លាំមើលរបស់ប្រជាពលរដ្ឋត្រូវបានបង្កើតឡើងនៅក្នុងក្រុងដើម្បីតាមដានការចំណាយនៃប្រាក់ចំណូលដែលប្រមូលបានដោយអនុលោមតាមក្រឹត្យច្បាប់នេះតែប៉ុណ្ណោះ ហើយត្រូវផ្តល់របាយការណ៍ដល់ប្រជាជន ក្រុមប្រឹក្សាភិបាលនៃគណៈកម្មការអគ្គិភ័យ ក្រុមប្រឹក្សាក្រុង និងអភិបាលក្រុង ។

B. ការជ្រើសរើសសមាជិក ។ គណៈកម្មាធិការនេះ ត្រូវមានសមាជិកចំនួនប្រាំរូប ។ សមាជិកមួយរូបនៃគណៈកម្មាធិការ ត្រូវតែត្រូវបានតែងតាំងដោយមន្ត្រីម្នាក់ៗដូចខាងក្រោម ៖ (1) អភិបាលក្រុង (2) ប្រធានអង្គភាពអគ្គីភ័យ LAFD (3) អគ្គធិការហិរញ្ញវត្ថុក្រុង (4) មន្ត្រីរដ្ឋបាលក្រុង និង (5) ប្រធានគណៈកម្មាធិការសុវត្ថិភាពសាធារណៈរបស់ក្រុមប្រឹក្សាក្រុង ។ សមាជិកគណៈកម្មាធិការឃ្លាំមើលរបស់ប្រជាពលរដ្ឋ ត្រូវតែជាប្រជាពលរដ្ឋរស់នៅក្នុងក្រុង ហើយមិនមែនជាបុគ្គលិកក្រុងបច្ចុប្បន្ន មន្ត្រី អ្នកម៉ៅការ ឬអ្នកផ្គត់ផ្គង់បច្ចុប្បន្នរបស់ក្រុងឡើយ ។ អតីតបុគ្គលិក មន្ត្រី ឬអ្នកផ្គត់ផ្គង់ ត្រូវមានលក្ខណសម្បត្តិគ្រប់គ្រាន់ ក្នុងការបម្រើការនៅក្នុងគណៈកម្មាធិការនេះ ដោយមានលក្ខខណ្ឌថា មិនមានទំនាស់ផលប្រយោជន៍ណាមួយ ដូចដែលបានកំណត់ដោយមេធាវីក្រុងឡើយ ។

ក្នុងចំណោមសមាជិកគណៈកម្មាធិការដែលត្រូវបានតែងតាំងដំបូង សមាជិកដែលត្រូវបានតែងតាំងដោយអភិបាលក្រុង ប្រធានអង្គភាពអគ្គីភ័យ LAFD អគ្គធិការហិរញ្ញវត្ថុក្រុង មន្ត្រីរដ្ឋបាលក្រុង និងប្រធានគណៈកម្មាធិការសុវត្ថិភាពសាធារណៈរបស់ក្រុមប្រឹក្សាក្រុង ត្រូវតែងតាំងសម្រាប់អាណត្តិបីឆ្នាំ ។ គ្មានសមាជិកណាម្នាក់អាចបម្រើការងាររលើសពីពីរអាណត្តិជាប់ៗគ្នានោះទេ ។

C. គោលបំណង និងយុត្តាធិការ ។ គណៈកម្មាធិការឃ្លាំមើលរបស់ប្រជាពលរដ្ឋត្រូវពិនិត្យមើលការចំណាយនៃប្រាក់ចំណូលដែលប្រមូលបានដោយអនុលោមតាមក្រឹត្យច្បាប់នេះដើម្បីកំណត់ថាតើមូលនិធិទាំងនោះត្រូវបានចំណាយសម្រាប់គោលបំណងដែលបានបញ្ជាក់នៅក្នុងមាត្រា 21.20.13 ហើយត្រូវចេញរបាយការណ៍ស្តីពីការរកឃើញរបស់ពួកគេទៅអភិបាលក្រុង ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាភិបាលនៃគណៈកម្មការអគ្គិភ័យ និងសាធារណជនយ៉ាងហោចណាស់ឱ្យបានម្តងក្នុងមួយឆ្នាំ ។ សមាជិកគណៈកម្មាធិការក៏អាចពិនិត្យមើលឡើងវិញនូវសវនកម្មហិរញ្ញវត្ថុ ឬសវនកម្មប្រតិបត្តិការប្រចាំឆ្នាំ ដែលធ្វើឡើងដោយសវនករឯករាជ្យផងដែរ ។ គណៈកម្មាធិការ ត្រូវកំហិតកិច្ចការឃ្លាំមើលរបស់ខ្លួនជាពិសេសទៅលើតែប្រាក់ចំណូលដែលទទួលបានតាមក្រឹត្យច្បាប់នេះប៉ុណ្ណោះ ។ ចំណូលដែលបានមកពីប្រភពផ្សេងទៀតត្រូវស្ថិតនៅក្រៅយុត្តាធិការរបស់គណៈកម្មាធិការឃ្លាំមើលរបស់ប្រជាពលរដ្ឋ ។

ដើម្បីថែរក្សាភាពត្រឹមត្រូវ និងឯករាជ្យភាពនៃដំណើរការឃ្លាំមើល សមាជិកគណៈកម្មាធិការនឹងមិនដើរតួនាទីផ្លូវការណាមួយក្នុងការចុះកិច្ចសន្យាម៉ៅការ ការគ្រប់គ្រងគម្រោង ឬទិដ្ឋភាពផ្សេងទៀតនៃការគ្រប់គ្រង ឬការផ្តល់ថវិការបស់ LAFD ឡើយ ។

គណៈកម្មាធិការមិនត្រូវបានទទួលបន្ទុកក្នុងការសម្រេចចិត្តលើអាទិភាពការចំណាយ កាលវិភាគ ព័ត៌មានលម្អិតគម្រោង ការសម្រេចចិត្តអំពីប្រភពមូលនិធិ ផែនការហិរញ្ញប្បទាន ឬការសន្ទុតអត្រាពន្ធទេ ។ គណៈកម្មាធិការ ត្រូវ

បំពេញតួនាទីត្រឹមតែជាទីប្រឹក្សាប៉ុណ្ណោះ ។ គណៈកម្មាធិការ មិនត្រូវមានដែនសមត្ថកិច្ចណាមួយផ្សេងទៀត ក្រៅពីដែនសមត្ថកិច្ចដែលត្រូវបានកំណត់ឱ្យដោយយោងតាមក្រឹត្យច្បាប់នេះឡើយ ។

អភិបាលក្រុង ឬតំណាងដែលបានចាត់តាំង ត្រូវផ្តល់ជំនួយបច្ចេកទេស ឬរដ្ឋបាលសមស្របណាមួយ ដែលត្រូវការដោយគណៈកម្មាធិការ ដើម្បីបំពេញភារកិច្ចរបស់ខ្លួន ឬដើម្បីផ្សព្វផ្សាយជាសាធារណៈនូវលទ្ធផលនៃការរកឃើញរបស់ខ្លួន ។

D. ការប្រជុំ ។ គណៈកម្មាធិការឃ្លាំមើលរបស់ប្រជាពលរដ្ឋត្រូវប្រជុំបីដងរៀងរាល់ឆ្នាំសារពើពន្ធនីមួយៗ (ឬដូចមានចែងក្នុងច្បាប់អនុម័ត ឬធ្វើវិសោធនកម្ម) ដោយមានកាលបរិច្ចេទប្រជុំជាក់លាក់ដែលត្រូវកំណត់ដោយសមាជិកគណៈកម្មាធិការ ។ ការប្រជុំរបស់គណៈកម្មាធិការឃ្លាំមើលរបស់ប្រជាពលរដ្ឋ ត្រូវស្ថិតក្រោមការអនុវត្តនៃច្បាប់ Brown Act ។ ការប្រជុំ ត្រូវតែមានការរៀបចំរបៀបវារៈច្បាស់លាស់ និងបើកទូលាយជូនសាធារណជនចូលរួម ។ កំណត់ហេតុនិងរបាយការណ៍របស់គណៈកម្មាធិការគឺជាឯកសារនៃកំណត់ត្រាសាធារណៈ ហើយនឹងត្រូវបានបង្ហោះនៅលើគេហទំព័រដែលផ្តល់ដោយក្រុង ។ ការប្រជុំបន្ថែមអាចត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការប្រសិនបើមានការចាំបាច់ ។ សមាជិកគណៈកម្មាធិការទាំងអស់ត្រូវចូលរួមវគ្គបណ្តុះបណ្តាល និងវគ្គតម្រង់ទិសមុនពេលចូលរួមកិច្ចប្រជុំគណៈកម្មាធិការទៀងទាត់លើកដំបូងរបស់ពួកគេ ។

សមាជិកគណៈកម្មាធិការ ត្រូវបានរំពឹងថានឹងចូលរួមការប្រជុំជាទៀងទាត់ទាំងអស់ ។ ការខកខានមិនបានចូលរួមកិច្ចប្រជុំពីរលើកជាប់ៗគ្នាអាចឈានទៅដល់ការដកចេញពីគណៈកម្មាធិការតាមឆន្ទានុសិទ្ធិរបស់មន្ត្រីក្រុងដែលបានតែងតាំងសមាជិកគណៈកម្មាធិការរូបនោះ ។

E. ប្រតិបត្តិការរបស់គណៈកម្មាធិការ និងការផ្តល់មូលនិធិ ។ គណៈកម្មាធិការឃ្លាំមើលរបស់ប្រជាពលរដ្ឋ នឹងជ្រើសរើសសមាជិកឱ្យធ្វើជាប្រធាន និងអនុប្រធានគណៈកម្មាធិការ ។ បុគ្គលិកក្រុងម្នាក់នឹងត្រូវបានតែងតាំងដោយអភិបាលក្រុង ឬចាត់តាំងឱ្យបម្រើការជាលេខាធិការ ។ លេខាធិការនឹងទទួលខុសត្រូវក្នុងការរៀបចំ ការបង្ហោះនិងចែកចាយរបៀបវារៈនិងកត់ត្រានៅក្នុងកិច្ចប្រជុំនីមួយៗ ។ កំណត់ហេតុប្រជុំដែលបានអនុម័តរួច ត្រូវតែបើកចំហជូនសាធារណជន ។ ការសម្រេចចិត្ត ជំហរ លទ្ធផលនៃការរកឃើញ និងនីតិវិធីរបស់គណៈកម្មាធិការ ត្រូវទាមទារឱ្យមានសំឡេងឆ្នោតភាគច្រើនដាច់ខាត ពីសំណាក់សមាជិកដែលបានចូលរួម ។ ក្ស្ម៉មដែលតម្រូវសម្រាប់ការប្រជុំនីមួយៗ ត្រូវមានសមាជិកយ៉ាងតិចចំនួនបីរូប ។ ចំណាយបន្តបន្ទាប់របស់គណៈកម្មាធិការឃ្លាំមើលរបស់ប្រជាពលរដ្ឋ ត្រូវទូទាត់ដោយប្រើប្រាស់ប្រាក់ចំណូលដែលទទួលបានពីពន្ធពិសេស ដែលត្រូវបានអនុញ្ញាតតាមក្រឹត្យច្បាប់នេះ ។

F. តំណែងទំនេរ ។ សមាជិកគណៈកម្មាធិការអាចត្រូវបានដកតំណែងចេញពីគណៈកម្មាធិការដោយមន្ត្រីក្រុងដែលបានតែងតាំងពួកគេសម្រាប់អវត្តមានច្រើនលើកច្រើនសារ (សូមមើលផ្នែករង D នៃផ្នែកនេះ) ចំពោះការល្មើសក្នុងមុខតំណែង ចំពោះការមិនបានបំពេញតាមលក្ខណៈសម្បត្តិដែលមានចែងនៅក្នុងផ្នែកនេះ ឬចំពោះការអសមត្ថភាព ឬការមិនស្មំគ្រចិត្តក្នុងការបំពេញភារកិច្ចរបស់សមាជិក ។ ក្នុងករណីដកតំណែង ការលាលែងពីតំណែង ឬមរណភាព មន្ត្រីក្រុងដែលបានតែងតាំងសមាជិកគណៈកម្មាធិការដែលតំណែងត្រូវបានទុកឱ្យនៅទំនេរ ត្រូវតែងតាំងបុគ្គលម្នាក់ដើម្បីបំពេញតំណែងទំនេរនេះ ។

G. ផ្សេងៗ ។ លើកលែងតែប្រធានបទទាំងឡាយណាដែលត្រូវបានចែងជាក់លាក់នៅក្នុងគោលការណ៍ណែនាំទាំងនេះ គណៈកម្មាធិការអាចព្រាង និងអនុម័តនីតិវិធីស្តង់ដារ និងបទបញ្ជាផ្ទៃក្នុងផ្ទាល់ខ្លួនរបស់ខ្លួនបានតាមរយៈសំឡេងឆ្នោតភាគច្រើន ។ រាល់នីតិវិធី និងបទបញ្ជាផ្ទៃក្នុងទាំងអស់របស់គណៈកម្មាធិការឃ្លាំមើលរបស់ប្រជាពលរដ្ឋ នៅតែស្ថិតក្រោមការពិនិត្យឡើងវិញ និងការអនុម័តពីក្រុមប្រឹក្សាក្រុង និងអភិបាលក្រុង ។ របាយការណ៍ និងសវនកម្មរបស់គណៈកម្មាធិការឃ្លាំមើលរបស់ប្រជាពលរដ្ឋ គឺស្ថិតក្រោមការពិនិត្យឡើងវិញ និងការអនុម័តពីក្រុមប្រឹក្សាក្រុង និងអភិបាលក្រុង ។

H. រយៈពេល ។ គណៈកម្មាធិការឃ្លាំមើលរបស់ប្រជាពលរដ្ឋនឹងនៅតែមានសុពលភាពរហូតដល់ការបោះឆ្នោតរបស់ក្រុមប្រឹក្សាក្រុង ដែលស្ថិតក្រោមការអនុម័តពីអភិបាលក្រុង ដើម្បីរឹសាយគណៈកម្មាធិការនេះ ។ ការរំសាយនេះ មិនអាចប្រព្រឹត្តទៅបានឡើយ ក្នុងអំឡុងពេល 10 ឆ្នាំដំបូង នៃការអនុវត្តក្រឹត្យច្បាប់នេះ ។

មាត្រា 21.20.15 - បទប្បញ្ញត្តិស្តីពីគណនេយ្យភាពសារពើពន្ធ ។

ចំនួនទឹកប្រាក់ដែលទទួលបានពីប្រភពចំណូលដែលមានគោលបំណងពិសេសនេះ និងរបៀបនៃការប្រើប្រាស់ទឹកប្រាក់នោះ ត្រូវតែបញ្ចូលទៅក្នុងការសវនកម្មប្រចាំឆ្នាំ នៃប្រតិបត្តិការហិរញ្ញវត្ថុរបស់ក្រុង ដោយសវនករឯករាជ្យដែលមានអាជ្ញាប័ណ្ណ ។ ចំណាយនៃសវនកម្មប្រចាំឆ្នាំនេះ ត្រូវទូទាត់ដោយប្រើប្រាស់ប្រាក់ចំណូលដែលទទួលបានពីពន្ធពិសេស ដែលត្រូវបានអនុញ្ញាតតាមក្រឹត្យច្បាប់នេះ ។

មាត្រា 21.20.16 – រយៈពេលនៃពន្ធ ។

អំណាចក្នុងការដាក់កំហិតពន្ធដែលបានកំណត់ដោយក្រឹត្យច្បាប់នេះនឹងនៅតែមានសុពលភាពរហូតដល់ត្រូវបានលុបចោលដោយម្ចាស់ឆ្នោត ។

មាត្រា 21.20.17 – សុពលភាពដាច់ដោយឡែក ។

ប្រសិនបើបទប្បញ្ញត្តិ មាត្រា ផ្នែករង កថាខណ្ឌ ប្រយោគ ឃ្លា ឬពាក្យណាមួយនៃក្រឹត្យច្បាប់នេះ ត្រូវបានធ្វើឱ្យ ឬត្រូវបានប្រកាសថា មោឃៈ ខុសច្បាប់ ឬផ្ទុយនឹងរដ្ឋធម្មនុញ ដោយចំណាត់ការចុងក្រោយនៃតុលាការដែលមានសមត្ថកិច្ច ឬដោយសារហេតុផលឬច្បាប់បង្ការណាមួយនោះ ភាពផ្ទុយនឹងរដ្ឋធម្មនុញ ភាពខុសច្បាប់ ឬមោឃភាពបែបនេះ ត្រូវប៉ះពាល់ត្រឹមតែបទប្បញ្ញត្តិ មាត្រា ផ្នែករង កថាខណ្ឌ ប្រយោគ ឃ្លា ឬពាក្យនោះតែប៉ុណ្ណោះ ហើយមិនត្រូវប៉ះពាល់ ឬធ្វើឱ្យប៉ះពាល់ដល់បទប្បញ្ញត្តិ មាត្រា ផ្នែករង កថាខណ្ឌ ប្រយោគ ឃ្លា ឬពាក្យដែលនៅសល់ ឬការអនុវត្តក្រឹត្យច្បាប់នេះចំពោះបុគ្គល ឬកាលៈទេសៈផ្សេងទៀតឡើយ ហើយសម្រាប់គោលបំណងនេះ បទប្បញ្ញត្តិនៃច្បាប់នេះ គឺអាចផ្តាច់ចេញពីគ្នាបាន ។ ដោយហេតុនេះ វាត្រូវបានប្រកាសថាជាចេតនារបស់ប្រជាពលរដ្ឋនៃក្រុង ដែលថាក្រឹត្យច្បាប់នេះ នឹងត្រូវបានអនុម័ត ដូចជាមិនមានការរាប់បញ្ចូលនូវបទប្បញ្ញត្តិ មាត្រា ផ្នែករង កថាខណ្ឌ ប្រយោគ ឃ្លា ឬពាក្យ ដែលផ្ទុយនឹងរដ្ឋធម្មនុញ ខុសច្បាប់ ឬមោឃៈ ទាំងនោះនៅក្នុងច្បាប់នេះឡើយ ។

មាត្រា 21.20.18 – វិសោធនកម្ម ។

ក្រុមប្រឹក្សាក្រុងមិនមានសិទ្ធិអំណាចក្នុងការធ្វើវិសោធនកម្មបទបញ្ញត្តិនេះទេ លើកលែងតែមានចែងយ៉ាងច្បាស់លាស់ក្នុងច្បាប់នេះ ។ ការធ្វើវិសោធនកម្មអាចត្រូវ បានប្រកាសឱ្យប្រើប្រាស់ ដោយមិនចាំបាច់មានការបោះឆ្នោតពីប្រជាពលរដ្ឋនោះឡើយ លុះត្រាតែការធ្វើវិសោធនកម្មនោះ ៖ (1) គឺចាំបាច់យ៉ាងតឹងរ៉ឹងក្នុងការអនុវត្ត ឬគ្រប់គ្រងក្រឹត្យច្បាប់នេះ (2) មិនផ្លាស់ប្តូរចំនួនអត្រា ឬរយៈពេលនៃពន្ធ (3) លើកកម្ពស់គោលបំណងនៃក្រឹត្យច្បាប់នេះ និង (4) ត្រូវបានអនុម័តដោយសំឡេងពីរភាគបីនៃសមាជិកក្រុមប្រឹក្សាក្រុងទាំងអស់ បន្ទាប់ពីការជូនដំណឹង និងការពិនិត្យជាសាធារណៈយ៉ាងហោចណាស់ 30 ថ្ងៃ ។

មាត្រា 21.20.19 – កាតព្វកិច្ចរក្សាកម្រិតចំណាយ (MOE) ។

A. វាគឺជាចេតនារបស់ប្រជាពលរដ្ឋ ដែលថាប្រាក់ចំណូលដែលប្រមូលបានក្រោមក្រឹត្យច្បាប់នេះ ត្រូវយកទៅបន្ថែមលើ ហើយមិនត្រូវយកទៅជំនួសឱ្យ ការចំណាយដែលមានស្រាប់របស់ក្រុង សម្រាប់ LAFD នោះឡើយ ។ ដើម្បីសម្រេចគោលបំណងនេះ ក្រុងត្រូវរក្សាឱ្យបានអប្បបរមានូវភាគរយជាមធ្យមភាគនៃកញ្ចប់ថវិកាចំណាយមិនចាំបាច់សរុបដែលបានផ្តល់ជូន LAFD ក្នុងអំឡុងពេលដប់ឆ្នាំសារពើពន្ធ ភ្លាមៗមុនកាលបរិច្ចេទចូលជាធរមាននៃក្រឹត្យច្បាប់នេះ (ហៅថា "អំឡុងពេលគោល") ។ អំឡុងពេលគោលត្រូវតែកំណត់ឱ្យថេរ គិតត្រឹមកាលបរិច្ចេទចូលជាធរមាននៃក្រឹត្យច្បាប់នេះ ហើយមិនត្រូវគណនាកាត់បន្ថយចុះក្រោម នៅក្នុងឆ្នាំបន្តបន្ទាប់ទៀតឡើយ ។ ។

B. ប្រសិនបើនៅពេលណាមួយ ក្រុងខកខានក្នុងការផ្តល់ថវិកាដើម្បីបំពេញតាមកម្រិតថវិកាដែលបានផ្តល់ដោយផ្នែកនេះ នោះក្រុងមិនត្រូវដាក់ឱ្យអនុវត្ត និងដាក់បន្ទុកពន្ធពិសេសដែលបានបង្កើតឡើងស្របតាមក្រឹត្យច្បាប់នេះ ក្នុងអំឡុងឆ្នាំសារពើពន្ធនោះឡើយ ។

C. ដើម្បីលើកកម្ពស់តម្លាភាព និងគណនេយ្យភាព ក្រុងត្រូវបញ្ជាក់ជារៀងរាល់ឆ្នាំអំពីអនុលោមភាពរបស់ខ្លួនជាមួយនឹងតម្រូវការកាតព្វកិច្ចរក្សាកម្រិតចំណាយនេះ ជាផ្នែកមួយនៃដំណើរការរៀបចំថវិកា ហើយការបញ្ជាក់បែបនេះត្រូវតែបើកចំហជូនសាធារណជន ។

D. គ្មានអ្វីនៅក្នុងផ្នែកនេះ ត្រូវរារាំងក្រុងមិនឱ្យបង្កើនការគាំទ្រមូលនិធិទូទៅដល់ LAFD ឱ្យលើសពីភាគរយមធ្យមភាគសម្រាប់អំឡុងពេលគោលនោះឡើយ ។

មាត្រា 21.20.20 – ការសាងសង់ថ្មី និងឱកាសការងារសម្រាប់ពលរដ្ឋក្នុងមូលដ្ឋាន ។

A. រាល់គម្រោងសាងសង់ស្ថានីយ៍ពន្លត់អគ្គីភ័យថ្មី និងគម្រោងជំនួសស្ថានីយពន្លត់អគ្គីភ័យដែលទទួលបានមូលនិធិពីក្រឹត្យច្បាប់នេះត្រូវស្ថិតនៅក្រោមកិច្ចព្រមព្រៀងការងាររបស់ក្រសួងការងារសាធារណៈនៃទីក្រុង Los Angeles (“ក្រសួងការងារសាធារណៈ PLA”) ។ ក្រុមប្រឹក្សាក្រុង អាចបញ្ចូលនូវគម្រោងសាងសង់ ការជួសជុលកែលម្អឡើងវិញ និងគម្រោងជំនួសផ្សេងទៀត ដែលទទួលបានថវិកាពីក្រឹត្យច្បាប់នេះ ទៅក្នុងកិច្ចព្រមព្រៀងពលកម្មគម្រោងរបស់ក្រសួងការងារសាធារណៈ PLA ទៅតាមការវិនិច្ឆ័យផ្ទាល់ខ្លួនរបស់ខ្លួនបាន ។

B. ប្រសិនបើកិច្ចព្រមព្រៀងពលកម្មគម្រោងជាក់លាក់ (“PLA”) ត្រូវបានអនុម័តដោយក្រុមប្រឹក្សាក្រុងដើម្បីអនុវត្តចំពោះការសាងសង់ ការជួសជុលកែលម្អឡើងវិញ និងគម្រោងជំនួសដែលទទួលបានមូលនិធិពីក្រឹត្យច្បាប់នេះ អ្នកម៉ៅការដែលអនុវត្តការសាងសង់ ការជួសជុល និងការងារជំនួសលើគម្រោងគ្រឿងអគារបែបនេះនឹងត្រូវបានតម្រូវឱ្យអនុលោមតាម PLA ជាក់លាក់ជាជាងក្រសួងការងារសាធារណៈ PLA ។

C. រាល់គម្រោងសាងសង់ ការជួសជុលកែលម្អឡើងវិញ និងគម្រោងជំនួស នៃស្ថានីយពន្លត់អគ្គិភ័យ ដែលទទួលបានថវិកាពីក្រឹត្យច្បាប់នេះ ត្រូវចាត់ទុកជាសំណង់សាធារណៈ ដែលត្រូវតែទូទាត់ប្រាក់ឈ្នួលតាមអត្រាដែលកំពុងមានកំណត់ជាធរមានដោយសមស្របទៅតាមក្រមពលកម្មនៃរដ្ឋ California ។

D. សម្រាប់គម្រោង LAFD ដែលទទួលបានថវិកាពីក្រឹត្យច្បាប់នេះ ក្រុមប្រឹក្សាក្រុងអាចតម្រូវឱ្យមានការបង្កើតកម្មវិធីអភិវឌ្ឍន៍កម្លាំងជំនាញ ដើម្បីបង្កើនឱកាសទទួលបានការងារក្នុងវិស័យសំណង់ សម្រាប់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន នៃទីក្រុង Los Angeles ។ កម្មវិធីណាមួយបែបនេះនឹងលើកកម្ពស់ការប្រើប្រាស់កម្មវិធីបង្រៀន និងកម្មវិធីមុនចូលសិក្សា ពិព័រណ៍ការងារ និងគំនិតផ្ទួចផ្តើមអភិវឌ្ឍន៍កម្លាំងជំនាញផ្សេងទៀត ដើម្បីធានាថាគម្រោង LAFD មានគោលដៅបង្កើតមាគ៌ាឆ្ពោះទៅរកការងារថ្នាក់កណ្តាលល្អសម្រាប់ពលរដ្ឋរស់នៅក្រុង ។

មាត្រា 3. វិធានដែលមានខ្លឹមសារផ្ទុយគ្នា ។

វិធានការនេះមានគោលបំណងប្រតិបត្តិការនៅក្នុងដែនកំណត់នៃច្បាប់រដ្ឋដែលគ្រប់គ្រងពន្ធប្រតិបត្តិការ និងការប្រើប្រាស់ ។ ប្រសិនបើវិធានការនេះ និងវិធានការក្រុងផ្សេងទៀតដែលលេចឡើងនៅលើសន្លឹកឆ្នោតជាមួយគ្នានីមួយៗ សុទ្ធតែដាក់ពន្ធលើប្រតិបត្តិការ និងការប្រើប្រាស់ ហើយការអនុម័តរួមគ្នានៃវិធានការបែបនេះនឹងបណ្តាលឱ្យអត្រាពន្ធស្រុកសរុបដែលអាចអនុវត្តបាននៅក្នុងក្រុងលើសពីការកំណត់ដែលបានបង្កើតឡើងដោយមាត្រា 7251.1 នៃក្រមស្តីពីចំណូល និងពន្ធរដ្ឋ California ឬលក្ខន្តិក:អ្នកស្នងតំណែងណាមួយ នោះបទប្បញ្ញត្តិនៃវិធានការនេះនឹងត្រូវបានចាត់ទុកថាមានទំនាស់នឹងវិធានការផ្សេងទៀតក្នុងវិសាលភាពនោះ ។

ដោយអនុលោមតាមអត្ថបទ II មាត្រា 10(b) នៃរដ្ឋធម្មនុញ្ញរដ្ឋ California ប្រសិនបើវិធានការនេះ និងវិធានការផ្ទុយគ្នាណាមួយត្រូវបានអនុម័តដោយអ្នកបោះឆ្នោតនៅក្នុងការបោះឆ្នោតតែមួយ វិធានការដែលទទួលបានសំឡេងគាំទ្រច្រើនជាងនឹងមានអាទិភាពលើគ្រប់ផ្នែកទាំងអស់ ទាក់ទងនឹងផ្នែកដែលផ្ទុយគ្នានេះ ។ ប្រសិនបើវិធានការនេះ ទទួលបានសំឡេងឆ្នោតគាំទ្រ

ភាគច្រើន ប៉ុន្តែតិចជាងវិធានការផ្សេងទៀតដែលមានខ្លឹមសារផ្ទុយគ្នានោះ វិធានការនេះត្រូវចូលជាធរមានក្នុងកម្រិតសមស្របណាដែលអាជ្ញាធរអាចធ្វើទៅបាន ដោយមិនឱ្យលើសពីដែនកំណត់ដែលបានកំណត់ដោយច្បាប់ ឬជាន់គ្នានឹងវិធានការដែលមានអាទិភាពនោះឡើយ ។

មាត្រា 4. កាលបរិច្ឆេទមានប្រសិទ្ធភាពអនុវត្ត; កាលបរិច្ឆេទប្រតិបត្តិការ ។

ក្រឹត្យច្បាប់នេះ ត្រូវចូលជាធរមានក្នុងរយៈពេលដប់ (10) ថ្ងៃ បន្ទាប់ពីក្រុមប្រឹក្សាក្រុង ឬស្ថាប័នគ្រប់គ្រងផ្សេងទៀត បញ្ជាក់ទទួលស្គាល់ថា ក្រឹត្យច្បាប់នេះ ត្រូវបានអនុម័តត្រឹមត្រូវដោយម្ចាស់ឆ្នោត ដែលបានបោះឆ្នោតនៅក្នុងការបោះឆ្នោតលើវិធានការប្រកាសឱ្យអនុវត្តក្រឹត្យច្បាប់នេះ ។ ប្រតិបត្តិការ និងពន្ធលើការប្រើប្រាស់ដែលបានដាក់នៅខាងក្រោមត្រូវប្រតិបត្តិការនៅថ្ងៃដំបូងនៃត្រីមាសប្រតិទិនទីមួយ ដែលចាប់ផ្តើមលើសពីមួយរយៈពេលដប់ (110) ថ្ងៃ បន្ទាប់ពីការអនុម័តក្រឹត្យច្បាប់នេះ (ហៅថា “កាលបរិច្ឆេទចូលជាធរមាន”) ឬដូចដែលមានចែងដោយច្បាប់ផ្សេងទៀត ។

មាត្រា 5. ការការពារតាមផ្លូវច្បាប់ ។

ប្រសិនបើត្រូវបានអនុម័តដោយម្ចាស់ឆ្នោតដោយសំឡេងភាគច្រើន ហើយបន្ទាប់មកត្រូវបានជំទាស់នៅក្នុងតុលាការនៃយុត្តាធិការមានសមត្ថកិច្ច ក្រុងត្រូវការពារក្រឹត្យច្បាប់នេះនៅក្នុងតុលាការនៃយុត្តាធិការមានសមត្ថកិច្ច ។ តាមរយៈការអនុម័តក្រឹត្យច្បាប់នេះ ដោយសំឡេងឆ្នោតភាគច្រើន ប្រជាពលរដ្ឋនៃក្រុង សូមប្រកាសប្រាប់ថា អ្នកផ្តើមគំនិតបង្កើតក្រឹត្យច្បាប់នេះ មានផលប្រយោជន៍ និងទាក់ទិនផ្ទាល់ខ្លួន ក្នុងការការពារក្រឹត្យច្បាប់នេះ ពីការប្តឹងតវ៉ាប្រឆាំងនឹងភាពស្របច្បាប់តាមរដ្ឋធម្មនុញ្ញ ឬតាមច្បាប់ ឬការអនុវត្តក្រឹត្យច្បាប់នេះ ។ ក្នុងករណីដែលក្រុងខកខានក្នុងការការពារក្រឹត្យច្បាប់នេះ ឬក្រុងខកខានក្នុងការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលដីការអវិជ្ជមានលើក្រឹត្យច្បាប់នេះ ទាំងស្រុង ឬមួយផ្នែក នៅចំពោះមុខតុលាការដែលមានសមត្ថកិច្ចណាមួយនោះ អ្នកផ្តើមគំនិតបង្កើតក្រឹត្យច្បាប់នេះ ត្រូវមានសិទ្ធិអះអាងពីផលប្រយោជន៍ និងការទាក់ទិនផ្ទាល់ខ្លួនរបស់ខ្លួនដោយចូលរួមការពារភាពស្របច្បាប់ និងការអនុវត្តក្រឹត្យច្បាប់នេះ នៅចំពោះមុខតុលាការដែលមានសមត្ថកិច្ចណាមួយ ហើយត្រូវបានផ្តល់អំណាចដោយប្រជាពលរដ្ឋ តាមរយៈក្រឹត្យច្បាប់នេះ ឱ្យធ្វើជាតំណាងរបស់ប្រជាពលរដ្ឋនៃក្រុង ហើយទីក្រុងត្រូវទទួលខុសត្រូវទូទាត់សងថ្លៃមេធាវីសមរម្យ ជូនដល់អ្នកផ្តើមគំនិតទាំងនោះ ។

មាត្រា 6. ការរៀបចំក្រមច្បាប់ ការចុះលេខ និងការកែសម្រួលបច្ចេកទេសដែលមិនប្រែប្រួលខ្លឹមសារ ។

ប្រសិនបើត្រូវបានអនុម័តដោយម្ចាស់ឆ្នោត ក្រឹត្យច្បាប់នេះ ត្រូវរៀបចំបញ្ចូលទៅក្នុងក្រមច្បាប់ក្រុង Los Angeles ។ លេខជំពូក ប្រការ និងផ្នែក ដែលបានចែងនៅក្នុងក្រឹត្យច្បាប់នេះ គឺសម្រាប់ជាឯកសារយោងតែប៉ុណ្ណោះ ហើយក្រឡាបញ្ជីក្រុង ត្រូវបានប្រគល់សិទ្ធិអំណាចក្នុងការកំណត់លេខជំពូក មាត្រា និងផ្នែកជំនួស ព្រមទាំងធ្វើការកែសម្រួលទម្រង់ អក្ខរាវិរុទ្ធ និងការយោងផ្ទៃក្នុងដែលមិនប្រែប្រួលខ្លឹមសារតាមការចាំបាច់ ដើម្បីឱ្យក្រឹត្យច្បាប់នេះមានប្រសិទ្ធភាពអនុវត្ត ដោយមិនធ្វើឱ្យប្រែប្រួលខ្លឹមសារដើមឡើយ ។

សេចក្តីប្រកាសសិទ្ធិឯកជនរបស់អ្នកបោះឆ្នោត

អ្នកមានសិទ្ធិដូចខាងក្រោម ៖

1. **សិទ្ធិដើម្បីបោះឆ្នោត បើសិនអ្នកគឺជាអ្នកបោះឆ្នោតដែលបានចុះឈ្មោះ ។** អ្នកមានសិទ្ធិបោះឆ្នោត បើសិនអ្នក៖
   - ★ ជាពលរដ្ឋអាមេរិកកំពុងរស់នៅរដ្ឋកាលីហ្វ៉រញ៉ា
   - ★ មានអាយុយ៉ាងតិច 18 ឆ្នាំ
   - ★ បានចុះឈ្មោះនៅកន្លែងដែលអ្នករស់នៅបច្ចុប្បន្ន
   - ★ បច្ចុប្បន្នមិនបម្រើរដ្ឋឬជាប់ពន្ធនាគារសហព័ន្ធសម្រាប់ការកាត់ទោសពីបទឧក្រិដ្ឋមួយ
   - ★ នៅពេលបច្ចុប្បន្ននេះ មិនបានរកឃើញដោយតុលាការថាអសមត្ថភាពខាងផ្លូវចិត្ត ដើម្បីបោះឆ្នោតឡើយ

2. **សិទ្ធិដើម្បីបោះឆ្នោត បើអ្នកជាអ្នកបោះឆ្នោតបានចុះឈ្មោះ សូម្បីតែឈ្មោះរបស់អ្នកមិននៅក្នុងបញ្ជី ក៏ដោយ ។** អ្នកនឹងបោះឆ្នោតដោយប្រើសន្លឹកឆ្នោតបណ្តោះអាសន្នមួយ ។ សន្លឹកឆ្នោតរបស់លោកអ្នកនឹងត្រូវបានរាប់ បើសិនមន្ត្រីបោះឆ្នោតសម្រេចថាលោកអ្នកមានលក្ខណសម្បត្តិអាចបោះឆ្នោតបាន ។

3. **សិទ្ធិដើម្បីបោះឆ្នោត បើសិនលោកអ្នកនៅឈរតម្រង់ជួរ ពេលការិយាល័យបោះឆ្នោតនោះបិទទ្វារ ។**

4. **សិទ្ធិដើម្បីបោះឆ្នោតជាសម្ងាត់** ដោយគ្មាននរណាម្នាក់រំខានលោកអ្នក ឬប្រាប់លោកអ្នកពីរបៀបបោះឆ្នោត ។

5. **សិទ្ធិដើម្បីទទួលបានសន្លឹកឆ្នោតថ្មីមួយ បើសិនលោកអ្នកបានធ្វើដោយភាន់ច្រឡំ**បើសិនលោកអ្នកមិនទាន់បានបោះឆ្នោតរបស់លោកអ្នកនោះទេ ។ លោកអ្នកអាច ៖
   ស្នើសុំមន្ត្រីបោះឆ្នោតនៅមណ្ឌលបោះឆ្នោតនូវសន្លឹកឆ្នោតថ្មី
   ជូរសន្លឹកឆ្នោតបោះឆ្នោត-តាម-សំបុត្ររបស់អ្នកសម្រាប់សន្លឹកឆ្នោតថ្មី នៅការិយាល័យបោះឆ្នោត ឬនៅមណ្ឌលបោះឆ្នោតរបស់អ្នក ឬ
   បោះឆ្នោតដោយប្រើសន្លឹកឆ្នោតបណ្តោះអាសន្ន ។

6. **សិទ្ធិដើម្បីទទួលបានជំនួយក្នុងការបោះសន្លឹកឆ្នោតរបស់លោកអ្នក** ពីជនណាម្នាក់ដែលលោកអ្នកជ្រើសរើស លើកលែងពីនិយោជក ឬតំណាងសហជីព របស់អ្នក។

7. **សិទ្ធិដើម្បីប្រគល់សន្លឹកឆ្នោតបោះឆ្នោត-តាម-សំបុត្ររបស់អ្នក ដែលបានបំពេញនៅមណ្ឌលបោះឆ្នោតណាមួយ** ក្នុងរដ្ឋកាលីហ្វ៉រនីញ៉ា។

8. **សិទ្ធិដើម្បីទទួលបានសម្ភារៈបោះឆ្នោតជាភាសាផ្សេងក្រៅពីភាសាអង់គ្លេស** បើសិនមានចំនួនមនុស្សគ្រប់គ្រាន់នៅក្នុងតំបន់បោះឆ្នោតរបស់លោកអ្នកនិយាយភាសានោះ ។

9. **សិទ្ធិដើម្បីសួរសំណួរនានាទៅកាន់មន្ត្រីបោះឆ្នោតអំពីនីតិវិធីបោះឆ្នោត** និងឃ្លាំមើលដំណើរការបោះឆ្នោត ។ បើសិនមនុស្សដែលលោកអ្នកសួរនោះ មិនអាចឆ្លើយសំណួររបស់លោកអ្នកបាន ពួកគេត្រូវតែបញ្ជូនលោកអ្នកទៅជួបមនុស្សត្រឹមត្រូវ ដើម្បីឆ្លើយសំណួរបាន ។ បើសិនលោកអ្នកមានបូកពារអុកឡុក ពួកគេអាចឈប់ឆ្លើយនឹងលោកអ្នក ។

10. **សិទ្ធិដើម្បីរាយការណ៍ពីសកម្មភាពខុសច្បាប់ ឬសកម្មភាពបន្លំសន្លឹកឆ្នោត** ទៅមន្ត្រីបោះឆ្នោត ឬការិយាល័យរបស់រដ្ឋលេខាធិការ។

បើសិនលោកអ្នកជឿជាក់ថា លោកអ្នកត្រូវបានបដិសេធនូវសិទ្ធិណាមួយនេះទូរស័ព្ទទៅលេខពិសេសអ្នកបោះឆ្នោតរបស់រដ្ឋលេខាធិការ តាមលេខឥតចេញថ្លៃជាសំងាត់បណ្តាញលាក់ការពិសេសរបស់ការិយាល័យរដ្ឋលេខាធិការតាម (800) 345-VOTE (8683)។

- នៅលើគេហទំព័រតាម **www.sos.ca.gov**
- តាមរយៈទូរស័ព្ទលេខ **(800) 345-VOTE (8683)**
- តាមរយៈអីមែល **elections@sos.ca.gov**

ព័ត៌មានអំពីលទ្ធភាពប្រើប្រាស់របស់អ្នកបោះឆ្នោត

លទ្ធភាពប្រើប្រាស់ និងឧបករណ៍ជំនួយផ្សេងទៀត
(800) 815-2666 ជម្រើសទី 4 (បណ្តាញទាន់ហេតុការណ៍ខោនធី LA)

មណ្ឌលបោះឆ្នោតខោនធី LA ផ្តល់នូវលទ្ធភាពប្រើប្រាស់ចេញចូលបានដល់រទេះរុញ និង/ឬ ការបោះឆ្នោតនៅតាមចិញ្ចើមថ្នល់។ នៅខាងក្នុងមណ្ឌលបោះឆ្នោត អ្នកអាចស្វែងរកឧបករណ៍ដើម្បីជួយអ្នកនៅក្នុងបទពិសោធន៍បោះឆ្នោតរបស់អ្នក។

ការថតសំឡេង (213) 978-0444
មានឧបករណ៍ថតសំឡេងនៅមណ្ឌលបោះឆ្នោតដើម្បីជួយអ្នក។

វិធានការនៃការថតសំឡេងរួមមាននៅក្នុងកូនសៀវភៅនេះគឺមានជាភាសាអង់គ្លេស អាមេនី ចិន ហ្វាស៊ី ហិណ្ឌូ ជប៉ុន ខ្មែរ កូរ៉ា រុស្ស៊ី អេស្ប៉ាញ តាកាឡុក ថៃ និង វៀតណាម។ ការថតសំឡេងទាំងនេះអាចរកបាននៅលើគេហទំព័ររបស់យើង៖ clerk.lacity.gov/elections/multilingual-services និងនៅទីតាំងដូចខាងក្រោម៖

Braille Institute Library
741 North Vermont Avenue
Los Angeles, CA 90029
(323) 660-3880

Central Library
630 West 5th Street
Los Angeles, CA 90071
(213) 228-7000

អ្នកបោះឆ្នោតក៏អាចស្នើសុំច្បាប់ចម្លងនៃការថតសំឡេងពីការិយាល័យរបស់យើងផងដែរ៖

Office of the City Clerk-Election Division
Attn: Audio Recordings
555 Ramirez Street, Space 300
Los Angeles, CA 90012

លេខទូរស័ព្ទ TTD (562) 462-2259
លេខទូរស័ព្ទ TTD មួយខ្សែគឺត្រូវបានផ្តល់ជូនសម្រាប់អ្នកបោះឆ្នោតដែលកំពុងមានជម្ងឺពិការសោតវិញ្ញាណ។

ជំនួយការភាសា (213) 978-0444
ទីក្រុងនេះក៏ផ្តល់នូវឯកសារបោះឆ្នោតផងដែរជាភាសាអាមេនី ចិន ហ្វាស៊ី ហិណ្ឌូ ជប៉ុន ខ្មែរ កូរ៉ា រុស្ស៊ី អេស្ប៉ាញ តាកាឡុក ថៃ និងវៀតណាម។

ទីក្រុងរបស់អ្នក។ សំឡេងរបស់អ្នក។ ក្រុមប្រឹក្សាសង្កាត់របស់អ្នក!

ចង់ដោះស្រាយបញ្ហារណ្តៅតាមផ្លូវមែនទេ? មានគំនិតផ្តួចផ្តើមសម្រាប់ការកែលម្អសោភណភាពសហគមន៍ដែរឬទេ? កំពុងស្វែងរកមធ្យោបាយដែលមានអត្ថន័យ ដើម្បីផ្សារភ្ជាប់ទំនាក់ទំនងជាមួយសហគមន៍របស់អ្នកមែនទេ?

ចូលរួមជាមួយក្រុមប្រឹក្សាសង្កាត់របស់អ្នក!

ក្រុមប្រឹក្សាសង្កាត់ត្រូវបានបង្កើតឡើងដោយប្រជាជននៅក្នុងសហគមន៍របស់អ្នក ដែលធ្វើការដើម្បីធានាថាទីក្រុង Los Angeles ឆ្លើយតបទៅនឹងតម្រូវការ បញ្ហាប្រឈម និងសេចក្តីប្រាថ្នារបស់សង្កាត់របស់អ្នក។ ក្នុងនាមជាស្ថាប័នប្រឹក្សាយោបល់ស្ម័គ្រចិត្តដែលត្រូវបានជ្រើសតាំង ក្រុមប្រឹក្សាសង្កាត់ដើរតួជា**សំឡេងរបស់អ្នកនៅក្នុងសាលាក្រុង**។

ក្រុមប្រឹក្សាសង្កាត់បំពេញតួនាទីយ៉ាងសំខាន់នៅក្នុងរដ្ឋាភិបាលទីក្រុង Los Angeles តាមរយៈ៖

- ការផ្តល់យោបល់ដល់ថ្នាក់ដឹកនាំទីក្រុង និងការតស៊ូមតិលើបញ្ហាក្នុងមូលដ្ឋាន
- ការកំណត់អាទិភាពសម្រាប់គម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងសហគមន៍
- ការតាមដាន និងការផ្តល់អនុសាសន៍លើសេវាទីក្រុង ដូចជាការជួសជុលផ្លូវថ្នល់ និងចិញ្ចើមផ្លូវ សុវត្ថិភាពសាធារណៈ និងការប្រមូលសំរាម
- ការផ្តល់មូលនិធិសម្រាប់ព្រឹត្តិការណ៍ គម្រោង និងគំនិតផ្តួចផ្តើមនានានៅក្នុងសហគមន៍របស់ពួកគេ
- និងច្រើនទៀត!

Los Angeles មានក្រុមប្រឹក្សាសង្កាត់ចំនួន 99 នាក់។
ដោយត្រូវបានចាត់ទុកជាគំរូនៃការចូលរួមក្នុងកិច្ចការសង្គមថ្នាក់មូលដ្ឋានដ៏ធំបំផុតនៅក្នុងប្រទេស ក្រុមប្រឹក្សានីមួយៗបម្រើប្រជាពលរដ្ឋទីក្រុង Los Angeles ដែលរស់នៅ ធ្វើការ សិក្សា គោរពបូជា ជាម្ចាស់អចលនទ្រព្យ ឬអាជីវកម្ម ឬធ្វើការស្ម័គ្រចិត្តនៅក្នុងសង្កាត់នោះ។

ចូលរួមថ្ងៃនេះ

ការបោះឆ្នោតក្រុមប្រឹក្សាភូមិដ្ឋាននឹងប្រព្រឹត្តទៅនៅឆ្នាំ 2027។ ក្នុងនាមជាពលរដ្ឋទីក្រុង Los Angeles ម្នាក់ អ្នកអាចក្លាយជាអ្នកដឹកនាំសហគមន៍បាន តាមរយៈការឈរឈ្មោះបោះឆ្នោតសម្រាប់អាសនៈនៅក្នុងក្រុមប្រឹក្សាសង្កាត់របស់អ្នក ព្រមទាំងតាមរយៈការចូលរួមជាអ្នកបោះឆ្នោតនៅក្នុងការបោះឆ្នោតដ៏សំខាន់នេះ។

សូមចូលទៅកាន់គេហទំព័រ www.99NCs.com ដើម្បីស្វែងរកក្រុមប្រឹក្សាសង្កាត់របស់អ្នក និងស្វែងយល់អំពីការបោះឆ្នោតក្រុមប្រឹក្សាភូមិដ្ឋានឆ្នាំ 2027 ឬទាក់ទងនាយកដ្ឋានពង្រឹងអំណាចសង្កាត់តាមរយៈ EmpowerLA@LACity.org ឬ (213) 978-1551។